ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាក្នុងលក្ខណៈសាកល

◆ ទស្សនៈអន្តរជាតិទៅលើសោកនាដកម្មរបស់កម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១១៧ ខែកញ្ញា ឆ្នាំ២០០៩

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ១១៧ ខែកញ្ញា ឆ្នាំ២០០៩

## មាតិកា

◆ការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា ................ ១

**ផ្នែកឯកសារ**

◆ប៊ិន សំបុក ៖ យុទ្ធជនកងពល៣១០ .................................................. ៦

◆ការជួយឧបត្ថម្ភរបស់កងទ័ព និងកម្មាភិបាលដល់បដិវត្តន៍ ........................ ៨

◆ទូច សាម៉េន អតីតគណៈសហករណ៍ភូមិតាព្រហ្ម ................................ ១០

◆ឡាយ ឡេន ហៅ ទូច ខុំ ........................................................... ១២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ការទៅដល់សហគមន៍ចាម-មូស្លីម ខេត្តកំពត ................................... ១៥

◆ហ៊ឹម ហ៊ុយ អតីតឆ្មាំផ្តល់កសិណពិតទាក់ទងនឹង ............................... ១៨

◆សាក្សីក្នុងដំណើរការជំនុំជម្រះក្តី ................................................... ២២

◆ការសួរដេញដោលពីភាពដែលអាចជឿបានរបស់សាក្សី ............................. ២៤

◆ការផ្តល់សក្ខីកម្មរបស់បុគ្គលិកមន្ទីរស-២១ ប្រឆាំងនឹង ឌុច .................... ២៦

◆ឌុច ទទួលស្គាល់សក្ខីកម្មរបស់សាក្សីឈ្មោះ សួស ធី ........................... ២៩

**ផ្នែកច្បាប់**

◆សុខភាពផ្លូវចិត្តនិងកេរដំណែលនៃរបបខ្មែរក្រហម ............................... ៣២

◆ទស្សនៈអន្តរជាតិទៅលើសោកនាដកម្មរបស់កម្ពុជា ............................... ៤០

◆រយៈពេលពីរថ្ងៃក្រោយសក្ខីកម្មរបស់សាក្សី ....................................... ៤៤

**វេទិកាពិភាក្សាសាធារណៈ**

◆ការចូលរួមរបស់ចាមមូស្លីមនៅក្នុងការសិក្សា ................................... ៥០

◆ជំរំទាសករពលកម្មរបស់ ឌុច ......................................................... ៥៤

◆សន្តិភាព យុត្តិធម៌ និងការផ្សះផ្សា ................................................. ៥៧

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆អតីតកាលរបស់ម្តាយខ្ញុំ ................................................................ ៥៩



ប្រជាជន ខ្មែរ-អ៊ីស្លាម កំពុងអានសៀវភៅ
“ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ”

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នាដៃលេខនេះ ៖*** ជា ធីតា, ម៉ែន ពិចិត្រ, ស្តេនសឺ ខ្រាយជឺ, ឡូរ៉ា ម៉េកដូណល, ឆាល ជេកសាន់, ម៉ារី អ៊ីរ៉ូស៊ីរី, ខាលី លីគូហ្គ, បេននី វីដយ៉ូណូ, សូ ហ្វារីណា និង លី សុខឃាង, ផេង ពង្សរ៉ាស៊ី ***អ្នកបកប្រែៈ*** ជា ដល្លា, ទែន សុខស្រីនិត ***និពន្ធនាយកទូទៅៈ*** ឆាំង យុ ***ជំនួយការនិពន្ធនាយកៈ*** ទេព ម៉េងឃាន, ញាណ សុជាតិ ***ក្រាហ្វិកកុំព្យូទ័រៈ*** ស៊ឹម សុភ័ក្ត្រ ***គ្រប់គ្រងការចែកផ្សាយៈ*** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# ការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាក្នុងលក្ខណៈសាកលៈ ផែនការយុទ្ធសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០៩-២០១១



សាមសិបឆ្នាំបន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជានៅតែប្រឈមមុខជាមួយនឹងកេរដំណែលដ៏ឈឺចាប់នៃអំពើប្រល័យពូជសាសន៍ ការធ្វើទារុណកម្ម និងអំពើឃោរឃៅ ។ នៅសប្តាហ៍នេះ ព្រឹត្តិការណ៍ជាតិមួយនឹងរំឭកឡើងវិញនូវការដួលរលំរបស់របបខ្មែរក្រហម ក៏ប៉ុន្តែស្នាមរបួសដែលបង្កឡើងកាលពីសម័យនោះនៅមិនទាន់បានជាសះស្បើយនៅឡើយទេ ។ ជម្លោះខាងនយោបាយយ៉ាងជូរចត់នឹងលេចឡើងសាជាថ្មីម្តងទៀតស្តីអំពីសារជាតិរបស់រដ្ឋាភិបាលដែលគ្រប់គ្រងបន្តពីរបបខ្មែរក្រហម ដោយបង្ហាញឲ្យឃើញពីសេចក្តីត្រូវការសុំឲ្យមានការផ្សះផ្សាជាតិ ។ សេចក្តីត្រូវការរកយុត្តិធម៌ក៏ត្រូវមានដែរ ។ ឥឡូវនេះ ដំណើរការជំនុំជម្រះដែលកំពុងដំណើរការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាជំហានមួយដ៏មានសារសំខាន់ ក៏ប៉ុន្តែការកាត់សេចក្តីអតីតមន្ត្រីរបស់របបកម្ពុជាប្រជាធិបតេយ្យយ៉ាងហោចប្រាំនាក់រួមមាន នួន ជា, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ និង ឌុច មិនអាចដោះស្រាយបាននូវភាពអយុត្តិធម៌ទាំងឡាយដែលទាក់ទងទៅនឹងការគ្រប់គ្រងរបស់របបខ្មែរក្រហមនិងកេរដំណែលរបស់របបនេះឡើយ ។

នៅក្នុងរវាងពីឆ្នាំ២០០៩និង២០១១ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងបន្តអនុវត្តបេសកកម្មយូរអង្វែងរបស់ខ្លួនក្នុងការជំរុញឲ្យមានការចងចាំ យុត្តិធម៌ និងការផ្សះផ្សា ។ យើងនឹងប្រមែប្រមូលភ័ស្តុតាងបន្ថែមទៀតស្តីពីអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងអប់រំប្រជាជនកម្ពុជាអំពីហេតុការណ៍ប្រវត្តិសាស្ត្រដែលទាក់ទងទៅនឹងរបបខ្មែរក្រហម ។ កិច្ចការរបស់យើងនឹងផ្តោតទៅលើសេចក្តីត្រូវការរបស់ប្រជាជនកម្ពុជា រួមមានជនរងគ្រោះនិងកូនចៅរបស់អ្នកទាំងនោះ ដែលជាគន្លឹះដ៏សំខាន់សម្រាប់អតីតកាល បច្ចុប្បន្នកាល និងអនាគតកាលរបស់ប្រទេស ។ ក្រៅពីការផ្តល់ការគោរពដល់វិញ្ញាណក្ខន្ធដល់អ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម សារសំខាន់មួយទៀតគឺត្រូវផ្សព្វផ្សាយឲ្យទៅដល់សាធារណជននិងផ្តល់ការគាំទ្រចំពោះប្រជាជនកម្ពុជានៅក្នុងប្រទេស ព្រមទាំងនៅជុំវិញពិភពលោក ។ ផែនការយុទ្ធសាស្ត្រសង្ខេបនេះគូសបញ្ជាក់ពីផែនការរបស់យើងក្នុងការបង្កើតយន្តកម្មយូរអង្វែងដែលនឹងជួយជម្នះបាននូវស្រមោលអំពើឃោរឃៅរបស់ខ្មែរក្រហម និងការកសាងអនាគតដ៏ភ្លឺស្វាងនៅក្នុងប្រទេសកម្ពុជា ។

### ១) កេរដំណែលដាក់ស្តែង

***ការកសាងមជ្ឈមណ្ឌលស្រាវជ្រាវពីអំពើប្រល័យពូជ-សាសន៍អចិន្ត្រៃយ៍*** ៖ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាប់ផ្តើមកសាងមជ្ឈមណ្ឌលអចិន្ត្រៃយ៍ដើម្បីពង្រីកកិច្ចការនិងធានាឲ្យបាននូវការប្តេជ្ញាចិត្តយូរអង្វែងទាក់ទងទៅនឹងសិទ្ធិមនុស្សនិងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ។ ក្រសួង

អប់រំរបស់ប្រទេសកម្ពុជាបានផ្តល់ឲ្យយើងនូវដីមួយកន្លែងយ៉ាងធំនៅភ្នំពេញដើម្បីធ្វើកិច្ចការនេះ ។ ដីដែលមានទំហំសរុបជិត ៤៨០០ម៉ែត្រការ៉េនេះ ស្ថិតនៅក្នុងបរិវេណវិទ្យាល័យបឹងត្របែក ដែលជាទីតាំងអតីតមន្ទីរសន្តិសុខខ្មែរក្រហម ។ យើងបានអនុញ្ញាតឲ្យក្រុមស្ថាបត្យករជំនាញមួយក្រុមនៅទីក្រុងញូវយ៉កដើម្បីគូសប្លង់អគារដែលនឹងក្លាយទៅជាមជ្ឈមណ្ឌលអចិន្ត្រៃយ៍ ។ ក្រុមអ្នកជំនាញបានទទួលជំនួយពីនិស្សិតស្ថាបត្យករនៃសាកលវិទ្យាល័យខូឡុំបៀ និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។ យើងមានគម្រោងបញ្ចុះបឋមសិលាសម្រាប់អគារថ្មីនេះនៅក្នុងឆ្នាំ២០១០ ។

មជ្ឈមណ្ឌលអចិន្ត្រៃយ៍នឹងត្រូវដាក់ឈ្មោះថា «វិទ្យាស្ថានស្លឹករឹត» ។ ឈ្មោះនេះឆ្លុះបញ្ចាំងពីកម្មវត្ថុសំខាន់របស់យើង ព្រមទាំងជាកេរ្តិ៍មរតករបស់ប្រទេសកម្ពុជា ។ ស្លឹករឹតជាស្លឹកឈើស្ងួតដែលមេដឹកនាំសាសនាកម្ពុជានិងអ្នកប្រាជ្ញនានាបានប្រើប្រាស់អស់រយៈពេលជាច្រើនសតវត្សរ៍មកហើយដើម្បីចងក្រងឯកសារ ប្រវត្តិសាស្ត្រ ផ្សព្វផ្សាយចំណេះដឹង និងថែរក្សាវប្បធម៌ក្នុងអំឡុងសម័យកាលគ្រប់គ្រងប្រកបដោយភាពឃោរឃៅ ។ ស្លឹកនេះតំណាងឲ្យសោភណ្ឌភាពនៃចំណេះដឹងនិងភាពមោះមុតរបស់មនុស្សនាយុគងងឹត ។ មជ្ឈមណ្ឌលអចិន្ត្រៃយ៍នេះនឹងអនុវត្តតួនាទីស្នូលចំនួនបីយ៉ាង ។ ទីមួយ) មជ្ឈមណ្ឌលអចិន្ត្រៃយ៍នឹងក្លាយទៅជាបូជនីយដ្ឋានដាក់ស្តែងមួយ ដោយលើកទឹកចិត្តឲ្យអ្នកមកទស្សនាទាំងឡាយធ្វើការគោរពនិងចងចាំជនរងគ្រោះដែលលាចាកលោកនេះ ព្រមទាំងអ្នកទាំងឡាយណាដែលរងទុក្ខលំបាកកាលពីជំនាន់ខ្មែរក្រហម ។ ទីពីរ) មជ្ឈមណ្ឌលនេះនឹងក្លាយជាទីកន្លែងអប់រំ ដោយបង្កលទ្ធភាពឲ្យមនុស្សជំនាន់នេះនិងជំនាន់ក្រោយបានរៀនអំពីអតីតកាលដែលពោរពេញទៅដោយភាពសោកសង្រេងរបស់កម្ពុជា ។ ការអប់រំនឹងធានាឲ្យបានថាប្រជាជនកម្ពុជានឹងមិនដែលភ្លេចនូវអ្នកដែលបានស្លាប់និងរងទុក្ខវេទនាយ៉ាងអយុត្តិធម៌ ហើយការអប់រំនេះនឹងផ្តល់ឲ្យអ្នកទាំងអស់នូវការទប់ស្កាត់អំពើរំលោភស្រដៀងគ្នានេះនាពេលអនាគត ។ ចុងក្រោយ មជ្ឈមណ្ឌលនេះនឹងក្លាយទៅជាទីកន្លែងស្រាវជ្រាវដោយស្វះស្វែងប្រែក្លាយទៅជាស្ថាប័នអាស៊ីនាំមុខគេ ដែលនឹងផ្តោតទៅលើការសិក្សាពីអំពើប្រល័យពូជសាសន៍ ដោយការសិក្សានេះនឹងភ្ជាប់ជាមួយបញ្ញវន្ត ព្រមទាំងស្ថាប័នផ្សេងៗទៀតនៅទូទាំងអាស៊ីនិងពិភពលោក ។

## ២) កេរដំណែលនៃការចងចាំ

ការអប់រំពីអំពើប្រល័យពូជសាសន៍ដោយសហការជាមួយក្រសួងអប់រំ ៖ ការអប់រំពីអំពើប្រល័យពូជសាសន៍មានសារសំខាន់ណាស់ ប្រសិនបើប្រជាជនកម្ពុជាចង់ថែរក្សានូវប្រវត្តិសាស្ត្ររបស់ខ្លួន ព្រមទាំងចងចាំអ្នកដែលត្រូវបានសម្លាប់នៅក្នុងអំពើឃោរឃៅរបស់ខ្មែរក្រហម ។ ការអប់រំក៏មានសារសំខាន់ដែរ ប្រសិនបើប្រជាជនកម្ពុជាចង់យល់ថាតើហេតុអ្វីនិងហេតុដូចម្តេច




លោក យុ ឆាំង និងជនរងគ្រោះ ខ្មែរក្រហមនៅក្នុងខេត្តតាកែវ ឆ្នាំ១៩៩៥

បានជាអំពើប្រល័យពូជសាសន៍កើតឡើង ដោយលើកឡើងអំពីផលប៉ះពាល់របស់អំពើសោកនាដកម្ម ព្រមទាំងដោះស្រាយភាពប្រឈមមុខបន្តបន្ទាប់ជាច្រើនដែលបន្សល់មកពីអំពើប្រល័យពូជសាសន៍នេះ ។ បច្ចុប្បន្ននេះ មជ្ឈមណ្ឌលឯកសារកម្ពុជាស្ថិតនៅក្នុងដំណាក់កាលសហការជាមួយក្រសួងអប់រំនិងអ្នកឯកទេស ដើម្បីបង្កើតកម្មវិធីសិក្សាសំខាន់ៗស្តីពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបញ្ចូលនៅក្នុងកម្មវិធីសិក្សារដ្ឋនៅចុងឆ្នាំ២០០៩ ។ ដោយមានការចូលរួមជាមួយអ្នកឯកទេសនៅក្នុងស្រុកនិងអន្តរជាតិ យើងនឹងធ្វើការបណ្តុះបណ្តាលឲ្យស៊ីជម្រៅដល់មន្ត្រីកម្ពុជាចំនួន២៨រូប ដែលនឹងក្លាយទៅជាអ្នកនាំមុខគេក្នុងការអប់រំពីអំពើប្រល័យពូជសាសន៍ ។ បន្ទាប់ពីនេះ មន្ត្រីទាំងអស់នេះនឹងបណ្តុះបណ្តាលគ្រូចំនួន១៨៥នាក់ផ្សេងទៀត ដើម្បីដឹកនាំឲ្យមានកិច្ចខិតខំប្រឹងប្រែងនៅតាមស្រុកនានាទូទាំងប្រទេសកម្ពុជា ។ យើងក៏នឹងរៀបចំឲ្យមានកម្មវិធីបណ្តុះបណ្តាលជាមូលដ្ឋានរយៈពេលខ្លីទៅឲ្យគ្រូបង្រៀនសិក្សាទូទាំងប្រទេសប្រហែល ៣០០០នាក់ដែរ ។

កម្មវិធីសិក្សានិងការបណ្តុះបណ្តាលរបស់យើងដកស្រង់ចេញពីសៀវភៅប្រវត្តិសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានចំណងជើងថា «ប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ» ។ សៀវភៅនេះទទួលបានការពេញចិត្តជាច្រើនទូទាំងប្រទេសនិងពិភពលោក ។ នេះជាសៀវភៅដំបូងបង្អស់ហើយដែលអប់រំយុវជនកម្ពុជាអំពីសោកនាដកម្មរបស់ខ្មែរក្រហមបន្ទាប់ពីរយៈពេលបីទសវត្សរ៍នៃភាពស្ងប់ស្ងាត់សម្រាប់ប្រធានបទនេះនៅតាមសាលារៀននៅក្នុងប្រទេសកម្ពុជា ។

សៀវភៅនេះក៏នឹងអាចរកបាននៅតាមប្រព័ន្ធអ៊ិនធឺណេតដែលអាចឲ្យអ្នកអានទូទាំងសាកលលោករកមើលបាន ។ ការអប់រំពីអំពើប្រល័យពូជសាសន៍ជាគន្លឹះដើម្បីរំដោះជនរងគ្រោះនៃអំពើឃោរឃៅរបស់ខ្មែរក្រហមនិងប្រែក្លាយអ្នកទាំងនោះឲ្យទៅអ្នកដឹកនាំនៅក្នុងកិច្ចខិតខំប្រឹងប្រែងជាសកលចំពោះបញ្ហាសិទ្ធិមនុស្សនិងសេចក្តីថ្លៃថ្នូរ ។ កិច្ចសហការរបស់យើងជាមួយនាយកដ្ឋានអប់រំបានទទួលការអបអរសាទរនិងការគាំទ្រជាអន្តរជាតិ ដោយរួមមានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ រដ្ឋាភិបាលស៊ុយអែដ ណ័រវ៉េ ដេនម៉ាក អាល្លឺម៉ង់ ញ៉ូហ្សេឡិន និងបែលហ្ស៊ិក វិទ្យាស្ថានសន្តិភាពប៊ើកចំហនិងទាដ្ឋទានថ្នាក់ជាតិសម្រាប់លទ្ធិប្រជាធិបតេយ្យដែលមានទីតាំងនៅសហរដ្ឋអាមេរិក ។

ការចងចាំជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យៈ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានគម្រោងចងក្រងនិងបោះពុម្ពផ្សាយសៀវភៅរាយនាមអ្នកទាំងឡាយណាដែលបានស្លាប់ក្រោមរបបខ្មែរក្រហមដែរ ។ សៀវភៅនេះនឹងផ្អែកទៅលើការស្រាវជ្រាវរបស់យើងនិងទទួលស្គាល់ជាក់ស្តែង ព្រមទាំងចងចាំដល់អ្នកដែលបានស្លាប់ ។ មកដល់ឥឡូវនេះមានឈ្មោះជាងមួយលាននាក់ស្ថិតនៅក្នុងប្រព័ន្ធទិន្នន័យរបស់យើង ។ ឈ្មោះថ្មីៗព្រមទាំងព័ត៌មានពាក់ព័ន្ធនានាត្រូវបានបន្ថែមជានិច្ច ។ សៀវភៅនេះនឹងត្រូវបែងចែកទៅតាមឃុំនីមួយៗក្នុងប្រទេសកម្ពុជា ហើយនឹងតម្កល់ទុកក្នុងការិយាល័យឃុំដែលអាចផ្តល់ឲ្យមនុស្សជំនាន់ឥឡូវនិងជំនាន់ក្រោយនូវបូជនីយដ្ឋានជាក់ស្តែង ដែលធ្វើ


ជនរងគ្រោះខ្មែរក្រហម នៅបូជនីយដ្ឋានអំពើប្រល័យពូជសាសន៍



យាយ ស៊ុន នៅក្នុងខេត្តតាកែវ ឆ្នាំ១៩៩៥

ឡើងដើម្បីឧទ្ទិសដល់ជនរងគ្រោះទាំងឡាយដែលបានស្លាប់ ។ សៀវភៅនោះក៏នឹងអនុញ្ញាតឲ្យក្រុមគ្រួសារនិងមនុស្សជំនាន់ក្រោយមានលទ្ធភាពស្រាវជ្រាវរកប្រវត្តិគ្រួសាររបស់ខ្លួន ដែលជាការស្រាវជ្រាវមិនចេះចប់សម្រាប់មនុស្សលោកទាំងឡាយ ។ ដើម្បីឈានទៅដល់សហគមន៍សាកលដ៏ទូលំទូលាយជាងនេះ យើងនឹងចេញផ្សាយនៅតាមបណ្តាញអេឡិចត្រូនិចដែរ ។

## ៣) កេរដំណែលយុត្តិធម៌

**ការបង្កើតឲ្យមានឯកសារជុំវិញពិភពលោក** ៖ មធ្យោបាយមួយទៀតដែលមជ្ឈមណ្ឌលឯកសារកម្ពុជានឹងជំរុញឲ្យមានការបង្ហាញនិងយុត្តិធម៌នៅក្នុងប្រទេសនិងនៅក្រៅប្រទេស គឺការដាក់ចូលក្នុងប្រព័ន្ធឌីជីថលចំនួនននូវឯកសារដែលបានធ្វើមីក្រូហ្វីល រួចជាង៩០០ដុំពីបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ យើងកំពុងធ្វើការជាមួយសកលវិទ្យាល័យរ៉ាត់គើស៍នៅក្នុងទីក្រុងញូវយ៉ក រដ្ឋញូជើស៊ី និងមជ្ឈមណ្ឌលសម្រាប់ស្រាវជ្រាវបណ្ណាល័យ ដើម្បីសម្រេចគោលបំណងដ៏សំខាន់នេះ និងធ្វើឲ្យការបងក្រងឯកសាររបស់យើងដែលទទួលបានការចាប់អារម្មណ៍អាចរកបានតាមនៅលើអ៊ិនធឺណេត ។ ការអនុវត្តបែបនេះនឹងអាចឲ្យអ្នកស្រាវជ្រាវជាន់ខ្ពស់ អ្នកសារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយរដ្ឋាភិបាល និងមន្ត្រីអន្តរជាតិ ពលរដ្ឋកម្ពុជានិងជនជាតិខ្មែរដែលរស់នៅក្រៅប្រទេសទាំងអស់អាចស្រាវជ្រាវយ៉ាងមានប្រសិទ្ធភាពទៅលើអំពើប្រល័យពូជសាសន៍ ។ ដើម្បីសម្រេចគោលបំណង យើងក៏នឹងរក្សាការសហការរឹងមាំជាមួយសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងដែរ ។

**ការពិនិត្យទៅលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយមន្ត្រីខ្មែរក្រហមថ្នាក់ក្រោម** ៖ គោលដៅបន្ថែមទៀតរបស់ការងារយើងគឺពង្រីកកេរដំណែលយុត្តិធម៌ដែលកំពុងតែកើតឡើងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រោងរៀបចំការសិក្សាមួយទាក់ទិនទៅនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្ត





ដោយកម្មាភិបាលខ្មែរក្រហមថ្នាក់ទាប ។ ការសិក្សានេះនឹងតាមដានការរំលោភបំពានផ្សេងៗដែលបានកើតឡើងនៅក្រោមរបបខ្មែរក្រហម ដោយពិនិត្យទៅលើទីតាំងបទឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយសមាជិកខ្មែរក្រហមថ្នាក់ក្រោមក្នុងរបបខ្មែរក្រហមដែលមានការស្រាវជ្រាវតិចតួចនៅឡើយ ។ ជាក់ស្តែង មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើសម្ភាសន៍ជាមួយមន្ត្រីនិងកម្មាភិបាលខ្មែរក្រហមរាប់ពាន់នាក់តាំងពីឆ្នាំ២០០១មក ដោយមានការគាំទ្រពីក្រសួងមហាផ្ទៃ ។ ការសិក្សានេះនឹងផ្តល់ឲ្យជនរងគ្រោះ ដែលមួយចំនួនប្រហែលជាចំឆ្ងាយពីដំណើរការសាលាក្តីដែលកំពុងកើតមានឡើងនូវឱកាសដើម្បីផ្តល់សក្ខីកម្មអំពីបទពិសោធន៍ផ្ទាល់ខ្លួន ហើយដែលនាំទៅរកការចុះសម្រុងជាមួយនឹងអតីតកាល ។ ស្រដៀងទៅនឹងគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សារបស់អាហ្វ្រិកខាងត្បូងដែរ ការសិក្សានេះសង្ឃឹមថានឹងមិនផ្តោតការទម្លាក់កំហុសទៅលើបុគ្គលណាមួយជាក់លាក់ឡើយ ប៉ុន្តែការផ្តល់ឲ្យជនរងគ្រោះដើម្បីនិយាយ ហើយនិងរឿងរ៉ាវរបស់គាត់ត្រូវបានគេដឹងឮ គឺជាជំហានសំខាន់ឆ្ពោះទៅរកយុត្តិធម៌និងការផ្សះផ្សាថ្នាក់ជាតិ ។

***ការរំឭកដល់ច្បាប់សិទ្ធិមនុស្សជាគន្លឹះ*** ៖ ទីបញ្ចប់ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងស្វះស្វែងរកការយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជាដើម្បីរៀបចំវេទិការំឭកដល់ការអនុម័តច្បាប់សិទ្ធិមនុស្សជាគន្លឹះ ។ ជាពិសេសយើងមានបំណងផ្តោតលើអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដែលសន្ធិសញ្ញាថ្កោលទោសនឹងហាមឃាត់មិនឲ្យមានការប្រព្រឹត្តអំពើប្រល័យពូជសាសន៍កាលពី៦០ឆ្នាំកន្លងទៅ ។ យើងក៏មានបំណងទាញការចាប់អារម្មណ៍ចំពោះសន្ធិសញ្ញាសិទ្ធិមនុស្សថ្មីៗរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ផងដែរ ។ យើងសង្ឃឹមថានឹងដឹកនាំវេទិកានេះដោយមានការសហការពីរដ្ឋាភិបាលកម្ពុជា ដែលបានអនុម័តសន្ធិសញ្ញាប្រល័យពូជសាសន៍កាលពីឆ្នាំ១៩៥០ និងបានចុះហត្ថលេខាលើអនុសញ្ញាសិទ្ធិមនុស្សរបស់អាស៊ានកាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨ ។

វេទិកាសន្ធិសញ្ញាប្រល័យពូជសាសន៍នេះនឹងតំណាងឲ្យគោលការណ៍ដ៏រឹងមាំរបស់ច្បាប់សិទ្ធិមនុស្សអន្តរជាតិនាសម័យទំនើប ខណៈពេលដែលវេទិកាអនុញ្ញាសិទ្ធិមនុស្សរបស់អាស៊ានបង្ហាញពីការប្តេជ្ញាចិត្តជាលក្ខណៈតំបន់ដែលបន្តដល់សិទ្ធិមនុស្សនិងភាពថ្លៃថ្នូរជាមូលដ្ឋាន ។ វេទិកាដែលស្នើឡើងនេះនឹងមានអ្នកចូលរួមពីសំណាក់ជាតិនិងអន្តរជាតិ និងជួយបំភ្លឺសេចក្តីត្រូវការជាបន្តបន្ទាប់សំខាន់ៗដើម្បីជំរុញឲ្យមានការគោរពសិទ្ធិមនុស្សនិងទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជានិងអន្តរជាតិ ។ យើងសង្ឃឹមថាវេទិកានេះនឹងបង្កើតឲ្យមានសហគមន៍អ្នកស្រាវជ្រាវជាន់ខ្ពស់ អ្នកតស៊ូមតិ មន្ត្រី និងអ្នកដទៃទៀតដែលមានការចាប់អារម្មណ៍ទាំងនៅក្នុងនិងក្រៅប្រទេសកម្ពុជាដើម្បីអនុវត្តបេសកកម្មនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងបម្រើជាមជ្ឈមណ្ឌលដ៏សំខាន់នៅក្នុងទ្វីបអាស៊ីដើម្បីធានាថាអំពើសាហាវឃោរឃៅដូចដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនអាចកើតឡើងម្តងទៀត ។ **ឆាំង យុ**

 

# ប៊ិន សំបុក : យុទ្ធជនកងពល៣១០

ស្លាកស្នាមនិងភាពសោកស្តាយក្រោយចូលបម្រើបដិវត្តន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅតែដក់ជាប់នៅក្នុងចិត្តរបស់ប្រជាជនជានិច្ច ទោះបីជារបបនេះបានកន្លងផុតទៅអស់រយៈពេល ៣០ឆ្នាំហើយក៏ដោយ ។ ដូច្នេះ មិនថាតែប្រជាជនដែលរស់នៅទីក្រុងឬទីជនបទទេនៅតែព្យាយាមនិយាយរំឭករឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបនេះប្រាប់កូនចៅរបស់ខ្លួនឲ្យដឹងជានិច្ចដើម្បីកុំឲ្យក្មេងជំនាន់ក្រោយយកតម្រាប់តាម ។ ប៉ុន្តែខុសប្លែកពីអ្នកទាំងនេះ ប៊ិន សំបុក ដែលជាប្រជាពលរដ្ឋម្នាក់រស់នៅភូមិព្រែកដឹក ឃុំសោប ស្រុកព្រែកប្រសប់ ខេត្តក្រចេះ បែរជាមិនសូវយករឿងរ៉ាវរបស់គាត់មកប្រាប់កូនៗរបស់គាត់ឡើយ ។ ទោះជាបែបនេះក្តី ក្រោយពីសំណេះសំណាលជាមួយបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួចមក សំបុក បែរជានិយាយរឿងរបស់គាត់ជាហូរហែដើម្បីចងក្រងជាឯកសារទុកឲ្យក្មេងជំនាន់ក្រោយបានដឹងពីរឿងជូរចត់នេះ ។

សំបុក គឺជាកូនប្រុសទី២នៅក្នុងចំណោមបងប្អូន៦នាក់ (ស្រី២ និងប្រុស៤) ។ កាលពីតូច ទោះបីជា សំបុក រៀនបានត្រឹមតែថ្នាក់ទី៧នៅសាលាសោបលើក៏ដោយ ក៏គាត់អាចអាននិងសរសេរភាសាបារាំងបានខ្លះដែរ ។ បន្ទាប់ពីរដ្ឋប្រហារនៅឆ្នាំ១៩៧០ សំបុក


ប៊ិន សំបុក

បានសម្រេចចិត្តឈប់រៀនមកជួយធ្វើស្រែជាមួយឪពុកម្តាយវិញ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៤ កងទ័ពខ្មែរក្រហមបានចូលមកគ្រប់គ្រងនៅភូមិសោបលើ ហើយបានឃោសនាឲ្យយុវជននិងយុវនារីចូលធ្វើបដិវត្តន៍ តាមរយៈសេចក្តីប្រកាសថាអង្គការត្រូវការទ័ព ។ នៅពេលនោះដោយសារតែ សំបុក មិនព្រមចូលបដិវត្តន៍ តាព្រាប ដែលជាកងសេនាជន និង តាយ៉េប ជាប្រធានយុទ្ធជនឃុំ បានចោទគាត់ថាជាខ្មែរស (កងទ័ពលន់ នល់) ។ ដោយមានអារម្មណ៍ភ័យខ្លាចខ្លាំងពេក សំបុក បានទៅសុំ តាសែម ដែលជាគណៈឃុំចូលកងផលិតឃុំ ដើម្បីគេចពីការចោទប្រកាន់នេះ ។ កងផលិតឃុំនេះមានទីតាំងស្ថិតនៅភូមិបឹងព្រែង មានសមាជិកមកពីភូមិ-ឃុំផ្សេងៗគ្នា ទាំងអស់ប្រហែលពី២០ទៅ៣០នាក់ ក្រោមការគ្រប់គ្រងរបស់គណៈឃុំឈ្មោះ ចែត ។ អង្គការបែងចែកការងារជាពីរក្រុមគឺយុវជនមួយក្រុមនិងយុវនារីមួយក្រុម ក្រោមការដឹកនាំរបស់តាព្រាប ជាប្រធានក្រុម ។ សំបុក មានភារកិច្ចធ្វើស្រែនិងលើកទំនប់ចាប់ពីព្រលឹមម៉ោង៦កន្លះដល់ម៉ោង៥ឬ៦ល្ងាចទើបអាចសម្រាកបាន ។ ប៉ុន្តែទោះបីជា សំបុក ព្យាយាមបញ្ចប់កិច្ចការនេះហើយក៏ដោយ ក៏គាត់មិនត្រូវបានអនុញ្ញាតឲ្យត្រឡប់មកលំនៅឋានវិញដែរ ។ ចំណែកការហូបចុកវិញ កងផលិតឃុំទាំងអស់ត្រូវហូបបាយរួមនៅសហករណ៍ ដោយមិនមានការកំណត់របបអាហារទេអាស្រ័យទៅលើអាហារដែលអង្គការមាន ។

នៅខែកក្កដា ឆ្នាំ១៩៧៤ តាសែម បានបញ្ជូន សំបុក និងសមាជិកកងដែលមានគ្នាចំនួន៥-៦នាក់ទៅសមរភូមិកោះត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ សំបុក ត្រូវបានដាក់បញ្ចូលទៅក្នុងកងវរសេនាតូចលេខ១៥ វរសេនាធំលេខ៨០៦ ក្នុងកងពលលេខ១ ក្រោមការគ្រប់គ្រងរបស់ប្រធានវរសេនាតូចឈ្មោះ ចយ ប្រធានវរសេនាធំឈ្មោះ ទុន និងប្រធានកងពលឈ្មោះ តាអឿន ។ នៅទីនេះ សំបុក ត្រូវរៀនអំពីក្បួនយុទ្ធសាស្ត្រយោធាដើម្បីប្រយុទ្ធជាមួយខ្មាំង ក្រោមការបង្ហាត់បង្រៀនពីប្រធានកងឈ្មោះ ហាន ។

ប៉ុន្តែហាត់រៀនបានតែរយៈពេល៤-៥ថ្ងៃ ស្រាប់តែអង្គការបញ្ជូន សំបុក និងកងវរសេនាធំលេខ៨០៦ ឲ្យទៅប្រយុទ្ធនៅសមរភូមិភ្នំបាសិត និងត្រពាំងព្រាយ ពាយព្យក្រុងភ្នំពេញ ដែលនៅទីនេះ អង្គការបែងចែកជាពីរកង គឺកងកាំភ្លើងធំ និងកងថ្មើរជើង ។

ក្រោយពីទទួលជ័យជម្នះទាំងស្រុងនៅឆ្នាំ១៩៧៥ កងទ័ពទាំងអស់មិនត្រូវបានអនុញ្ញាតឲ្យប្រើកាំភ្លើងទេ ព្រោះកងវរសេនាធំទាំងអស់ត្រូវផ្លាស់ឲ្យទៅធ្វើស្រែនៅប្រាំងចំរេះវិញ ដែលនៅទីនេះ កងវរសេនាធំលេខ៨០៦ដែលមានសមាជិកប្រហែល៤០០នាក់ ត្រូវបានរំលាយទៅជាកងវរសេនាតូចលេខ១៥ ។ ចំណែកកងពលលេខ១១ត្រូវប្តូរឈ្មោះទៅជាកងពលលេខ៣១០ ក្រោមការគ្រប់គ្រងរបស់ តាអឿន ។ រយៈពេល២ទៅ៣ខែក្រោយមក តាអឿន បានបញ្ជាឲ្យ សំបុក និងវរសេនាតូចទាំងអស់ទៅធ្វើស្រែនៅកប់ស្រូវ ។ សំបុក មានភារកិច្ចកាប់ដីមួយហិកតាឲ្យហើយក្នុងរយៈពេលមួយថ្ងៃ ជាមួយសមាជិក៤ឬ៥នាក់ទៀត ។ ការងារនេះជួនកាលធ្វើរហូតដល់ភ្លឺស្ទើរគ្មានពេលឈប់សម្រាក ហើយថែមទាំងត្រូវបានកាត់បន្ថយរបបអាហារទៀត ។

នៅឆ្នាំ១៩៧៧ ចាប់ផ្តើមមានការបែកបាក់សាមគ្គីគ្នានិងមានការចោទប្រកាន់ថ្នាក់ដឹកនាំរបស់ខ្លួនយកទៅសម្លាប់ចោល ។ ពេលនោះ សំបុក ដឹងថា អ្នកដែលធ្វើការមិនល្អនឹងត្រូវអង្គការចាប់ខ្លួនជាមិនខាន ដូចជា ទុន ដែលជាប្រធានវរសេនាធំ ហុន (ជំនួសតំណែងរបស់ ទុន) ចយ ប្រធានវរសេនាតូច១៥ និង ឆាន (ជំនួសតំណែងរបស់ ចយ) ។ មិនត្រឹមតែអ្នកទាំងនេះទេ តាអឿន ក៏ត្រូវអង្គការចាប់ខ្លួនដែរដោយចោទថាជាសេអ៊ីអា ។ ក្រោយហេតុការណ៍នេះ កងទ័ពទាំងអស់ត្រូវស្ថិតនៅក្រោមការតាមដានយ៉ាងតឹងរ៉ឹងបំផុតរបស់ពួកនិរតី ហើយមិនត្រូវធ្វើសកម្មភាពអ្វីប្រឆាំងនឹងបញ្ជារបស់អង្គការបានឡើយ បើមិនអ៊ីចឹងទេនឹងនឹងត្រូវចាប់ខ្លួនដូចអ្នកទាំងនោះដែរ ។ ក្រោយមក សំបុក និងប្រធានវរសេនាតូចព្រមទាំងប្រធានវរសេនាធំត្រូវបញ្ជូនឲ្យទៅរៀននៅសាលាហ៊ីកហ៊ឺនក្រុងភ្នំពេញត្រង់ម្តុំវត្តភ្នំ ។ សំបុក នៅចាំបានថា អង្គការមានចាក់ខ្សែអាត់អំពីចម្លើយក្បត់របស់ តាអឿន ឲ្យកងទ័ពទាំងអស់ស្តាប់គ្រប់ៗគ្នា ។ ក្រោយបញ្ចប់វគ្គនេះ សំបុក ត្រូវបញ្ជូនឲ្យទៅធ្វើស្រែនៅបឹងប្រាយាបដែលមានប្រធានឈ្មោះ ស៊ុប មកពីភូមិភាគនិរតី និង នី ជាអនុប្រធាន ។ ការងារមិនមានលក្ខណៈខុសពីមុនទេ ប៉ុន្តែ សំបុក មានការព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្លួនជាងមុន ពីព្រោះមនុស្សនៅក្នុងកងបានបាត់ខ្លួនជាបណ្តើរៗ ដូចជា ដេត ដែលជាប្រធានក្រុមរបស់គាត់ត្រូវអង្គការហៅទៅរៀនសូត្រ ក្រោយមកគាត់ក៏បាត់ខ្លួនរហូត ។ លើសពីនេះទៅទៀត សំបុក បានឃើញហេតុការណ៍ដែលខ្មែរក្រហមបានសម្លាប់យោធាភូមិភាគបូព៌ាចំនួនប្រហែលពី២០០ទៅ៣០០នាក់ ដោយផ្ទាល់ភ្នែកនៅភូមិតាហីវ ។ ធ្វើការបានមួយរយៈ សំបុក ក៏មានជំងឺត្រូវសម្រាកព្យាបាលនៅពេទ្យព្រះកុមារលារយៈពេលមួយខែ ដែលគឺជាមន្ទីរពេទ្យសម្រាប់ព្យាបាលតែយោធាប៉ុណ្ណោះ ។

នៅឆ្នាំ១៩៧៩ សំបុក និងកងពលទាំងអស់ត្រូវបញ្ជូនឲ្យទៅប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅស្នួល ដែលលើកនេះកងពល៣១០នេះត្រូវផ្លាស់ទៅជាកងពល២០៧វិញ ក្រោមការគ្រប់គ្រងរបស់ ញ៉ី ជាប្រធានកងពល ។ ប៉ុន្តែប្រយុទ្ធបានប្រហែលពីរខែ សំបុក ត្រូវរងរបួសនៅសមរភូមិត្រង់ដៃទាំងសងខាងទ្រូង និងភ្នែក ។ ក្រោយពីសម្រាកព្យាបាលនៅមន្ទីរពេទ្យព-៩៨ រយៈពេលប្រហែលជា៣ខែ សំបុក ត្រូវបានបញ្ជូនតាមរថភ្លើងទៅសមរភូមិនៅស្រុកបវេល ខេត្តបាត់ដំបងទៀត ។ លើកនេះ សំបុក មិនបានប្រយុទ្ធជាមួយកងទ័ពវៀតណាមទេ ព្រោះពេលទៅដល់ខេត្តនេះប្រទេសជាតិក៏ត្រូវបានរំដោះ ។ ដោយឃើញព្រឹត្តិការណ៍មានភាពច្របូកច្របល់បែបនេះ សំបុក បានឆ្លៀតឱកាសនោះលួចរត់មកផ្ទះវិញជាមួយកងទ័ពផ្សេងទៀត ។ ពេលមកដល់ខេត្តសៀមរាប កងទ័ពវៀតណាមបានឃាត់ខ្លួន សំបុក រយៈពេលមួយសប្តាហ៍ ដើម្បីរៀនពីគោលនយោបាយវៀតណាមដែលមានគ្រូបង្រៀនជាជនជាតិវៀតណាម និងមានអ្នកបកប្រែម្នាក់ ។

ធ្វើដំណើរដោយថ្មើរជើងអស់រយៈពេលប្រហែលជាកន្លះខែ សំបុក បានមកដល់ផ្ទះជួបជុំគ្រួសារនិងបងប្អូន ។ នៅឆ្នាំ១៩៨៤ សំបុក បានរៀបការជាមួយនារីម្នាក់ឈ្មោះ សាបឿន ។ ចុងក្រោយ សំបុក សំណូមពរឲ្យមានការចងក្រងជាឯកសារប្រវត្តិសាស្ត្រអំពីសម័យខ្មែរក្រហមដើម្បីទុកឲ្យក្មេងជំនាន់ក្រោយបានយល់ដឹងនិងសិក្សា ជាពិសេសអប់រំមិនឲ្យរបបនេះកើតឡើងជាលើកទីពីរទៀត ។ **តាត លក្ខិណា**

# ការជួយឧបត្ថម្ភរបស់កងទ័ព និងកម្មាភិបាលដល់បដិវត្តន៍

*សេចក្តីដកស្រង់ចេញពីសេចក្តីអធិប្បាយៈ*

*១) តាំងពីប្រទេសយើងត្រូវបានរំដោះដោយពេញលេញ និងពិតប្រាកដមក កងទ័ពបដិវត្តន៍របស់យើងមិនទាន់បានទទួលនូវអារម្មណ៍ស្នេហាជាតិ និងអារម្មណ៍រំភើបរីករាយតាមរយៈជ័យជម្នះដ៏អស្ចារ្យនេះនៅឡើយទេ ។ ដោយស្ថិតនៅក្រោមការដឹកនាំដ៏ឆ្លាតវៃ និងត្រឹមត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា កងទ័ពបដិវត្តន៍របស់យើងបានយល់ដឹងយ៉ាងច្បាស់លាស់ពីភាពខុសគ្នារវាងមិត្ត និងសត្រូវ ។ ទន្ទឹមនឹងនោះ កងទ័ពរបស់យើងបានយកចិត្តទុកដាក់ជាដរាបក្នុងការប្រកាន់ខ្ជាប់នូវស្មារតីប្រុងប្រយ័ត្នក្នុងជួរបដិវត្តន៍ ។ កងទ័ពបដិវត្តន៍របស់យើងតែងតែត្រៀមខ្លួនជាស្រេចដើម្បីការពារប្រទេសនិងបូរណភាពដែនដី ដោយមិនអនុញ្ញាតឲ្យសត្រូវចូលមកអនុវត្តនូវការធ្វើវិទ្ធង្សនា បំផ្លិចបំផ្លាញនិងឈ្លានពានរបស់ខ្លួននៅក្នុងទឹកដីរបស់យើងឡើយ ។*

*ស្របពេលជាមួយគ្នានេះដែរ កងទ័ពបដិវត្តន៍របស់យើងបានយកចិត្តទុកដាក់លើការអប់រំស្តីពីគោលជំហរសាមគ្គីភាពនិងភាពរួបរួមគ្នាជាមួយនឹងប្រជាជនកសិករ និងកម្មករសមូហភាពដែលស្ថិតនៅក្រោមការដឹកនាំដ៏វាងវៃ និងត្រឹមត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ។ កងទ័ពបដិវត្តន៍យើងមិនអនុញ្ញាតឲ្យសត្រូវបង្កនូវជម្លោះ និងវិវាទជាមួយយើងឡើយ ។ នេះគឺដោយសារតែកងទ័ពបដិវត្តន៍របស់យើងបានប្រកាន់ខ្ជាប់នូវទស្សនៈ និងគោលជំហរដ៏រឹងមាំថា ទោះបីជាទទួលបរាជ័យក៏ដោយ ក៏សត្រូវរបស់ជាតិនិងសត្រូវរបស់ប្រជាជនយើងទាំងនោះនៅតែរក្សានូវគោលដៅយុទ្ធសាស្ត្ររបស់ពួកគេ ដើម្បីប្រែក្លាយរដ្ឋកម្ពុជាប្រជាធិបតេយ្យយើងឲ្យក្លាយទៅជារដ្ឋអាណានិគមរបស់ពួកគេគ្រប់កាលៈទេសៈទាំងអស់ ។ ដោយស្ថិតនៅក្រោមការដឹកនាំដ៏ឆ្លាតវៃ និងត្រឹមត្រូវរបស់បក្សកម្ពុជាប្រជាធិបតេយ្យក្នុងសមាសភាពជាអ្នកការពារប្រទេស រដ្ឋបាលបដិវត្តន៍ កសិករ-កម្មករ ប្រព័ន្ធសមូហភាព បក្សកម្ពុជាប្រជាធិបតេយ្យ និងប្រជាជន រួមទាំងកងទ័ពបដិវត្តន៍យើងបានប្រកាន់ខ្ជាប់យ៉ាងខ្ពង់ខ្ពស់នូវស្មារតីស្នេហាជាតិ ស្រឡាញ់ប្រជាជន និងរាប់អានចូលចិត្តប្រជាជនវណ្ណៈក្រីក្រ ។ ប្រជាជននិងកងទ័ពបដិវត្តន៍យើងតែងតែបានប្រកាន់ខ្ជាប់នូវអណ្តាតភ្លើងនៃការប្រមាថបែបជាតិកំហឹងវណ្ណៈ និងឈាមនៃភាពស្អប់ខ្ពើមជានិច្ចទៅកាន់សត្រូវគ្រប់ប្រភេទទាំងអស់ ។*

*តាមពិតក្រោយពីការរំដោះជាតិបានយ៉ាងពេញលេញនិងប្រាកដមក កងទ័ពបដិវត្តន៍យើងបានយកចិត្តទុកដាក់យ៉ាងខ្ជាប់ខ្ជួនដើម្បីការពារដែនដីគោក កោះ ដីសមុទ្រ និងសមុទ្រដោយអស់ពីសមត្ថភាព ។ ដីជាកេរដំណែលដែលដូនតាយើងបានបន្សល់ទុកឲ្យមិនបានបាត់បង់ សូម្បីតែមួយម៉ែត្រការ៉េ ។ នេះគឺជាជ័យជម្នះដ៏អស្ចារ្យមួយទៀតបន្ទាប់ពីជ័យជម្នះប្រវត្តិសាស្ត្រ ១៧ មេសា ដ៏អស្ចារ្យ ។ ជ័យជម្នះដ៏មានសារសំខាន់បែបនេះ គឺជាលទ្ធផលដែលកើតចេញពីស្មារតីប្រុងប្រយ័ត្នរបស់កងទ័ពបដិវត្តន៍យើងដែលស្ថិតនៅក្រោមការដឹកនាំដ៏ឆ្លាតវៃ និងត្រឹមត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ហេតុផលនេះទើបធ្វើឲ្យកងទ័ពបដិវត្តន៍របស់យើងបន្តការពារ និងទទួលការអប់រំបន្ថែមលើគោលជំហរនៃភាពប្រុងប្រយ័ត្នក្នុងជួរបដិវត្តន៍ ហើយដោយសារតែគោលជំហរនៃភាពប្រុងប្រយ័ត្នដ៏រឹងមាំនេះហើយ ទើបកងទ័ពបដិវត្តន៍របស់យើងមិនបានបន្ធូរបន្ថយនូវការការពារប្រឆាំងលើសត្រូវគ្រប់ប្រភេទទាំងអស់ ។*

*ជាសរុប ខណៈពេលដែលកំពុងរក្សានូវស្មារតីប្រុងប្រយ័ត្នខ្ពស់ក្នុងជួរបដិវត្តន៍ដោយស្ថិតនៅក្រោមការដឹកនាំដ៏ឆ្លាតវៃនិងត្រឹមត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា កងទ័ពបដិវត្តន៍យើងបានទទួលនូវជោគជ័យក្នុងការការពារនិងជួយកសាងប្រទេស ។ កងទ័ពរបស់យើងបានសន្យាថានឹងរក្សានូវស្មារតីប្រុងប្រយ័ត្នក្នុងជួរបដិវត្តន៍នេះគ្រប់ពេលវេលាទាំងអស់ដើម្បីធ្វើឲ្យប្រទេស រដ្ឋបាលបដិវត្តកសិករ-កម្មករ ប្រព័ន្ធសមូហភាព និងបក្សកុម្មុយនីស្តកម្ពុជាស្ថិតនៅក្នុងភាពរុងរឿងជាដរាបតទៅ ។*

*២) ដើម្បីការពារនិងកសាងប្រទេសឲ្យស្ថិតក្នុងស្ថានភាព*

រីកចម្រើន និងមានអំណាចក្នុងល្បឿនដ៏លឿន និងក្នុងគោលជំហរឯករាជ្យភាពនិងភាពជឿជាក់លើខ្លួនឯង បក្សកុម្មុយនីស្តយើងបានកំណត់ទុកជាមុននូវគោលដៅសម្រាប់គម្រោងការដំណាំស្រូវ ។ ដើម្បីសម្រេចនូវកិច្ចការនេះឲ្យបានជោគជ័យ បក្សកុម្មុយនីស្តកម្ពុជាយើងបានផ្តោតសំខាន់លើការអប់រំប្រជាជនទូទាំងប្រទេសក្នុងមាគ៌ានយោបាយបក្ស ហើយធ្វើឲ្យប្រជាជនយើងមានអារម្មណ៍ស្ងើចសរសើរលើមាគ៌ានយោបាយបក្សនេះ ដូច្នេះកងទ័ពយើងអាចប្រែក្លាយការយល់ដឹងពីនយោបាយនេះឲ្យទៅជាកម្លាំងទ័ពដ៏ខ្លាំងក្លាសម្រាប់បង្កបង្កើតដំណាំស្រូវ ។

បក្សកុម្មុយនីស្តកម្ពុជាយើងបានចាត់ទុកចលនាផលិតកម្មស្រូវរបស់កសិករក្នុងសហករណ៍យើងទូទាំងប្រទេសទាំងអស់ជាសមរភូមិជួរមុខដ៏ក្តៀវក្លា ដើម្បីស្ថាបនាជួរកម្មាភិបាលបដិវត្តន៍យើងនិងដើម្បីបំពាក់បំប៉ននូវឆន្ទះដ៏មុតមាំដើម្បីធ្វើការតស៊ូដោយភាពក្លាហានបំផុត និងជម្នះរាល់ឧបសគ្គ មិនថាតូច ឬធំ និងពុះពារនូវសេចក្តីលំបាកវេទនាគ្រប់បែបយ៉ាងទាំងអស់ ។ កម្មាភិបាលបដិវត្តន៍យើងគ្រប់លំដាប់ថ្នាក់ទាំងអស់ត្រូវបានសម្រួលអារម្មណ៍ហ៊ឹកហាត់ និងកែប្រែគោលគំនិតរបស់ពួកគេដោយចលនាប្រជាជនដ៏ច្រើនកុះករដើម្បីការពារនិងកសាងប្រទេស ។ ដោយសារតែកងទ័ពទាំងអស់គ្នាធ្លាប់មានបទពិសោធន៍ក្នុងចលនាប្រជាជនដ៏ច្រើនកុះករ ទាំងអស់នេះហើយបានជាកម្មាភិបាលបដិវត្តន៍យើងគ្រប់លំដាប់ថ្នាក់ទាំងអស់អាចធ្វើការឈ្វេងយល់យ៉ាងច្បាស់លាស់និងស្រូបយកមាគ៌ានយោបាយបក្សនិងកិច្ចការបដិវត្តន៍របស់យើងយ៉ាងខ្ជាប់ខ្ជួន ហើយអាចធ្វើឲ្យគ្រប់គ្រងរាល់កិច្ចការទាំងអស់បានមិនថាការងារធ្ងន់ឬស្រាលទេ ។ ដូច្នេះកម្មាភិបាលបដិវត្តន៍យើងសុទ្ធតែមានសមត្ថភាពខ្ពស់ក្នុងការធ្វើឲ្យការងារបដិវត្តន៍អភិវឌ្ឍទៅមុខយ៉ាងឆាប់រហ័សដោយមហាលោតផ្លោះ ។

មាគ៌ាកសាងកម្មាភិបាលបដិវត្តន៍នៅក្នុងចលនាប្រជាជនដ៏ច្រើនកុះករក្នុងបដិវត្តន៍សង្គមនិយមដើម្បីការពារនិងកសាងប្រទេសបានធ្វើឲ្យជួរកម្មាភិបាលបដិវត្តន៍យើងកាន់តែមានគំនិតចាស់ទុំឡើង ។ បក្សយើងបានបីបាច់ថែរក្សាកម្មាភិបាលបដិវត្តន៍ទាំងក្នុងនិងក្រៅបក្សជានិច្ច ។ មិនថានៅពេលសន្តិភាព ឬសេចក្តីលំបាកវេទនាយ៉ាងណាក្តី ក្នុងសមាសភាពជាអ្នកគ្រប់គ្រងជាតិ បដិវត្តន៍ និងជោគវាសនារបស់ជាតិ និងប្រជាជនយើង កម្មាភិបាលបដិវត្តន៍យើងតែងតែប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវស្មារតីទំនួលខុសត្រូវខ្ពស់ទាក់ទិននឹងកាតព្វកិច្ចដែលផ្តល់ឲ្យដោយបក្ស និងប្រជាជន ។

កម្មាភិបាលបដិវត្តន៍យើងប្រកបដោយស្មារតីរស់រវើកនៃភាពប៉ិនប្រសប់ក្នុងការច្នៃប្រឌិត និងផ្តួចផ្តើម ។ ជាមួយគ្នានេះដែរកងទ័ពរបស់យើងក៏បានយកចិត្តទុកដាក់ក្នុងការអប់រំប្រជាជននិងលើកតម្កើងទស្សនៈនិងគោលជំហរផ្នែករចនាសម្ព័ន្ធ មនោគមន៍វិជ្ជានិងនយោបាយ រួមទាំងយកចិត្តទុកដាក់លើការជ្រោមជ្រែងកម្លាំងបដិវត្តន៍ដើម្បីខិតខំប្រឹងប្រែងបំពេញកិច្ចការបដិវត្តន៍ប្រកបដោយប្រសិទ្ធភាពនិងសកម្មបំផុត ។ ដូច្នេះហើយបានជាគ្មានកម្លាំងណាមួយត្រូវបានមើលរំលងហួសឬទុកឲ្យមានភាពខ្ជិលច្រអូសឡើយ ។ កម្មាភិបាលបដិវត្តន៍យើងបានប្រកាន់យកនូវទស្សនៈនិងគោលជំហរដ៏ច្បាស់លាស់ថា កិច្ចការជ្រោមជ្រែង រៀបចំ និងប្រើប្រាស់កម្លាំងបដិវត្តន៍នៅគ្រប់លំដាប់ថ្នាក់ទាំងអស់ដើម្បីបំពេញនូវកិច្ចការបដិវត្តន៍ក្នុងឥរិយាបថម៉ឺងម៉ាត់ មានប្រសិទ្ធភាពនិងយ៉ាងសកម្មនេះគឺជាផ្នែកមួយនៃការតស៊ូបដិវត្តន៍សង្គមនិយមដើម្បីការពារអភិវឌ្ឍប្រទេស និងធ្វើឲ្យប្រទេសមានកាន់តែមានការរីកចម្រើនលូតលាស់ ។

មធ្យោបាយមួយក្នុងចំណោមមធ្យោបាយដ៏មានប្រសិទ្ធភាពដែលត្រូវបានប្រើប្រាស់ដោយកម្មាភិបាលបដិវត្តន៍ដើម្បីជ្រោមជ្រែងប្រជាជនឲ្យអនុវត្តបដិវត្តន៍សង្គមនិយមដើម្បីការពារនិងកសាងប្រទេស ហើយដើម្បីធ្វើឲ្យកម្រិតជីវភាពរស់នៅរបស់ប្រជាជនមានភាពល្អប្រសើរនោះគឺថាការចូលរួមធ្វើការងារជាមួយប្រជាជនកសិករក្នុងសហករណ៍យើងដោយជួបប្រជុំជាមួយប្រជាជនដើម្បីដកស្រង់បទពិសោធន៍រស់នៅ និងចែករំលែកជាមួយពួកគេនូវស្នាមរបួសនិងទុក្ខក្រៀមក្រំ ។ ដោយបានប្រកាន់ខ្ជាប់នូវស្មារតីបង្រួបបង្រួមដ៏ទូលំទូលាយ និងស្មារតីគោរពបដិវត្តន៍ ហើយដោយបានចូលយ៉ាងជ្រៅនៅក្នុងចលនាប្រជាជនដ៏ច្រើនកុះករដូចត្រីក្នុងទឹក កម្មាភិបាលបដិវត្តន៍យើងអាចធ្វើការយល់ដឹងអំពីចលនាប្រជាជនដ៏ច្រើនកុះករនេះកាន់តែល្អប្រសើរឡើង ។ បន្ថែមពីនេះដោយបានស្រូបយកនូវទស្សនៈផ្នែកសង្គមនិយមនិងនយោបាយទាក់ទិននឹងប្រជាជនដោយម៉ឺងម៉ាត់ កម្មាភិបាលបដិវត្តន៍ យើង

បានធ្វើការស្វែងយល់គ្រប់បញ្ហាទាំងអស់ដែលមាននៅក្នុងគម្រោងការបង្កើនផលិតផល និងផ្នែកបច្ចេកវិជ្ជាគ្រប់ប្រភេទទាំងអស់របស់បក្ស ។ ដូច្នេះកម្មាភិបាលបដិវត្តន៍យើងបានប្រែខ្លួនឲ្យក្លាយមកជាសមាសភាពដ៏សំខាន់នៅក្នុងវិស័យនយោបាយ និងមនោគមន៍វិជ្ជា និងក្នុងវិស័យបច្ចេកវិជ្ជារបស់បក្ស ។ ហេតុដូច្នេះក្នុងចលនាបដិវត្តន៍សង្គមនិយមដើម្បីការពារនិងកសាងប្រទេសនិងដើម្បីធ្វើឲ្យកម្រិតជីវភាពរស់នៅមានភាពប្រសើរឡើង កម្មាភិបាលបដិវត្តន៍យើងបានធ្វើឲ្យខ្លួនជ្រួតជ្រាបនូវគោលជំហរផ្នែករចនាសម្ព័ន្ធមនោគមន៍វិជ្ជា និងផ្នែកនយោបាយរបស់បក្សដោយប្រុងប្រយ័ត្ន ហើយបានធ្វើឲ្យខ្លួនមានជំនឿជឿជាក់កាន់តែជ្រៅទៅលើការដឹកនាំដ៏ត្រឹមត្រូវរបស់បក្សនិងជឿលើចលនាប្រជាជនបដិវត្តន៍របស់យើង ។ **ឯកសារ D២៩៨០២**

# ទូច សារ៉េន អតីតគណៈសហករណ៍ភូមិតាព្រំ

បន្ទាប់ពីជ័យជម្នះរបស់កងទ័ពបដិវត្តន៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានធ្វើការបែងចែកវណ្ណៈសង្គមជាពីរគឺប្រជាជនថ្មីនិងប្រជាជនមូលដ្ឋាន ។ ប្រជាជនថ្មី ឬប្រជាជន១៧ មេសាមិនត្រូវបានអង្គការជឿទុកចិត្តឡើយ ហើយថែមទាំងទទួលការស្អប់ខ្ពើមពីសំណាក់អង្គការនិងមិនឲ្យកាន់មុខតំណែងនៅក្នុងរបបនេះទៀត ។ ចំណែកប្រជាជនមូលដ្ឋានឬប្រជាជនចាស់វិញ សំដៅទៅលើគ្រួសារកសិករក្រីក្រ និងជាមនុស្សដែលអង្គការជឿទុកចិត្ត ហើយអាចក្លាយទៅជាប្រធានសហករណ៍ ឬប្រធានកងផ្សេងៗ តួយ៉ាងដូចជា ទូច សារ៉េន គឺជាប្រជាជនមូលដ្ឋានត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាគណៈសហករណ៍នៅក្នុងភូមិតាព្រំ ឃុំមានជ័យ ស្រុកឈូក ខេត្តកំពត ដោយសារគាត់ជាគ្រួសារកសិករនិងក្រីក្រ ។

កាលពីកុមារភាព សារ៉េន រៀននៅក្នុងសាលាវត្តទល់ដែលមានចម្ងាយមួយគីឡូម៉ែត្រពីផ្ទះ រួចក៏បានបន្តការសិក្សានៅអនុវិទ្យាល័យតានីទូកមាសក្នុងទឹកដីកំណើត ។ នៅឆ្នាំ១៩៦៦ ដោយសារបញ្ហាជីវភាពមានការលំបាក សារ៉េន ក៏ឈប់រៀនមកជួយធ្វើស្រែឪពុកម្តាយនៅផ្ទះវិញ ។ រយៈពេលមួយឆ្នាំក្រោយមក សារ៉េន ត្រូវបានឪពុកម្តាយផ្សំផ្គុំឲ្យរៀបការជាមួយនារីម្នាក់ឈ្មោះ អ៊ុក វ៉ាន់ ដែលរស់នៅភូមិជាមួយគ្នា ។ នៅឆ្នាំ១៩៧៦ សារ៉េន ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាឈ្លបឃុំ ប៉ុន្តែរយៈពេល


កងចល័តខ្មែរក្រហមកំពុងជីកប្រឡាយ

ពីរខែក្រោយមកគាត់ក៏ត្រូវអង្គការផ្លាស់ឲ្យធ្វើជាកងទ័ពវិញ ។ រហូតដល់ចុងឆ្នាំ១៩៧៧ ទើបអង្គការចាត់តាំង សាម៉េន ឲ្យធ្វើជាប្រធានភូមិតាព្រុំ ។

ក្នុងឋានៈជាប្រធានភូមិ សាម៉េន បានបែងចែកពលកម្មនិងរបបអាហារមិនឲ្យខុសគ្នាឡើយ រវាងប្រជាជនមូលដ្ឋាននិងប្រជាជន១៧មេសា ។ លើសពីនេះទៅទៀត នៅពេលដែលប្រជាជនធ្វើការអស់កម្លាំង សាម៉េន បានបញ្ជាឲ្យមនុស្សពីរ-បីនាក់ទៅបេះដូងដាក់រទេះ និងដកដំឡូងមីយកមកស្ងោរហូបទាំងអស់គ្នា ។ សាម៉េន ផ្គត់ផ្គង់ប្រជាជននៅក្នុងមូលដ្ឋានរបស់គាត់មិនឲ្យមានការអត់ឃ្លានឡើយ ទោះជាមានការស្នើសុំពីថ្នាក់លើឲ្យយកស្រូវពីមូលដ្ឋានក៏ដោយ ។ នៅពេលប្រជាជន១៧មេសាជួបការលំបាក សាម៉េន តែងតែចេញមុខដើម្បីដោះស្រាយបញ្ហានោះជានិច្ច ។ ជាក់ស្តែង សាម៉េន បានជួយប្រជាជនបីគ្រួសារដែលរត់ពីចេញពីខេត្តតាកែវឲ្យរួចផុតពីការតាមចាប់ខ្លួនរបស់អង្គការនិងឲ្យស្នាក់នៅក្នុងសហករណ៍របស់គាត់ទៀត ពីព្រោះនៅសហករណ៍មុន បីគ្រួសារនេះត្រូវបានបង្ខំឲ្យធ្វើការហួសកម្លាំងនិងផ្តល់របបអាហារឲ្យហូបមិនគ្រប់គ្រាន់ទេ ។ ដោយសារតែមានចិត្តអាណិតដល់ប្រជាជនបីគ្រួសារនេះ សាម៉េន ក៏នាំទៅជួបមេឃុំដើម្បីសុំសិទ្ធិបានរស់នៅក្នុងភូមិ-ឃុំនេះ ដែលក្នុងចំណោមបីគ្រួសារនោះមានម្នាក់ឈ្មោះ ឆាវ ជាអតីតនាយទាហានស័ក្តិបីសម័យ លន់ នល់ ចេះច្នៃម៉ាស៊ីនអារឈើ ម៉ាស៊ីនដុតធ្យូងនិងឧបករណ៍ច្នៃប្រឌិតផ្សេងៗ ។ ទោះបីជាគ្រួសារទាំងបីនេះត្រូវអង្គការចោទប្រកាន់ថាជាខ្មាំងក៏ដោយ ក៏គាត់មិនខ្លាចអ្វីទាំងអស់ ថែមទាំងហ៊ានតវ៉ាបដិសេធថាមិនមានខ្មាំងរស់នៅសហករណ៍របស់គាត់ឡើយ ។ សាម៉េន គិតថា «ប្រសិនបើអង្គការយកបីគ្រួសារនេះត្រឡប់ទៅវិញ អ្នកទាំងនេះពិតជាស្លាប់មិនខាន» ។ ចុងក្រោយ សាម៉េន អាចសង្គ្រោះជីវិតបីគ្រួសារនេះបាន ។

នៅឆ្នាំ១៩៧៨ សាម៉េន បានជួយស្ត្រីម្នាក់ជាប្រជាជន១៧មេសា ដែលត្រូវបានចាប់ខ្លួនដោយសារប្រធានក្រុមរបស់ស្ត្រីនោះបានរាយការណ៍ទៅថ្នាក់លើថាបានប្រព្រឹត្តខុសសីលធម៌ជាមួយជនជាតិចិនម្នាក់ដែលធ្វើការនៅក្នុងក្រុមជាមួយគ្នារហូតដល់មានផ្ទៃពោះ ។ ពេលនោះ សាម៉េន បានប្រាប់ហេតុផលទៅអង្គការថ្នាក់លើថា ទោះបីជាស្ត្រីម្នាក់នោះមានផ្ទៃពោះដោយសារបញ្ហាខុសសីលធម៌ក៏ដោយ គឺគ្រាន់តែហៅអ្នកទាំងពីរមកអប់រំផ្ទាល់បានហើយ ព្រោះជារឿងធម្មជាតិដែលមិនអាចហាមឃាត់បាន ។ នៅពាក់កណ្តាលឆ្នាំ១៩៧៨ សាម៉េន ក៏បានជួយបុរសម្នាក់ទៀតដែលត្រូវបានសហករណ៍ស្រុកឈូកឃុំមានជ័យចោទប្រកាន់ថាជាខ្សែរយៈរបស់វៀតណាម ។ នៅពេលដែលឈ្លបឃុំប្រគល់សំបុត្រឲ្យ សាម៉េន បានបដិសេធថា នៅក្នុងសហករណ៍របស់គាត់មិនមានខ្មាំងលាក់ខ្លួននៅទីនោះទេ ព្រោះបុរសម្នាក់នេះមិនមានធ្វើសកម្មភាពណាមួយដែលត្រូវចោទថាជាខ្មាំងឡើយ ដោយគាត់នៅធ្វើការនៅទីនោះជាប្រចាំ ។

នៅឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមវាយចូលក្នុងសហករណ៍ សាម៉េន បានរត់គេចខ្លួននៅតាមជ្រលងភ្នំក្នុងទឹកដីខេត្តកំពត ។ នៅតាមផ្លូវធ្វើដំណើរដោយសារអាណិតក្មេងៗដែលត្រូវឪពុកម្តាយបោះបង់ចោល សាម៉េន ក៏បាននាំក្មេងៗទាំងនោះរត់ទៅជាមួយគាត់ ដោយបានផ្តល់អាហារនិងថែទាំក្មេងៗទាំងនោះដូចជាកូនបង្កើត ។ ប៉ុន្តែក្រោយមក ក្មេងៗទាំងនោះត្រូវបានកងទ័ពវៀតណាមយកទៅដាក់នៅក្នុងមជ្ឈមណ្ឌលមួយដើម្បីបញ្ជូនត្រឡប់ទៅលំនៅឋានវិញ ។

រហូតដល់ឆ្នាំ១៩៨០ សាម៉េន និងប្រពន្ធរបស់គាត់បាននាំគ្នាត្រឡប់មករស់នៅក្នុងភូមិគគីរ ឃុំភ្នំព្រីក ស្រុកភ្នំព្រីក ខេត្តបាត់ដំបងរហូតដល់សព្វថ្ងៃនេះ ។ **ថា ធីតា**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# ឡាយ ឡេន ហៅ ទូច ខុំ
## យុទ្ធជនកងពិសេសវរសេនាធំលេខ៣២ កងពលលេខ៧០៣

### ជីវប្រវត្តិសង្ខេប

ឡាយ ឡេន ហៅ ទូច ខុំ អាយុ ២០ឆ្នាំ មានស្រុកកំណើតនៅភូមិព្រៃកែស ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត តំបន់៣៥ ភូមិភាគនិរតី ។ ខ្ញុំ មាន ពុកឈ្មោះ ឡាយ លន និងម្តាយឈ្មោះ ទូច ញ៉ី នៅរស់ទាំងពីរនាក់ ។

ខ្ញុំ រស់នៅជាមួយឪពុកម្តាយតាំងពីតូច ដោយជួយគាត់ទាំងពីរធ្វើស្រែចម្ការ និងធ្វើស្ករត្នោត ។ ខ្ញុំ មិនដែលបានចូលសាលារៀនដូចក្មេងដទៃទេ ។ នៅឆ្នាំ១៩៧២ ក្រោយពីភូមិរបស់ ខ្ញុំ ត្រូវខ្មែរក្រហមរំដោះបានមួយឆ្នាំក្រោយមក ខ្ញុំ ក៏បានចូលបម្រើបដិវត្តន៍ធ្វើជាឈ្លបឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច ។ មុនពេលដែល ខ្ញុំ ត្រូវបានអង្គការចាប់ខ្លួន ខ្ញុំ គឺជាយុទ្ធជនកងពិសេសវរសេនាធំ៣២ កងពល៧០៣ ។

នៅឆ្នាំ១៩៧៤ ខ្ញុំ ត្រូវបានអង្គការផ្លាស់ឲ្យទៅកងយោធាស្រុកកំពង់ត្រាច ។ ក្រោយពេលបក្សកុម្មុយនីស្តកម្ពុជារំដោះបានទឹកដីទាំងស្រុង យោធាស្រុកកំពង់ត្រាចទាំងអស់ត្រូវអង្គការបញ្ជូនទៅយោធាតំបន់៣៥ ខេត្តកំពត ក្នុងកងវរសេនាតូច៦៥ ប្រចាំនៅតាមព្រំដែនស្រុកទូកមាស ក្រោមការគ្រប់គ្រងរបស់ សាត ជាប្រធានក្រុម ។

នៅទីនោះ ខ្ញុំ ត្រូវបានអង្គការថ្នាក់លើចាត់តាំងឲ្យដាំបន្លែ ។ ខ្ញុំ ធ្វើការនេះមិនដែលហ៊ានឈប់សម្រាកទេ ប៉ុន្តែរបបអាហារវិញ ខ្ញុំ ទទួលបានអង្ករតែមួយកំប៉ុងក្នុងមួយថ្ងៃប៉ុណ្ណោះ ។ ទោះបីជា ខ្ញុំ ធ្លាប់ត្រូវបានមិត្តក្នុងក្រុមកសាងពីបញ្ហាដែលគាត់ខ្ជិលធ្វើការងារ និងដើរលួចដំឡូងហូបក៏ដោយ ក៏គាត់មិនដែលចាប់អារម្មណ៍ឡើយ ។ ដោយសារតែ ខ្ញុំ ជាមនុស្សសេរីម្នាក់ ដូច្នេះរាល់ពេលដែលធ្វើការអស់កម្លាំង ខ្ញុំ តែងតែទៅសម្រាកអង្គុយជជែកគ្នាលេងជាមួយ សាត, ទូច ជាកងវរសេនាតូច៦៥ និង គុយ ជាមេពួកកងវរសេនាតូច៦៥ ដែលជាអ្នកសេរីដូចគាត់ដែរ ។

### ការបណ្តុះគំនិតឲ្យក្បត់បដិវត្តន៍

ជាទូទៅ នៅពេលដែលអ្នកទាំងបួនសម្រាកជជែកគ្នាលេង សាត តែងតែនិយាយអំពីរឿងនារីភេទ និងប្រៀបធៀបពីភាពខុសគ្នារវាងរបបសង្គមកាលពីមុនជាមួយនឹងរបបសង្គមបដិវត្តន៍សព្វថ្ងៃ ។ សាត បានរំពឹកថា «ការតស៊ូវណ្ណៈក្នុងសង្គមបច្ចុប្បន្នគឺងតែងណាស់ ធ្វើការជាប់ គ្មានពេលទំនេរ ពុំមានប្រាក់ចាយ មិនអាចដើរលេងឬនិយាយស្តីដោយសេរីបាន មិនអាចរកប្រពន្ធដោយខ្លួនឯងបាន អាហារហូបចុកក៏មិនមានគ្រប់គ្រាន់ធ្វើឲ្យកងទ័ពស្គមរីងរៃស្ទើរគ្រប់ៗគ្នា ហើយប្រសិនបើនរណាម្នាក់ហ៊ានសេរីមិនសមូហភាព ច្បាស់ជាត្រូវអង្គការយកទៅកសាងបាត់ហើយ ។



កាលពីសង្គមចាស់វិញ បន្ទាប់ពីធ្វើស្រែរួច ប្រជាជនអាចសម្រាកបានយ៉ាងសុខស្រួល អាចដើរលេង ឬទៅលេងបុណ្យក៏បាន។ មិនតែប៉ុណ្ណោះ ប្រសិនបើយើងជាមនុស្សខិលខូចវិញ អាចញ៉ែស្រីបានតាមចិត្ត...»។

រហូតមកដល់រដូវធ្វើស្រែឆ្នាំ១៩៧៦ អង្គភាពរបស់ ខ្ញុំ ត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែនៅព្រៃទន្លេជាប់នឹងព្រំដែន។ យោធានៅក្នុងកងទាំងអស់ត្រូវងើបទៅធ្វើស្រែតាំងពីព្រលឹមប្រហែលជាម៉ោង៣ឬ៤ទៀបភ្លឺ។ នៅពេលឈប់សម្រាកពីការងាររម្ងងៗ អ្នកទាំងបួនតែងតែទៅអង្គុយជុំគ្នា ហើយ សាត តែងតែអប់រំដោយយករឿងដដែលៗមកនិយាយ ជាពិសេសរិះគន់អង្គការបដិវត្តន៍និងណែនាំឲ្យស្អប់អង្គការ។ ក្រោយមក សាត បានសួរទៅអ្នកទាំងបីថា ប្រសិនបើចង់បានអាហារហូបចុកគ្រប់គ្រាន់ និងរស់នៅស្រួលដូចកាលពីសង្គមចាស់វិញ ត្រូវតែធ្វើការប្រឆាំងបដិវត្តន៍ហើយនិងរបបសម្ហូហភាព។ សាត និយាយបន្ថែមថា «បើអង្គការឲ្យធ្វើអ្វីយើងធ្វើឲ្យតែរួចពីដៃទៅបានហើយ ហើយផលដែលបានមកពីដំដំឡូង ល្ពៅ យើងលួចយកមកស្ងោរស៊ីឲ្យអស់ ដើម្បីបំផ្លាញសម្ហូហភាព...»។

## សកម្មភាពក្បត់នឹងបដិវត្តន៍

ស្ថិតនៅក្រោមការអប់រំបណ្តុះស្មារតីឲ្យស្អប់អង្គការបដិវត្តន៍ ខ្ញុំ ទូច និងគុយ ចាប់ផ្តើមធ្វើសកម្មភាពប្រឆាំងនឹងអង្គការជាមួយនឹង សាត។ ប៉ុន្តែជាដំបូង សាត ក៏បានបញ្ជាក់ប្រាប់ថា «អ្វីដែលយើងនឹងធ្វើ គឺធ្វើជាសេ.អ៊ី.អា.ប្រឆាំងនឹងបដិវត្តន៍ដោយសហការជាមួយនឹងពួកបរទេស។ ដូច្នេះយើងត្រូវខំប្រមូលកម្លាំងបន្ថែមទៀត ដោយបញ្ចុះបញ្ចូលមិត្តណាដែលសេរីដូចគ្នា ដើម្បីឲ្យបានកម្លាំងកាន់តែច្រើន។ រីឯអ្នកដឹកនាំយើងក៏មិនតូចដែរគឺ បងចន អតីតគណៈវរសេនាធំតំបន់៣៥។ មួយវិញទៀត យើងត្រូវធ្វើសកម្មភាពបំផុសយុទ្ធជនណាដែលសេរីឲ្យរត់ទៅផ្ទះ ដើម្បីធ្វើឲ្យខ្សោយកម្លាំងបដិវត្តន៍ ដោយប្រាប់ថាបើនរណារត់ទៅនៅមូលដ្ឋានវិញ គេរៀបគ្រួសារឲ្យ ប៉ុន្តែត្រូវលាក់ការណ៍ឲ្យជិត...»។

នៅឆ្នាំ១៩៧៦ ខ្ញុំ បំផុសបានមិត្តម្នាក់ឲ្យរត់ត្រឡប់ទៅផ្ទះ



កងទ័ពខ្មែរក្រហមនៅពហុកីឡដ្ឋានជាតិអូរឡាំពិក

វិញ ។ ជាសរុប អ្នកទាំងបួនបាន បញ្ចុះបញ្ចូលឲ្យមិត្តនៅក្នុងកងរត់ចោលជួរអស់ចំនួន១២នាក់ ។ ជាងនេះទៅទៀត ខ្ញុំ បានធ្វើឲ្យបាត់គោអស់ចំនួនមួយនឹម ដោយបណ្តោយឲ្យវាឆ្លងចូលទៅក្នុងទឹកដីវៀតណាម នៅពេលដែលអង្គការបានចាត់តាំងគាត់ឲ្យទៅឃ្វាលគោបីនឹមនៅជិតព្រំដែន ។

ចុងឆ្នាំ១៩៧៦ សាត ក៏បានប្រាប់ ខ្ញុំ ទូច និង គុយ ឲ្យដឹងថា បច្ចុប្បន្នគាត់ទទួលផែនការផ្ទាល់ពី បងរ៉េត ដែលជាកងហានៅវរសេនាតូច៦៥ ដោយ រ៉េត មានកម្លាំងម្នាក់ទៀតឈ្មោះ សឿន ជាអនុក្រុមទី៣ កងហាទី២ កងធំ៣៤ វរសេនាតូច៦៥ តំបន់៣៥ និងជាអ្នកទទួលបញ្ជា ផ្ទាល់ពី បងចន ។ ខ្ញុំ ធ្លាប់បានជួបមុខ រ៉េត ម្តងនៅពេលដែលគាត់ធ្វើដំណើរត្រឡប់មកផ្ទះវិញ បន្ទាប់ពីស្រោចទឹកបន្លែរួច ។ ស្រែប្រាំងចុងឆ្នាំដដែល ខ្ញុំ សាត ទូច និង គុយ បានធ្វើពុតជាឈឺមិនទៅធ្វើការ រួចនាំគ្នាលួចដំឡូង ល្ពៅរបស់សហករណ៍មកហូប ព្រមទាំងបានបង្កការស្អុតស្អាញដល់អង្គភាពជាញឹកញាប់ ។

ដើមឆ្នាំ១៩៧៧ បន្ទាប់ពីសម្រាកនៅភូមិចាស់បានមួយរយៈ អង្គភាពរបស់ ខ្ញុំ ត្រូវបញ្ជាទៅច្បាំងជាមួយវៀតណាមនៅសមរភូមិភ្នំកូនត្រីដែលវៀតណាមបោះទីតាំងលើដីខ្មែរ ។ មុននឹងធ្វើដំណើរទៅសមរភូមិ សាត បានណែនាំ ខ្ញុំ ទូច និងគុយ ឲ្យបង្កភាពចលាចល ដោយកុហកយោធាឲ្យដកថយវិញ ព្រោះទ័ពវៀតណាមបានព័ទ្ធជិតអស់ហើយ បន្ទាប់មកចាំបាញ់កម្លាំងបដិវត្តន៍ពីក្រោយខ្នង ។ ពេលនោះ ទ័ពបដិវត្តន៍ស្ទើរតែវាយឈ្នះខ្មាំងទៅហើយ តែ ខ្ញុំ សាត ទូច និង គុយ បានធ្វើសកម្មភាពបំផុសបំផុលឲ្យកងទ័ពដកថយ ។ ឃើញដូច្នេះ ទ័ពខ្មាំងក៏ព័ទ្ធជាប់យោធាមួយចំនួននៅលើចង្កេះភ្នំ ។ ចំណែកឯក្រុមរបស់ ខ្ញុំ បានបាញ់សម្លាប់ទ័ពបដិវត្តន៍អស់ម្នាក់ ។

នៅដើមឆ្នាំ១៩៧៨ អង្គភាពរបស់ ខ្ញុំ ត្រូវអង្គការថ្នាក់លើចាត់តាំងឲ្យវាយទីតាំងវៀតណាមនៅតំបន់ភ្នំអកយំ ប៉ុន្តែ ខ្ញុំ មិនបានចូលរួមធ្វើសកម្មភាពជាមួយយុទ្ធជនផ្សេងទេ ។ ពេលដែលទ័ពសម្រុកចូលបន្ទាយភ្នំអកយំ អ្នកទាំងបួនបានបាញ់កងទ័ពពីក្រោយបណ្តាលឲ្យស្លាប់យុទ្ធជនបដិវត្តន៍ម្នាក់ ។ បន្ទាប់ពីបែកបន្ទាយភ្នំអកយំ កងរបស់ ខ្ញុំ ក៏ដកទៅសម្រាកនៅខាងកើតភ្នំដិន ។ នៅទីនោះ អ្នកទាំងបួននាំគ្នាខិតខំបញ្ចុះបញ្ចូល និងប្រមែប្រមូលគ្នាបន្ថែមទៀត ។ ប៉ុន្តែ ខ្ញុំ មិនអាចទាក់ទងបានកម្លាំងផ្សេងទេ ។ មួយខែក្រោយមក ពេលដែលអង្គភាពរបស់ ខ្ញុំ ត្រូវទៅសមរភូមិទន្លេបាសាក់ អ្នកទាំងបួនបែរជាគេចមកដេកនៅខាងក្រោយវិញ ព្រមទាំងបំផុសឲ្យទ័ពបដិវត្តន៍រត់ចោលជួរទៀត ។ ក្រោយពីរត់បានបន្តិច យុទ្ធជនបដិវត្តន៍ទាំងអស់ក៏ត្រូវប្រធានវរសេនាធំបញ្ជាឲ្យត្រឡប់ទៅវិញ ។ ប៉ុន្តែ ខ្ញុំ និងគ្នារបស់គាត់មិនបានធ្វើតាមបញ្ជា ។

ក្រោយពីសភាពការណ៍ផ្ទុះនៅភូមិភាគបូព៌ា អង្គភាពរបស់ ខ្ញុំ ត្រូវឡើងទៅវាយនៅភូមិភាគបូព៌ាទាំងអស់ លើកលែងតែ គុយ និង ទូច ព្រោះអ្នកទាំងពីរឈឺគ្រុន ។ បន្ទាប់ពីចូលសមរភូមិស្រុកសំរោងបានមួយខែ ខ្ញុំ ក៏ត្រូវរបួសមកសម្រាកព្យាបាលនៅមន្ទីរពេទ្យ «៦មករា» ទីក្រុងភ្នំពេញរយៈពេលមួយខែកន្លះ ។ ប្រហែលកន្លះខែក្រោយមក ខ្ញុំ បានទាក់ទងជាមួយ ម៉េង ដែលបច្ចុប្បន្នបានផ្លាស់មកកងពិសេស៧០៣ និង អាន ដែលមានគំនិតស្រឡាញ់របបឯកជនជាងរបបបដិវត្តន៍ ។ បន្ទាប់ពី ខ្ញុំ រាយការណ៍ប្រាប់ ស៊ឹម បានកន្លះខែ ខ្ញុំ អាន និង ម៉េង ចាប់ផ្តើមធ្វើសកម្មភាពសេរីរបស់ខ្លួន ។ នៅថ្ងៃប្រជុំដាក់ផែនការទៅវាយសមរភូមិស្រុកសំរោង អ្នកទាំងបីបានទៅដល់ក្រោយគេ ដោយសារតែទើបត្រឡប់មកពីលួចដកដំឡូងរបស់អ្នកភូមិហូប ។

## អង្គការឃាត់ខ្លួន

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៨ មិត្តនៅក្នុងកងបាននាំគ្នាធ្វើដំណើរទៅសមរភូមិស្រុកសំរោងតាមផែនការកំណត់ ។ ពេលនោះ ស៊ឹម និង អាន មិនបានចូលរួមទេ ដោយបានធ្វើពុតជាឈឺ ។ ចំណែក ខ្ញុំ និង ម៉េង ត្រូវទៅនៅជាមួយនឹងមិត្តដែលទើបមកដល់ថ្មី មានភារកិច្ចវាយពីខាងក្នុងមកខាងក្រៅ ។ ប៉ុន្តែនៅខណៈពេលដែលឃើញមិត្តនៅខាងមុខដើរជាន់មីនផ្ទុះ ពេលធ្វើដំណើរជិតដល់បន្ទាយវៀតណាម ខ្ញុំ និង ម៉េង ក៏បានបំផុសចលនាឲ្យដកថយ ដោយកុហកថាទ័ពវៀតណាមបានព័ទ្ធជុំជិត ។ ដោយសារតែរកមិនឃើញអ្នកដែលបានបង្កភាពចលាចល ប្រធានវរសេនាធំក៏បញ្ជាឲ្យទៅវាយនៅទីនោះម្តងទៀត ។ ប៉ុន្តែ ខ្ញុំ និង ម៉េង បានគេចមិនទៅចូលរួមទេ ។ ក្រោយមក ដល់ថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៨ ខ្ញុំ ក៏ត្រូវបានអង្គការចាប់ខ្លួន ដោយសារតែសកម្មភាពក្បត់នឹងបដិវត្តន៍របស់គាត់ ។ **ម៉ែន ពិចិត្រ**

# ការទៅដល់សហគមន៍ចាម-ម៉ូស្លីម ខេត្តកំពត

ដោយសារតែទឹកជន់ហូរហៀរនៅក្នុងខេត្តកំពត កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកជំនួយការផ្នែកច្បាប់បានទៅដល់វិហារ នូរ៉ូល-អ៊ីស្សាន នៅក្នុងភូមិ តាឌីប យឺតជាងការកំណត់ទុកជាមុន ។ យ៉ាងណាមិញ ទឹកជន់លិចនេះមិនបានបង្អាក់ប្រជាជនប្រហែលជាពីររយនាក់មិនឲ្យចូលរួមពិភាក្សាជាមួយក្រុមការងារយើងទាក់ទិននឹងបទពិសោធន៍របស់ប្រជាជនចាម-មូស្លីម ក្នុងអំឡុងពេលរបបខ្មែរក្រហមឡើយ ។ អ្នកភូមិបាននាំគ្នាអង្គុយនៅលើឥដ្ឋការ៉ូដែលបែកដាច់ដោយឡែកពីគ្នាជាក្រុមបុរស និងក្រុមស្ត្រី ហើយអ្នកភូមិដែលមានវ័យចំណាស់អង្គុយខាងមុខ ។ ខ្ញុំបានអង្គុយជិតក្រុមស្ត្រីវ័យចំណាស់ដែលទម្រង់មុខមាត់របស់គាត់មើលទៅមានរាងមុខមូលនិងស្បែកភ្លឺថ្លា ។ ជាមួយគ្នានេះ ក្រុមស្ត្រីចំណាស់នេះបានធ្វើឲ្យខ្ញុំមានអារម្មណ៍ថា ខ្ញុំជាមនុស្សចម្លែក ។ ក្រោយមក កញ្ញា សូ ហ្វារីណា អ្នករៀបចំគម្រោងបាន ពន្យល់ប្រាប់ខ្ញុំថាអាកប្បកិរិយាបែបនេះ គឺបណ្តាលមកពីដើមកំណើតរបស់ជនជាតិដើមចាម(វៀតណាមខាងជើង) និង ជ្វា (ឥណ្ឌូនេស៊ី)របស់អ្នកទាំងនោះ ។

ក្រោយពីការនិយាយណែនាំខ្លួនដំបូងរបស់កញ្ញា ហ្វារីណា លោកនាយក ឆាំង យុ បានសុំឲ្យក្រុមអ្នកភូមិខិតចូលឲ្យជិតក្រុមការងារដើម្បីជំរុញឲ្យមានកិច្ចពិភាក្សាដ៏ជិតស្និទ្ធបំផុតមួយ ។ ដោយសារតែមានការបកប្រែដោយកញ្ញា សើ សាយ្យាណា បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំក៏អាចចាប់បាននូវព័ត៌មានភាគច្រើននៅក្នុងកិច្ចពិភាក្សានៅពេលព្រឹកនេះ ។ ដោយមានការចាប់អារម្មណ៍សំខាន់ទៅលើក្រុមស្ត្រីចំណាស់ លោក ឆាំង យុ បានពន្យល់ពីដំណើរវិវត្តន៍ទៅមុខរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយបានសួរទៅកាន់អ្នកភូមិថាតើគាត់ចាប់អារម្មណ៍នៅក្នុងការចូលរួមតាមដានដំណើរការកាត់ក្តី ឌុច រយៈពេលមួយថ្ងៃក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ ។ ទោះបីជាមានអារម្មណ៍ថាអៀននិងភ័យខ្លាចក៏ដោយ ក៏អ្នកភូមិប្រហែលជាម្ភៃនាក់បានលើកដៃឡើងដែលភាគច្រើនសុទ្ធតែជាស្ត្រី ។ ខណៈពេលដែលមិនមានសារសំខាន់អ្វីនឹងត្រូវព្រួយបារម្ភចំពោះដំណើរនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្ត្រីម្នាក់បានពន្យល់ប្រាប់ថាគាត់ចង់ចូលរួមក្នុងដំណើរការកាត់ក្តីដើម្បីមើលមុខឌុច បុរសដែលបានប្រព្រឹត្តនូវអំពើឃោរឃៅ ។ ចំណែកឯអ្នកដទៃទៀតមានគោលបំណងចូលរួមក្នុងដំណើរការកាត់ក្តីដើម្បីបញ្ជាក់ថាក្រោយពី៣០ឆ្នាំកន្លងមក ជនដៃដល់នឹងត្រូវបានកាត់ទោសឲ្យទទួលខុសត្រូវការប្រព្រឹត្តរបស់ខ្លួន ។ អាស្រ័យលើភាសាកាយវិការ ការបញ្ចេញទឹកមុខ និងការសើចញឹកញាប់របស់អ្នកនិយាយ ខ្ញុំគិតថាជនរងគ្រោះកំពុងតែរៀបរាប់រឿងនិទានដែលមានន័យល្អ ឬកំប្លែង ។ ប៉ុន្តែ


ចាមមូស្លីមកំពុងស្តាប់ការពន្យល់របស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីតុលាការខ្មែរក្រហម

នៅពេលដែលកញ្ញា សាយ្យាណា ចាប់ផ្តើមបកប្រែប្រាប់អំពីរឿងរ៉ាវរបស់ស្ត្រីនោះទាក់ទិននឹងការសម្លាប់និងភាពអត់ឃ្លានរបស់សាច់ញាតិគាត់តាំងពីបងប្អូនស្រី ជីដូនជីតានិងពូរបស់គាត់ដោយខ្មែរក្រហម ខ្ញុំមានអារម្មណ៍ភ្ញាក់ផ្អើលជាមួយនឹងការសម្តែងអាកប្បកិរិយារីករាយរបស់ស្ត្រីនេះ ខណៈពេលដែលគាត់បានរៀបរាប់ពីសោកនាដកម្មទាំងនេះ ។ ក្នុងនាមជាប្រជាជនមកពីលោកខាងលិច ខ្ញុំបានស្វែងយល់ពីភាពខុសគ្នានៃការសម្តែងទឹកមុខបញ្ឈាក់ពីទុក្ខសោកនិងសោកនាដកម្មរបស់ប្រជាជនខ្មែរ ។ ជាទូទៅរឿងរ៉ាវវិនាសអន្តរាយនៅលោកខាងលិចត្រូវបានរៀបរាប់ឡើងដោយមានការប៉ះទង្គិចផ្លូវចិត្តនិងការសម្រក់ទឹកភ្នែកដែលសម្តែងចេញឲ្យឃើញ ។ ផ្ទុយទៅវិញ ស្ត្រីនេះបានបរិយាយភាពសោកសៅរបស់គាត់តាមរយៈស្នាមញញឹមនិងសំឡេងសើច ។ ខណៈពេលដែលលោក ឆាំង យុ សួរពីសមត្ថភាពគាត់ក្នុងការអត់ឱនទោសដល់ជនដៃដល់ ស្ត្រីនេះបានបដិសេធដោយសំឡេងរាបស្មើថា គ្មានលទ្ធភាពណាមួយអាចធ្វើឲ្យមានការអត់ឱនទោសទេ ។ ការបដិសេធមិនធ្វើការអត់ឱនទោសរបស់គាត់នៅតែមាន ទោះបីជាលោក ឆាំង យុ បានសួរស្ត្រីនេះពីការបង្រៀនសាសនាអ៊ីស្លាមរបស់គាត់ដែលមានជាប់ពាក់ព័ន្ធជាមួយនឹងការអត់ឱនទោសនេះក៏ដោយ ។ យើងអាចដឹងតាមរយៈទឹកមុខគាត់ថាគាត់បានដឹងតាមរយៈបទពិសោធន៍និងជំនឿសាសនាថាគាត់ត្រូវបានតម្រូវឲ្យធ្វើការអត់ឱនទោស ប៉ុន្តែស្ត្រីរូបនេះគ្រាន់តែមិនអាចផ្តល់នូវការអត់ឱនទោសបានតែប៉ុណ្ណោះ ។ ការនិយាយឆ្លើយឆ្លងនេះបានផ្តោះទៅរកចម្លើយច្បាស់លាស់ដ៏ខ្លីមួយថា «គ្មាននរណាដឹងសោះ» ថាតើការសង់ជំងឺចិត្តប្រភេទណាដែលតុលាការអាចផ្តល់ឲ្យ ។ ការសងជំងឺចិត្តគ្រប់បែបមិនអាចនឹងមានភាពគ្រប់គ្រាន់ទេសម្រាប់ស្ត្រីនេះ ពីព្រោះថាការខូចខាតដែលកើតមាននៅក្នុងជីវិតរបស់គាត់មិនអាចសងមកវិញបានទេ ហើយការសងជំងឺចិត្តនេះទៀតសោតក៏មិនអាចធ្វើឲ្យគាត់ទទួលបានសមាជិកគ្រួសារគាត់ត្រឡប់មកវិញបានដែរ ។

ការបើកចំហនិងការស្ម័គ្រចិត្តរបស់ក្រុមអ្នកភូមិដើម្បីបញ្ចេញទស្សនៈ និងរឿងរ៉ាវរបស់គេ មិនត្រូវទាមទារឲ្យធ្វើឡើងឡើយ ប៉ុន្តែមានអ្នកភូមិជាច្រើននៅក្នុងក្រុមបានស្វាគមន៍ឱកាស



អ្នកភូមិកំពុងស្តាប់ការពន្យល់អំពីតុលាការខ្មែរក្រហម

ក្នុងការចែករំលែកបទពិសោធន៍គេទៅកាន់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងយុវជនជំនាន់ក្រោយដែលស្ថិតក្នុងការចូលរួមពិភាក្សានេះ ។ ការពិតដែលថាយើងទាំងអស់ខ្មែរ ចាម និងជនជាតិអាមេរិក បានជួបជុំគ្នាដើម្បីចែករំលែកបទពិសោធន៍និងទទួលបាននូវសៀវភៅដំបូងមួយក្បាលស្តីពីខ្មែរក្រហមនោះ ហាក់បីដូចជាបានជំរុញឲ្យអ្នកភូមិមានការជឿជាក់ក្នុងការនិយាយរៀបរាប់រឿងរ៉ាវរបស់គាត់ ដែលក្នុងក្រុមអ្នកភូមិមួយចំនួនតូចបានអវត្តមាននៅក្នុងការនិយាយពីរឿងរ៉ាវរបស់គាត់ ។ ដំណើរការនៃការជួបជុំរបស់អ្នករាល់គ្នាក្នុងឱកាសនេះ ហាក់បីដូចជាបានធ្វើឲ្យរឿងរ៉ាវរបស់អ្នកភូមិមានការទទួលដឹងឮ និងធ្វើឲ្យការរង់ចាំរបស់គាត់អស់រយៈពេលជាច្រើនឆ្នាំសម្រាប់បុគ្គលណាម្នាក់មកទទួលស្គាល់នូវរឿងរ៉ាវដែលកើតមានឡើងនៅក្នុងសហគមន៍ប្រជាជនចាម-ម៉ូស្លីម មានការទទួលដឹងឮដែរ ។ ការទទួលដឹងឮនេះបានស្ថិតនៅក្នុងភាពស្ងប់ស្ងាត់ទៅវិញ ខណៈពេលដែលលោក ឆាំង យុ



បានអញ្ជើញសមាជិកវ័យក្មេងម្នាក់ក្នុងក្រុមឲ្យអានផ្នែកខ្លះនៅក្នុងសៀវភៅដែលរៀបរាប់ពីបទពិសោធន៍របស់ប្រជាជន ចាម-ម៉ូស្លីម ក្នុងអំឡុងពេលគ្រប់គ្រងរបស់ខ្មែរក្រហម ។ ក្រោយពីបានរកឃើញក្មេងម្នាក់ដែលមានសមត្ថភាព និងស្ម័គ្រចិត្តអាន ក្រុមអ្នកភូមិបាននាំគ្នាស្តាប់យ៉ាងយកចិត្តទុកដាក់ ខណៈដែលយុវជនម្នាក់នេះបានអាននូវការប្រព្រឹត្តមកលើប្រជាជនចាម-ម៉ូស្លីម ជូនដល់អ្នកភូមិស្តាប់ ។ សូម្បីតែក្មេងយុវវ័យក្នុងចំណោមអ្នកភូមិទាំងអស់នេះ ក៏បានយកចិត្តទុកដាក់ស្តាប់ដោយទទួលស្គាល់ទាំងស្រុងថា រឿងរ៉ាវទាំងអស់ដែលចាស់ៗធ្លាប់បាននិយាយប្រាប់សុទ្ធតែជាការពិត ហើយឥឡូវរឿងរ៉ាវទាំងនេះកំពុងត្រូវបានកត់ត្រាទុកនៅក្នុងសៀវភៅមួយក្បាលដែលនឹងត្រូវបានអានដោយប្រជាជនខ្មែរគ្រប់រូប និងប្រជាជនក្នុងពិភពលោក ។ ការតាមដានអង្កេតនេះក៏បានបន្តគាំទ្រដោយការបញ្ជាក់អះអាងដោយផ្ទាល់ពីអ្នកភូមិដែលថាដំណើររឿងដែលមាននៅក្នុងសៀវភៅនេះពិតជាមានភាពត្រឹមត្រូវច្បាស់លាស់ ។

អ្វីដែលខ្ញុំគិតថានឹងអាចក្លាយជាការងារមួយដែលពោរពេញដោយភាពឈឺចាប់សម្រាប់ជនរងគ្រោះក្នុងការនិយាយរៀបរាប់ពីបទពិសោធន៍របស់គេនោះ បានក្លាយទៅជាភាពធូរស្បើយអារម្មណ៍យ៉ាងខ្លាំងសម្រាប់អ្នកភូមិចាស់ៗ និងសម្រាប់ការស្វែងយល់ដ៏ពេញលេញ ឬការរំឭកដល់យុវជនថាព្រឹត្តិការណ៍ទាំងអស់នេះពិតជាបានកើតមានឡើងចំពោះសមាជិកគ្រួសារ និងអ្នកជិតខាងគេមែន ។ អ្នកអង្កេតខ្លះបានជំទាស់ថាការប្រជុំពិភាក្សាពីអតីតកាលដែលមានរបួសស្នាម និងឈឺចាប់បែបនេះ គួរតែត្រូវបានធ្វើឡើងដោយមានការដឹកនាំដោយគ្រូពេទ្យផ្នែកសតិអារម្មណ៍ ។ យ៉ាងណាមិញ នៅក្នុងសហគមន៍ដូចជាសហគមន៍មួយនេះដែលយើងបានទស្សនា ខ្ញុំមានអារម្មណ៍ថាការពិភាក្សាជាក្រុមគឺជាយានមួយដ៏សមរម្យធ្វើឲ្យមានភាពធូរស្បើយ និងការទទួលស្គាល់ពីភាពឈឺចាប់របស់ជនរងគ្រោះ ស្របពេលដែលការធ្វើបែបនេះបានធ្វើឲ្យមានការរំឭកដល់អ្នកភូមិក្មេងៗពីអតីតកាលនៃសហគមន៍របស់គេ ។ ទោះបីជាអ្នកភូមិ តាឪប ខ្លះគ្មានថ្ងៃព្យាបាលភាពឈឺចាប់ ឬក៏ព្យាបាលមិនបាននោះ អ្នកភូមិទាំងអស់នេះក៏បានស្វែងយល់ពីអត្ថប្រយោជន៍នៃការចែករំលែករឿងរ៉ាវរបស់គេទៅកាន់សហគមន៍គេទាំងមូលផងដែរ ។ ក្រោយពីការចែកចាយសៀវភៅមកអ្នកភូមិដែលមានវត្តមាននៅក្នុងវិហារនូរ៉ូល-អ៊ីស្សានបានចាកចេញជាមួយនឹងការអះអាងជាក់ស្តែងថាអ្វីដែលបានកើតឡើងក្នុងអំឡុងរបបខ្មែរក្រហមពិតជាត្រឹមត្រូវ ។ ជាមួយគ្នានេះ អ្នកភូមិទាំងអស់ក៏បានចាកចេញទៅដោយមានការដឹងឮថាប្រជាជនខ្មែរទូទាំងប្រទេសនឹងអានសៀវភៅមួយនេះដែលប្រាប់ពីជ្រុងមួយនៃភាពងងឹតនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជាអំពីទស្សនៈរបស់ប្រជាជនចាម-ម៉ូស្លីម ។ ទោះបីជាសម្រាប់ថ្ងៃនេះ ការទទួលស្គាល់ថាត្រឹមត្រូវនេះមិនបានក្លាយជាដំណើរការផ្សះផ្សា និងការអត់ឱនទោសក៏ដោយ ក៏រឿងរ៉ាវរបស់អ្នកភូមិទាំងអស់ត្រូវបានទទួលដឹងឮ ហើយឥឡូវនេះរឿងរ៉ាវមួយចំណែករបស់គេបានក្លាយជាផ្នែកមួយនៃរបៀបដែលប្រជាជនខ្មែរនឹងត្រូវបានបង្រៀនពីអំឡុងពេលនៃរបបខ្មែរក្រហម ។

**ស្តេនសឺ ខ្វាយជី**

# ហ៊ឹម ហ៊ុយ: អតីតឆ្មាំផ្តល់កសិណពិតទាក់ទងទៅនឹងកិច្ចការនៅទួលស្លែងនិងជើងឯក

ក្នុងវ័យអាយុ៥៨ឆ្នាំ ហ៊ឹម ហ៊ុយ បានត្រឡប់ទៅកាន់វេទិកាសម្រាប់សាក្សីបំភ្លឺនៅថ្ងៃនេះ ហើយបានធ្វើសក្ខីកម្មយ៉ាងលម្អិតអំពីកិច្ចការជាច្រើននៅគុកទួលស្លែង (ស-២១) និងវាលពិឃាតនៅជើងឯក ដែលទីតាំងសម្ងាត់ទាំងពីរនេះដឹកនាំដោយជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ ក្នុងករណីដែល ឌុច អះអាងថាគាត់បានដឹងតិចតួចអំពីកិច្ចការពីមួយថ្ងៃទៅមួយថ្ងៃ ហើយសាក្សីផ្សេងទៀតត្រូវបានប្រគល់កិច្ចការឲ្យធ្វើនៅកន្លែងមិនសូវសំខាន់ជាការប្រសើរជាមុននៅពេលបានឮដំណឹងថា ព័ត៌មានដែលបានមកពីឆ្មាំគុកធ្លាប់បានសង្កេតមើលកិច្ចការពេលដែលគាត់បានធ្វើកាលពីជំនាន់ខ្មែរក្រហម ហើយឆ្មាំគុកម្នាក់នេះមានភារកិច្ចទទួលខុសត្រូវជាច្រើន ហើយក៏ធ្លាប់បានធ្វើកិច្ចការជាច្រើនកន្លែងផងដែរ ។ ឆ្មាំគុកម្នាក់នេះនឹងបន្តធ្វើសក្ខីកម្មថែមទៀតនៅថ្ងៃច័ន្ទសប្តាហ៍ក្រោយ ។

ហ៊ឹម ហ៊ុយ មិនបានអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការមិននិយាយស្តីទេ ប៉ុន្តែមេធាវីរបស់គាត់មិនបាននិយាយអ្វីទាំងអស់ពេញមួយថ្ងៃ ។

កាលពីម្សិលមិញ ហ៊ឹម ហ៊ុយ បានបង្ហាញខ្លួនដែលមានរយៈពេលយូរល្មមដើម្បីសុំពេលពិគ្រោះជាមួយមេធាវីរបស់គាត់ទាក់ទងទៅនឹងសិទ្ធិក្នុងការការពារខ្លួនពីការជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋ ។ ទោះបីជាសាក្សីមានសិទ្ធិនេះក៏ដោយ ជាការគួរឲ្យចង់ដឹងចង់ឮណាស់ថា អំឡុងពេល៦ម៉ោងនៃការចោទសួរនៅថ្ងៃនេះ ហ៊ឹម ហ៊ុយ មិនបានអនុវត្តសិទ្ធិរបស់គាត់ដោយមិននិយាយស្តីទេ ហើយបានសារភាពថាខ្លួនបានសម្លាប់យ៉ាងហោចណាស់ក៏អ្នកទោសម្នាក់ដែរនៅជើងឯក ។



ហ៊ឹម ហ៊ុយ ឆ្នាំ២០០៩



ហ៊ឹម ហ៊ុយ ឆ្នាំ១៩៧៧

មេធាវីរបស់ ហ៊ឹម ហ៊ុយ ដែលត្រូវបានចាត់តាំងដោយអង្គភាពគាំពារសាក្សីនិងអ្នកជំនាញនៃជំនុំជម្រះវិសាមញ្ញមិនបាននិយាយអ្វីទាំងអស់ក្នុងអំឡុងពេលសវនាការនៅថ្ងៃនេះ ។ ស្របពេលជាមួយគ្នានេះដែរ នៅតែមានភាពស្រពេចស្រពិលថាតើគាត់ត្រូវបានផ្តល់សិទ្ធិឲ្យនិយាយឬក៏អត់ ។ យោងតាមអង្គភាពកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះបានឲ្យដឹងថា មេធាវីបានផ្តល់ប្រឹក្សាដល់សាក្សីជាជាងមេធាវីនោះនិយាយខ្លួនឯងអំពីបញ្ហាតូចតាចទាក់ទងទៅនឹងការការពារខ្លួនឯងដើម្បីកុំឲ្យជាប់បទឧក្រិដ្ឋ ។ ព្រឹកនេះ លោកប្រធានចៅក្រម និល ណុន សួរទៅកាន់ ហ៊ឹម ហ៊ុយ ថាតើចង់ឲ្យមេធាវីរបស់ខ្លួនមានវត្តមាននៅក្នុងបន្ទប់សវនាការដែរឬអត់ ខណៈពេលដែលមេធាវីរូបនេះកំពុងតែអង្គុយនៅក្នុងបន្ទប់រួចទៅហើយ ឬមួយក៏ចង់ឲ្យគាត់អង្គុយនៅខាងក្រៅសវនាការវិញ ។ ហ៊ឹម ហ៊ុយ បានឆ្លើយតបវិញថា គាត់ចង់ឲ្យមេធាវីរបស់គាត់អង្គុយក្នុងបន្ទប់សវនាការនេះ ។ ក្រោយមកលោកប្រធានបានប្រាប់ទៅ ហ៊ឹម ហ៊ុយ ថាខ្លួនមានសិទ្ធិត្រឹមតែទទួលយកដំបូន្មានពីមេធាវីរបស់ខ្លួនដើម្បីចៀសផុតពីការដាក់ទោសលើខ្លួនឯងប៉ុណ្ណោះ ហើយរាល់សំណួរទាំងអស់ ហ៊ឹម ហ៊ុយ ត្រូវតែឆ្លើយដោយខ្លួនឯង ។

## កិច្ចការនៅក្នុងនិងជុំវិញមន្ទីរស-២១

ក្នុងឆ្នាំ១៩៧២ ឬ ១៩៧៣ ហ៊ឹម ហ៊ុយ ត្រូវបង្ខំឲ្យចូលធ្វើទ័ពខ្មែរក្រហម ហើយក្រោយពីការហាត់ពីជំនាញទ័ពរួចមក គាត់ត្រូវបានបញ្ជូនពីអង្គភាពមួយទៅកាន់អង្គភាពមួយទៀត ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គភាពរបស់ ហ៊ឹម ហ៊ុយ បានរួមចំណែកជួយខ្មែរក្រហម «រំដោះ» យកទីក្រុងភ្នំពេញ ។ បន្ទាប់ពីនោះមក គាត់បានទៅធ្វើស្រែក្រោមការដឹកនាំរបស់សមមិត្ត ហ៊ី ដែលជាអនុប្រធានរបស់ ឌុច ។ ហ៊ី នេះហើយដែលជាអ្នកជ្រើសរើស ហ៊ឹម ហ៊ុយ ទៅធ្វើការនៅមន្ទីរស-២១ ។

អង្គភាព «កងការពារ» របស់ ហ៊ឹម ហ៊ុយ មានទីតាំងធ្វើការនៅក្នុងអគារតូចមួយនៅខាងក្រោយបរិវេណមន្ទីរស-២១ដើម្បីការពារប្រកបូលនិងចាំទទួលអ្នកទោសពេលមកដល់ ។ អង្គភាពរបស់ ហ៊ឹម ហ៊ុយ ក៏មាននាទីក្នុងការចាប់ចងអ្នកទោស យកអ្នកទោសដែលចាប់រួច ហើយបញ្ជូនទៅជើងឯកដែរ ។ ពេលទំនេរពីកិច្ចការរបស់អង្គភាព ហ៊ឹម ហ៊ុយ មាននាទីចិញ្ចឹមសត្វទៀត ។ ហ៊ឹម ហ៊ុយ បានបញ្ជាក់ថា គាត់ជាកងការពារសាមញ្ញម្នាក់ប៉ុណ្ណោះ ហើយគាត់ត្រូវបានតែងតាំងឲ្យធ្វើជាប្រធានអង្គភាព ក្រោយពេលសហការីដែលធ្វើការជាមួយគាត់ខ្លះបានបាត់ខ្លួន ។ ក្នុងនាមជាប្រធាន គាត់មានភារកិច្ចយាមល្បាតជុំវិញមន្ទីរនិងអគារនៅស-២១ទាំងមូល ដើម្បីធានាបានថា កងការពារបានយាមល្បាតត្រឹមត្រូវ ។

អង្គភាពរបស់ ហ៊ឹម ហ៊ុយ បានទទួលបញ្ជាពី ឌុច តាមរយៈហ៊ឺ ដើម្បីអនុវត្តន៍ការចាប់ខ្លួននៅក្នុងទីក្រុងភ្នំពេញ ។ ហ៊ឹម ហ៊ុយ បានទៅផ្សារថ្មីក្នុងក្រុងភ្នំពេញនៅពេលយប់ ដើម្បីចាប់សត្រូវដែលអ្នកទាំងនោះត្រូវបានលួងលោមដោយកម្មាភិបាលខ្មែរក្រហមឲ្យមកដោយលេសផ្សេងៗ ។ អង្គភាពរបស់ ហ៊ឹម ហ៊ុយ ក៏បានទៅទីតាំងឆ្ងាយៗឯជនបទដើម្បីដឹកអ្នកទោសដែលបានចាប់ដោយអង្គភាពយោធា ឬដោយការិយាល័យធ្វើការដើម្បីបញ្ជូនមកមន្ទីរស-២១ ។ ឌុច បានបញ្ជា ហ៊ឹម ហ៊ុយ ឲ្យទៅដឹកអ្នកទោសប្រហែលជា១៥នាក់ក្នុងឯកសណ្ឋានទាហានវៀតណាមចំនួនពីរដង ។ «និរសារក្រុង» ក៏បាននាំជនជាតិខ្មែរដែលទើបត្រឡប់មកពីបរទេសទៅកាន់មន្ទីរស-២១ផងដែរ ដោយវិធីបោកបញ្ឆោត ហើយអង្គភាពរបស់ ហ៊ឹម ហ៊ុយ ជាអ្នកចាប់អ្នកទាំងនោះ ។

នៅពេលដែលអ្នកទោសត្រូវបានបញ្ជូនទៅមន្ទីរស-២១ អ្នកទាំងនោះត្រូវបានដាក់ខ្នោះជើង ខ្នោះដៃ បិទមុខ ហើយឲ្យអង្គុយនៅក្នុងឡានទ្រុង ។ អ្នកទោសមិនត្រូវបានអនុញ្ញាតឲ្យរំកិលចុះឡើងដែលអាចនាំឲ្យមានការគេចខ្លួនបានទេ ។ ការធ្វើដំណើរពីកន្លែងមួយទៅកន្លែងតម្រូវឲ្យមានលិខិតអនុញ្ញាត ហើយមានម្ដងនោះ ហ៊ឺ បានឲ្យសំបុត្រមួយទៅ ហ៊ឹម ហ៊ុយ ដោយមានហត្ថលេខារបស់ សុន សេន ដែលជាប្រធានរបស់ ឌុច ។

ពេលមកដល់មន្ទីរស-២១ភ្លាម អ្នកទោសម្នាក់ៗត្រូវឆ្លងកាត់អគារតូចមួយដែលមានទីតាំងនៅខាងក្រោយបរិវេណមន្ទីរស-២១ ។ សម្រាប់អ្នកដែលមិនទាន់បានចាប់ខ្លួន អង្គភាពរបស់ ហ៊ឹម ហ៊ុយ ត្រូវនាំអ្នកទាំងនោះចូលក្នុងបន្ទប់ ហើយឲ្យអ្នកទាំងនោះអង្គុយលើកៅអី រួចចាប់អ្នកនោះតែម្ដង ។ ជួនកាលអ្នកទោសពី៥០ទៅ៦០នាក់មកដល់ក្នុងពេលដំណាលគ្នាតែមួយ ។ ក្នុងករណីនេះអ្នកទោសទាំងអស់នោះត្រូវបានចាប់ចងក្នុងពេលតែមួយជាមួយគ្នា ។ អ្នកទោសទាំងអស់ត្រូវបានកត់ត្រាទុកដោយសរសេរឈ្មោះនិងថតរូបដោយប្រគល់លេខកូដសម្រាប់ម្នាក់ៗមុននឹងបញ្ជូនទៅកាន់អង្គភាពណាមួយនិងសម្រេចថាអ្នកទោសនោះមានសារសំខាន់ប៉ុណ្ណា ហើយបន្ទប់មួយណាត្រូវបញ្ជូនទៅ ។ ក្នុងដំណាក់កាលនោះ អ្នកទោសមិនសូវសំខាន់នឹងត្រូវបញ្ជូនទៅមន្ទីរអប់រំទៅព្រៃស (ស-២៤) មិនមែនទៅមន្ទីរស-២១ទេ ។

ទាក់ទងនឹងលក្ខខណ្ឌនៅក្នុងមន្ទីរឃុំឃាំង ហ៊ឹម ហ៊ុយ បានបញ្ជាក់ថា កងការពារជាអ្នកផ្ដួតទឹកឲ្យអ្នកទោសដោយយកទុយោបាញ់ចូលទៅក្នុងបន្ទប់ឃុំឃាំង ។ វិធីនេះត្រូវយកមកប្រើប្រាស់ដោយសារខ្លាចអ្នកទោសមានឱកាសរត់រួច ។ ហ៊ឹម ហ៊ុយ ក៏បានបញ្ជាក់ផងដែរថា អ្នកទោសទទួលបានរបបអាហារមិនគ្រប់គ្រាន់ទេ ហើយម្នាក់ៗមានរូបរាងស្គមស្គាំងយ៉ាងខ្លាំងដោយទទួលបានរបបបបរមួយថ្ងៃពីរពេល ហើយមួយពេលៗទទួលបានតែមួយវែកកន្លះប៉ុណ្ណោះក្នុងម្នាក់ ។ ហ៊ឹម ហ៊ុយ និយាយបន្ថែមទៀតថា អ្នកទោសស្ត្រីត្រូវចាត់ទុកថាខ្សោយណាស់ទៅហើយមិនអាចបះបោរបានទេ ដូច្នេះអ្នកទោសទាំងនោះមិនត្រូវបានដាក់ខ្នោះដៃឡើយ ហើយត្រូវបានបង្ខាំងទុកក្នុងបន្ទប់ដែលចាក់សោជាប់នៅជាមួយកូន ។ ហ៊ឹម ហ៊ុយ មិនដែលតាមដានមើលអ្នកទោសពេលកំពុងសួរចម្លើយទេ ប៉ុន្តែគាត់បានរៀបរាប់ថា អ្នកទោសទាំងអស់ត្រូវបានជាប់ឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ ។ គាត់បាននិយាយបន្ថែមថា អ្នកទោសជាច្រើនបានស្លាប់នៅក្នុងមន្ទីរឃុំឃាំងដោយសារមិនអាចទ្រាំទ្រនឹងរបួសពីការធ្វើទារុណកម្មបាន ហើយសាកសពទាំងនោះត្រូវបានកប់ភ្លាមៗនៅក្នុងបរិវេណមន្ទីរស-២១ ។ អ្នកដែលមិនបានស្លាប់នៅក្នុងបន្ទប់ឃុំឃាំងត្រូវយកទៅសម្លាប់ចោលមួយឬពីរសប្ដាហ៍ក្រោយពីសួរចម្លើយ ។ តាមការរៀបរាប់របស់ ហ៊ឹម ហ៊ុយ បានឲ្យដឹងថាបុគ្គលិកមន្ទីរ

ស-២១ដែលត្រូវបានបោសសម្អាតអ្នកទោសសំខាន់ៗ ឈ្លើយសឹកវៀតណាម ជនបរទេស និងកុមារត្រូវបានសម្លាប់នៅជិតបរិវេណមន្ទីរស-២១ ជាជាងយកទៅសម្លាប់នៅជើងឯក ។ អ្នកទោសត្រូវបានប្រាប់ថាឲ្យទៅរស់នៅផ្ទះថ្មី ហើយក្រោយមកអ្នកទោសទាំងនោះត្រូវយកចេញពីបន្ទប់ឃុំឃាំងនៅពេលយប់ ។ ក្រោយមក កងការពារបានបណ្តើរអ្នកទោសទៅមាត់រណ្តៅជាកន្លែងដែលអ្នកទោសត្រូវបានបង្ខំឲ្យលុតជង្គង់ ។ ក្រោយមក កងការពារបានយកដែកក្បៀរទេះដើម្បីវាយកញ្ចឹង-ក អ្នកទោសមុននឹងអារ-ក សម្លាប់ជាក្រោយមុនទម្លាក់ចូលក្នុងរណ្តៅ ។ បន្ទាប់មកអ្នកទោសត្រូវបានដោះខោអាវចេញអស់ ហើយខ្នោះដៃក៏ត្រូវដោះចេញដែរសម្រាប់ប្រើប្រាស់នៅថ្ងៃក្រោយទៀត ។ អ្នកទោសត្រូវបានធាក់ចូលក្នុងរណ្តៅ រួចហើយកប់ភ្លាមៗ ។

ទាក់ទងនឹងចំនួនអ្នកទោស ហ៊ឹម ហ៊ុយ បានរំឭកថា ជនបរទេសដែលមានមាឌធំ សក់ពណ៌ទង់ដែងបីបួននាក់ត្រូវបានយកទៅដុតនៅតាមផ្លូវដោយឱបភ្ជាប់នឹងកៅស៊ូកង់ឡាន ក្រោយពីអ្នកទាំងនោះត្រូវបានសម្លាប់នៅជិតមន្ទីរស-២១រួចហើយ ។ ហ៊ឹម ហ៊ុយ បានរៀបរាប់ទៀតថា ឌុច អាចនិយាយត្រូវនៅត្រង់ថា ជនជាតិវៀតណាម៣៤៥នាក់ត្រូវបានជាប់ឃុំឃាំងនៅមន្ទីរស-២១ ហើយ ហ៊ឹម ហ៊ុយ យល់ថា អ្នកទោសវៀតណាមទាំងនោះត្រូវបានសម្លាប់នៅជិតបរិវេណមន្ទីរនេះ ។ គាត់ក៏បានប៉ាន់ប្រមាណថាកុមារចំនួនពី៥០ទៅ៦០នាក់ដែលមានអាយុចាប់ពី១ទៅ៨ឆ្នាំត្រូវបានសម្លាប់នៅជិតបរិវេណនោះដែរ ។

ឌុច បាននិយាយរៀបរាប់ថា គ្មាននរណាម្នាក់នៅមន្ទីរស-២១ត្រូវបានដោះលែងឲ្យមានសេរីភាពទេ ។ ហ៊ឹម ហ៊ុយ បានបញ្ជាក់ថាត្រង់ចំណុចនេះគឺការពិតជាទូទៅ ក៏ប៉ុន្តែ ហ៊ឹម ហ៊ុយ បានបញ្ជាក់ទៀតថាមានម្តងនោះគាត់បានឃើញអ្នកទោសជនជាតិថៃមួយក្រុមត្រូវបានដោះលែង តែគាត់មិនដឹងពីមូលហេតុនោះទេ ។ គាត់បានរៀបរាប់ទៀតថា កម្មាភិបាលនៅមន្ទីរស-២១ត្រូវបានបោសសម្អាតយ៉ាងច្រើន ក្នុងនោះកម្មាភិបាល២០០នាក់ក្នុងចំណោម៤០០នាក់ត្រូវបានបោសសម្អាត ។ ភាគច្រើននៃបុគ្គលិករបស់មន្ទីរស-២១ គឺជាអតីតកងទ័ពរបស់កងពល៧០៣ ។ ក្នុងឆ្នាំ១៩៧៧ កម្មាភិបាលកងពល៧០៣ជាច្រើនមកពីវាលស្រែជើងឯកត្រូវបានសួរចម្លើយ ហើយចម្លើយសារភាពទាំងអស់នោះបញ្ជាក់ថា អ្នកទាំងនោះមានអតីតជាបុគ្គលិកមន្ទីរស-២១ ។ ហ៊ឹម ហ៊ុយ មិនបានដឹងទេថា តើអ្នកទោសដែលត្រូវបាត់ខ្លួននោះបានធ្វើអ្វីខុសទេ គាត់គ្រាន់តែដឹងថា «មនុស្សបានបាត់ខ្លួនជាបន្តបន្ទាប់» ។

ហ៊ឹម ហ៊ុយ ក៏បាននិយាយទៀតថា កងការពារណាដែលមានកំហុសតូចតាចត្រូវបានបញ្ជូនទៅមន្ទីរស-១ដើម្បីធ្វើការអប់រំ ។ កាលពីពេលចូលធ្វើការនៅមន្ទីរស-២១ដំបូង ហ៊ឹម ហ៊ុយ អាចដើរមើលតាមចិត្ត ហើយក៏អាចជជែកលេងជាមួយមិត្តធ្វើការជាមួយគ្នាបានដែរ ប៉ុន្តែក្រោយពីមានការបោសសម្អាត ម្នាក់ៗសុទ្ធតែត្រូវបានតាមដានជាប់រហូត ដូច្នេះការដើរហើរទៅកន្លែងណាមួយនិងការសន្ទនាជាមួយកម្មាភិបាលឯទៀតមានការតឹងតែងយ៉ាងខ្លាំង ។

ពេលសួរថាតើការសម្លាប់ធ្វើឡើងយ៉ាងដូចម្តេចនៅជើងឯក? ហ៊ឹម ហ៊ុយ បានរៀបរាប់យ៉ាងលម្អិត ដែលរហូតមកទល់ពេលនេះគាត់ជាមនុស្សតែម្នាក់ដែលបានបកស្រាយយ៉ាងលម្អិតអំពីកិច្ចការនៅវាលពិឃាតជើងឯកក្រោមការត្រួតត្រារបស់ ឌុច ។ ក្រោយពី ហ៊ឺ បានឲ្យបញ្ជីឈ្មោះភ្លាម អង្គភាពរបស់ ហ៊ឹម ហ៊ុយ ត្រូវទៅយកអ្នកទោសចេញពីបន្ទប់ឃុំឃាំងនៃមន្ទីរស-២១ នៅវេលាម៉ោង៦:៣០នាទីល្ងាច ហើយបណ្តើរអ្នកទោសនោះទៅក្នុងដាក់ក្នុងឡានទ្រុងដែលគ្របជិត នៅទីនោះអ្នកទោសត្រូវដាក់ឲ្យអង្គុយទាំងជើងជាប់ខ្នោះ ហើយចងមុខដែលនឹងត្រូវធ្វើដំណើរនៅលើចម្ងាយផ្លូវរយៈពេល៣០នាទីពីមន្ទីរស-២១ ទៅកាន់ជើងឯក ។ អ្នកទោសទាំងនោះត្រូវបានប្រាប់ថាឲ្យទៅកាន់លំនៅឋានថ្មី ។ ហ៊ឹម ហ៊ុយ មាននាទីឆែកមើលបញ្ជីឈ្មោះអ្នកទោសនៅក្នុងបញ្ជីនិងផ្ទៀងផ្ទាត់មើលចំនួនអ្នកទោសមុននឹងឡានទ្រុងដឹកទៅជើងឯក ។

ពេលមកដល់ អង្គភាពនៅជើងឯកមានភារៈចាំទទួលអ្នកទោស ។ ដំបូងអង្គភាពនោះត្រូវបញ្ឆេះម៉ាស៊ីនភ្លើងដើម្បីបំភ្លឺផ្លូវ ។ អ្នកទោសទាំងអស់ត្រូវបង្ខំឲ្យចាំនៅក្នុងបន្ទប់បិទជិតមួយនៅជាន់ខាងក្រោមនៃផ្ទះដ៏ធំមួយ ។ អ្នកទោសត្រូវយកចេញម្តងមួយៗទៅកាន់រណ្តៅដែលត្រូវសម្លាប់តាមបែបបទរបស់មន្ទីរស-២១

ដោយវាយនិងដែកគោ្វរទេះទៅលើកញ្ចឹងក បន្ទាប់មកអ្នកទោសត្រូវអារបំពង់កដើម្បីធានាថាអ្នកនោះបានស្លាប់ហើយ ។ សម្លៀកបំពាក់ និងខ្នោះដៃរបស់អ្នកទោសត្រូវបានដោះចេញ ។ អ្នកទោសទាំងនោះត្រូវធាក់ទម្លាក់ចូលក្នុងរណ្តៅ ហើយកប់ភ្លាមៗ ។ ដោយសារតែមានចំនួនអ្នកទោសច្រើន ហើយទីតាំងនោះងងឹតផង ត្រូវចំណាយពេលរាប់ម៉ោងដើម្បីសម្លាប់មនុស្សម្នាក់ ជួនកាលរហូតដល់ម៉ោងពីររំលងអធ្រាត្រឯណោះ ។ ក្នុងដំណាក់កាលនេះ បុរសម្នាក់បានគេចខ្លួន តែក្រោយមកត្រូវបានចាប់បានមកវិញ ។ ពេលដែលឌុចបានរៀបរាប់កាលពីប៉ុន្មានសប្តាហ៍មុននេះថា គាត់បានទៅដល់ជើងឯកតែម្តងគត់ក្រោយពីត្រូវបានបង្ខំដោយមេរបស់គាត់នោះ ហ៊ឹម ហ៊ុយ បានធ្វើសក្ខីកម្មដោយបាននិយាយថា ឌុចបានទៅដល់ជើងឯកយ៉ាងហោចណាស់ក៏ពីរដងដែរ ។ ម្តងនោះគាត់នៅទីនោះរហូតដល់អ្នកទោសទាំងអស់ត្រូវបានសម្លាប់ ។ ខណៈពេលដែលគ្រាមុន ហ៊ឹម ហ៊ុយ បានប្រាប់ទៅសហចៅក្រមស៊ើបអង្កេតថា ឌុច បានបង្រៀនគាត់អំពីវិធីសាស្ត្រសម្លាប់នាពេលប្រជុំមួយនោះ ពេលនេះ ហ៊ឹម ហ៊ុយ បានកែប្រែចម្លើយរបស់គាត់វិញដោយបញ្ជាក់នៅថ្ងៃនេះថា ហ៊ី ជាអ្នកបង្រៀនវិធីសម្លាប់ដល់គាត់ ។ ម៉្យាងវិញទៀត កាលពីមុន ហ៊ឹម ហ៊ុយ បានប្រាប់សហចៅក្រមស៊ើបអង្កេតថា មានម្តងនោះ ឌុច បានបង្គាត់ប្រាប់គាត់ឲ្យសម្លាប់មនុស្សម្នាក់ ។ ពេលនេះ ហ៊ឹម ហ៊ុយ បានបង្វែរចម្លើយរបស់ខ្លួនវិញដោយនិយាយថា គាត់មិនច្បាស់ទេថាតើ ឌុច ឬក៏ ហ៊ី ប៉ុន្តែគាត់ច្បាស់ថា មានតែអ្នកទាំងពីរនេះទេដែលបានប្រាប់ឲ្យគាត់សម្លាប់មនុស្ស ។ លើសពីនេះទៅទៀត ហ៊ឹម ហ៊ុយ បានប្រាប់សហចៅក្រមព្រះរាជអាជ្ញាថាមានពេលមួយនោះ ឌុច បានបញ្ជាគាត់ឲ្យសម្លាប់មនុស្ស ។ ចៅក្រម ឡាវើញ បានស្នើ ឌុច ឲ្យក្រោកឈរហើយសួរទៅកាន់ ហ៊ឹម ហ៊ុយ ថា «តើជានរណាគេ?» ចៅក្រម ឡាវើញ បានសួរទៅ ហ៊ឹម ហ៊ុយ ម្តងទៀតដោយអាការៈបង្ខំឲ្យឆ្លើយថាតើ ឌុច ឬដែលជាអ្នកបញ្ជា ហ៊ឹម ហ៊ុយ ឲ្យសម្លាប់បុរសម្នាក់នោះ ។ ហ៊ឹម ហ៊ុយ បានព្យាយាមកែប្រែភាពស្រពេចស្រពិលរបស់គាត់ដោយពន្យល់ថា កាលនោះជើងឯកមានសភាពងងឹត ហើយកងការពារត្រូវតែរូតរះសម្លាប់មនុស្សឲ្យបានមុនថ្ងៃរះ ។

ស-២៤

នៅចុងឆ្នាំ១៩៧៨ ហ៊ឹម ហ៊ុយ និងមនុស្សពីរក្រុមផ្សេងទៀតត្រូវបានបញ្ជូនទៅមន្ទីរស-២៤ដើម្បីធ្វើស្រែ ជីកប្រឡាយ និងធ្វើទំនប់ទឹក ។ បើតាមការធ្វើសក្ខីកម្មដោយសង្ខេបកន្លងមកនេះនៅតែមានភាពស្រពេចស្រពិលនៅឡើយថាតើ ហ៊ឹម ហ៊ុយ ត្រូវបានបញ្ជូនទៅទីនោះក្នុងនាមជាអ្នកទោសឬក៏ទៅធ្វើស្រែធម្មតា ។ ហ៊ឹម ហ៊ុយ បានអះអាងថា គាត់គេងធម្មតានៅពេលយប់ ហើយមិនត្រូវបានដាក់ខ្នោះនៅពេលយប់ទេ ។ គាត់មិនបានប្រាប់អង្គជំនុំជម្រះទេថាហេតុអ្វីបានជាគាត់ត្រូវបញ្ជូនទៅទីនោះ ហើយគាត់បានទៅទីនោះរហូតដល់ពេលដែលវៀតណាមវាយបានទីក្រុងភ្នំពេញនៅខែមករា ឆ្នាំ១៩៧៩ ។

### វិធានការការពារត្រូវបានបដិសេធ

អង្គសវនាការបានប្រកាសពីភាពមិនយល់ស្របទៅនឹងសំណើរបស់សាក្សី KW10 ដែលបានសុំឲ្យមានវិធានការការពារ ។ អង្គភាពគាំពារសាក្សីនិងអ្នកជំនាញបានផ្តល់ជូនអង្គសវនាការនូវការវាយតម្លៃភាពប្រថុយប្រថានសម្ងាត់មួយ ហើយអង្គភាពមិនបានផ្តល់អនុសាសន៍ឲ្យមានវិធានការការពារទេព្រោះសាក្សីដែលជាអតីតអ្នកសួរចម្លើយនៅមន្ទីរស-២១ គឺត្រូវបានស្គាល់ជាសាធារណៈ ហើយសាធារណជនស្គាល់គាត់រួចទៅហើយបើទោះបីជាគាត់ធ្វើសក្ខីកម្មក្នុងបន្ទប់បិទជិតក៏ដោយ ។ អង្គសវនាការយល់ស្របជាមួយអង្គភាពគាំពារសាក្សីនិងអ្នកជំនាញដោយសង្កត់ធ្ងន់ថា សាក្សី KW10 ត្រូវបានស្គាល់ដោយសាធារណជនទូទៅរួចទៅហើយ ហេតុដូច្នេះវិធានការការពារពិតជាគ្មានប្រសិទ្ធភាពទេ ។ ម៉្យាងវិញទៀត ក្រុមគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់គាត់ សុទ្ធតែដឹងពីប្រវត្តិរបស់គាត់អស់ទៅហើយ ។

តាមវិធានផ្ទៃក្នុងលេខ២៩ បានចែងថា ពេលមានសំណើអង្គសវនាការអាចបង្គាប់បញ្ជាឲ្យមានវិធានការការពារដើម្បីការពារដល់សាក្សី «ដែលមកបង្ហាញខ្លួនប្រសិនបើការបង្ហាញខ្លួននោះអាចធ្វើឲ្យអាយុជីវិត សុខភាព ឬក្រុមគ្រួសារ ឬសាច់ញាតិជិតស្និតរបស់ពួកគេត្រូវស្ថិតក្នុងសភាពគ្រោះថ្នាក់ធ្ងន់ធ្ងរ» ។ វិធាននេះបានផ្តល់ឲ្យមានវិធានការនេះ ដោយការប្រើប្រាស់ម៉ាស៊ីនថតការប្រើឈ្មោះក្លែងក្លាយ ការបំប្លែងសំឡេងដើមនិងការបិទបាំងភិនភាគ ។ **ឡូរ៉ា ម៉ាកដូណាល**

# សាក្សីក្នុងដំណើរការជំនុំជម្រះក្តី

សមត្ថភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការជួយជ្រោមជ្រែងខបត្តម្ភដល់វិស័យអប់រំនិងដំណើរការផ្សះផ្សាជាតិបានឃើញយ៉ាងពិតប្រាកដនៅក្នុងថ្ងៃនេះ ដោយសារមានសិស្ស និស្សិត និងយុវជនរាប់រយនាក់ត្រូវបានទទួលស្វាគមន៍ជាភ្ញៀវកត្តិយសរបស់តុលាការ ។ មុនពេលដំណើរការនីតិវិធីចាប់ផ្តើម អ្នកតំណាងឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏បានចំណាយពេលពន្យល់ណែនាំពីយន្តការមូលដ្ឋានរបស់តុលាការដល់អ្នកចូលរួមដើម្បីឲ្យគេទាំងអស់គ្នា ធ្វើការស្វែងយល់កាន់តែល្អប្រសើរអំពីអ្វីដែលគេនឹងបានឃើញ ។

ដំណើរការនីតិវិធីជំនុំជម្រះក្តីបានទទួលនូវសក្ខីកម្មបន្ថែមទៀតពី ហ៊ឹម ហ៊ុយ អតីតឆ្មាំយាមគុកនៅមន្ទីរស-២១ ដែលធ្លាប់ស្ថិតនៅក្រោមបញ្ជារបស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ (ហៅ ឌុច) ក្នុងអំឡុងសម័យខ្មែរក្រហម ។ មុនពេលសំណួរត្រូវបានចោទសួរ សាក្សីត្រូវបានក្រើនរំឭកដោយអង្គសវនាការថាគាត់មានសិទ្ធិក្នុងការបដិសេធមិនធ្វើការឆ្លើយតបនឹងសំណួរដែលដាក់ពិរុទ្ធភាពលើខ្លួនឯង បន្ទាប់ពីមានការស្នើសុំពីសហព្រះរាជអាជ្ញាទាក់ទិននឹងបញ្ហានេះ ។

ដំណើរការថ្ងៃនេះបានចាប់ផ្តើមឡើងជាមួយនឹងសំណួរពីសហព្រះរាជអាជ្ញាដែលសង្កត់ធ្ងន់ទៅលើប្រតិបត្តិការប្រចាំថ្ងៃនៅក្នុងមន្ទីរស-២១ ។ ក្រៅពីធ្វើការនៅក្នុងគុក ហ៊ឹម ហ៊ុយ មានទំនួលខុសត្រូវពិសេសដើម្បីជួយក្នុងការចាំទទួលយក និងដឹកជញ្ជូនអ្នកទោសដែលចូលមកក្នុងគុក ។ នៅពេលដែលត្រូវបានសួរថាតើបញ្ជាផ្តល់ឲ្យគាត់ចេញមកពីអ្នកណា សាក្សីបានឆ្លើយតបថាគាត់បានទទួលបញ្ជាដោយផ្ទាល់ពីប្រធានថ្នាក់លើរបស់គាត់គឺ បង ហ៊ី ។ យ៉ាងណាមិញ សាក្សីក៏បាននិយាយថា ឌុច ជាអ្នកសម្រេចលើកិច្ចការអ្វីៗទាំងអស់ទាក់ទិននឹងអ្នកដែលត្រូវចាប់ខ្លួនសួរចម្លើយនិងសម្លាប់ ។ ជាមួយគ្នានេះ សាក្សីក៏បានផ្តល់នូវសក្ខីកម្មដែលហាក់បីដូចជាបង្ហាញថា ឌុច បានជួយជំរុញដំណើរឃោសនាការដើម្បីផ្គត់ផ្គង់ការគាំទ្រដល់របបខ្មែរក្រហម ។ ទាក់ទិននឹងការប្រព្រឹត្តទៅលើអ្នកទោសវៀតណាម ហ៊ឹម ហ៊ុយ បានឆ្លើយថា គាត់បានឃើញអ្នកទោសវៀតណាមទាំងអស់នេះត្រូវបានបង្ខំឲ្យស្លៀកឯកសណ្ឋានទាហានរបស់ខ្លួននិងបានថតរូប ខណៈពេលដែលគេឈរនៅតាមដងវិថី ។ម្យ៉ាងទៀត ចម្លើយសារភាពរបស់អ្នកទោសវៀតណាមដែលទទួលបានពីការសួរចម្លើយត្រូវបានចាក់ផ្សាយតាមប៉ុស្តិ៍វិទ្យុ ។ ភាគច្រើននៃសក្ខីកម្មនេះបានបង្ហាញពីអត្ថប្រយោជន៍ដល់សហព្រះរាជអាជ្ញា ពីព្រោះថាសក្ខីកម្មនេះបានព្យាយាមឆ្លុះបញ្ចាំងពីតួនាទីរបស់ ឌុច ក្នុងរបបខ្មែរក្រហមដែលជាអ្នកមេគំនិតដ៏សកម្មម្នាក់ក្នុងឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

លោក វីលលៀម ស្មីត ប្រធានសហព្រះរាជអាជ្ញា ក៏បានសួរសំណួរមួយចំនួនដែលទាក់ទងនឹងសម្ព័ន្ធភាពរវាង ឌុច និងបុគ្គលិកនៅមន្ទីរស-២១ ។ ហ៊ឹម ហ៊ុយ បានអធិប្បាយពីវិធីសាស្ត្រគ្រប់គ្រងរបស់ ឌុច ថាមានភាព «ល្អិតល្អន់ និងតឹងរ៉ឹង» ដោយនិយាយថា ឌុច សម្រេចអ្វីគ្រប់យ៉ាងទាំងអស់ ហើយបុគ្គលិកទាំងអស់បានគោរពតាមបញ្ជារបស់ ឌុច យ៉ាងម៉ឺងម៉ាត់បំផុត ។ សាក្សីបានពន្យល់ប្រាប់ថា បុគ្គលិកនៅមន្ទីរស-២១ មានអារម្មណ៍ភ័យខ្លាច ឌុច ហើយព្យាយាមគោរព ឌុច ឲ្យល្អបំផុតតាមតែអាចធ្វើបាន ដោយសារតែភាពភ័យខ្លាចនឹងជីវិតរបស់គេ ។ សាក្សីបាននិយាយបន្តទៀតថា គាត់ភ័យខ្លាចណាស់រហូតដល់គាត់គិតថាការរៀបការមិនអាចធ្វើឲ្យគាត់មានសុវត្ថិភាពទេ ពីព្រោះថាការរៀបការអាចបង្កើតឱកាសនៃការស្លាប់បាន ។ គាត់បាននិយាយថា ខណៈពេលដែលមនុស្សម្នាក់ត្រូវបានចោទប្រកាន់ថាជាខ្មាំងនោះ រូបគេនិងសមាជិកគ្រួសាររបស់បុគ្គលនោះទាំងមូលជាធម្មតាត្រូវបានសម្លាប់ចោលទាំងអស់ ដូច្នេះ ហ៊ឹម ហ៊ុយ គិតថាការនៅម្នាក់ឯងមានសុវត្ថិភាពជាង ។ សាក្សីបានបញ្ចប់ឃ្លានេះដោយនិយាយថា សូម្បីតែ

ថ្ងៃនេះក្នុងអង្គសវនាការ វត្តមានរបស់ ឌុច បានធ្វើឲ្យគាត់មានភាពភ័យខ្លាចដដែល ។

ក្រោយពីសហព្រះរាជអាជ្ញាបានបញ្ចប់ការសួរ ដល់វេនរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីចោទសួរសំណួរទៅកាន់សាក្សី ។ អាលែន វើនើ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្រុមមួយ បានចាប់ផ្តើមសួរជាមួយនឹងសំណួរមួយចំនួនដែលបន្តជជីកសួរ ដើម្បីស្វែងរកព័ត៌មានអំពីការចូលរួមពាក់ព័ន្ធរបស់ ឌុច ក្នុងការសម្រេចជាផ្លូវការរបស់មន្ទីរស-២១ ។ ប៉ុន្តែការយកចិត្តទុកដាក់លើបញ្ហានេះបានផ្លាស់ប្តូរទិសដៅពី ឌុច មកកាន់ពិរុទ្ធភាពនៃឧក្រិដ្ឋកម្មរបស់សាក្សីវិញម្តង ខណៈពេលដែលអ្នកស្រី ស៊ូដហ្សីនស្គី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ បានចាប់ផ្តើមសួរសាក្សីអំពីការចូលរួមរបស់គាត់ក្នុងការធ្វើទារុណកម្ម និងការសម្លាប់ ។ ដោយព្យាយាមធ្វើការសង្កត់ធ្ងន់ទៅលើសមាសភាពរបស់បុគ្គលក្នុងការផ្តល់សក្ខីកម្ម អ្នកស្រី ស៊ូនហ្សីនស្គី បានចាប់ផ្តើមសំណួររបស់អ្នកស្រី ដោយធ្វើការរំឭកដល់សាក្សីថាជនរងគ្រោះកំពុងតែស្ថិតនៅក្នុងអង្គសវនាការ ហើយឲ្យចងចាំនូវទំនួលខុសត្រូវរបស់ខ្លួនដើម្បីជួយជ្រោមជ្រែងដល់ដំណើរការផ្សះផ្សាជាតិ ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ និងក្រុមបីបានបន្តស្វែងរកសេចក្តីលម្អិតពីការប្រព្រឹត្តទៅលើអ្នកទោសដោយសាក្សីដែលជាអ្នកអះអាងថាអ្នកទោសត្រូវបានដាក់នៅក្នុងផ្ទះនិងធ្វើទារុណកម្ម ក្នុងសម្លៀកបំពាក់ដែលមានតែខោខ្លី ហើយចំណែកឯកូនក្មេងវិញត្រូវបានសម្លាប់ដូចគ្នានឹងឪពុកម្តាយរបស់គេ ។ លោក ហុង គីមសួន មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួនបានបញ្ចប់រយៈពេលសួរសំណួររបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដោយធ្វើឲ្យសាក្សីឃើញពីកំហុសរបស់ខ្លួនក្នុងនាមជាអ្នកនៅក្រោមបង្គាប់ដ៏ស្លូតត្រង់ម្នាក់របស់ ឌុច ដែលបានអនុវត្តរាល់ការបញ្ជារបស់ ឌុច ។ ខណៈពេលដែលត្រូវសួរថាតើគាត់ទទួលការណែនាំពី ឌុច យ៉ាងដូចម្តេចខ្លះសម្រាប់អ្នកទោសដែលត្រូវនាំចូល ហ៊ឹម ហ៊ុយ បាននិយាយថាគាត់ទទួលបានបញ្ជីឈ្មោះមួយដែល ឌុច បានដាក់រួមគ្នា ។ ខណៈពេលដែលត្រូវសួរថាតើហេតុអ្វីបានជាគាត់បានធ្វើតាមបញ្ជាដោយងប់ងុលដូច្នេះ ហ៊ឹម ហ៊ុយ បាននិយាយសាថ្មីម្តងទៀតពីភាពភ័យខ្លាចដែល ឌុច បានធ្វើបង្កឲ្យកើតមានក្នុងមន្ទីរស-២១ ដោយនិយាយថា កំហុសមួយអាចនឹងឆក់យកជីវិតរបស់គាត់បាន ។

មុនពេលមេធាវីការពារក្តីចាប់ផ្តើមសួរសំណួររបស់ខ្លួន ឌុច បានផ្តល់សេចក្តីអធិប្បាយមួយទាក់ទិននឹងការឆ្លើយតបរបស់ខ្លួនទៅកាន់សក្ខីកម្មរបស់សាក្សី ។ ទោះបីជាមើលទៅដូចជាមានន័យពីរ ឌុច បាននិយាយថាសក្ខីកម្មរបស់ ហ៊ឹម ហ៊ុយ គឺ «ប្រកបដោយការពិត ទោះបីជាមានការបំភ្លេចចោលខ្លះៗ ប៉ុន្តែវាមិនចោទជាបញ្ហាអ្វីឡើយ» ។ សំខាន់ជាងនេះ ឌុច បានទទួលស្គាល់ទំនួលខុសត្រូវរបស់ ហ៊ឹម ហ៊ុយ ដោយនិយាយថារាល់ឧក្រិដ្ឋកម្មរបស់ ហ៊ឹម ហ៊ុយ គឺសុទ្ធតែកើតចេញពីការអនុវត្តតាមបញ្ជារបស់ ឌុច ទាំងអស់ ។

ទោះបីជាមានការសម្តែងកាយវិការថា ឌុច ទទួលស្គាល់ពីទំនួលខុសត្រូវខ្ពស់ក៏ដោយ ក៏មេធាវីការពារក្តីបានចំណាយពេលរបស់គេជាមួយនឹងសាក្សីដោយព្យាយាមប្រមូលនូវកំហុសនៃភាពខុសគ្នាមួយរវាងសាក្សី និងជនជាប់ចោទ ។ ក្នុងការឆ្លើយតបទៅកាន់សំណួរពីលោកមេធាវីការពារក្តី ហ្វ្រង់ស័រ រូ សាក្សីបានផ្តល់សក្ខីកម្មថាធ្លាប់បានទទួលធ្វើការខុសត្រូវលើមនុស្ស១១ទៅ១២នាក់ ហើយក្នុងមុខងារជាប្រធានក្រុមនេះ សាក្សីបានអនុវត្តបញ្ជាឲ្យដឹកជញ្ជូនអ្នកទោសសពីមន្ទីរស-២១ ទៅជើងឯកសម្រាប់ការសម្លាប់ ។ លោក រូ បានបញ្ចប់ការសួរសំណួររបស់ខ្លួន ដោយចោទសួរទៅកាន់សាក្សីថាតើសាក្សីយល់ស្របទេដែលថាចលនារបស់ខ្មែរក្រហមត្រូវបានទទួលជោគជ័យ ដោយសារតែអ្នករាល់គ្នាបានអនុវត្តតាមបញ្ជារបស់គណៈកម្មាការមជ្ឈិមទាំងងប់ងុល ។ ហ៊ឹម ហ៊ុយ បានយល់ស្រប ។ ទោះបីជាលោក រូ មិនបាននិយាយដូច្នេះក្តី ក៏សំណួររបស់លោក រូ ប្រហែលជាទុកឲ្យអង្គសវនាការពិចារណាអំពីកាលៈទេសៈទាំងពីររបស់សាក្សី និងជនជាប់ចោទ (ឌុច) ។ ដោយបង្ហាញឲ្យឃើញថាទាំង ហ៊ឹម ហ៊ុយ និង ឌុច ជាទៀងទាត់បានដើរតួជាអន្តរការីដោយទទួលយកបញ្ជាពីថ្នាក់លើ និងអនុវត្តបញ្ជាទាំងនោះតាមរយៈការនៅក្រោមបង្គាប់ លោក រូ បានបន្សល់ទុកនូវចម្ងល់មួយថាតើហេតុអ្វីបានជាអ្នកទាំងពីរមានតួនាទីខុសដោយឡែកពីគ្នាបែបនេះនៅក្នុងវង្វង់ភ្នែករបស់តុលាការនិងសាធារណជន ។

**ឆាល វៀគសាន់**

# ការសួរដេញដោលពីភាពដែលអាចជឿបានរបស់សាក្សីចាប់ផ្តើមដំណើរការបន្ត


ប្រាក់ ខន ឆ្នាំ២០០៩

ប្រាក់ ខន អតីតអ្នកសួរចម្លើយនៅគុកទួលស្លែង (មន្ទីរ ស-២១) បានត្រឡប់ចូលមកកាន់កន្លែងសាក្សីវិញនៅថ្ងៃនេះនិងបានបន្តផ្តល់សេចក្តីលម្អិតស្តីពីប្រតិបត្តិការក្នុងគុកដែលគ្រប់គ្រងដោយជនជាប់ចោទ កាំង ហ្គេកអ៊ាវ (ហៅ ឌុច) ។

សហព្រះរាជអាជ្ញា ហាក់បីដូចជាទទួលស្គាល់ថាភាពដែលអាចជឿបានរបស់សាក្សីនឹងទទួលរងការខូចខាតដោយសាររបាយការណ៍មិនស្របគ្នាដែលសាក្សីបានផ្តល់ឲ្យកាលពីថ្ងៃមុន ។ សហព្រះរាជអាជ្ញាបានប្រើពេលវេលារបស់ខ្លួនដើម្បីធ្វើការបញ្ជាក់សេចក្តីលម្អិតនៃសក្ខីកម្មរបស់សាក្សីម្តងទៀត ។ សហព្រះរាជអាជ្ញា តាន់ សេណារុង បានចាប់ផ្តើមសួរសាក្សីដោយបង្ហាញពីផែនទីនៃមន្ទីរស-២១ និងសួរសាក្សីឲ្យបង្ហាញប្រាប់តុលាការពីទីតាំងជាក់លាក់ដែលបានលើកឡើងកាលពីម្សិលមិញ រួមមានទីកន្លែងដែលការសួរចម្លើយប្រព្រឹត្តឡើង ទីកន្លែងឃុំឃាំងអ្នកទោសនិងទីកន្លែងដែល ប្រាក់ ខន បានឃើញទារកត្រូវបានសម្លាប់ដោយប្រធានថ្នាក់លើម្នាក់នោះ ។ សហព្រះរាជអាជ្ញា វីលៀម ស្មីត បានបង្ហាញខ្សែវីឌីអូមួយចំនួនដកស្រង់ពីឯកសារ «មន្ទីរស-២១: ម៉ាស៊ីនពិឃាដខ្មែរក្រហម» ដែលបានឆ្លុះបង្ហាញពីបទសម្ភាសន៍ដែល ប្រាក់ ខន បានផ្តល់កាលពីមុនទាក់ទងនឹងបទពិសោធន៍របស់ ប្រាក់ ខន នៅមន្ទីរស-២១ ។ ដើម្បីជួយតម្រង់ទិសដៅដល់សក្ខីកម្មរបស់សាក្សី លោក ស្មីត បានចាក់បង្ហាញខ្សែវីឌីអូនីមួយៗ ហើយបន្ទាប់មកបានសួរទៅកាន់ ប្រាក់ ខន ថាតើរបាយការណ៍កាលពីមុនរបស់ ប្រាក់ ខន មានភាពត្រឹមត្រូវដែរឬទេ ។ គម្រោងការណ៍នេះបានបង្ហាញថាមានអត្ថប្រយោជន៍ ពីព្រោះថាសហព្រះរាជអាជ្ញាអាចជំរុញឲ្យមានការយល់ដឹងដែលសមស្របដ៏ប្រសើរមួយលើសក្ខីកម្មរបស់ ប្រាក់ ខន ។ យ៉ាងណាមិញ វាហាក់បីដូចជាមិនមានភាពច្បាស់លាស់ទេថាតើ ប្រាក់ ខន ពិតជាបានចងចាំយ៉ាងច្បាស់នូវព្រឹត្តិការណ៍ដែល ប្រាក់ ខន បានផ្តល់សក្ខីកម្មឬថាតើ ប្រាក់ ខន កំពុងតែបញ្ជាក់អះអាងរបាយការណ៍ទាំងនេះដើម្បីចៀសវាងពីការបង្ហាញនូវភាពមិនស្មោះត្រង់របស់ខ្លួនតែប៉ុណ្ណោះមែនទេ ។

ក្រោយពីសហព្រះរាជអាជ្ញាបានបញ្ចប់ទៅ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានចាប់ផ្តើមការចោទសួរសំណួរមួយខ្សែដែលមានបំណងដើម្បីពិពណ៌នាថា ឌុច ជាមេដឹកនាំដែលប្រកាន់ខ្ជាប់នូវការគ្រប់គ្រងផ្តាច់ការលើសកម្មភាពរបស់អ្នកនៅក្រោមបង្គាប់របស់ខ្លួន ។ ជាការឆ្លើយតបនឹងសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ខន បានពិភាក្សាពីរបៀបដែលគាត់ត្រូវបានអនុញ្ញាតឲ្យចេញចូលរោងបាយ គុក និងបន្ទប់សួរចម្លើយនៅមន្ទីរស-២១ តែប៉ុណ្ណោះ ដោយសារតែវិធានដ៏តឹងរ៉ឹងរបស់ ឌុច ធ្វើការដាក់កម្រិតបុគ្គលិកពីទីតាំងដែលត្រូវធ្វើការ ។ ប្រាក់ ខន ក៏បាននិយាយផងដែរថាក្នុងរយៈពេលបីថ្ងៃមុនពេលវៀតណាមចូលដល់ភ្នំពេញនៅខែមករា ឆ្នាំ១៩៧៩ អ្នកសួរចម្លើយមិនបានទទួលបញ្ជាអ្វីពី ឌុច ឡើយ ដូច្នេះហើយអ្នកសួរចម្លើយទាំងនោះបានចំណាយពេលធ្វើការរបស់គេដោយ «អង្គុយជុំគ្នាមិនធ្វើអ្វីទាំងអស់» ។

ប៉ុន្តែមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ម៉ាទីន ហ្សាកាំង អាចធ្វើឲ្យការខិតខំប្រឹងប្រែងរបស់សហព្រះរាជអាជ្ញាមិនមានសារសំខាន់ខណៈពេលដែលអ្នកស្រីបានជ្រើសរើសប្រើពេលវេលារបស់អ្នកស្រីសាកសួរសាក្សីដើម្បីចោទសួរ ឌុច ជំនួសវិញ ។ នៅពេលដែលត្រូវបានសួរពីរបាយការណ៍របស់ ប្រាក់ ខន ឌុច បានបំភ័យសាក្សីដោយនិយាយថា របាយការណ៍ខ្លះត្រូវបាន «ប្រឌិតឡើង» ។ លោកប្រធានចៅក្រម និល ណុន បានចូលរួមដោះស្រាយបញ្ហានេះ និងបានក្រើនរំឭក ឌុច មិនឲ្យ «ដាក់សម្ពាធលើសាក្សី» និងឲ្យ «ប្រកាន់ខ្ជាប់នូវឥរិយាបថសមរម្យ» ។

ក្នុងដំណាក់កាលពាក់កណ្តាលលើកទីពីរក្នុងដំណើរការនីតិវិធីថ្ងៃនេះ មេធាវីការពារក្តីបានព្យាយាមកាត់បន្ថយភាពដែលអាច

ជឿបានរបស់សាក្សី ដោយរិះគន់លើការយល់ដឹងជាមូលដ្ឋានរបស់ ប្រាក់ ខន ទាក់ទិននឹងសក្ខីកម្មរបស់ខ្លួន ។ ជាការឆ្លើយតបនឹង សំណួរពីមេធាវីការពារក្ដី លោក ហ្រ្វង់ស្វ័រ រូ សាក្សីបានទទួល ស្គាល់ថារបាយការណ៍ខ្លះក្នុងសក្ខីកម្មរបស់គាត់កើតចេញពីការ តាមដានសាក្សីមុនៗផ្ដល់សក្ខីកម្មនៅក្នុងតុលាការកាត់ទោស ឌុច ។ បន្ថែមពីលើនេះ ប្រាក់ ខន ក៏បានសារភាពថាគាត់បានសម្រាក ព្យាបាលនៅមន្ទីរពេទ្យតាំងពីឆ្នាំ១៩៧៨ រហូតដល់ថ្ងៃរំដោះរបស់ វៀតណាមក្នុងឆ្នាំ១៩៧៩ ហេតុដូច្នេះហើយ ប្រាក់ ខន មិនបាន ឃើញហេតុការណ៍អ្វីនៅមន្ទីរស-២១ ដោយខ្លួនឯងនោះទេក្នុង អំឡុងពេលនោះ ។

មេធាវីការពារក្ដីបានប្រើពេលវេលាសេសសល់របស់ខ្លួន ដើម្បីជំទាស់លើជំនឿដែលថា បុគ្គលិកមន្ទីរស-២១ បានប្រកាន់ ខ្ជាប់នូវបទបញ្ជារបស់ ឌុច យ៉ាងមុតមាំ ។ លោក រូ បានបង្ហាញ កំណត់ហេតុរបស់អ្នកសួរចម្លើយរបស់មន្ទីរស-២១ម្នាក់ទៀត ដកស្រង់ចេញពីវគ្គសិក្សារបស់ ឌុច ដែលនិយាយថា អ្នកសួរ ចម្លើយដំបូងបង្អស់គួរតែអាស្រ័យលើ «ការដាក់សម្ពាធផ្នែក នយោបាយ» និងប្រើប្រាស់ការធ្វើទារុណកម្មជាវិធីសាស្ត្របន្ទាប់ បន្សំមួយតែប៉ុណ្ណោះ ។ បន្ទាប់មក លោក រូ បានធ្វើការប្រៀបធៀប ឲ្យខុសគ្នាជាមួយនឹងរបាយការណ៍ដែលផ្ដល់ឲ្យដោយសាក្សីដែល បង្ហាញថា ការធ្វើទារុណកម្មជាវិធីសាស្ត្រដ៏សំខាន់ក្នុងការសួរចម្លើយ ដែលត្រូវបានប្រើប្រាស់ដោយបុគ្គលិក ។ ជាការឆ្លើយតប សាក្សី បានអះអាងថា ឌុច តាមពិតបានបង្គាប់អ្នកយាមមុនដំបូងឲ្យ ធ្វើការអាស្រ័យលើ «ការដាក់សម្ពាធផ្នែកនយោបាយ» និង ឃោសនាការ ។

## ជម្លោះនីតិវិធីបានរំខានដល់អង្គជំនុំជម្រះសាលាដំបូង

នៅពេលដែលមេធាវីការពារក្ដីបានបញ្ចប់ អង្គសវនាការ បានណែនាំខ្លួនសាក្សីបន្ទាប់គឺ គក ស្រស់ អតីតអ្នកយាមមន្ទីរ ស-២១ ។ ជាការឆ្លើយតបនឹងសំណួរពីលោកប្រធានចៅក្រម និល ណុន និងចៅក្រម ធូ មណី គក ស្រស់ បានរៀបរាប់យ៉ាង សង្ខេបពីបទពិសោធន៍របស់ខ្លួនក្នុងអំឡុងពេលរបបខ្មែរក្រហម ។ គក ស្រស់ បានពន្យល់ប្រាប់ថា ដំបូងគាត់បានចូលបម្រើបដិវត្តន៍ ក្នុងឆ្នាំ១៩៧៣ ធ្វើជាសមាជិកម្នាក់របស់កងពលធំលេខ១១២ ។ ក្រោយពីខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ គក ស្រស់ ត្រូវ បានផ្លាស់ទៅគុកតាខ្មៅ ហើយក្រោយមកត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ឲ្យធ្វើការជាអ្នកយាម ។

យ៉ាងណាមិញ សក្ខីកម្មរបស់ គក ស្រស់ ត្រូវបានពន្យារ ខណៈពេលដែលសហព្រះរាជអាជ្ញា លោក វីលលៀម ស្មីត និង មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី អ្នកស្រី ស៊ីលកេ ស្ទូដហ្សិនស្គី បាន ធ្វើការស្នើសុំដល់អង្គសវនាការទាក់ទងនឹងនីតិវិធីនៃការចោទសួរ សាក្សី ។ លោក ស្មីត បាននិយាយពីបញ្ហាថាតើភាគីដើមបណ្ដឹង រដ្ឋប្បវេណីក្នុងអង្គសវនាការទាំងមូលអាចចោទសួរជនជាប់ចោទ នៅពាក់កណ្ដាលពេលនៃការចោទសួរលើសាក្សីបានដែរឬទេនិង បានជំទាស់ថានីតិវិធីបែបនេះអាចអនុញ្ញាតឲ្យជនជាប់ចោទបំភិត បំភ័យសាក្សី និងធ្វើឲ្យសាក្សីមិនមានទំនុកចិត្ត ។ សំណើរបស់លោក ស្មីត គឺជាការឆ្លើយតបទៅនឹងសេចក្ដីសម្រេចលើការអនុញ្ញាតឲ្យ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាទីន ហ្សារកាំង សួរសំណួរ ឌុច នៅ ពាក់កណ្ដាលនៃសក្ខីកម្មរបស់ ប្រាក់ ខន ជាលើកដំបូងក្នុងថ្ងៃនេះ ។ លោក ស្មីត បានស្នើសុំថា អង្គសវនាការគួរតែផ្លាស់ប្ដូរនីតិវិធីរបស់ ខ្លួនដើម្បីការពារការអនុវត្តបែបនេះសម្រាប់ថ្ងៃអនាគត ។ ជាការ ឆ្លើយតប មេធាវីការពារក្ដីបានជំទាស់ថាសហព្រះរាជអាជ្ញាមាន «ភាពភ័យខ្លាចនឹងការសន្ទនាដែលមានឥទ្ធិពលទៅវិញទៅមក» ។

ក្រោយពីសំណើរបស់សហព្រះរាជអាជ្ញា អ្នកស្រី ស្ទូដហ្សិនស្គី បាននិយាយពីពេលវេលាកំណត់ ដែលផ្ដល់ឲ្យភាគីដើមបណ្ដឹងរដ្ឋ ប្បវេណីសម្រាប់ការចោទសួរ ហើយបានស្នើសុំថាភាគីដើមបណ្ដឹង រដ្ឋប្បវេណីអាចដាក់សំណួរដែលគេមិនអាចសួរទៅសាក្សីនៅមុខ ចៅក្រមដែលជាអ្នកអាចធ្វើការពិចារណាថាតើសំណួរបែបនេះគួរ តែត្រូវបានដាក់ចោទសួរទៅកាន់សាក្សីដែរឬទេ ។ មេធាវីការពារក្ដី បានបដិសេធយ៉ាងដាច់ខាតដោយលោក រូ បានធ្វើការចោទប្រកាន់ លើអ្នកស្រី ស្ទូដស៊ីនស្គី ពីបទប៉ុនប៉ងគេចវេះចេញពីសេចក្ដីសម្រេច របស់ចៅក្រមដើម្បីកំណត់ពេលវេលារបស់ភាគីដើមបណ្ដឹងរដ្ឋប្ប វេណី ។

អង្គសវនាការបានព្រមព្រៀងធ្វើការពិចារណាលើសំណើ ទាំងពីរនេះ និងបានកំណត់ធ្វើសេចក្ដីសម្រេចនៅថ្ងៃច័ន្ទ ទី២៧ ខែកក្កដា ឆ្នាំ២០០៩ ។ **ឆាល វេគសាន់**

# ការផ្តល់សក្ខីកម្មរបស់បុគ្គលិកមន្ទីរស-២១ ប្រឆាំងនឹង ឌុច

ទោះបីជា គក ស្រស់ ធ្លាប់បានផ្តល់សក្ខីកម្មតាំងពីថ្ងៃពុធហើយក៏ដោយ ក៏នៅថ្ងៃនេះ ចៅក្រមនៅតែបានរំឭកអំពីសិទ្ធិរបស់គាត់ដែលជាសាក្សីថាគាត់មានសិទ្ធិបដិសេធមិនឆ្លើយនឹងសំណួរដែលអាចមានពិរុទ្ធភាពដល់ខ្លួនរបស់គាត់ឬសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ។


គក ស្រស់

នៅខណៈពេលដែល គក ស្រស់ មានតួនាទីជាអ្នកយាមអ្នកទោសនៅពីរមុខសញ្ញា គឺយាមនៅខាងក្នុង និងខាងក្រៅ ចៅក្រម ធូ មណី ក៏បានសួរសំណួរទៅកាន់ គក ស្រស់ អំពីការសម្លាប់មនុស្សនៅមន្ទីរស-២១ ប៉ុន្តែ គក ស្រស់ បានរៀបរាប់ថា គាត់មិនដែលដឹងថាមានអ្នកទោសនៅមន្ទីរស-២១ ត្រូវបានយកទៅសម្លាប់ទេ ។ អ្វីដែលមិនគួរឲ្យជឿជាងនេះទៅទៀត គឺសូម្បីតែការបាត់ខ្លួនរបស់បុគ្គលិកនៅមន្ទីរស-២១ ក៏គាត់មិនបានដឹងដែរ ។ ដើម្បីបញ្ជាក់ពីការងាររបស់ គក ស្រស់ ឲ្យបានច្បាស់ ចៅក្រម ខាតព្រ៊ាយ ក៏បានសួរសំណួរបន្តជាច្រើនទៅកាន់ គក ស្រស់ ដើម្បីបញ្ជាក់ពីការចងចាំរបស់គាត់ចំពោះការផ្តល់បទសម្ភាសន៍នៅក្នុងសៀវភៅមួយដែលមានចំណងជើងថា «សំឡេងពីមន្ទីរស-២១» និពន្ធដោយ ដេវីដ ឆេនល័រ ។ គក ស្រស់ បានបកស្រាយថា គាត់ពិតជាបានផ្តល់បទសម្ភាសន៍ឲ្យលោក ដេវីដ ឆេនល័រ មែន ។ នៅពេលដែលចៅក្រមរំឭកឃ្លាមួយចំនួនដែលគាត់បានផ្តល់បទសម្ភាសន៍ដល់លោក ដេវីដ ឆេនល័រ ប្រហែលជា១០ឆ្នាំមុន គក ស្រស់ ហាក់ដូចជាធ្វើឲ្យចៅក្រម ក៏ដូចជាអ្នកចូលរួមមានការងឿងឆ្ងល់ជាខ្លាំង ព្រោះគាត់បែរជាឆ្លើយថាមិនចាំទេឬមិនដឹង ព្រោះមានរយៈពេលយូរឆ្នាំមកហើយ ។

ក្រោយមក ចៅក្រម ខាតព្រ៊ាយ ក៏បានសួរសំណួរទៅ ឌុច វិញថា តើគាត់មានដែលនិយាយថា “ការវាយអ្នកទោសត្រូវតែសាហាវ ហើយការធ្វើនោះគឺដើម្បីមូលហេតុជាតិ និងវណ្ណៈដែរឬទេ”? ឌុច ក៏បានឆ្លើយតបថា បើតាមឯកសារថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៦ គឺវាឃ្លាតពីន័យដើមដែលគាត់បានបង្រៀន ។ ហើយបើតាមគាត់ចាំ គាត់ប្រហែលជាធ្លាប់និយាយថាដើម្បីបុព្វហេតុជាតិនិងវណ្ណៈ ។ គាត់បន្ថែមទៀតថា «ជនណាក៏ដោយ ឲ្យតែអង្គការចាប់មកគឺជាខ្មាំង បើមិនអឺចឹងអ្នកសួរចម្លើយមិនអាចយកចម្លើយបានទេ» ប៉ុន្តែពាក្យថាវាយឲ្យសាហាវគាត់មិនដែលធ្លាប់និយាយទេ ។

ក្រោយពីស្តាប់ចម្លើយរបស់ គក ស្រស់ ដែលបានឆ្លើយទៅកាន់ចៅក្រម ខាតព្រ៊ាយ រួចមក លោក ចៅក្រម ឡាវែញ ក៏មានសំណួរជាច្រើនដើម្បីសួរទៅ គក ស្រស់ ផងដែរ ។ ដោយ គក ស្រស់ តែងតែនិយាយថាមិនចាំ ចៅក្រម ឡាវែញ ក៏បានសួរទៅកាន់គាត់ថា «តើលោកមានបញ្ហាការចងចាំ ឬក៏លោកមិនចាំពីព្រឹត្តិការណ៍?» លោក គក ស្រស់ ក៏បានឆ្លើយថា គាត់មិនចាំពីរឿងនេះទេ ពីព្រោះគាត់គិតតែរឿងគ្រួសារច្រើនជាង ។ គក ស្រស់ បានបន្ថែមថា គាត់បានស្គាល់ ឌុច ហើយនៅពេលនោះ គាត់ហៅ ឌុច ថា «តាឌុច» ។ ដើម្បីសាកល្បងនឹងសមត្ថភាពចងចាំរបស់ គក ស្រស់ ចៅក្រម ឡាវែញ ក៏បានសួរបញ្ជាក់ទៅកាន់ គក ស្រស់ ថា តើគាត់នៅចាំកិច្ចសម្ភាសដែលបានធ្វើនៅថ្ងៃទី៣ ខែមេសា ឆ្នាំ ២០០៨ ដែរឬទេ? គក ស្រស់ ក៏បានឆ្លើយថា គាត់ចាំតែអ្វីដែលគាត់បានផ្តល់កិច្ចសម្ភាសនៅថ្ងៃនោះប៉ុណ្ណោះ ចំណែកអ្វីដែលបានធ្វើនៅលើកមុន គាត់ភ្លេចអស់ហើយ ព្រោះគាត់មិនសូវយកចិត្ត

ទុកដាក់ទៅលើរឿងនោះទេ ។ ចៅក្រមក៏បានបន្តថា «តើលោកមានការភ័យខ្លាច ឬខ្លាចនរណាដែរឬទេ?» គក ស្រស់ ក៏បានឆ្លើយតបនឹងសំណួរនោះដោយមិនមានភាពរអាក់រអួលថា «ខ្ញុំមិនខ្លាចអ្វីទេ» ។

ដោយសារតែចម្លើយដែលទទួលបានជាអវិជ្ជមានច្រើនដូច្នេះ ចៅក្រម ឡាវ៉ែញ ចោទជាសំណួរទៅ គក ស្រស់ ថាតើគាត់មានបានដឹងអំពីចំណុចដែលថាមុននឹងធ្វើជាសាក្សីត្រូវស្បថដែរឬទេ? គក ស្រស់ ក៏បានឆ្លើយថា គាត់បានដឹង ។ អ្នកចូលរួមស្តាប់សវនាការ និងចៅក្រម ហាក់ដូចជាមានភាពភ្ញាក់ផ្អើលកាលដែលឮ គក ស្រស់ និយាយថា ការងារនៅមន្ទីរស-២១ គឺជាការងារធម្មតា ។ ដើម្បីឆ្លើយតបនឹងអ្វីដែល គក ស្រស់ បានអះអាង ចៅក្រមក៏សួរថា ប្រសិនបើគេហៅលោកទៅធ្វើការនេះទៀត តើលោកនឹងធ្វើទៀតដែរឬទេ? គក ស្រស់ ក៏បានបដិសេធថាឈប់ធ្វើហើយរាងហើយ ។ គក ស្រស់ បានរៀបរាប់ពីបុគ្គលិកលក្ខណៈរបស់ ឌុច ថា ឌុច ដឹកនាំបុគ្គលិកឲ្យធ្វើការធម្មតា គ្មានការបង្ខិតបង្ខំទេ ដែលធម្មតានេះមានន័យថា ជាការងារប្រចាំថ្ងៃគ្រប់ពេល និងធ្វើជាហូរហែរហូតមក ។ ប៉ុន្តែទោះបីជា គក ស្រស់ បានអះអាងថាជាការងារនៅមន្ទីរស-២១ ជាការងារធម្មតាក៏ដោយ ក៏នៅចុងក្រោយគាត់នៅតែពោលពាក្យថាគាត់មានការឈឺចាប់ដែរក្នុងអំឡុងពេលនោះ ប៉ុន្តែមិនដឹងគេចទៅណា ចេះតែទ្រាំទៅ ។

ក្រោយពីសម្រាករយៈពេល២០នាទី ចៅក្រម និល ណុល ក៏បានប្រកាសពីសេចក្តីសម្រេចទាក់ទងនឹងការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា វីលលៀម ស្មីត កាលពីថ្ងៃពុធទី២២ ។ ដោយសារសហព្រះរាជអាជ្ញា មានពេលតែ១៥នាទីដើម្បីសួរសាក្សី សហព្រះរាជអាជ្ញាបានសួរសំណួរមួយចំនួនតូចតែប៉ុណ្ណោះ ដើម្បីឲ្យ គក ស្រស់ ជួយបំភ្លឺបន្ថែម ។ សំណួរមុនៗដែល គក ស្រស់ បានឆ្លើយ បានបញ្ជាក់ថា គាត់មិនបានដឹងឮពីការសម្លាប់នៅមន្ទីរស-២១ទេ ប៉ុន្តែពេលនេះ គក ស្រស់ បែរជាឆ្លើយសំណួររបស់សហព្រះរាជអាជ្ញាថាគាត់ដឹងថានៅពេលកងទ័ពវៀតណាមជិតចូលមកដល់ មានបញ្ជាថាឲ្យយកអ្នកទោសទៅសម្លាប់ទាំងអស់ ហើយបញ្ជានោះប្រហែលជារបស់ ឌុច ពីព្រោះ ឌុច ធំជាងគេនៅពេលនោះ ។

បន្ទាប់ពីសហព្រះរាជអាជ្ញាបានសួរសំណួរទៅសាក្សីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស៊ុដហ្វ៊ីនស្គី បានសួរសំណួរទៅសាក្សី ។ សាក្សី គក ស្រស់ បានបញ្ជាក់ថាគាត់បានឃើញ ឌុច នៅបន្ទប់សួរចម្លើយ ប៉ុន្តែមិនដឹងថាមានរយៈពេលប៉ុន្មានទេ ហើយក៏មិនដឹងថាអ្នកទោសនោះសំខាន់ឬមិនសំខាន់ដែរ ព្រោះពេលនោះគាត់នៅចម្ងាយពីបន្ទប់ដែល ឌុច ដើរមើលប្រហែល៥០ម៉ែត្រ ។ ចំណែកបទសម្ភាសដែលគាត់បានធ្វើជាមួយ ដេវីដ ឆេនល័រ កាលពី១០មុនគាត់នៅតែឆ្លើយភាគច្រើនថាគាត់មិនចាំ ឬមិនដឹង ។

បន្ទាប់ពី គក ស្រស់ បានផ្តល់សក្ខីកម្ម អង្គជំនុំជម្រះបានទុកឱកាសឲ្យ ឌុច ធ្វើការបញ្ចេញយោបល់ទៅលើសក្ខីកម្មរបស់ គក ស្រស់ ។ ឌុច បានប្រាប់ទៅអង្គសវនាការថា គាត់ចាប់អារម្មណ៍ គក ស្រស់នេះ តាំងពីគាត់បានអានសៀវភៅរបស់លោក ដេវីដ ឆេនល័រ មកម្ល៉េះ ។ ទោះបីជាការផ្តល់សក្ខីកម្មរបស់ គក ស្រស់ ហាក់ដូចជាមិនបានដាក់បន្ទុកទៅលើ ឌុច ក៏ដោយ ក៏ ឌុច ធ្វើការសន្និដ្ឋានថា គក ស្រស់ មិនមែនជាបុគ្គលិកមន្ទីរស-២១ទេ ដោយផ្អែកទៅលើចំណុចបី ៖ ១) គាត់មិនមានភារកិច្ចអ្វីទៅអើតតាមបន្ទប់សួរចម្លើយអ្នកទោសទេ ។ ២) គាត់បង្រៀនគោលនយោបាយអំពីខ្មាំងជាក់លាក់នៅស-២១ ។ ៣) គាត់ឲ្យអ្នកទោសទៅថតឯកសារ ។ ក្រៅពីអំណះអំណាងទាំងបីនេះ ឌុច បានអះអាងថាបើ គក ស្រស់ ពិតជាបុគ្គលិកមន្ទីរស-២១មែន គក ស្រស់ គួរតែស្គាល់មេរបស់ខ្លួនដំបូងឈ្មោះ ណាត ។ ទោះជាយ៉ាងណាក្តី នៅជិតដល់ពេលអាហារថ្ងៃត្រង់ ឌុច បានប្រាប់ទៅអង្គសវនាការថា គាត់ក៏នឹងមិនបដិសេធដែរប្រសិនបើសហព្រះរាជអាជ្ញាយកបញ្ជីឈ្មោះបុគ្គលិកនៅមន្ទីរ ស-២១ មកបង្ហាញ ។

ដោយសារ ឌុច បានបដិសេធសក្ខីកម្មរបស់ គក ស្រស់ ថាមិនមែនជាបុគ្គលិកមន្ទីរស-២១ ចៅក្រម ឡាវ៉ែញ ក៏បានសួរសំណួរ ឌុច បន្ថែមទៀតថា បានស្គាល់បុគ្គលិកទាំងអស់នៅមន្ទីរស-២១ដែរឬទេ? បន្ទាប់មក ឌុច ក៏បានបកស្រាយយ៉ាងច្បាស់លាស់អំពីបុគ្គលិកដែលចូលមកធ្វើការនៅទីនេះ ។

ក្រោយពី គក ស្រស់ បានបញ្ចប់ការផ្តល់សក្ខីកម្មនៅពេលព្រឹក សួស ធី ដែលជាសក្សីបន្តមានលេខសម្គាល់គឺ០៧ នៅវេលាថ្ងៃត្រង់នេះហាក់ដូចជាផ្តល់សក្ខីកម្មដែលមានភាពច្បាស់លាស់

ច្រើនទាក់ទងនឹងការងាររបស់គាត់ជាអ្នកកាន់ខាងបញ្ជីកត់ឈ្មោះអ្នកទោសចូលនិងចេញ ។

សួស ធី អាយុ៥៨ឆ្នាំ មានមុខរបរធ្វើស្រែ ។ ក្រោយពី សួស ធី ចូលធ្វើបដិវត្តន៍ តាមរយៈការអំពាវនាវរបស់សម្តេចសីហនុ សួស ធី ត្រូវបានចាត់តាំងឲ្យធ្វើជាឈ្លបឃុំកោះខែល ។ នៅឆ្នាំ១៩៧២ សួស ធី ត្រូវបានបញ្ចូលក្នុងភូមិភាគពិសេស វរសេនាតូចលេខ ១១២ វរសេនាធំ២៣ ។ នៅចុងឆ្នាំ១៩៧៥ ហ៊ិ បានយក សួស ធី មកនៅធ្វើការជាមួយគាត់ នៅមន្ទីរឃុំឃាំងប៉េហ្ស៊ី ដោយមានតួនាទីជាកាន់កាប់បញ្ជីចេញនិងចូល ។ នៅទីនោះបានរយៈពេលមួយខែ មន្ទីរនេះក៏ផ្លាស់ទៅជាមន្ទីរស-២១ ដែលសព្វថ្ងៃហៅថាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងដែលដឹកនាំដោយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ។

នៅពេលសួរអំពីការងារដែលបានធ្វើនៅមន្ទីរស-២១ សក្ខីកម្មរបស់ សួស ធី បានធ្វើឲ្យចៅក្រម និល ណុល មានការចាប់អារម្មណ៍ជាខ្លាំង ពីព្រោះសក្ខីកម្មរបស់គាត់បានលេចចេញនូវភ័ស្តុតាងថ្មីដែលពីមុនមកមិនដែលមានសាក្សីណានិយាយអំពីមន្ទីស-២១ថា មានបែងចែកជាមន្ទីរស-២១ «ក» «ខ» និង «ឃ» ទេ ។

នៅគុក៧០៣ សួស ធី មានតួនាទីធ្វើប្រវត្តិរូបសង្ខេប (ឈ្មោះ អាយុ ទីលំនៅ និងឈ្មោះឪពុកម្តាយ) រួចរាយការណ៍ទៅម៉េង ជាប្រចាំថ្ងៃ ។ ដល់ពេលដែលផ្លាស់មក ស-២១ សួស ធី នៅធ្វើការនេះដដែល ។ នៅមន្ទីរស-២១ «ក» គឺជាអង្គភាពសួរចម្លើយ «ខ» គឺជាអង្គភាពកងការពារ ក្រោមការគ្រប់គ្រងរបស់ ហ៊ិ និង «ឃ» ជាមន្ទីរអប់រំកែប្រែសាជាថ្មី នៅស្រែ ដែលក្រោយមកគឺ ស-២៤ ។

## ការងារធ្វើបញ្ជី

អ្នកទោសចូលៈ ពេលអ្នកទោសត្រូវបានដឹកចូលមកមន្ទីរស-២១ សួស ធី បានឲ្យអ្នកទោសចូលធ្វើប្រវត្តិរូបម្នាក់ម្តងដោយអ្នកទោសទាំងនោះត្រូវបានបិទមុខ និងចងដៃ ។ បន្ទាប់មកអ្នកទោសត្រូវបញ្ជូនទៅថតរូប ដោយពេលនោះអ្នកទោសត្រូវស្រាយមុខចេញ និងដោះចំណងដៃ ។ ក្រោយពីចងមុខនិងចងចំណងដូចមុនហើយ កងការពារក៏បញ្ជូនអ្នកទោសទៅដាក់នៅក្នុងបន្ទប់សម្រាប់ឃុំខ្លួន ។ បន្ទាប់ទៀត សួស ធី ដើរទៅស្រង់ឈ្មោះអ្នកទោសម្តងទៀតនៅតាមបន្ទប់តូចធំ និងអគារណាមួយដើម្បីងាយស្រួលដល់អ្នកសួរចម្លើយ ។ ប៉ុន្តែការស្រង់ឈ្មោះនេះមិនបានរាយការណ៍ទៅអង្គការថ្នាក់លើទេ គឺដើម្បីងាយស្រួលសម្រាប់គាត់ពេលដែលកងសួរចម្លើយមកយកទោសទៅសួរចម្លើយ ។

អ្នកទោសចេញៈ នៅពេល ហ៊ិ យកបញ្ជីឈ្មោះដែលមានចំណាររបស់ ឌុច មកឲ្យ សួស ធី គាត់ត្រូវស្រង់លេខបន្ទប់ដាក់នៅលើបញ្ជីនោះដើម្បីឲ្យកងការពារងាយស្រួលយកចេញ ។ ប៉ុន្តែមុនពេលដឹកអ្នកទោសចេញទៅ សួស ធី ត្រូវពិនិត្យមើលឈ្មោះអ្នកទោសម្តងទៀត នៅខាងមុខមាត់ទ្វារចេញចូល ដើម្បីកុំឲ្យច្រឡំព្រោះ ហ៊ិ បានប្រាប់ថា «ប្រសិនបើច្រឡំ គឺខ្លាំងហើយ» ។ ក្រោយពីពិនិត្យហើយ សួស ធី ត្រូវយកបញ្ជីនេះទៅប្រគល់ឲ្យ ហ៊ិ វិញ ។

សួស ធី ធ្វើការនេះតែម្នាក់ឯងក្នុងរយៈពេល២៤ម៉ោង ។ ពេលធ្វើបញ្ជីនេះ សួស ធី សម្គាល់ឃើញអ្នកទោសដែលដឹកចូលមកជាធម្មតាមានចំនួនប្រហែលជា២០-៣០នាក់ ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៧៨ទៅ សួស ធី ឃើញថាមានអ្នកទោសដឹកមកច្រើនប្រហែលជា៥០-៦០នាក់ក្នុងមួយថ្ងៃ ។ ទោះជាអ្នកទោសដឹកមកមានចំនួនច្រើនក៏ដោយ ក៏ការធ្វើប្រវត្តិរូបនៅតែធ្វើដូចធម្មតាដដែល ។

ក្នុងករណីប្រសិនបើមានអ្នកទោសសំខាន់ អ្នកទោសទាំងនោះមិនត្រូវបានបញ្ជូនមកកន្លែងរបស់ សួស ធី ទេ ដោយពេលនោះ ហ៊ិ គ្រាន់តែយកឈ្មោះនោះមកឲ្យគាត់ដើម្បីបញ្ចូលក្នុងបញ្ជីប៉ុណ្ណោះ ។ **តាត លក្ខិណា និង ជា ផល្លា**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

*វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ផងចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។* **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ឌុច ទទួលស្គាល់សក្ខីកម្មរបស់សាក្សីឈ្មោះ សួស ធី នៅក្នុងអង្គសវនាការ

ដោយសារ សួស ធី ជាបុគ្គលិកកងការពារខាងកាប់កាន់បញ្ជីអ្នកទោសចេញចូលទាំងអស់នៅមន្ទីរស-២១ នៅវេលាព្រឹកនេះ មេធាវីក្រុមពីរអ្នកស្រី ស៊ុដហ្វីនស្គី បានធ្វើសំណើសុំទៅអង្គសវនាការឲ្យផ្តល់ពេលវេលាបន្ថែម២០នាទីទៀតទៅលើរយៈពេល៤០នាទី ដែលអង្គសវនាការផ្តល់ឲ្យដើម្បីសួរសាក្សីរូបនេះអំពីសំណួរជាក់លាក់មួយចំនួន ដោយសារកូនក្តីរបស់គាត់ពីរនាក់មានឈ្មោះក្នុងបញ្ជីអ្នកទោសដែលសាក្សី សួស ធី បានធ្វើនៅអំឡុងពេលនោះ ។

ក្រោយពីស្តាប់ការស្នើសុំនេះ លោកប្រធានចៅក្រម និល ណុន បានប្រកាសសម្រេចថានឹងបង្កើនពេលវេលាទៅឲ្យគ្រប់ភាគីទាំងអស់ ប៉ុន្តែមិនមែនទៅលើភាគីក្រុមពីរតែម្នាក់នោះទេ ។ បន្ទាប់មក ចៅក្រម និល ណុន បានឲ្យមន្ត្រីខាងសោតទស្សន៍បង្ហាញពីបញ្ជីឈ្មោះមួយចំនួនដែលបានធ្វើនៅអំឡុងពេលនោះថាសាក្សីបានធ្វើឯកសារនេះដែរឬទេ? ប៉ុន្តែចម្លើយរបស់សាក្សី សួស ធី គឺផ្នែកខាងកងសួរចម្លើយជាអ្នកធ្វើបញ្ជីនេះ ចំណែកឯកសារខ្លះទៀតគាត់ពិតជាបានធ្វើមែន ប៉ុន្តែធ្វើទៅតាមអ្វីដែល ហ៊ិ បានប្រគល់មកឲ្យប៉ុណ្ណោះ ។

ទោះបីជាសាក្សី សួស ធី ឆ្លើយបែបនេះក៏ដោយ ក៏គាត់បានលើកឡើងនូវអ្វីដែលគាត់បានដឹងដើម្បីប្រាប់ដល់អង្គសវនាការឲ្យជឿជាក់ទៅលើសក្ខីកម្មរបស់គាត់ ។ សួស ធី បានប្រាប់អង្គសវនាការថា ចំពោះអ្នកទោសនៅមន្ទីរស-២៤(ព្រៃស) គឺមានផ្នែកសម្រាប់ធ្វើបញ្ជីនៅទីនោះ ហើយបញ្ជីទាំងអស់ត្រូវប្រគល់ទៅឲ្យ ម៉េង ជាប្រធានកងការពារ ។ ចំណែកអ្នកទោសដែលដឹកពីមន្ទីរស-២៤ ចូលមកមន្ទីរស-២១ គឺត្រូវយកទៅកម្ទេចទាំងអស់ ។ នៅដើមខែមករា ឆ្នាំ១៩៧៩ អ្នកទោសនៅក្នុងមន្ទីរឃុំឃាំងស-២១ទាំងអស់ ត្រូវបានបញ្ជាឲ្យបោសសម្អាតទាំងអស់ លើកលែងតែអ្នកទោសនៅក្នុងគុកពិសេស និងអ្នកទោសធ្វើការនៅខាងក្រៅ ។ សួស ធី បានបញ្ជាក់ថា អ្នកទោសទាំងអស់ដែលឃុំឃាំងក្នុងមន្ទីរសុទ្ធតែមានសភាពស្គមស្គាំងដោយសារខ្វះខាតអាហារនិងគ្មានខ្យល់អាកាសល្អ ។ ជាទម្លាប់ នៅវេលាម៉ោង៤ល្ងាច សួស ធី ត្រូវត្រួតពិនិត្យលើបញ្ជីចុងក្រោយរបស់អ្នកទោសមុនយកទៅកម្ទេចដោយត្រូវសួរឈ្មោះ និងតួនាទីដែលប្រព្រឹត្តទៅរយៈពេលមិនលើសពីមួយម៉ោង ។ បន្ទាប់មក ហ៊ិ ក៏បញ្ជាទៅកងពិសេស ឬ ហ៊ុយ ឬ ប៉េង ដើម្បីដឹកយកទៅកម្ទេចតែម្តង ។

ក្រៅពីការឆ្លើយបំភ្លឺរបស់សាក្សីទាក់ទងការកម្ទេចអ្នកទោសជាមនុស្សចាស់ ចៅក្រម ខាតព្រ៉ាយ បានសួរសំណួរទៅកាន់សាក្សី សួស ធី អំពីការសម្លាប់កូនក្មេងនៅមន្ទីរស-២១ ។ សួស ធី បានបញ្ជាក់ប្រាប់ថា ក្មេងៗពិតជាមានដឹកចូលមន្ទីរស-២១ ជាមួយឪពុកម្តាយប្រាកដមែន ដែលមានចំនួន៣-៤នាក់ក្នុងមួយលើកៗ ហើយក្មេងៗទាំងនោះមិនត្រូវបានធ្វើប្រវត្តិរូបទេ ។ ក្មេងៗត្រូវនាំចេញដោយកងការពារ បន្ទាប់ពីធ្វើប្រវត្តិរូបឪពុកម្តាយហើយ ។ ប៉ុន្តែ ក្មេងៗទាំងនោះមិនត្រូវបានដឹកយកទៅសម្លាប់ជាមួយឪពុកម្តាយទេ ហើយគាត់ក៏មិនបានដឹងពីការនាំក្មេងទៅសម្លាប់និងសម្លាប់នៅទីកន្លែងណានោះដែរ ។ បន្ទាប់មក ចៅក្រម ខាត់ព្រ៉ាយ បានឲ្យក្រុមសោតទស្សន៍បង្ហាញឯកសារចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៧ ដែលមានចំណារនៅខាងក្រោមថា «រួមកុមារ១៦០ ទាំងអស់ផ្នែកស្រែ១៧៨ ដែលត្រូវយកទៅកម្ទេចចោល» មាន ហ៊ិ ជាអ្នកចុះហត្ថលេខា ។ សួស ធី បានទទួលស្គាល់ឯកសារទាំងនោះ ប៉ុន្តែគាត់មិនបានឃើញកុមារទាំងនោះបញ្ជូនចូលក្នុងបញ្ជីស-២១នោះទេ ហើយការកម្ទេចគឺ ហ៊ិ បញ្ជាទៅ ប៉េង ផ្ទាល់ ។

បន្ទាប់ពីការសួរសំណួរទាក់ទងនឹងការសម្លាប់កុមារមក ចៅក្រមឡាវ៉ែញ បានសួរសាក្សីពីរបៀបរបបធ្វើការងារ និងធ្វើបញ្ជីអ្នកទោសនៅមន្ទីរស-២១ ។ ក្រៅពីធ្វើបញ្ជីអ្នកទោស និងធ្វើប្រវត្តិរូបសង្ខេបដើម្បីកត់ត្រាពីឈ្មោះភូមិ-ឃុំ ឪពុកម្តាយ សួស ធី មិនមានធ្វើឯកសារអ្វីផ្សេងទៀតទេ គឺមានកងសួរចម្លើយផ្សេងទៀតជាអ្នកធ្វើ ។ ចំពោះឯកសារប្រវត្តិរូបនេះ សួស ធី បានធ្វើចំនួនពីរច្បាប់ ដោយមួយច្បាប់តម្កល់ទុកនៅកន្លែងកងការពារ (កន្លែងគាត់រក្សាទុក) និងមួយច្បាប់ទៀតប្រគល់ឲ្យ ម៉េង រក្សាទុកនៅខាងក្រោមន្ទីរស-២១ (រក្សាទុកទាំងឯកសារសួរចម្លើយ និងបញ្ជីឈ្មោះអ្នកទោសទាំងអស់) ។

ដើម្បីបញ្ជាក់អំពីសក្ខីកម្មដែល ហ៊ឹម ហ៊ុយ បានធ្វើកាលពីថ្ងៃមុន នៅថ្ងៃនេះ ចៅក្រមក៏បានសួរសំណួរទៅកាន់ សួស ធី ដែលបានធ្វើការនៅផ្នែកកងការពារដែរថាតើ ហ៊ឹម ហ៊ុយ ធ្វើកងការពារនៅមន្ទីរស-២១រហូតដល់ឆ្នាំ១៩៧៩ ឬត្រូវបានបញ្ជូនទៅធ្វើស្រែនៅឆ្នាំ១៩៧៨? សួស ធី បានស្គាល់ឈ្មោះ ហ៊ឹម ហ៊ុយ ប៉ុន្តែមិនអាចសន្និដ្ឋានបានទេ ព្រោះ ហ៊ុយ ធ្វើការនៅខាងក្រៅ។ បន្ទាប់មកព្រះរាជអាជ្ញា តាន់ សេណារ៉ុង លើកឡើងពីកងការពារម្នាក់ឈ្មោះ គក ស្រស់។ សាក្សី សួស ធី បញ្ជាក់ថាគាត់មិនដែលស្គាល់និងមិនដែលចាប់អារម្មណ៍ឈ្មោះនេះទេ លើកលែងតែពេទ្យ រិន ពេទ្យ ទ្រី និងពីរនាក់ទៀតដែលគាត់មិនចាំឈ្មោះ។ តាមរយៈការលើកឡើងពីការអះអាងរបស់សាក្សីនៅក្នុងកំណត់ហេតុដែលបានសម្ភាសន៍នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨ ព្រះរាជអាជ្ញាបានបង្ហាញពីឯកសារនិងរូបថតអ្នកទោសដែលឈឺស្លាប់។ សួស ធី បានធ្វើឯកសារពីការស្លាប់តាមរយៈពេទ្យដែលបញ្ជូនមកប៉ុណ្ណោះ ប៉ុន្តែតាមការសន្និដ្ឋានអ្នកទោសទាំងនោះស្លាប់ដោយសារការអត់អាហារ និងការធ្វើទារុណកម្ម។

ការផ្ទៀងផ្ទាត់បញ្ជីអ្នកទោសចុងក្រោយដើម្បីយកទៅកម្ទេចមិនមានវត្តមាន ឌុច មកត្រួតពិនិត្យទេ ព្រោះសាក្សីបានបញ្ជាក់ថាការងាររបស់បុគ្គលិកនៅក្នុងមន្ទីរស-២១ដាច់ដោយឡែកពីគ្នាសូម្បីតែការហូបបាយ និងទំនាក់ទំនងនៅតាមអង្គភាពនីមួយៗ។ នៅក្នុងការអះអាងរបស់សាក្សីចំពោះកំណត់ហេតុបូមឈាមអ្នកទោស គឺបានប្រព្រឹត្តទៅដោយមានគ្រូពេទ្យបានស្នើទៅ ហ៊ី បន្ទាប់ពីទទួលបានសំណើរួច ហ៊ី ក៏បានស្នើទៅ ឌុច ដើម្បីសម្រេចយកអ្នកទោសចេញ។ ពីម្សិលមិញ សាក្សី សួស ធី បានសន្និដ្ឋានការបូមឈាមអ្នកទោសប្រព្រឹត្តទៅតែពីរដងប៉ុណ្ណោះ ដែលសរុបមានប្រហែល២០នាក់ ហើយអ្នកទោសដែលបានបូមរួចគ្មានវាសនាបានរស់ឡើយ។ បន្ទាប់មក ហ៊ី បានបញ្ជូនឈ្មោះអ្នកទោសដែលយកទៅបូមឈាមទាំងអស់នេះមកឲ្យគាត់ដើម្បីកត់ចូលទៅក្នុងបញ្ជី អ្នកទោសដែលត្រូវបានដឹកយកទៅកម្ទេច។

បន្ទាប់មក ព្រះរាជអាជ្ញា តាន់ សេណារ៉ុង បានស្នើទៅចៅក្រម ដើម្បីបង្ហាញពីប្រវត្តិរូបរបស់អ្នកទោសឈ្មោះ ភឹង គុន ដែល សួស ធី បានធ្វើប្រវត្តិរូបដោយផ្ទាល់ដៃ ប៉ុន្តែសាក្សីមិនបានដឹងពីដោគវាសនារបស់អ្នកទោសនិងទីកន្លែងដែលត្រូវបានយកទៅកម្ទេចទីណានោះទេ។ ដោយសាក្សីកត់ចំណាំមិនបានច្បាស់លាស់ពីទីតាំងចៅក្រមក៏បានបង្ហាញបញ្ជីរាយឈ្មោះអ្នកទោសដែលមានឈ្មោះអ្នកទោស ភឹង គុន នៅក្នុងនោះ ប៉ុន្តែ សួស ធី លើកឡើងពីភាពភ្លេចភ្លាំងរបស់គាត់ដដែល។

សហព្រះរាជអាជ្ញាអន្តរជាតិ អានី បានបន្តការសួរទាក់ទងការងារប្រចាំថ្ងៃរបស់សាក្សីក្នុងការកត់ឈ្មោះអ្នកទោសចេញ-ចូល និងបន្ទប់ឃុំឃាំងរបស់អ្នកទោស។ សួស ធី បានអះអាងថាបន្ទប់សម្រាប់ឃុំឃាំងអ្នកទោសមានគ្រប់គ្រាន់ ចំណែកអ្នកទោសខ្លះដែលដឹកចូលក្នុងមន្ទីរស-២១ដោយមិនឲ្យដឹងមុន ហ៊ី បានបញ្ជាឲ្យអ្នកថតរូបទៅថតដល់បន្ទប់ឃុំឃាំងតែម្តង។ ចំពោះអ្នកទោសស្លាប់នៅក្នុងបន្ទប់ឃុំឃាំង ឬអ្នកទោសយកទៅសម្លាប់ សួស ធី មិនបានដឹងពីការថតរូបទុកនោះទេ។ បន្ទាប់មក ដើម្បីចង់បានព័ត៌មានបន្ថែមទៀតទៅលើការថតរូបអ្នកទោសព្រះរាជអាជ្ញាសួរសំណួរទៅកាន់ ឌុច ដើម្បីបញ្ជាក់។ ឌុច បានបដិសេធចំពោះរូបថតដែលបានបង្ហាញនោះ ប៉ុន្តែគាត់ទទួលស្គាល់តែរូបថតរបស់អ្នកទោសសំខាន់ដែលថ្នាក់លើបញ្ជាមកឲ្យថតរូប ដូចជា វន វ៉េត ឆាយ គឹមហ៊ី និង លី ផែន ដែលបានយកទៅកម្ទេច ហើយយកទៅកប់ក្នុងផ្លូវចំនួនបីថ្ងៃមកហើយ ក៏ត្រូវគាស់យកសាកសពដើម្បីថតរូបដែរ។

ចំពោះឈ្លើយសឹកវៀតណាមដែលបញ្ជូនមកស-២១ សួស ធី មិនបានដឹងពីចំនួនច្បាស់លាស់ទេ គឺប្រហែល១០០នាក់ប៉ុណ្ណោះ ប៉ុន្តែ សួស ធី បញ្ជាក់ថានៅពេលមានផ្ទុះសង្គ្រាមរវាងវៀតណាម និងខ្មែរក្រហម ទើបឃើញអ្នកទោសវៀតណាមបញ្ជូនមកច្រើន។

ដោយសារពេលវេលារបស់សហព្រះរាជអាជ្ញាក្នុងការសួរសំណួរអស់ពេល ការពិភាក្សាដេញដោលលើសក្ខីកម្មរបស់ សួស ធី បានផ្តល់ឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសួរសំណួរម្តង។ មេធាវី ហុង គឹមសួន បានសុំឲ្យ សួស ធី បញ្ជាក់ថាតើដឹងដោយរបៀបណាចំពោះអ្នកទោសនៅគុកពិសេស និងនៅខាងក្រៅដែលមិនត្រូវបានយកទៅកម្ទេច។ សួស ធី បានអះអាងថា អ្នកទោសនៅខាងក្រៅមិនបានកត់នៅក្នុងបញ្ជីទេ ចំណែកអ្នកទោសនៅគុកពិសេសក៏មិនមានកត់នៅក្នុងបញ្ជីអ្នកទោសដែលយកទៅកម្ទេចរបស់គាត់ដែរ។

នៅពេលរសៀល ដំណើរការសួរដេញដោលនៅតែប្រព្រឹត្ត

ទៅដោយមានមេធាវីលោក គឹម ម៉េងឃី សុំអនុញ្ញាតពីលោកចៅក្រមដើម្បីបង្ហាញប្រវត្តិរូបរបស់អ្នកទោស ប៉ុន្តែតាមការឆ្លើយបំភ្លឺរបស់សាក្សី សួស ធី គាត់មិនបានធ្វើប្រវត្តិរូបនោះទេ។ បន្ទាប់ពីសាក្សីមិនអាចកត់សម្គាល់បាន មេធាវី ស៊ុដហ្សីនស្គី ក៏បង្វែរទៅសួរពីរយៈពេលឃុំខ្លួនអ្នកទោសលើសពី១៩ខែ។ សួស ធី បានបញ្ជាក់ថា អ្នកទោសដែលឃុំឃាំងនៅក្នុងមន្ទីរស-២១ មិនលើសពីរយៈពេលពីរខែទេ ប៉ុន្តែគាត់ចាំមិនច្បាស់ពីការឃុំខ្លួនលើសកំណត់នោះទេ។ មេធាវីបានស្នើសុំទៅលោកចៅក្រមឲ្យដាក់បង្ហាញឯកសារបញ្ជីឈ្មោះអ្នកទោសចូលនៅថ្ងៃ១២ ខែ២ ឆ្នាំ១៩៧៦ ដើម្បីឲ្យសាក្សីធ្វើការកត់សម្គាល់ទៅលើបន្ទប់ឃុំឃាំង ប៉ុន្តែសាក្សីមិនបានបង្ហាញពីភាពមិនច្បាស់លាស់ក្នុងការចងចាំរបស់គាត់។ មេធាវីក៏បន្តស្នើទៅចៅក្រមដើម្បីបង្ហាញប្រវត្តិរូបអ្នកទោស ភីង គុន ដែលឃុំឃាំងនៅក្នុងផ្ទះមួយ បន្ទប់ធំ៣ តូច៣។ បន្ទាប់ពីបានពិនិត្យរួចរាល់ សាក្សីបានទទួលស្គាល់ប្រវត្តិរូបនេះនិងធ្វើការកត់សម្គាល់ទៅលើការផ្លាស់ប្តូរបន្ទប់ឃុំឃាំងរបស់អ្នកទោសដោយយោងតាមកងការពារបានរាយការណ៍ពីការផ្លាស់ប្តូរបន្ទប់របស់អ្នកទោសមកគាត់កត់ចូលក្នុងបញ្ជី។ ជាមួយគ្នានោះ មេធាវី ទ្រី ស៊្រីណា សួរសំណួរទៅកាន់ សួស ធី ពីប្រយោជន៍ដែលគាត់ទទួលបានក្នុងអំឡុងពេលបំពេញការងារនៅមន្ទីរស-២១។ សួស ធី បានឆ្លើយថា «គ្មានប្រយោជន៍អ្វីទេ គឺបានត្រឹមតែការភ័យខ្លាចប៉ុណ្ណោះ ខ្លួនរបស់គាត់ដូចជាគ្មានវិញ្ញាណ»។

ក្រោយមកមេធាវីការពារជនជាប់ចោទ កា សាវុត្ថ បានស្នើទៅអង្គសវនាការដើម្បីឲ្យ ឌុច បកស្រាយអពីមន្ទីរស-២១ ដែលសាក្សី សួស ធី បានអះអាងថាមន្ទីរស-២១ មានបែងចែកជាមន្ទីរស-២១ «ក» «ខ» និង «ឃ» ប៉ុន្តែមិនច្បាស់ថាតើមានមន្ទីរស-២១«គ»ឬអត់ ឌុច រៀបរាប់ថា គាត់មិនបដិសេធទៅនឹងសក្ខីកម្មដែល សួស ធី បានប្រាប់ទៅអង្គសវនាការទេ ថែមទាំងបានបញ្ជាក់បន្ថែមទៀតថា ស-២១«ក» គឺសំដៅទៅភ្នំពេញទាំងមូល ស-២១«ខ» សំដៅលើភ្នំពេញដែរ ប៉ុន្តែកន្លែងកងការពារ ចំណែក ស-២១ «គ» គឺជាចម្ការផ្លៃឈើនៅតាខ្មៅ និងស-២១ «ឃ» ឬ ស-២៤ ជាកន្លែងស្រែដូចអ្វីដែល សួស ធី អះអាងពិតប្រាកដ។ ទាក់ទងទៅនឹងសំណួរដែលលោក កា សាវុត្ថ សួរថាតើឃើញអ្នកទោសលោតពីលើអគារឬទេ ឬឃើញការប្រើខ្សែពួរដើម្បីធ្វើអត្តឃាតឬទេ? សួស ធី បានឆ្លើយថាមិនដឹង ឬមិនដែលបានឃើញហេតុការណ៍នោះទេ។ ប៉ុន្តែគាត់បានប្រាប់ទៅមេធាវីការពារក្តីថា គាត់ស្គាល់តែឈ្មោះ ឌុច ប៉ុណ្ណោះ ដែលមានសិទ្ធិបញ្ជានៅក្នុងមន្ទីរស-២១។

ចៅក្រមបានឲ្យ ឌុច ធ្វើការសន្និដ្ឋានអំពីសក្ខីកម្មរបស់ សួស ធី។ ដំបូង ឌុច បានផ្តល់ការអង្កេតមួយដែលជាប្រយោជន៍ដល់អង្គសវនាការអំពីសំណួរដែលមេធាវី ទី ស៊្រីណា សួរទៅកាន់សាក្សីអំពីឈ្មោះ ហ៊ិ និងឈ្មោះ ហោ ជាមនុស្សតែមួយដែរឬទេ? ឌុច បានប្រាប់អង្គសវនាការថា ឈ្មោះទាំងពីរនេះគឺជាឈ្មោះតែមួយ ដែលលោក សុន សេន បានសរសេរច្រឡំពីឈ្មោះ ហ៊ិ ទៅជាឈ្មោះ ហោ វិញ ហើយក្រោយមក ហ៊ិ រក្សាឈ្មោះ ហោ សម្រាប់ជាកិត្តិយសដល់មេដែលបានដាក់ឲ្យគាត់រហូតមក។

ឌុច បានទទួលស្គាល់ថាឈ្មោះ សួស ធី ពិតជាបុគ្គលិកមន្ទីរស-២១ ប្រាកដមែន ដោយមិនចាំបាច់ទាមទារឯកសារអ្វីឡើយ។

ឌុច បានបន្ថែមទៅលើសក្ខីកម្មរបស់ សួស ធី ចំនួនពីរចំណុចអំពីអ្នកទោសដែលបានលួចរត់ពីមន្ទីរស-២១គឺជាយោធារបស់កងពល១៧០ ក្រោយមកសេនាធិការក៏បញ្ជាឲ្យចាប់ខ្លួនមកមន្ទីរស-២១វិញ ចំណែកអ្នកទោសឈ្មោះ ចយ គាត់មិនបានដឹងពីហេតុការណ៍នោះទេ។ ចំណែកអ្នកទោសម្នាក់ទៀតគឺឈ្មោះ ប៉ូច ដែល ហ៊ិ បានប្រាប់ថាឃើញធ្វើសកម្មភាពមិនល្អ ដូច្នេះទើបគាត់រាយការណ៍ទៅថ្នាក់លើ បន្ទាប់មក សុន សេន ក៏បញ្ជាឲ្យយកទៅកម្ទេច។

ចុងក្រោយ ឌុច បានប្រាប់អង្គសវនាការថា សក្ខីកម្មរបស់ សួស ធី មានលក្ខណៈពិតជាមូលដ្ឋាន។ ឌុច បានសរសើរពីភាពសហការល្អរបស់ សួស ធី ជាមួយអង្គសវនាការដើម្បីរកយុត្តិធម៌ជូនប្រជាជនកម្ពុជា។ ជាចុងក្រោយ ឌុច បាន «សរសើរចំពោះឆន្ទៈរបស់ សួស ធី ក្នុងការផ្តល់សក្ខីកម្ម និងបានទទួលស្គាល់ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរស-២១។ ប៉ុន្តែ ឌុច ក៏បានបញ្ជាក់ចំពោះមនុស្សមិនជាប់ពាក់ព័ន្ធជាមួយរឿងនេះ សូមកុំតាំងខ្លួនមកជាប់ព័ន្ធឲ្យសោះ ព្រោះគាត់មិនចង់ឲ្យគេមកភ្ជាប់ជាមួយនឹងរឿងឧក្រិដ្ឋនេះទេ»។ **គាត លក្ខិណា និង សោម ប៊ុនថន**

# សុខភាពផ្លូវចិត្តនិងកេរដំណែលនៃរបបខ្មែរក្រហម

ការចាប់ផ្តើមនៃតុលាការខ្មែរក្រហមដែលមានឈ្មោះជាផ្លូវការថា (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) បាននាំយកនូវក្តីសង្ឃឹមថ្មីសម្រាប់ការផ្សះផ្សានិងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា ។ ដូចដែលបានរំពឹងទុក មានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើដំណើរការរបស់អង្គជំនុំជម្រះ និងសារប្រយោជន៍នៃដំណើរនោះសម្រាប់អនាគតរបស់កម្ពុជា ។

ទោះជាយ៉ាងនេះក្តី បញ្ហាដែលមិនសូវមានការយកចិត្តទុកដាក់ដែលពាក់ព័ន្ធនឹងដំណើរការរបស់អង្គជំនុំជម្រះគឺសេវកម្មសុខភាពផ្លូវចិត្តនៅកម្ពុជា ។ មានការប៉ាន់ប្រមាណថា ៦០ភាគរយនៃអ្នកនៅរស់ពីរបបខ្មែរក្រហមមានជំងឺផ្លូវចិត្ត ។ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៩ ខ្ញុំមានឱកាសធ្វើដំណើរទៅខេត្តស្វាយរៀងជាមួយក្រុមគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនៅទីនោះ ខ្ញុំបានឃើញផលប៉ះពាល់នៃជំងឺផ្លូវចិត្តទៅលើជីវិតប្រជាជនដោយផ្ទាល់ភ្នែក ។

## ***របបខ្មែរក្រហមនិងជំងឺផ្លូវចិត្ត***

### ***១) ជំងឺផ្លូវចិត្តនិងការរំឭកពីរបបខ្មែរក្រហម***

ខ្ញុំបានចំណាយពេលប្រហែលមួយសប្តាហ៍ជាមួយនឹងក្រុមគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការធ្វើដំណើរទៅខេត្តស្វាយរៀង ហើយជួបជាមួយជនរងគ្រោះនៃរបបខ្មែរក្រហម ។ នៅអំឡុងពេលទស្សនកិច្ច ខ្ញុំបានចាប់អារម្មណ៍នឹងស្ត្រី «ខ» ម្នាក់ដែលខ្ញុំបានជួបនៅភូមិញ៉ី ។ ស្ត្រី «ខ» ម្នាក់នេះ មិនចាំថាខ្លួនឯងអាយុប៉ុន្មានទេ ហើយគាត់មិនអាចរៀបរាប់ពីរឿងរ៉ាវរបស់គាត់តាមលំដាប់លំដោយបានឡើយ ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្គាល់ឃើញរោគសញ្ញានៃជំងឺផ្លូវចិត្តរបស់គាត់យ៉ាងឆាប់រហ័ស ។ នោះគឺជារោគសញ្ញាដែលប្រជាជនកម្ពុជាធ្លាប់បានដឹង ។ យោងទៅតាមរបាយការណ៍ឆ្នាំ២០០៧ របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម អ្នកនៅរស់ពីរបបខ្មែរក្រហមភាគច្រើនឃើញនូវព្រឹត្តិការណ៍ដែលអាចធ្វើឲ្យមនុស្សធម្មតា «បាត់បង់» នូវសមត្ថភាពចងចាំ និងយល់ដឹងពី ដំណើរការដែលគេបានជួបប្រទះ ។

ចំណុចដែលគួរឲ្យចាប់អារម្មណ៍គឺ អ្នកភូមិផ្សេងទៀតជួយនិយាយពីប្រវត្តិរឿងរបស់គាត់ ។ បុរសពីរនាក់ប្តូរវេនគ្នាបំពេញពាក្យបណ្តឹងនិងលុបអ្វីដែលមិនច្បាស់លាស់ដែលគាត់បាននិយាយ ។ ប្រៀបបីដូចជាគេកំពុងតែនិយាយពីរឿងរ៉ាវរបស់គាត់ប្រាប់គាត់ ។ វាធ្វើឲ្យខ្ញុំគិតទៅដល់ផលប៉ះពាល់នៃជំងឺផ្លូវចិត្តទៅលើការរំឭកពីរឿងរ៉ាវនៅសម័យនោះ ។ ប្រសិនបើមិនមានការរំឭកទៅដល់រឿងរ៉ាវនៅរបបនោះទេ រឿងរ៉ាវរបស់អ្នកនៅរស់ដែលមានជំងឺផ្លូវចិត្តដែលមិនមានអ្នករំឭកសោះនឹងបាត់បង់ជា រៀងរហូត ។

រឿងរ៉ាវដែលគាត់នៅចាំច្បាស់នោះគឺការបង្ខំគាត់ឲ្យរៀបការ ។ ជាការពិត មកដល់សព្វថ្ងៃនេះ គាត់រស់នៅជាមួយបុរសដែលគាត់រៀបការជាមួយដដែល នោះគឺបុរសដែលគាត់រៀបការជាមួយដើម្បីជៀសផុតពីការសម្លាប់ ។ ខណៈពេលដែលគាត់រៀបរាប់ពីព្រឹត្តិការណ៍នៅថ្ងៃរៀបការរបស់គាត់ គាត់ចង្អុលទៅស្វាមីរបស់គាត់ដែលអង្គុយយ៉ាងស្ងៀមស្ងាត់ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីគាត់ ។ គ្មាននរណាដឹងថា ស្វាមីរបស់គាត់ធ្វើជាអ្នកចងចាំនូវអ្វីដែលគាត់បានជួបប្រទះដែលគាត់មិនអាចបំភ្លេចបានដោយរបៀបណាទេ ។

នៅអំឡុងពេលទស្សនកិច្ច ខ្ញុំយល់ឃើញថា អ្នកនៅរស់បានត្រៀមខ្លួនបង្ហាញពីរបួសនៅលើខ្លួនរបស់គេជាជាងរបួសផ្លូវចិត្តជាក់ស្តែងដូចជាស្ត្រីម្នាក់ដែលខ្ញុំបានជួបនៅភូមិរោទិ៍ ។ ដោយត្រូវបានបង្ខំឲ្យលើកទំនប់នៅរបបខ្មែរក្រហម ស្ត្រីម្នាក់នេះបានរៀបរាប់ពីពេលដែលគាត់ធ្លាក់ពីលើទំនប់ជាច្រើនលើកច្រើនសាដែលបណ្តាលឲ្យគាត់មានស្នាមរបួសនៅលើខ្លួនមកដល់សព្វថ្ងៃនេះ ។ ការខ្វះខាតអាហារ និងការមើលឃើញមិនច្បាស់ កើតឡើងដោយសារការខ្វះខាតវីតាមីនអា និងគ្រោះថ្នាក់ដែលបណ្តាលមកពីការបង្ខំឲ្យធ្វើការនៅពេលយប់ដែលកាន់តែមានសភាពធ្ងន់ធ្ងរទៅៗ ។ ការឈឺចាប់ខាងផ្លូវចិត្តដែលកើតឡើងដោយសារការបំបែកគាត់ និងសមាជិកគ្រួសាររបស់គាត់បានធ្វើឲ្យរបួសនោះកាន់តែធ្ងន់ធ្ងរឡើង ប៉ុន្តែគាត់មិនបានរៀបរាប់ពីបញ្ហានេះទេ ។ គាត់មានអាយុ១៨ឆ្នាំ នៅពេលដែលខ្មែរក្រហមចូលមកដល់ភូមិ ។ ទោះបីជាគ្រួសាររបស់គាត់ត្រូវ

បានជម្លៀសទៅកន្លែងតែមួយក៏ដោយ ក៏ខ្មែរក្រហមបានបំបែកសមាជិកគ្រួសាររបស់គាត់ទៅកន្លែងផ្សេងគ្នាថែមទៀត ។ នៅអំឡុងពេលនោះគាត់និងគ្រួសាររបស់គាត់មិនបានរស់នៅជាមួយគ្នាដូចជាគ្រួសារទេ ។ ការទៅលេងផ្ទះត្រូវបានដាក់កំហិតប្រជាជនអាចទៅលេងផ្ទះបានលុះត្រាតែមានការអនុញ្ញាត ។ គាត់បានសូមអនុញ្ញាតទៅសួរសុខទុក្ខសមាជិកគ្រួសាររបស់គាត់ដែលមានជំងឺពីរលើក ប៉ុន្តែត្រូវបានខ្មែរក្រហមបដិសេធ ។ ខ្មែរក្រហមចាប់គាត់ហើយដាក់ទណ្ឌកម្មឲ្យធ្វើការជាទម្ងន់និងធ្វើបាបព្រោះហ៊ានប្រឆាំងនឹងបញ្ជារបស់អង្គការរត់ទៅរកបងប្អូនដែលមានជំងឺ ។

របួសផ្លូវចិត្តរបស់ស្ត្រីឈ្មោះ «ខ» ម្នាក់នេះមិនបានបញ្ចប់ទេនៅពេលដែលរបបខ្មែរក្រហមបានដួលរលំ ។ ជាមួយនឹងការចូលមកដល់របស់កងទ័ពវៀតណាម គាត់បានរត់ចេញពីជំរំពលកម្ម ហើយមករស់នៅជួបជុំជាមួយគ្រួសាររបស់គាត់ម្តងទៀត ប៉ុន្តែមិនមានវត្តមានឪពុករបស់គាត់ទេ ។

អ្នកនៅរស់ពីរបបខ្មែរក្រហមជាច្រើនមានចម្ងល់អំពីការតស៊ូដើម្បីរស់ និងកន្លែងអ្នកដែលជាទីស្រឡាញ់គេរស់នៅ ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលដឹងពីការស្លាប់នៃសមាជិកគ្រួសាររបស់អ្នកភូមិត្រូវនាំយកព័ត៌មានដែលមិនសប្បាយចិត្តទៅឲ្យអ្នកភូមិ ។ នេះប្រៀបបីដូចជាដាវដែលមានមុខពីរ ។ ខណៈពេលដែលអ្នកនៅរស់សុខចិត្តទទួលស្គាល់ការពិត ហើយបំភ្លេចនូវអ្វីដែលនៅជាមួយគេជាយូរណាស់មកហើយ ព័ត៌មានដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ឲ្យគេបានធ្វើឲ្យរបួសដ៏ឈឺចាប់ពីអតីតកាលរើឡើងវិញ ហើយធ្វើឲ្យក្តីសង្ឃឹមដែលគេរំពឹងថាអ្នកជាទីស្រឡាញ់របស់គេដែលនៅរស់បានស្លាប់បាត់បង់អស់ ។

## ២) ការរួមបញ្ចូលគ្នានៃព្រឹត្តិការណ៍របួសផ្លូវចិត្ត

លទ្ធភាពរបស់អ្នកនៅរស់ក្នុងការរួមបញ្ចូលព្រឹត្តិការណ៍ដែលបង្កឲ្យមានរបួសផ្លូវចិត្តមានលក្ខណៈខុសគ្នា ។ កត្តាជាច្រើនដូចជាស្ថានភាពនិងរឿងផ្ទាល់ខ្លួនដើរតួនាទីក្នុងការកំណត់ថា តើមនុស្សម្នាក់ឆ្លើយតបនឹងរបួសផ្លូវចិត្តនេះដោយរបៀបណា ។ កត្តាមួយបែបនេះគឺជាការគាំទ្រនិងផ្តល់ជំនួយដល់ផ្លូវចិត្តអ្នកដែលមានរបួសផ្លូវចិត្ត ។ មានវេជ្ជបណ្ឌិតដែលមានសមត្ថភាពប្រមាណ៤០០នាក់ក្នុងប្រទេសកម្ពុជានៅដើមទសវត្សរ៍៧០ ។ ប៉ុន្តែភាគច្រើននៃអ្នកទាំងនោះត្រូវបានសម្លាប់នៅក្នុងរបបខ្មែរក្រហម ដែលធ្វើឲ្យបាត់បង់ការផ្តល់ការព្យាបាលដែលមានជំនាញ និងបាត់បង់ការគ្រប់គ្រង ការផ្តល់សេវាសុខភាព ។ នៅពេលធ្វើការសន្ទនាជាមួយស្ត្រី «ខ» គាត់បានរំឭកពីថ្នាំអាចម៍ទន្សាយដែលខ្មែរក្រហមឲ្យលេបដើម្បីព្យាបាលជំងឺរបស់គាត់ ។ ការមិនបានផ្តល់សេវាសុខភាពត្រឹមត្រូវបានធ្វើឲ្យការរំខានដល់សុខភាពផ្លូវចិត្តរបស់ស្ត្រីទាំងពីរនេះនិងអ្នកផ្សេងទៀតកាន់តែធ្ងន់ធ្ងរ ។

ប៉ុន្តែ កត្តាផ្សេងទៀតដែលទំនងជាអាចជះឥទ្ធិពលដល់លទ្ធភាពរបស់អ្នកនៅរស់គឺជាកង្វះខាតនៃស្ថិរភាពនិងសន្តិសុខ ។ ខ្មែរក្រហមបានបំបែកគ្រួសារឲ្យនៅដាច់ពីគ្នាបណ្តាលឲ្យទំនាក់ទំនងគ្រួសារដែលកាលពីមុនធ្លាប់តែល្អដាក់គ្នាក្លាយជាអាក្រក់ ។ ខ្ញុំគិតថា ការបំបែកគ្រួសាររបស់ស្ត្រី «ខ» មិនត្រឹមតែជះឥទ្ធិពលដល់ផ្លូវចិត្តរបស់គាត់ប៉ុណ្ណោះ វាថែមទាំងធ្វើឲ្យគាត់មិនអាចស្វែងរកសុភមង្គលនៅក្នុងគ្រួសាររបស់គាត់ទៀតផង ។

ការខ្វះខាតសន្តិសុខគ្រាន់តែជាការបំផ្លាញមួយប៉ុណ្ណោះ ។ ស្ត្រី «ក» បាននិយាយថា ខ្មែរក្រហមតែងតែតាមដានគាត់ជានិច្ចបន្ទាប់ពីគាត់ត្រូវបានបង្ខំឲ្យរៀបការ ។ អ្នកដទៃដែលត្រូវបានបង្ខំឲ្យរៀបការក៏បាននិយាយដូច្នេះដែរ ។ ឈ្លបខ្មែរក្រហមចង់ឲ្យអ្នកដែលត្រូវបានបង្ខំឲ្យរៀបការធ្វើដូចជាប្តីប្រពន្ធ ។ ទោះបីជាមានឬមិនមានឈ្លបក៏ដោយ ក៏អារម្មណ៍ភ័យខ្លាចជាពិសេសអារម្មណ៍ភ័យខ្លាចដែលកើតឡើងនៅផ្ទះប្រហែលជាអាចបណ្តាលឲ្យមានការជះឥទ្ធិពលដល់ផ្លូវចិត្តឬធ្វើឲ្យការជះឥទ្ធិពលនោះកាន់តែអាក្រក់ឡើង ។

## ៣) របួសផ្លូវចិត្តសង្គម

ខ្មែរក្រហមបានធ្វើឲ្យប្រជាជនមានរបួសផ្លូវចិត្តដែលមិនអាចបំភ្លេចបាន ។ ការស្រាវជ្រាវបង្ហាញឲ្យឃើញថា របួសផ្លូវចិត្តមិនត្រឹមតែធ្វើឲ្យបុគ្គលមានវិបត្តិផ្លូវចិតប៉ុណ្ណោះ វាថែមទាំងជះឥទ្ធិពលដល់សង្គមទៀតផង ។ របបខ្មែរក្រហមត្រូវទទួលខុសត្រូវចំពោះការធ្វើឲ្យខូចខាតដល់ទំនាក់ទំនងបុគ្គលនិងទំនាក់ទំនងរបស់ក្រុមព្រមទាំងទទួលខុសត្រូវចំពោះភាពភ័យខ្លាចនិងការមិនជឿទុកចិត្តគ្នារបស់ប្រជាជនកម្ពុជា ។ លើសពីនេះទៅទៀត មនុស្សជាច្រើនបានយល់ថាខ្មែរក្រហមបានជំរុញឲ្យមានការប្រាស្រ័យទាក់ទងគ្នា

មិនល្អការមិនចូលរួមក្នុងសង្គមនិងអំពើហិង្សានៅក្នុងសង្គម ។ ដោយគិតទៅដល់ការបំផ្លាញដល់សង្គមជារួមដែលកើតឡើងនៅរបបខ្មែរក្រហមនៅពេលព្យាបាលជំងឺផ្លូវចិត្តនៅកម្ពុជា យើងចាំបាច់ត្រូវតែពិចារណាទៅលើបញ្ហានេះជាមួយនឹងបុគ្គលិកដែលមានរបួសផ្លូវចិត្ត ។

## ស្ថានភាពថ្មីនៃសេវាសុខភាពផ្លូវចិត្តនៅកម្ពុជា

អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា (សេវាសុខភាពផ្លូវចិត្ត) បានប៉ាន់ប្រមាណថា ២៨.៤ភាគរយនៃប្រជាជនកម្ពុជាមានជំងឺបាក់ស្បាត ១១.៥ភាគរយ មានជំងឺអាកប្បកិរិយា ហើយ៤០ភាគរយមានជំងឺថប់អារម្មណ៍ ។ ទោះបីជាមានចំនួនគួរឲ្យព្រួយបារម្ភយ៉ាងនេះក្តីកម្ពុជានៅតែមិនបានត្រៀមខ្លួនព្យាបាលជំងឺផ្លូវចិត្តជាលក្ខណៈជាតិទេ ។ ពេទ្យវិកលចរិត២៦នាក់ ពេទ្យទូទៅ១០០នាក់ ដែលទទួលវគ្គបណ្តុះបណ្តាលផ្នែកសុខភាពផ្លូវចិត្ត១២សប្តាហ៍ អង្គការជាតិ និងអន្តរជាតិ៩ ជាអ្នកផ្តល់សេវាសុខភាពដល់ប្រជាជន១៨លាននាក់ ។ ពេទ្យវិកលចរិតដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៣៥ នៅតែជាពេទ្យវិកលចរិតតែមួយគត់នៅក្នុងប្រទេស ។

## សេចក្តីសន្និដ្ឋាន

នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ខ្មែរក្រហមបានគ្រប់គ្រងប្រទេសកម្ពុជាដោយស្របច្បាប់និងមិនគិតទៅដល់ប្រជាជនរាប់លាននាក់ដែលគេបានបំផ្លាញផងទេ ។ អ្នកដែលនៅរស់មិនត្រឹមតែមិនអាចបំភ្លេចអ្វីដែលបានកើតឡើងនៅរបបខ្មែរក្រហមប៉ុណ្ណោះទេ គេថែមទាំងនៅមានជំងឺផ្លូវចិត្តបណ្តាលមកពីការបំផ្លាញដែលគេឃើញដោយផ្ទាល់និងទារុណកម្មដែលគេធ្លាប់ទទួល ។ ជាមួយនឹងដំណើរការទៅមុខរបស់អង្គជំនុំជម្រះ ខ្ញុំសង្ឃឹមថា បញ្ហាជំងឺផ្លូវចិត្តនឹងត្រូវបានដោះស្រាយទាំងស្រុង ។ ការដោះស្រាយនេះគឺមិនត្រឹមតែដើម្បីការចងចាំរបបខ្មែរក្រហមជាបុគ្គលប្បរមនោះទេ គឺដើម្បីអនាគតរបស់កម្ពុជាផងដែរ ។

**ម៉ារី អ៊ីរ៉ូស៊ី**

# ដំណឹងស្វែករកប្អូនប្រុសឈ្មោះ គង់ មីត



នាងខ្ញុំឈ្មោះ គង់ ថុល អាយុ៦២ឆ្នាំ រស់នៅភូមិព្រិច ឃុំទ្រាល ស្រុកបារាយណ៍ ខេត្តកំពង់ធំ មានឪពុកឈ្មោះ ម៉ុន ជាជនជាតិ បារាំង និងម្តាយឈ្មោះ កែវ វ៉ាត់ ។ នាងខ្ញុំសូមប្រកាសស្វែររកប្អូនប្រុសឈ្មោះ គង់ មីត ដែលបានបាត់ខ្លួននៅក្នុងរដ្ឋប្រហារទម្លាក់ សម្តេច សីហនុ ឆ្នាំ១៩៧០ ។ ប្រហែលជាឆ្នាំ១៩៩៧ ខ្ញុំបានទទួលដំណឹងពីអ្នកភូមិដែលរស់នៅខណ្ឌស៊ឹងមានជ័យ ថា គង់ មីត បានមករកម្តាយរបស់គាត់ កែ វ៉ាត ដែលមានមុខរបរលក់ថ្នាំ ។ ក្រោយមកទៀត ខ្ញុំមិនដែលបានទទួលដំណឹងអ្វីពី គង់ មីត ទៀតទេ ។

ដូច្នេះប្រសិនបើប្អូនប្រុសបានឮ ឬបានអានសេចក្តីប្រកាសនេះ សូមមករកបងតាមអាស័យដ្ឋានខាងលើ ឬតាមរយៈទូរស័ព្ទលេខ ០១២ ៧៨៧ ៥៧៥, ០១២ ៨៩៩ ០៧១, ០៩២ ៥៦៣ ០០៧ ។ សូមអរគុណ ។

# សេចក្តីប្រកាសស្វែររកកូនស្រី វ៉ាន់ រុំ

នាងខ្ញុំឈ្មោះ ជួប រ៉េម អាយុ៧១ឆ្នាំ រស់នៅភូមិសាមគ្គី ឃុំអង្គរជ័យ ស្រុកអង្គរជ័យ ខេត្តកំពត ។ នាងខ្ញុំសូមប្រកាសស្វែររកកូនស្រីឈ្មោះ វ៉ាន់ រុំ ដែលសព្វថ្ងៃមានអាយុប្រហែល៣៨ឆ្នាំ បានបាត់ខ្លួននៅឆ្នាំ១៩៧៥ ។ នៅពេលនោះ វ៉ាន់ រុំ ត្រូវបានប្រធានភូមិឈ្មោះ គឿន បញ្ជូនឲ្យធ្វើស្រែអំបិលនៅកែប ។ ក្រោយមកទៀត ខ្ញុំបានទទួលដំណឹងពីម្តាយមីងរបស់ខ្ញុំឈ្មោះ វ៉ាន់ សៀន ថាគាត់បានជួបជាមួយ វ៉ាន់ រុំ ម្តងនៅក្បែរហាងទឹកត្រីមួយ ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹងអ្វីពី វ៉ាន់ រុំ ទាំងអស់ ។

ដូច្នេះបើកូនបានដំណឹងនេះ សូមមកជួបម្តាយនៅភូមិឃុំខាងលើ ឬទំនាក់ទំនងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ការអភ័យទោសមិនមែនជាតម្រូវការចាំបាច់ទេ

ប្រសិនបើខ្ញុំមានការរំពឹងទុកច្បាស់លាស់ទៅលើអ្វីដែលខ្ញុំចង់ចាំនៅពេលដែលខ្ញុំធ្វើការ ការរំពឹងទុកនោះគឺពាក់ព័ន្ធនឹងបទពិសោធន៍របស់ជនរងគ្រោះដែលខ្ញុំនឹងស្តាប់ឮ និងរបៀបដែលខ្ញុំនឹងឆ្លើយតបទៅវិញ ។ ខ្ញុំបានអានសៀវភៅជាច្រើន ។ ប៉ុន្តែពេលដែលអ្នកស្តាប់រឿងរបស់ជនរងគ្រោះរៀបរាប់រឿងរ៉ាវរបស់គាត់កាលពីសម័យឃើចាប់ដោយអន្តុយ នៅទល់មុខជនរងគ្រោះ ហើយដោយនិយាយថា កម្មាភិបាលខ្មែរក្រហមបានប្រកកូនស្រីរបស់គាត់ចូលទៅក្នុងបាវស្រូវរួចក៏គ្រវែងទៅក្នុងទឹកទន្លេ ហើយគាត់បានឃើញព្រឹត្តិការណ៍នោះដោយផ្ទាល់ភ្នែក ។

នៅពេលនេះអ្នកនឹងដឹងថា គម្លាតរវាងការពិតដែលមើលឃើញនិងទ្រឹស្តីអរូបិយគឺជារឿងពីរខុសគ្នាយ៉ាងដាច់ស្រឡះ ។ ជំនឿនិងទស្សនៈសីលធម៌ដែលអ្នកមាននៅក្នុងខ្លួន ឥឡូវនេះបែរជាមិនសូវមានទៅវិញនៅពេលដែលអ្នកស្តាប់ការរៀបរាប់របស់មនុស្សម្នាក់នូវបទពិសោធន៍ដ៏ចុកចាប់ខ្លោចផ្សា ។

នៅពេលដែលខ្ញុំទៅធ្វើការនៅខេត្តជាមួយក្រុមជួយជនរងគ្រោះរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការពាក្យបណ្តឹងទៅតុលាការ ខ្ញុំបានប្រាស្រ័យទាក់ទងជាមួយប្រជាជនខ្មែរនៅខេត្តកំពង់ឆ្នាំង និងសហគមន៍ចាមមូស្លីមនៅខេត្តកំពត ។ ខ្ញុំបានសន្ទនាជាមួយប្រជាជនកម្ពុជាដែលអាចចែករំលែករឿងរ៉ាវរបស់គាត់និងធ្លាប់បានចំណាយពេលមួយថ្ងៃទៅស្តាប់ការផ្តល់សក្ខីកម្មរបស់សាក្សីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប្រៀបដូចជាសត្វល្អិតមួយនៅក្នុងរឿងព្រេងខ្មែរដែលមានមាត់តូចមិនអាចស៊ីចំណីធំៗបាន បញ្ហាការលើកលែងទោសគឺនៅស្រពេចស្រពិលនៅលើអាកាសនៅឡើយ បន្ទាប់ពីមានរឿងរ៉ាវដ៏អាក្រក់កើតឡើងដែលធ្វើឲ្យមានការមិនពេញចិត្តជាខ្លាំង ។

នៅពេលដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចូលទៅដល់ភូមិ អ្នកទាំងនោះបានស្វាគមន៍អ្នកដែលសម្រេចចិត្តចូលរួមក្នុងការប្រជុំពិភាក្សា ហើយបានសួរអ្នកដែលមកចូលរួមទាំងនោះថាតើគេធ្លាប់បានដឹងពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ ។ បុគ្គលិកទាំងនេះនៅបន្តប្រាប់អ្នកភូមិអំពីការងាររបស់អង្គជំនុំជម្រះថាតើអង្គជំនុំជម្រះកំពុងតែកាត់ទោសអ្នកណា ហើយថាតើគេចូលរួមជាមួយតុលាការតាមរយៈការបំពេញពាក្យបណ្តឹងឬបែបបទតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយរបៀបណា ។ ក្នុងអំឡុងពេលប្រជុំ អ្នកភូមិត្រូវបានលើកទឹកចិត្តឲ្យចែករំលែកពីបទពិសោធន៍ដែលគេបានជួបប្រទះដោយបើកចំហ ប្រកបដោយភាពយោគយល់ ។ អ្នកភូមិតែងតែបង្ហាញពីការលំបាកក្នុងការរំឭកពីរឿងនេះ ហើយមានភាពធូរស្រាលនៅពេលនិយាយអំពីរឿងអតីតកាលជាមួយអ្នកដែលជួបប្រទះនឹងការឈឺចាប់ស្រដៀងគ្នា ។ នៅក្នុងការប្រជុំពិភាក្សានេះ អ្នកទាំងអស់គ្នាមានអារម្មណ៍យល់ចិត្ត និងលើកទឹកចិត្តគ្នា វាពិតជាល្អណាស់ដែលឃើញបែបនេះ ។

## ***សាសនា***

អ្នកប្រណិប័តន៍ពុទ្ធសាសនាបាននិយាយថា ម្នាក់ៗគួរតែអត់ឱនឲ្យគ្នា ទើបគ្មានជំពាក់កម្មទៅជាតិក្រោយទៀត ។ តើអ្វីយល់យ៉ាងម៉េចដែរ? «*នេះមិនមែនមានតែពុទ្ធសាសនិកទេ*» ។

ការជួបពិភាក្សានេះគឺនៅក្នុងខេត្តកំពង់ឆ្នាំង ។ មនុស្សម្នាសើចក្អាកក្អាយនៅពេលដែលស្ត្រីម្នាក់ពាក់អាវពណ៌ខ្មៅនិយាយពាក្យនេះចេញមកនៅក្នុងអំឡុងពេលប្រជុំកាលពីថ្ងៃព្រហស្បតិ៍ទី២៣ ខែកក្កដា កន្លងមកនេះ ប៉ុន្តែគាត់អាចគ្រប់គ្រងអារម្មណ៍ខ្លួនឯងបានយ៉ាងល្អ ។ ម៉្យាងវិញទៀត ប្រជាជនភាគច្រើនដែលបាននិយាយពាក្យដូចគ្នានេះបានបញ្ជាក់ថា ការអភ័យទោសគឺមានភាពងាយស្រួលណាស់ខាងទ្រឹស្តី ប៉ុន្តែការអនុវត្តមានការលំបាកជាទីបំផុត ។ សាសនាតែងតែដោះស្រាយទៅលើជម្លោះផ្ទៃក្នុង ។ ឧទាហរណ៍ ពេលសួរថាតើសាសនាអាចបង្រួបបង្រួមកំហឹងចំពោះខ្មែរក្រហមដោយរបៀបណា ។ ស្ត្រីម្នាក់បាននិយាយថា ព្រះពុទ្ធប្រហែលជាមិនដឹងថាយើងអាចនឹងទទួលរងនូវការឈឺចាប់របៀបណាទេ ពេលដែលព្រះអង្គសរសេរអំពីទ្រឹស្តីនៃការអភ័យទោសនេះ

ឡើង ។ ខ្ញុំស្វែងយល់ឃើញថា អ្នកភូមិជាច្រើននាក់ដែលយើងបាននិយាយជាមួយបានលើកយកទស្សនវិជ្ជានៃសាសនាផ្សេងៗដោយផ្អែកទៅលើបំណងរៀងៗខ្លួនក្នុងការអភ័យទោស ។ អ្នកភូមិម្នាក់ដែលយោងទៅតាមគម្ពីរកូរ៉ានបានដកស្រង់មកថា ការអភ័យទោសគឺជាភាពសុចរិត ហើយអ្នកផ្សេងទៀតដូចជាស្ត្រីចំណាស់ម្នាក់នៅឯភូមិចាមមួយក្នុងខេត្តកំពតសម្អាងទៅលើមាគ៌ាសាសនាដោយនិយាយរៀបរាប់ថា «បើអ្នកប្រល័យជីវិតគេ អ្នកនឹងជំពាក់ជីវិតខ្លួនឯងទៅអ្នកនោះ ប៉ុន្តែអ្នកខ្លះបានប្រល័យជីវិតមនុស្សច្រើនណាស់...» ក្រោយមកខ្ញុំឆ្ងះបញ្ជាំងឃើញថា មនុស្សផ្សេងទៀតនៅក្នុងសហគមន៍ចាមដែលខ្ញុំបានជួបក៏មានទស្សនៈស្រដៀងគ្នានេះដែរ ។

សមត្ថភាពក្នុងការអភ័យទោសគឺជាគុណសម្បត្តិផងនិងភាពជាសប្បុរស និងការអត់ធ្មត់ផង ។ ចំណុចទាំងបីនេះជាអ្វីដែលមនុស្សម្នាក់ៗចង់បានយ៉ាងខ្លាំង ហើយចំណុចនេះក៏គួរតែយកមកអនុវត្តជាទូទៅផងដែរ ប៉ុន្តែកាលៈទេសៈតែងតែមិនអនុញ្ញាតឲ្យគាត់ធ្វើបាននោះទេ ។ គ្មានបទដ្ឋាន គោលបំណងច្បាស់លាស់ក្នុងការអភ័យទោសទេ ហើយការអភ័យទោសនេះក៏មិនអាចវិនិច្ឆ័យបានដែរ ព្រោះនេះជារឿងផ្ទាល់ខ្លួនដែលដក់ជាប់ក្នុងចិត្តយ៉ាងជ្រៅ ។ ទោះជាយ៉ាងណា សញ្ញាណនៃការលើកលែងទោសរបស់មនុស្សម្នាក់ដែលបានរស់នៅក្នុងទីកន្លែងដែលមានលក្ខណៈសុខស្រួលគឺមានភាពខុសប្លែកពីមនុស្សម្នាក់ទៀតដែលរស់នៅទីកន្លែងដែលទទួលរងនូវវិបត្តិក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ មានតែអ្នកដែលជួបនូវបទពិសោធន៍ឈឺចាប់ទេដែលបានយកជំនឿមកអនុវត្តផ្ទាល់ហើយ ក្នុងនោះគឺប្រជាជនកម្ពុជានៅក្នុងខេត្តកំពតនិងកំពង់ឆ្នាំងនេះឯង ។ តើពុទ្ធសាសនិក អ្នកកាន់សាសនាឥស្លាម ឬសាសនាអ្វីផ្សេងទៀតហាក់បីដូចជាមានភាពប្រេះស្រាំនៅក្នុងប្រព័ន្ធជំនឿរបស់ខ្លួនដែលការឈឺចាប់និងអសមត្ថភាពរបស់ខ្លួនក្នុងការអភ័យទោសត្រូវបានដ្អឹបទុក ។

នៅឯពិធីប្រជុំដែលខ្ញុំបានចូលរួម អ្នកចូលរួមទាំងអស់មើលទៅដូចជាមានការអៀនខ្មាសយ៉ាងខ្លាំង ។ នៅក្នុងខេត្តកំពត អ្នកដែលកាន់ក្បាលមេក្រូបាននិយាយបង្ហាញនូវភាពរីករាយដែលគាត់បានខិតខំប្រឹងប្រែងដើម្បីនាំយកអ្នកដែលធ្លាប់ធ្វើទុកបុកម្នេញគាត់ទៅកាន់យុត្តិធម៌ ។ អ្នកភូមិទាំងនោះនិយាយថា គ្មានផ្លូវណាអាចយកគ្រួសាររបស់ខ្លួនដែលបានបាត់បង់ហើយនោះមកវិញបានទេ ហើយក៏មិនអាចលុបលាងនូវអ្វីដែលគាត់ធ្លាប់ទទួលរងបានដែរ ប៉ុន្តែការនាំយកជនដៃដល់ទៅកាត់ទោសគឺត្រូវតែជាចំណុចចាប់ផ្តើមដែលមិនអាចចៀសផុតប៉ុណ្ណោះ ។ ក្រោយពេលសួរទៅកាន់អ្នកភូមិឲ្យបញ្ចេញយោបល់អំពីបទពិសោធន៍របស់គាត់ អ្នកភូមិពីរឬបីនាក់ចង់និយាយយ៉ាងខ្លាំង ។

ស្ត្រីម្នាក់អង្គុយនិងស្តាប់យ៉ាងយកចិត្តទុកដាក់ស្តាប់រាល់ពាក្យពេចន៍ទាំងអស់របស់ដំណើរការតុលាការ ហើយគាត់បានយកក្បាលមេក្រូ និងបាននិយាយពេលដែលគាត់មានឱកាស ។ គាត់បានប្រាប់យើងអំពីការស្លាប់នៃគ្រួសាររបស់គាត់ ហើយគាត់បានរៀបរាប់ថា គាត់គឺជាមនុស្សតែម្នាក់គត់នៅក្នុងគ្រួសារដែលបានរស់រានមានជីវិត ។ កិច្ចប្រជុំក្រោយមកទៀតក្នុងថ្ងៃដដែលមានបុរសចំណាស់ម្នាក់ដែលអង្គុយចាំស្តាប់រាល់ការពិភាក្សារហូតមកបានឡើងនិយាយអំពីអ្វីដែលគាត់ត្រូវបានបង្ខំឲ្យហូបសាច់ជ្រូក ព្រោះខ្មែរក្រហមដឹងថា នេះជាការរំលោភបំពានវិន័យសាសនា ហើយគាត់បានរៀបរាប់ទៀតថា គាត់ត្រូវខ្មែរក្រហមទុកជីវិតដោយសារតែគាត់បានធ្វើការយ៉ាងខ្លាំង ហើយអ្នកផ្សេងទៀតត្រូវបានសម្លាប់ទាំងអស់ ។

## ច្បាប់ និងការដាក់ទោស

ពេលខ្លះ នៅពេលដែលខ្ញុំអង្គុយនៅលើកម្រាលថ្ម ហើយភ្នែកសម្លឹងទៅរកប្រជាជនទាំងនោះ ខ្ញុំនឹកភ្នកឃើញថា សមត្ថភាពក្នុងការអភ័យទោសគឺជាកត្តាដ៏សំខាន់ ហើយទ្រឹស្តីសាសនាជាច្រើនបានរៀបរាប់អំពីគុណសម្បត្តិនៃការអភ័យទោសនេះ ចុះហេតុអ្វីបានជាអ្នករួចរស់ជីវិតទាំងនេះមិនអាចរំសាយកំហឹងរបស់ខ្លួនបាន? ការដែលមិនអភ័យទោសគឺជាសិទ្ធិរបស់មនុស្សម្នាក់ៗ ។ សាមសិបឆ្នាំបន្ទាប់ពីសម័យខ្មែរក្រហមបានបញ្ចប់ ជនដៃដល់ជាច្រើននាក់បានស្លាប់បាត់បង់ជីវិត ហើយជនជាប់ចោទត្រឹមតែប្រាំនាក់ប៉ុណ្ណោះដែលកំពុងត្រូវបានយកមកកាត់ទោសក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិមួយ ។ ការដាក់ទោសតែមួយគត់ដែលជនរងគ្រោះជាច្រើនចង់បានចំពោះអ្នកដែលធ្លាប់ធ្វើទុក្ខបុកម្នេញមកលើខ្លួនគឺនៅតែរក្សាទុកនូវកំហឹងនិងជម្រើសក្នុងការមិន

អភ័យទោស ។

ខ្ញុំចង់ដឹងយ៉ាងខ្លាំងថាតើជនរងគ្រោះប៉ុន្មាននាក់ដែលគិតថា ការបង្កើតអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជាថាជាការសងសឹក ។ ជនរងគ្រោះខ្លះដែលមិនសូវមានចំណាប់អារម្មណ៍ជាមួយនឹងតុលាការមានគំនិតដូច្នេះ ព្រោះគាត់គ្មានចង់បានការសងសឹកទៀតទេ ហើយអ្នកខ្លះទៀតបានសម្តែងនូវការគាំទ្រដល់ដំណើរការសាលាក្តីនេះដោយផ្ទាល់ ។ នៅក្នុងប្រទេសដែលប្រព័ន្ធច្បាប់មានការអភិវឌ្ឍច្រើន ច្បាប់មិនត្រូវបានគេមើលឃើញបែបនេះទេ ។ ច្បាប់គឺពិតជាដូចទៅនឹងអ្វីដែលទើបតែរៀបរាប់ខាងលើនេះ ហើយវាមានលក្ខណៈដាច់ស្រឡះពីឆន្ទៈរបស់ប្រជាជន ។ ឧក្រិដ្ឋជនត្រូវតែដាក់ទណ្ឌកម្មចំពោះទង្វើរបស់ខ្លួនមិនមែនដោយសារបំណងប្រាថ្នារបស់ជនរងគ្រោះក្នុងការដាក់ទោសទេ ពីព្រោះសង្គមយល់ឃើញថាត្រូវតែធ្វើដូច្នេះ ។ ការមើលទៅលើផ្លូវច្បាប់ក្នុងគោលបំណងបែបនេះ និងក្នុងលក្ខណៈគ្មានសមានចិត្ត អាចធ្វើឲ្យការអភ័យទោសមានភាពងាយស្រួល ព្រោះមិនចាំបាច់ត្រូវការចង់បាន



ការឡើងសួរសំណួររបស់ហាគិម-ទូន ក្នុងខេត្តកំពត

ការសងសឹកទេ ។ ទង្វើខុសឆ្គងត្រូវបានទទួលស្គាល់និងដាក់ទណ្ឌកម្មដោយស្វ័យប្រវត្តិ ដោយទុកឲ្យជនរងគ្រោះនូវសេរីភាពក្នុងការជ្រើសរើសថាតើត្រូវអភ័យទោសឬអត់? នៅក្នុងករណីដូចជាប្រទេសកម្ពុជាដែលជនដៃដល់ភាគច្រើនមិនត្រូវបានដាក់ទណ្ឌកម្មជម្រើសបែបនេះមិនដូចគ្នាទេ ។ ព្រោះប្រជាជនទាំងនេះមិនដែលទទួលបាននូវយុត្តិធម៌ពីសង្គមសោះមកទល់ពេលនេះ មនុស្សនឹងយល់ថា កំហឹងគឺជាវិធីតែមួយគត់ដែលជនដៃដល់ត្រូវតែទទួល ។ បើសិនជាគ្មានកំហឹងចំពោះជនដៃដល់ទេ នោះគឺជាឧក្រិដ្ឋកម្មតែមួយគត់ដែលមិនមានលទ្ធផល ។

## ទស្សនៈនៃការលើកលែងទោស

ទ្រឹស្តីនៃការលើកលែងទោសមានអត្ថន័យស្រពេចស្រពិលណាស់ ជាពិសេសគឺវាមាននិយមន័យលើសពីមួយ ។ លោក ប៊ីស៊ប ចូសិប បាតល័រ បានពិពណ៌នាអំពីការលើកលែងទោសនេះថាជាការបញ្ឈប់ចំណង់សងសឹក និងលះបង់កំហឹងរបស់ជនរងគ្រោះ ។ ទស្សនៈនៃការការលើកលែងទោសនេះ ជំរុញឲ្យមានការយល់ឃើញបែបឯកតោភាគីមួយ ដែលតម្រូវមិនឲ្យមានការប្រឆាំងគ្នារវាងជនដៃដល់ និងជនរងគ្រោះ ដោយឲ្យមនុស្សគ្រប់រូបទទួលយកនូវធម៌ព្រះពុទ្ធដែលមិនឲ្យមនុស្សប្រព្រឹត្តអំពើបាបដោយការបញ្ចេញកំហឹង ។ សាស្ត្រាចារ្យ ឆាល ហ្គ្រីសវូល បានប្រានចោលទស្សនៈមួយនេះដោយអះអាងថាជនរងគ្រោះមិនបានបញ្ចេញពីអារម្មណ៍ពិតរបស់ខ្លួន តែបែរជាកប់វាចោលទៅវិញ ។

នៅក្នុងទស្សនៈរបស់សាស្ត្រាចារ្យ ឆាល ហ្គ្រីសវូល ដំណើរការនៃការលើកលែងទោសគឺទាមទារឲ្យមានច្រើនជាងអន្តរកាលរវាងជនដៃដល់ និងជនរងគ្រោះទៅទៀត ។ ការលើកលែងទោសរបស់បុគ្គលម្នាក់ៗ គឺទាមទារឲ្យបុគ្គលម្នាក់នោះមើលឃើញពីភ័ស្តុតាងនៃបំណងរបស់អ្នកបង្កស្នាមរបួសក្នុងការស្វែងយល់ពីការឈឺចាប់របស់ជនរងគ្រោះ ជាពិសេសគឺត្រូវទទួលស្គាល់សកម្មភាពរបស់ខ្លួនដែលបង្កឲ្យមានអន្តរាយកើតឡើងបែបនេះ ។ម្យ៉ាងទៀត ជនរងគ្រោះត្រូវមើលឃើញឲ្យច្បាស់ថា អ្នកបង្កស្នាមរបួសនោះបានទទួលខុសត្រូវរាល់ទង្វើរបស់ខ្លួនដោយប្រានចោលទង្វើអាក្រក់ទាំងនោះ ហើយនៅថ្ងៃមុខនឹងមិនប្រព្រឹត្តទង្វើអាក្រក់នោះម្តងទៀតឡើយ ។

ខ្ញុំយល់ឃើញថាទស្សនៈទីពីរនេះគឺមានលក្ខណៈលើសលប់ពិបាកនឹងឈានដល់ខ្លាំងណាស់ ដែលជាការរារាំងមួយមិនឲ្យអ្នកដែលនៅរស់រានមានជីវិតរពីរបបខ្មែរក្រហមធ្វើការលើកលែងទោសដល់អ្នកដែលធ្វើបាបខ្លួននោះទេ ។ នេះអាចនិយាយបានថាទស្សនៈរបស់លោក បាតល័រ ក្នុងការលះបង់កំហឹងចោលប្រហែលជាអាចក្លាយទៅជាប្រភេទនៃការលើកលែងទោសតែមួយគត់ដែលប្រជាជនកម្ពុជាអាចសម្រេចបាន ។ អ្នករស់រានមានជីវិតជាច្រើន គឺមិនបានស្គាល់ថាតើនរណាជាកម្មាភិបាល នរណាជាអ្នកបង្កគ្រោះថ្នាក់ដោយផ្ទាល់ ជាពិសេសភាគច្រើននៃកម្មាភិបាលជាន់ខ្ពស់របស់របបនេះសុទ្ធតែបានបាត់ខ្លួន ។ ទោះបីជាកម្មាភិបាលជាន់ខ្ពស់ទាំងនោះមិនបានបាត់ខ្លួនក៏ដោយចុះ ក៏អ្នកដែលធ្លាប់ខ្មែរក្រហមធ្វើបាបមិនអាចទទួលការសុំខមាទោសម្នាក់ម្តងៗបានដែរ ហើយចំពោះការសុំខមាទោសជារួមវិញ គឺមិនអាចក្លាយទៅជាថ្នាំបំបាត់ការឈឺចាប់ក្នុងការសម្រាលស្នាមរបួសដ៏ជ្រៅដែលធ្លាប់បង្កឡើងបានឡើយ ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់បាននិយាយថា «វាជាការងាយស្រួលណាស់ក្នុងការសុំខមាទោស តែក្រោយមកម្នាក់ហ្នឹងធ្វើអីចឹងដដែលទៀត» ។ ជាក់ស្តែង ភាពស្មោះត្រង់ក្នុងការសុំខមាទោស គឺជាកត្តាមួយសំខាន់ក្នុងការធ្វើឲ្យមានការទទួលយកការសុំខមាទោសនេះ តែសម្រាបជនរងគ្រោះវិញគឺមានអារម្មណ៍ស្ទាក់ស្ទើរក្នុងការជឿជាក់ ។ ដោយនិយាយបែបនេះការសុំខមាទោសតែមួយគត់ដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបាននោះគឺចេញពីអតីតមេគុកទួលស្លែង ឌុច ដែលថ្មីៗនេះកំពុងតែទទួលការកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ។ ឌុចទទួលខុសត្រូវចំពោះការធ្វើទារុណកម្មនិងសម្លាប់មនុស្សអស់ជាង ១០០០០ នាក់ រួមមាន បុរស នារី និងក្មេងៗ ហើយ ឌុច ក៏ជាមេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យដែលធ្វើការសុំខមាទោសចំពោះមុខជនរងគ្រោះ ។ នៅក្នុងអង្គប្រជុំដែលខ្ញុំបានចូលរួម អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតែងតែត្រូវបានសួរពីប្រតិកម្មរបស់ពួកគាត់ទាក់ទងនឹងការសុំខមាទោសនេះ ។ ទោះបីជាមានស្ត្រីម្នាក់បាននិយាយថាវាល្អដែរកាលដែលចេះទទួលកំហុស តែមានប្រជាជនខ្លះបានបដិសេធចំពោះការស្នើសុំរបស់ ឌុច នេះ ចំណែកអ្នកខ្លះទៀតនិយាយថា «*យ៉ាងហោចណាស់ក៏បើកទ្វារចំហសម្រាប់ការលើកលែងទោសដែរ*» ។

ខ្ញុំអាចយល់បានពីរបៀបនៃការស្នើសុំឲ្យមានការលើកលែងទោសនេះដែលមើលទៅមិនសមរម្យចំពោះជនរងគ្រោះមួយចំនួន ។ ពីព្រោះដូចថាពេលដែលយើងរឹបអូសអ្វីៗទាំងអស់ពីនរណាម្នាក់នោះគឺវាយឺតពេលទៅហើយក្នុងការស្នើសុំអ្វីមួយមកវិញ ។ អង្គភាពជនរងគ្រោះបានសាកសួរជនរងគ្រោះម្នាក់ៗពីការឆ្លើយតបរបស់ពួកគាត់ចំពោះការសុំខមាទោសរបស់ ឌុច ប៉ុន្តែទទួលបានការគាំទ្រតិចតួចណាស់ ។ ពិសិដ្ឋ មកពីខេត្តស្វាយរៀង ដែលបន្តនូវក្តីស្រមៃរបស់ប្រពន្ធគាត់ក្នុងការចូលរួមសវនាការរបស់ ឌុច បានអះអាងថា «*ខ្ញុំជឿជាក់ថាមនុស្សជាទូទៅ រួមទាំងខ្ញុំផងគឺមិនអាចអនុគ្រោះឲ្យ ឌុច បានទេ*» ។ សុភា មកពីខេត្តកំពង់ធំក៏យល់



ស្របដែរថា គាត់មិនអាចទទួលយកការសុំខមាទោសរបស់ ឌុច បានឡើយ «ទោះបីជាយ៉ាងណាក៏ដោយ» ។ ចំណែក សុផន មកពីខេត្តកំពង់ចាមវិញ នៅពេលដែលត្រូវបានសួរសំណួរមួយនេះ គាត់ក៏ឆ្លើយតបវិញថា ឌុច ប្រាកដជាមាន «សារជាតិឃោរឃៅខ្លាំងណាស់...ព្រោះតាមខ្ញុំជួបបទពិសោធន៍រស់នៅក្នុងសម័យនោះយល់ថាខ្មែរក្រហមទុកតែអ្នកណាដែលសាហាវឃោរឃៅឲ្យនៅរស់តែប៉ុណ្ណោះ» ។ ដូចនេះ សុផន «មិនអាចលើកលែងទោសឲ្យ ឌុច បានទេ ដោយសារតែទុក្ខវេទនាជាច្រើនដែលជនរងគ្រោះបានទទួលរង» ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់បានលើកឡើងពីចំណុចមួយដ៏គួរឲ្យភ្ញាក់ផ្អើលថា ការសុំខមាទោសរបស់ ឌុច គឺបានផ្តល់ជូនត្រឹមតែអ្នកដែលរងគ្រោះក្នុងមន្ទីរស-២១ ប៉ុណ្ណោះ «ចុះចំពោះពួកយើងវិញ?» ។

**សន្និដ្ឋាន**



ឆាំង យុ សួរប្រជាជនខ្មែរអ៊ីស្លាមអំពីដំណើរការតុលាការខ្មែរក្រហមនៅក្នុងខេត្តកំពត

ចំពោះប្រជាជនកម្ពុជាផ្សេងទៀត និងប្រជាជនដែលមិនទទួលយកការសុំខមាទោសរបស់ ឌុច បានសម្តែងឲ្យឃើញថាវាមើលទៅដូចជាយឺតពេលទៅហើយចំពោះការលើកលែងទោសនេះ ។ មុនពេលដែលខ្ញុំមកដល់ប្រទេសកម្ពុជា ខ្ញុំគិតថានឹងសួរនរណាម្នាក់ដើម្បីដឹងពីទស្សនៈរបស់គាត់ ប៉ុន្តែពេលខ្លះភាពវិសេសវិសាលគឺដូចជាភាពល្អប្រណីតមួយដែលមិនមែនមនុស្សគ្រប់រូបសុទ្ធតែអាចធ្វើទៅបាននោះទេ ដោយឡែកប្រជាជនទាំងអស់នេះវិញគឺបានបាត់បង់អ្វីៗទាំងអស់ ។ ប្រជាជនទាំងនេះមិនមែនគ្រាន់តែទទួលរងការឈឺចាប់កាលពី៣០ឆ្នាំមុនប៉ុណ្ណោះទេ ប៉ុន្តែពួកគាត់ទទួលរងការឈឺចាប់ជារៀងរាល់ថ្ងៃដោយសារពួកគាត់មិនអាចបំភ្លេចអតីតកាលបាន ។ ស្ត្រីម្នាក់ដែលធ្លាប់មានកូន៨នាក់ ហើយឥឡូវនេះសល់កូនតែម្នាក់គឺជាអ្នកនៅរស់ពីរបបខ្មែរក្រហម ហើយរស់នៅតែម្នាក់ឯងដោយសារតែប្តីរបស់គាត់ត្រូវបានយកទៅសម្លាប់ចោល និងបុរសពិការដៃជើងដោយសារតែការធ្វើទារុណកម្មដើម្បីបង្ខំឲ្យធ្វើការងារដែលទាំងអស់នេះគឺសុទ្ធតែជាឧទាហរណ៍ជាក់ស្តែង ។ តាមភ័ស្តុតាងទាំងនេះ អាចបញ្ជាក់បានថា ពេលវេលាមិនអាចព្យាបាលគ្រប់របួសស្នាមបាននោះទេ ។

ការលើកលែងទោសគឺជាជម្រើសមួយ ។ វាគឺជាការសម្រេចស្របច្បាប់នូវអ្វីដែលថាការបំពានក្រមសីលធម៌របស់សាសនានិងទស្សនវិជ្ជាដើម្បីសម្រេចចេញនូវអ្វីមួយឲ្យមានលក្ខណៈជាមនុស្សជាតិ ដូចជាការសម្រេចដើម្បីរួបរួមឲ្យមានភាពថ្លៃថ្នូររបស់បុគ្គលម្នាក់ៗដោយមិនពាក់ព័ន្ធនឹងការលើកលែងទោសអ្វីទៀតនោះទេ ។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមគឺមិនមែនចេះតែអន្តុយចងកំហឹងគ្រប់វិនាទីនោះទេ ហើយក៏មិនអាចចេះតែស្ងប់រាល់ថ្ងៃដែរ ។ ប៉ុន្តែកាលបើយើងទៅសួរគាត់ គាត់នឹងឆ្លើយប្រាប់អ្នកអំពីកំហឹងដែលគាត់មានចំពោះខ្មែរក្រហម ។ នេះគឺជាការពិតដែលនៅជិតជាមតាមគាត់ជាប់រហូតមក ។ នៅពេលដែលប្រជាជនទាំងនោះរស់នៅដោយអវត្តមានអ្នកជាទីស្រឡាញ់ និងការចងចាំដែលចេះតែនឹកឃើញដោយមិនបានព្រាងទុក ហើយការនឹកឃើញរឿងរ៉ាវឈឺចាប់នោះនៅជិតជាមយូរណាស់ ក្រោយពេលការជួបជុំបានបញ្ចប់ទៅហើយ ។ **ខាលី លីគួហ្គ**

# ទស្សនៈអន្តរជាតិទៅលើសោកនាដកម្មរបស់កម្ពុជា

នៅខែកុម្ភៈឆ្នាំមុន មេដឹកនាំខ្មែរក្រហមដែលបានសម្លាប់ប្រជាជនខ្លួនឯងអស់ចំនួន ១,៧លាននាក់ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ត្រូវបាននាំយកទៅកាត់ទោសនៅក្នុងតុលាការកម្ពុជាដែលមានជំនួយពីអង្គការសហប្រជាជាតិ ។ ហេតុអ្វីបានជាត្រូវចំណាយពេលយូរយ៉ាងនេះ គឺច្រើនជាង៣០ឆ្នាំដើម្បីនាំយកយុត្តិធម៌មកឲ្យកម្ពុជា? ចម្លើយអាចត្រូវបានរកឃើញតាមរយៈចលនានយោបាយអន្តរជាតិក្នុងអំឡុងសង្គ្រាមត្រជាក់ និងកិច្ចចរចាដែលចំណាយពេលយូរហួសពីការស្មានរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីបង្កើតតុលាការ ។ ក្នុងអំឡុងសង្គ្រាមត្រជាក់ ដោយយោងទៅតាមទីតាំងភូមិសាស្ត្រនយោបាយ ប្រទេសកម្ពុជាបានក្លាយជាឧបករណ៍សម្រាប់ទាមទារអំណាចនៅអាស៊ីអាគ្នេយ៍របស់ប្រទេសចិន សហភាពសូវៀត និងសហរដ្ឋអាមេរិក ។ ២០ឆ្នាំមុនពេលមានការចូលមកដល់នៃបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ កម្ពុជាបានជួបប្រទះនូវភាពវឹកវរចលាចល សង្គ្រាមស៊ីវិល អំពើប្រល័យពូជសាសន៍ និងការអស់សង្ឃឹម ។ រយៈកាលនោះអាចត្រូវបានបែងចែកជាបីដំណាក់កាលដែលក្នុងនោះមានអន្តរជាតិជាអ្នកដើរតួនាទីយ៉ាងសំខាន់ ។ ដំណាក់កាលទី១ ពីពាក់កណ្តាលចុងឆ្នាំ១៩៦០ រហូតដល់ឆ្នាំ១៩៧៥ ។ នៅដំណាក់កាលទី១ ព្រឹត្តិការណ៍ពីរបានជួយសម្រួលដល់ខ្មែរក្រហមដែលជាចលនាកុម្មុយនីស្តសម្ងាត់នៅក្នុងព្រៃឲ្យទទួលបានជ័យជម្នះដែលបានបំផ្លាញប្រទេសកម្ពុជា ។ ដោយសារភាពអព្យាក្រឹតរបស់សម្តេចព្រះនរោត្តម សីហនុ នៅក្នុងសង្គ្រាមត្រជាក់និងការសង្ស័យទៅលើភាគខាងកើតនៃប្រទេសកម្ពុជាថាបានជួយដល់កងទ័ពវៀតណាម ប្រធានាធិបតីនៃសហរដ្ឋអាមេរិក លោក រីឆាត នីកសុន និងហេនរី ឃីសស៊ីងជឺ ដែលជាទីប្រឹក្សាសន្តិសុខជាតិរបស់លោកបានធ្វើឲ្យមានការទម្លាក់គ្រាប់បែកនៅកម្ពុជាពីឆ្នាំ១៩៦៩ដល់ឆ្នាំ១៩៧៣ ។ ការទម្លាក់គ្រាប់បែកនៅកម្ពុជានៅពេលនោះគឺច្រើនជាងពេលដែលទម្លាក់នៅប្រទេសជប៉ុនក្នុងអំឡុងសង្គ្រាមលោកលើកទីពីរទៅទៀត ។ ព្រឹត្តិការណ៍ទី២ គឺសម្តេចព្រះនរោត្តម សីហនុ ត្រូវបានទម្លាក់ពីអំណាចដោយអ្នកស្តាំនិយមដែលគាំទ្រដោយសហរដ្ឋអាមេរិក គឺសេនាប្រមុខ លន់ នល់ ។ សម្តេចព្រះនរោត្តម សីហនុ បានភៀសព្រះកាយទៅប៉េកាំង ហើយចាប់ផ្តើមគាំទ្រ ប៉ុល ពត ដែលជាមេដឹកនាំខ្មែរក្រហម ។ ដោយមានជំនួយពីប៉េកាំង ប៉ុល ពត បានទម្លាក់ លន់ នល់ យ៉ាងឆាប់រហ័ស ហើយបានបង្កើតជារបបដ៏ឃោរឃៅមួយចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលនេះស្ទើរតែជារបបដ៏ឃោរឃៅជាងគេដែលមាននៅក្នុងប្រវត្តិសាស្ត្រសម័យទំនើប ។ របបដ៏សាហាវឃោរឃៅនេះបាននាំយកទុក្ខវេទនាដែលមិនធ្លាប់មានពីមុន ជាក់ស្តែងដូចជាធ្វើឲ្យទីក្រុងគ្មានមនុស្សនៅ ធ្វើទារុណកម្ម សម្លាប់អ្នកដែលមានចំណេះវិជ្ជា បង្កើតគោលនយោបាយដែលបង្កឲ្យមានការបង្អត់អាហារ ជំងឺ និងការសម្លាប់ប្រជាជនកម្ពុជា១,៧លាននាក់ ដែលប្រហាក់ប្រហែលនឹងមួយភាគបីនៃប្រជាជនសរុប ។ ដំណាក់កាលទី២នៃសោកនាដកម្មរបស់កម្ពុជាចាប់ផ្តើមពីថ្ងៃទី១ ខែមេសា ។ កុម្មុយនីស្តសម្ងាត់បានបង្កើនអំណាចយ៉ាងលឿន ហើយបានដណ្តើមយកអំណាចគ្រប់គ្រងប្រទេសកម្ពុជាពីសេនាប្រមុខ លន់ នល់ ដែលជាអ្នកស្តាំនិយម ។ អាស្រ័យហេតុនេះ អ្វីដែលលោក នីកសុន និង ឃីសស៊ីងជឺ បានធ្វើ និងអ្វីដែលធ្វើឡើងដើម្បីជាជំនួយដល់សម្តេចព្រះនរោត្តម សីហនុ បានធ្វើឲ្យ ប៉ុល ពត ឡើងកាន់អំណាចទាំងស្រុង ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានបណ្តេញខ្មែរក្រហម ហើយបណ្តេញមេដឹកនាំនៃរបបនោះនិងអ្នកនៅក្រោមបង្គាប់ឲ្យទៅព្រំដែនថៃ ។ រដ្ឋាភិបាលថ្មីដែលមានឈ្មោះថាសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានបង្កើតឡើង ។ រដ្ឋាភិបាលថ្មីនេះបានបង្កើនអំណាច ដែលមិនមានការទទួលស្គាល់តាមផ្លូវច្បាប់ ។ ជាអកុសល មហាសន្និបាតដែលដឹកនាំដោយសហរដ្ឋ

អាមេរិកនិងចិន បានចេញសេចក្ដីសម្រេចសម្រាប់រយៈពេល១១ឆ្នាំពីឆ្នាំ១៩៧៩-១៩៩១ ដោយទទួលស្គាល់របបខ្មែរក្រហមដ៏ឃោរឃៅថាជារដ្ឋាភិបាលស្របច្បាប់ ហើយបដិសេធមិនទទួលស្គាល់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ដំណាក់កាលទីបីនៃសោកនាដកម្មគឺប្រទេសកម្ពុជាត្រូវបានអនុម័តហាមឃាត់មិនឲ្យមានជំនួយ ខណៈពេលដែលខ្មែរក្រហមដែលនៅក្នុងព្រៃបានទទួលការគាំទ្រពីប្រទេសចិន និងប្រទេសលោកខាងលិចដែលនេះធ្វើឲ្យប្រជាជនកម្ពុជាទទួលរងនូវទុក្ខវេទនាអស់រយៈពេល១១ឆ្នាំបន្ថែម ។

រដ្ឋាភិបាលដែលមិនមានការទទួលស្គាល់ដោយច្បាប់ត្រូវបានបង្កើតឡើងបន្ទាប់ពីវៀតណាមបានបញ្ចប់ការកាប់សម្លាប់ដោយផ្ដួលរំលំរបបខ្មែរក្រហម នេះគឺជាការរៀបចំដែលអាចបន្ថយភាពវឹកវរនៅក្នុងប្រទេស ។ ទោះបីជារបបថ្មីរបស់ប្រទេសកម្ពុជាបានសម្រេចនាំយកមេដឹកនាំខ្មែរក្រហមដែលនៅរស់ទៅកាត់ទោសក៏ដោយ ក៏ដំណើរការនេះត្រូវបានពន្យារពេលដោយសារតែជម្លោះនយោបាយទៅលើអធិបតេយ្យភាពនិងយុត្តិធម៌អន្តរជាតិរួមទាំងការលំបាកក្នុងការផ្ដល់ថវិកា ។ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ គឺ៣០ឆ្នាំបន្ទាប់ពីរបបខ្មែរក្រហមដ៏ឃោរឃៅបានដួលរលំ ហើយ១២ឆ្នាំបន្ទាប់ពីមានការអនុម័តឲ្យបង្កើតតុលាការពិសេសអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលបង្កើតឡើងដោយអង្គការសហប្រជាជាតិចាប់ផ្ដើមសវនាការកាត់ទោសជនដែលសំខាន់ៗដែលបានសម្លាប់រង្គាលប្រជាជនកម្ពុជា ។

អ្នកនិពន្ធ និងអតីតមន្ត្រីនៅអង្គការសហប្រជាជាតិ លោក ប៊ែននី វីយ៉ូណូ បានអះអាងថាតុលាការត្រូវតែបង្ហាញពីការទទួលស្គាល់ដោយត្រង់ថាអ្នកដែលមានអំណាចសំខាន់ៗធ្លាប់បានបដិសេធមិនផ្ដល់យុត្តិធម៌ដល់ប្រទេសកម្ពុជាជាយូរណាស់មកហើយ ។ មានការសង្ឃឹមទុកមុនថា តុលាការដែលប្រជាជនបានរង់ចាំជាយូរណាស់មកហើយនឹងចាប់ផ្ដើមដំណើរការព្យាបាលនិងផ្សះផ្សាជាតិដែលតម្រូវឲ្យមានការចូលរួមយ៉ាងពេញទំហឹងពីក្នុងនិងក្រៅប្រទេស ។

តាមការពិត បញ្ហារបស់តុលាការដែលនឹងកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់ ដែលមានការគាំទ្រដោយអង្គការសហប្រជាជាតិ ហើយដែលនឹងបានចាប់ផ្ដើមដំណើរការនៅភ្នំពេញគឺតុលាការនេះកាត់ទោសតែអ្នកសម្លាប់បុណ្ណោះប៉ុន្តែមិនកាត់ទោសអ្នករួមគំនិតទេ ។ អំពើហួសហេតុ ដែលកើតមាននៅប្រទេសកម្ពុជាចែកចេញជាបីដំណាក់ ។ ប៉ុល ពត ទំនងជាមិនមានអំណាចប្រសិនបើ មិនមាន ឃីស ស៊ីងជី ប៉ុន្តែ ឃីស ស៊ីងជី នឹងមិនមកអង្គុយនៅកន្លែងក្របកសេះនៅក្នុងសវនាការនោះទេ ។ ឃីស ស៊ីងជី កំពុងតែណែនាំលោកប្រធានាធិបតី អូបាម៉ា អំពីភូមិសាស្ត្រនយោបាយ ។ មិនថា ម៉ាហ្គារ៉េត ថាច់ឆឺ ឬអតីតមន្ត្រី និងមន្ត្រីជាន់ខ្ពស់របស់លោកស្រីមួយចំនួនដែលគាំទ្រខ្មែរក្រហមដោយសម្ងាត់បន្ទាប់ពីវៀតណាមបានផ្ដួលរំលំរបបនោះ មិនមែនជាអ្នកដែលចូលរួមចំណែកបង្កើតដំណាក់កាលទី៣នៃអំពើហួសហេតុនៅកម្ពុជានេះទេ ។ នៅឆ្នាំ១៩៧៩ រដ្ឋាភិបាលអង់គ្លេសនិងសហរដ្ឋអាមេរិកបានដាក់ការហាមឃាត់ទៅលើប្រទេសកម្ពុជាដោយសារតែវៀតណាមដែលជាអ្នករំដោះប្រទេសកម្ពុជាបានចូលរួមក្នុងភាគីខុសនៅពេលសង្គ្រាមត្រជាក់ ។ យុទ្ធនាការរបស់ការិយាល័យបរទេសមួយចំនួនមានលក្ខណៈអាក្រក់ ឬសាហាវឃោរឃៅ ។ នៅអង្គការសហប្រជាជាតិ អង់គ្លេសបានទាមទារឲ្យរបប ប៉ុល ពត ដែលបានដួលរលំនៅបន្តមាន «សិទ្ធិ» តំណាងឲ្យជនរងគ្រោះកម្ពុជានៅអង្គការសហប្រជាជាតិ ហើយបានបោះឆ្នោតគាំទ្រ ប៉ុល ពត នៅទីភ្នាក់ងារអង្គការសហប្រជាជាតិដែលរួមមានវត្តមានរបស់អង្គការសុខភាពពិភពលោក ដោយហេតុនេះទើបធ្វើឲ្យមានការរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍នៅក្នុងស្រុករបស់ប្រទេសកម្ពុជា ។

ដើម្បីដើរតួធ្វើជាល្អវិញ អង់គ្លេស សហរដ្ឋអាមេរិក ចិន និងអ្នកគាំទ្រ ប៉ុល ពត បានបង្កើតសម្ព័ន្ធ «មិនមែនកុម្មុយនីស្ត» មួយនៅក្រៅប្រទេស ដែលតាមការពិតអ្នកទាំងនេះមានអំណាចដោយសារតែខ្មែរក្រហម ។ នៅប្រទេសថៃ សេ.អ៊ី.អា និងភ្នាក់ងារការពារសម្ងាត់បានបង្កើតទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងខ្មែរក្រហម ។ នៅឆ្នាំ១៩៨៣ រដ្ឋាភិបាលរបស់ ថាច់ឆឺ បានបញ្ជូនក្រុម SAS ឲ្យមកបណ្ដុះបណ្ដាល «សម្ព័ន្ធ» នោះអំពីបច្ចេកមីនទៅឲ្យប្រទេសមួយដែលមានមីនច្រើនជាងគេនៅលើពិភពលោកលើកលែងតែប្រទេសអាហ្វហ្គានីស្ថាន ។ ថាច់ឆឺ បានសរសេរលិខិតមួយទៅ នេល គីនណុក មេដឹកនាំគណៈបក្សប្រឆាំងថា រដ្ឋាភិបាលអង់គ្លេសមិនមានជាប់ពាក់ព័ន្ធនឹងការបណ្ដុះបណ្ដាលដែលមានការផ្ដល់សម្ភារៈឬ

សហការជាមួយកងទ័ពខ្មែរក្រហមអ្វីឡើយ ។ ការនិយាយមិនពិតនេះពិតជាអស្ចារ្យណាស់ ។ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩១ រដ្ឋាភិបាលនេះត្រូវបានបង្ខំឲ្យសារភាពនៅក្នុងសភាថា ក្រុម SAS បានធ្វើការបណ្តុះបណ្តាល «សម្ព័ន្ធ» ដោយសម្ងាត់ ។ ប្រសិនបើចង់ឲ្យមានយុត្តិធម៌អន្តរជាតិ អ្នកដែលធ្លាប់គាំទ្ររបប ប៉ុល ពត គួរតែត្រូវបានកោះហៅឲ្យទៅតុលាការនៅភ្នំពេញ យ៉ាងហោចណាស់ក៏មានឈ្មោះរបស់អ្នកទាំងនោះនៅក្នុងបញ្ជីដែរ ។

នៅប្រទេសកម្ពុជា ចលនាការទូតនៃសង្គ្រាមត្រជាក់បានបោសសម្អាតរបបខ្មែរក្រហមដែលសាហាវឃោរឃៅ ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមនិងអ្នកដែលចាកចេញពីខ្មែរក្រហមបានបញ្ចប់របបខ្មែរក្រហម ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាដែលនឹងបង្កើនអំណាចនៅក្នុងប្រទេសទៅដល់ទៅ៩០ ភាគរយត្រូវបានបង្កើតឡើង ។

ខណៈពេលដែលបញ្ហាត្រូវបានបញ្ជូនទៅញូវយ៉ក សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិដែលដឹកនាំដោយសហរដ្ឋអាមេរិក និងចិន បានផ្តល់អាសនៈរបស់ប្រទេសកម្ពុជាដែលមាននៅមហាសន្និបាតទៅឲ្យរបបឃោរឃៅខ្មែរក្រហម ។ រដ្ឋាភិបាលពិតប្រាកដនៅភ្នំពេញ ដែលបានបញ្ចប់ការសម្លាប់បែរជាក្លាយទៅជាអ្នកដែលអន្តរជាតិមិនចូលចិត្ត ។ ខ្មែរក្រហមដ៏អាក្រក់ដែលជាអ្នកតំណាងកម្ពុជានៅអង្គការសហប្រជាជាតិនេះនៅតែបន្ត១១ ឆ្នាំបន្ថែមទៀត ដែលធ្វើឲ្យប្រជាជនកម្ពុជានៅតែរងទុក្ខវេទនា ។ ការនាំយកមេដឹកនាំខ្មែរក្រហមទៅកាត់ទោសនៅទសវត្សរ៍៨០ មិនមានការចាប់អារម្មណ៍ពីប្រទេសដែលមានអំណាចទេ ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាបានកាត់ទោសមេដឹកនាំខ្មែរក្រហម ប៉ុល ពត និង អៀង សារី ប៉ុន្តែមានតែប្រទេសមួយចំនួនប៉ុណ្ណោះដែលចាប់អារម្មណ៍ ។

ជាទីបញ្ចប់ ការចូលរួមរបស់អន្តរជាតិក្នុងការដោះស្រាយបញ្ហានៅកម្ពុជាត្រូវបានបង្កើតឡើង តាមរយៈការខបត្ថម្ភគាំទ្រដោយអង្គការសហប្រជាជាតិទៅលើការបោះឆ្នោត នៅខែឧសភា ឆ្នាំ១៩៩៣ ព្រមទាំងការបង្កើតរដ្ឋាភិបាលថ្មីដែលជារាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាដឹកនាំដោយនាយករដ្ឋមន្ត្រីពីររូប គឺព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ និង ហ៊ុន សែន ។ នៅខែមិថុនា ឆ្នាំ១៩៩៧ បន្ទាប់ពីការផ្តល់យោបល់ដ៏រឹងមាំមួយរបស់ ថូម៉ាស ហេមម៉ាប៊ឺក ដែលជាអ្នកតំណាងពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការសិទ្ធិមនុស្សនៅកម្ពុជា សហនាយរដ្ឋមន្ត្រីបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីនាំយកមេដឹកនាំខ្មែរក្រហមទៅកាត់ទោស ។ ក្រុមអ្នកជំនាញអង្គការសហប្រជាជាតិបានផ្តល់យោបល់ឲ្យបង្កើតតុលាការកូនកាត់ ដូចជាតុលាការនៅសេរ៉ាឡេអូន ។ បន្ទាប់ពីការទាស់ទែងគ្នានៅខែកក្កដា ឆ្នាំ១៩៩៧ រដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយនាយករដ្ឋមន្ត្រីតែមួយគឺលោក ហ៊ុន សែន បានបដិសេធយ៉ាងរហ័សទៅនឹងគំនិតនោះ ហើយស្នើឲ្យបង្កើតតុលាការកម្ពុជាដែលមានជំនួយពីអន្តរជាតិ ។

យើងអាចសន្និដ្ឋានថា រដ្ឋាភិបាលភ័យខ្លាចថាចរិតលក្ខណៈរបស់អង្គការសហប្រជាជាតិ អ្នកផ្តល់ជំនួយ និងអង្គការសិទ្ធិមនុស្សអាចពង្រីកវិសាលភាពរបស់តុលាការដោយធ្វើការកាត់ទោសជនដៃដល់បន្ថែមដែលក្នុងនោះរួមមានអតីតអតីតកម្មាភិបាលខ្មែរក្រហមដែលបច្ចុប្បន្នកំពុងធ្វើការបម្រើរដ្ឋាភិបាល ខណៈពេលដែលកម្ពុជាកំណត់ថានឹងកាត់ទោសមេដឹកនាំជាន់ខ្ពស់តែ៥នាក់ប៉ុណ្ណោះ ។ ការព្រួយបារម្ភរបស់កម្ពុជាគឺផ្អែកទៅតាមគោលការណ៍ មិនមែនផ្អែកទៅលើការកំណត់ចំនួនមនុស្សដែលត្រូវកាត់ទោសនោះទេ ពីព្រោះរដ្ឋាភិបាលព្រួយបារម្ភថាការកាត់ទោសមនុស្សបន្ថែមអាចបណ្តាលឲ្យមានអស្ថិរភាព ។ ការព្រួយបារម្ភរបស់កម្ពុជាហាក់ដូចជាពិត ពីព្រោះនៅឆ្នាំ២០០៨ថ្មីៗនេះ យ៉ាសហ្គាយ អ្នកតំណាងអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការសិទ្ធិមនុស្សបានអះអាងនៅក្នុងរបាយការណ៍ខែមីនា ឆ្នាំ២០០៨ ដើម្បីផ្ញើទៅក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិថា «នឹងមានការសោកល្បែងពិតនៅពេលដែលជនសង្ស័យដែលមានការជាប់ពាក់ព័ន្ធនឹងរដ្ឋាភិបាលត្រូវបានស៊ើបអង្កេត ហើយបញ្ជូនទៅអង្គជំនុំជម្រះមុនពេលសវនាការ» ។

ការគ្រប់គ្រងទៅលើតុលាការគឺជាបញ្ហាសំខាន់ដែលរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិតែងតែមានយោបល់ខុសគ្នា ។ វាមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេកាលដែលការចរចាត្រូវចំណាយពេលវេលាយូរជាងការស្មាន និងមានការមិនយល់ស្របគ្នាជាច្រើនរហូតដល់ផ្អាកការចរចានៅខែកុម្ភៈ ឆ្នាំ២០០២ ដែល

អង្គការសហប្រជាជាតិជាអ្នកដកខ្លួនចេញ ។ ភាពយឺតយ៉ាវនៃដំណើរការចរចាជាមួយអង្គការសហប្រជាជាតិរបស់រដ្ឋាភិបាលបានធ្វើឲ្យទំនាក់ទំនងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន និងចិនដែលជាអតីតអ្នកគាំទ្រខ្មែរក្រហមកាន់តែប្រសើរឡើង ។ នៅខែមិថុនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អង្គជំនុំជម្រះចាប់ផ្ដើមដំណើរការនៅឆ្នាំ ២០០៦ ។

ចាប់តាំងពីពេលនោះមក តុលាការបានសម្រេចនូវជោគជ័យជាច្រើនរួមទាំងការចាប់ខ្លួនមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់ និងមានការចូលរួមរបស់ចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិ ។ មានគេកោតសរសើរជាខ្លាំងទៅលើការបង្កើតអង្គភាពបន្ថែមមួយដែលធ្វើឲ្យជនរងគ្រោះអាចចូលរួមនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះ ។ នៅខែកក្កដា ឆ្នាំ២០០៨ មានការប្រកាសថាសវនាការលើកដំបូងនឹងចាប់ផ្ដើមនៅខែកញ្ញា ។ ប៉ុន្តែនៅទីបញ្ចប់ វាត្រូវចំណាយពេល៨ខែបន្ថែមទៀត ។ អ្នកគាំទ្រតុលាកាបានអះអាងថាតុលាការអាចជាឧបករណ៍មួយសម្រាប់ធ្វើឲ្យប្រព័ន្ធតុលាការនៅក្នុងប្រទេសដែលត្រូវបានកម្ទេចដោយសង្គ្រាម ការផ្លាស់ប្ដូរនយោបាយ ការគ្រប់គ្រងនិងការរំខានដល់នយោបាយប្រសើរឡើង ។

ចំពោះចំណុចអវិជ្ជមាន គឺការខ្វះខាតឯករាជ្យភាពនិងចៅក្រមកម្ពុជាដែលទទួលការបណ្ដុះបណ្ដាល ការចោទប្រកាន់អំពីអំពើពុករលួយ និងបញ្ហាការរៀបចំថវិកាបានរំខានដល់ដំណើរការហើយជាក់ស្ដែង ការចរចាដែលចំណាយពេលយូរហួសពីការស្មាននៅតែបន្តក្នុងអំឡុងពេលអនុវត្តន៍កិច្ចព្រមព្រៀង ។ ជាក់ស្ដែងនៅខែកុម្ភៈឆ្នាំ២០០៩ ព្រះរាជអាជ្ញាអន្តរជាតិនៅតែបន្តអះអាងថាគួរតែធ្វើការកាត់ទោសជនត្រូវចោទបន្ថែម ខណៈពេលដែលព្រះរាជអាជ្ញាកម្ពុជាអះអាងថាកាត់ទោសមេដឹកនាំតែ៥នាក់គឺគ្រប់គ្រាន់ហើយ ។

ខណៈពេលដែលតុលាការទទួលថវិកាពីអ្នកផ្ដល់វិភាគទានស្ម័គ្រចិត្ត ម្ចាស់ជំនួយជាបុគ្គលអាចមានឥទ្ធិពលដល់ដំណើរការនេះ ។ ប្រទេសម្ចាស់ជំនួយមានការព្រួយបារម្ភនៅពេលដែលមានការចោទប្រកាន់អំពើពុករលួយនៅតុលាការ ។ មានការផ្ដល់របាយការណ៍ថាសហរដ្ឋអាមេរិកដែលមិនទាន់បានផ្ដល់វិភាគទានដល់តុលាការហើយប្រហែលជាប្រទេសផ្សេងទៀតចង់ឲ្យតុលាការមានអ្នកគ្រប់គ្រងម្នាក់ដែលមានចរិតលក្ខណៈជាអន្តរជាតិគ្រប់គ្រងទៅលើប្រធានរដ្ឋបាលកម្ពុជានិងអនុប្រធានអន្តរជាតិ ។

ដើម្បីធ្វើឲ្យម្ចាស់ជំនួយពេញចិត្ត តុលាការបានបង្កើតការណាត់ជួបមួយនៅខែមិថុនា ដែលក្នុងនោះរួមមាន ដេវីដ ថូបឺត ព្រះរាជអាជ្ញានៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលត្រូវបានឲ្យនាមថាជាអ្នកជំនាញសម្រាប់អគ្គលេខាធិការអង្គការសហប្រជាជាតិដែលមានអំណាចពិសេសទៅលើការត្រួតពិនិត្យថវិកា ។ នុត រ៉ូសេនហូក អ្នកដែលធ្លាប់ធ្វើការនៅក្នុងបេសកកម្មនៅកូសូវ៉ូ របស់អង្គការសហប្រជាជាតិបានគ្រប់គ្រងតំណែងរបស់ មីសែល លី ដែលជាអ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិនិងជាអនុប្រធានរដ្ឋបាលនៅតុលាការ ។ មានប្រភពមកពីអង្គការសហប្រជាជាតិថា លោកស្រី មីសែល លី ដែលមានសញ្ជាតិចិន មិនមានភាពតឹងរ៉ឹងទៅលើបុគ្គលិកកម្ពុជាទេ ។ យើងនឹងមើលថាតើគុណភាពនៃអំណាចថ្មីនឹងធ្វើប្រតិបត្តិការជារៀងរាល់ថ្ងៃទៅលើដំណើរការរបស់តុលាការយ៉ាងដូចម្ដេច? នៅចុងឆ្នាំ២០០៨ មានការស៊ើបអង្កេតទៅលើអំពើពុករលួយនៅតុលាការ ប៉ុន្តែអ្វីដែលគេរកឃើញមិនទាន់បានបោះពុម្ពផ្សាយនៅឡើយទេ ។

ទោះបីជាការបង្កើតតុលាការមានសភាពយឺតយ៉ាវ ប៉ុន្តែវានៅតែមានសារសំខាន់សម្រាប់ដំណើរការព្យាបាលនិងផ្សះផ្សាជាតិដែលប្រជាជនបានរង់ចាំជាយូរណាស់មកហើយ ។ ដំណើរការនេះតម្រូវឲ្យមានការយល់ដឹងយ៉ាងពេញទំហឹងអំពីអ្វីដែលបានកើតឡើង ។ សេចក្ដីសន្និដ្ឋានយ៉ាងជោគជ័យទៅលើតុលាការនឹងរួមបញ្ចូលទាំងការទទួលស្គាល់ចំពោះការបដិសេធមិនផ្ដល់យុត្តិធម៌ដល់ប្រទេសកម្ពុជានៅអំឡុងទសវត្សរ៍៨០ ។ សេចក្ដីសន្និដ្ឋានដែលជោគជ័យបែបនេះនឹងអាចបញ្ចប់នូវទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតរបស់កម្ពុជាហើយអាចធ្វើឲ្យប្រជាជនកម្ពុជាបំភ្លេចនូវអ្វីដែលបង្កើតឡើងដោយខ្មែរក្រហមមកលើកម្ពុជា ។

**បេនឌី ទីដយ៉ុណូ**

# រយៈពេលពីរថ្ងៃក្រោយសក្ខីកម្មរបស់សាក្សីដែលអាចសួរសំណួរបាន ឌុច បានបង្រៀនអតីតអ្នកនៅក្រោមបង្គាប់របស់គាត់ឱ្យ "ប្រាប់ការពិតទៅ!"

**សហព្រះរាជអាជ្ញា និងភាគីដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលសច្ចភាពនៃសក្ខីកម្មរបស់ ម៉ម ណៃ**

កាលពីម្សិលមិញ ចៅក្រម និងមេធាវីបានបញ្ជាក់មិនសូវល្អិតល្អន់ប៉ុន្មានទេ តាមរយៈពាក្យសម្តីនិងសូរសំឡេងរបស់ពួកគេថា ម៉ម ណៃ អតីតអ្នកសួរចម្លើយ នៅគុកទួលស្លែងមិនបាននិយាយប្រាប់អង្គសវនាការនូវការពិតទាំងស្រុងទេ ។ ខណៈពេលដែលមានសិទ្ធិមិនធ្វើការឆ្លើយតប និងសិទ្ធិប្រឆាំងនឹងការធ្វើពិរុទ្ធកម្មលើខ្លួនឯងបានក្លាយទៅជាចំណុចសំខាន់ក្នុងការពិភាក្សានិងវែកញែកពីវត្តមានរបស់ ម៉ម ណៃ គាត់ក៏ត្រូវបានក្រើនរំឭកពីកាតព្វកិច្ចរបស់គាត់ក្នុងការនិយាយការពិតនិងបានប្រាប់ពីផលវិបាកដែលកើតមានឡើងក្នុងការមិននិយាយការពិតដែរ ។ ថ្ងៃនេះ ពាក្យសម្តីកុហកមិនត្រូវបានបញ្ជាក់ឲ្យដឹងឡើយ ។ ផ្ទុយទៅវិញ ទាំងចៅក្រម និងភាគីដើមបណ្តឹងរដ្ឋប្បវេណីបែរជាបង្ហាញពីឯកសារសរសេរដោយដៃរាប់រយទំព័ររបស់ ម៉ម ណៃ ហើយឯកសារទាំងនោះមិនមានភាពល្អិតល្អន់អ្វីឡើយ ។

ជាសង្ខេប កាលពីម្សិលមិញ ម៉ម ណៃ បានផ្តល់សក្ខីកម្មថាគាត់បានសួរចម្លើយអ្នកទោស ហើយចម្រាញ់យកនូវចម្លើយសារភាពរបស់អ្នកទោសទាំងនោះនៅក្នុងផ្ទះមួយក្បែរអគារមន្ទីរស-២១ ដោយ «ប្រើប្រាស់នយោបាយ» សួរសំណួរដដែលម្តងហើយម្តងទៀត និងផ្តល់ពេលវេលាឲ្យអ្នកទោសទាំងនោះបង្ហាញពីកំហុសរបស់ខ្លួន។ ម៉ម ណៃ បាននិយាយថា គាត់មិនដែលបានធ្វើទារុណកម្ម មិនដែលបង្គាប់ឲ្យធ្វើទារុណកម្ម ហើយក៏មិនដឹងថាតើអ្នកសួរចម្លើយដទៃទៀតបានធ្វើទារុណកម្មលើអ្នកទោសឬក៏អត់ឡើយ ។ ម៉ម ណៃ បានអះអាងថា អ្នកទោសទាំងអស់មើលទៅហាក់បីដូចជាមានសុខភាពល្អ ហើយគាត់ក៏បាននិយាយបន្ថែមទៀតថា គាត់មិនដឹងពីស្ថានភាពនៃការឃុំឃាំង ឬដោគវាសនារបស់អ្នកទោសទាំងអស់នោះក្រោយពីគាត់សរសេរចម្លើយសារភាពរបស់អ្នកទោសទាំងអស់នោះឡើយ ។ ម៉ម ណៃ បានអះអាងទៀតថា គាត់មិនដឹងពីទ្រង់ទ្រាយសំខាន់ៗដូចជាចំនួនបុគ្គលិក និងរចនាសម្ព័ន្ធរបស់មន្ទីរស-២១នេះទេ ពីព្រោះថាគាត់


ម៉ម ណៃ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ


ម៉ម ណៃ នៅក្នុងឆ្នាំ២០០៩

គ្រាន់តែធ្វើខ្លួនជាមនុស្ស «ខ្វាក់និងថ្លង់» ដើម្បីគេចចេញពីហានិភ័យ និងគ្រាន់តែចំណាយពេលវេលារបស់គាត់ក្នុងផ្ទះសួរចម្លើយតែម្នាក់ឯងប៉ុណ្ណោះ ។

ក្រោយពីការពិនិត្យពិច័យបន្ថែម សេចក្តីអះអាងជាច្រើនរបស់ ម៉ម ណៃ មិនត្រូវបានគេជឿទាំងស្រុងទេ ។ ខណៈពេលដែល ម៉ម ណៃ បានប្រកាន់នូវគោលជំហរដែលថាគាត់មិនបានធ្វើទារុណកម្មដោយផ្ទាល់លើអ្នកទោសដែលគាត់បានសួរចម្លើយ ការបង្ហាញពីសកម្មភាពដែលធ្វើកាលពីមុននៅមន្ទីរស-២១ ឡើងវិញនៅខែកុម្ភៈ ឆ្នាំ២០០៨ ដែល ម៉ម ណៃ បានចូលរួមជាមួយនឹងចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជនត្រូវចោទ កាំង ហ្គេកអ៊ាវ (ហៅ ឌុច) ម៉ម ណៃ បាននិយាយថាគាត់ធ្លាប់បានប្រើ «រំពាត់និងខ្សែភ្លើង» ក្នុងប្រតិបត្តិការសួរចម្លើយរបស់គាត់កន្លងមក ។ ខណៈពេលដែលត្រូវបានបង្គាប់ឲ្យរំឭកពីពាក្យសម្តីនេះនៅក្នុងថ្ងៃនេះម្តងទៀត ម៉ម ណៃ បែបជាផាកទៅអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការមិនឆ្លើយតបទៅវិញ ។

កាលពីម្សិលមិញ ដោយមានការអនុញ្ញាតពីចៅក្រម សហព្រះរាជអាជ្ញាអន្តរជាតិ លោក វីលលៀម ស្មិត បានប្រគល់ជូនសៀវភៅសរសេរដែលមានចំនួន៣០០ទំព័របន្ថែមដើម្បីពិនិត្យមើលឡើងវិញសម្រាប់ការពិភាក្សាក្នុងថ្ងៃនេះ ។ ម៉ម ណៃ បានបញ្ជាក់ថាឯកសារនេះមានផ្ទុកនូវចំណារ និងការសរសេរចម្លងរបស់គាត់ចេញពីការបង្រៀនមួយចំនួនដែល ឌុច បានបង្រៀនក្នុងអំឡុងវគ្គសិក្សារបស់បុគ្គលិក ។ ស្របពេលដែលកាលពីម្សិលមិញ ម៉ម ណៃ បាននិយាយថា គាត់មិនបានដឹងថាតើទារុណកម្មត្រូវបានអនុវត្ត ឬថាតើ ឌុច បានបញ្ជាឲ្យអនុវត្តការធ្វើទារុណកម្ម ឬក៏អត់នោះ សហព្រះរាជអាជ្ញាលោក វីលលៀម ស្មិត បានអធិប្បាយថាសៀវភៅសរសេរមួយក្បាលនេះគឺ «ពោរពេញទៅដោយឯកសារយោងនៃការធ្វើទារុណកម្ម» នៅមន្ទីរស-២១ ។ លោក វីលលៀម ស្មិត បានសួរ ម៉ម ណៃ ថាតើវាត្រឹមត្រូវដែរឬទេដែល ម៉ម ណៃ ពិតជាបានដឹងពីការធ្វើទារុណកម្មនៅមន្ទីរស-២១ ពីព្រោះថាទាំង ម៉ម ណៃ និងអ្នកសួរចម្លើយដទៃទៀតត្រូវបានបង្គាប់ឲ្យអនុវត្តការធ្វើទារុណកម្មដូចដែលបានបង្ហាញឲ្យឃើញយ៉ាងច្បាស់តាមរយៈសៀវភៅសរសេរមួយនេះ ។ ម៉ម ណៃ បានឆ្លើយថាគាត់មិនដែលត្រូវបានបង្គាប់ឲ្យធ្វើទារុណកម្មដោយផ្ទាល់ទេ ហើយក៏មិនដែលដឹងថារបៀបធ្វើទារុណកម្មអ្វីខ្លះដែលអ្នកសួរចម្លើយដទៃទៀតបានអនុវត្តដែរ ។

ម្សិលមិញ ម៉ម ណៃ បានប្រកាន់ជំហរថាគាត់មិនបានដឹងពីព័ត៌មានទាក់ទិននឹងរបៀបដែលកងសួរចម្លើយរបស់គាត់ត្រូវបានរៀបចំឡើងចំនួនមនុស្សប៉ុន្មាននាក់ធ្វើការក្នុងកងនេះ និងអ្វីខ្លះដែលអ្នកសួរចម្លើយទាំងនោះបានអនុវត្ត ពីព្រោះថាកងរបស់គាត់មិនដែលបានជួបប្រជុំ ឬពិភាក្សាពីការអនុវត្តណាមួយឡើយ ។ ថ្ងៃនេះ លោក វីលលៀម ស្មិត បានចាក់បង្ហាញ «គម្រោងការងារ» នៅមន្ទីរស-២១ ហើយ ម៉ម ណៃ បានបញ្ជាក់ថាទំព័រជាច្រើននៅក្នុងឯកសារនេះគឺត្រូវបានសរសេរដោយដៃរបស់គាត់ ។ លោក វីលលៀម ស្មិត បានសង្ខេបឯកសារនេះដែលបានបង្ហាញយ៉ាងច្បាស់ពីរចនាសម្ព័ន្ធនៃកងសួរចម្លើយ ការបែងចែកចំនួនការងារ និងទំនួលខុសត្រូវជាច្រើនរបស់បុគ្គលផ្សេងៗគ្នា ។ គម្រោងការងារនេះក៏បានផ្តល់នូវសេក្តីលម្អិតពីអង្គប្រជុំជាក់លាក់របស់របបនេះដែលក្នុងនោះការប្រជុំខ្លះបានធ្វើឡើងរៀងរាល់បីថ្ងៃម្តង ។ ខណៈពេលដែលត្រូវសួរថាតើ ម៉ម ណៃ យល់ស្របថាក្នុងអំឡុងពេលនោះថាគាត់ពិតជាបានដឹងពីរចនាសម្ព័ននៃកងសួរចម្លើយទាំងស្រុង និងជាអ្នកសម្របសម្រួលដ៏សំខាន់ម្នាក់នោះ ម៉ម ណៃ បានឆ្លើយថា «ខ្ញុំមិនយល់ស្របជាមួយអ្នកទេ» ហើយក្រោយមកក៏មិនបានផ្តល់នូវការពន្យល់ឲ្យច្បាស់លាស់ដែរ ។

ម៉ម ណៃ បានផ្តល់សក្ខីកម្មថាគាត់បានសួរចម្លើយឈ្លើយសឹកវៀតណាមចំនួនពី២០-៣០នាក់ និងជនស៊ីវិលស៊ើបការណ៍វៀតណាមម្នាក់ឬពីរនាក់ប៉ុណ្ណោះ ។ លោក វីលលៀម ស្មិត បានដកស្រង់នូវសេចក្តីអះអាងរបស់ ឌុច ដែលថា ម៉ម ណៃ ជាអ្នកទទួលខុសត្រូវក្នុងការសួរចម្លើយអ្នកទោសវៀតណាមនៅមន្ទីរស-២១ ទាំងអស់ដោយសារតែជំនាញភាសារបស់គាត់ ។ ម៉ម ណៃ បានយល់ស្របចំពោះសេចក្តីអះអាងនេះ ។ បន្ទាប់មក លោក វីលលៀម ស្មិត ក៏បានដកស្រង់បញ្ជីអ្នកទោសរបស់មន្ទីរស-២១ ដែលមានកត់ត្រានូវអ្នកទោសជាឈ្លើយសឹកវៀតណាមចំនួន ១២២នាក់ និង អ្នកស៊ើបការណ៍វៀតណាមចំនួន ១៨៤នាក់ ។ ខណៈពេលដែលត្រូវបានសួរថាតើគាត់ពិតជាបានធ្វើការសួរចម្លើយ

អ្នកទោសវៀតណាមទាំងអស់នេះទេ ម៉ម ណៃ បានសម្រេចមិនធ្វើការឆ្លើយតប ។

បន្ទាប់ពីបានបញ្ចប់ការសួរសំណួរមួយនេះ លោក វីលលៀម ស្មីត បានចោទសួរ ម៉ម ណៃ ថាតើគាត់កំពុងតែធ្វើការកាត់បន្ថយតួនាទីរបស់គាត់នៅមន្ទីរស-២១ ដើម្បីធ្វើឲ្យខ្លួនគាត់មានការឃ្លាតឆ្ងាយពីឧក្រិដ្ឋកម្មដែរឬទេ ។ ម៉ម ណៃ បានឆ្លើយតបថា «ខ្ញុំមិនដែលមានគំនិតធ្វើបែបនេះឡើយ» ។

ដោយសារតែឥទ្ធិពលដ៏រំដើបរំជួល មេធាវីការពារក្តីអន្តរជាតិ លោក ហ្វ្រង់ស័រ រូ បានក្រោកឈរប្រាប់ថា ព្រះរាជអាជ្ញាបានធ្វើការកោះហៅសាក្សីរូបនេះ ។ បន្ទាប់ពីបានឈប់សួរសំណួរ ម៉ម ណៃ លោក រូ បានអរគុណព្រះរាជអាជ្ញាសម្រាប់ការកោះហៅសាក្សីនេះ ហើយក៏បាននិយាយថាប្រសិនបើព្រះរាជអាជ្ញាមានសាក្សីបន្ថែមរបៀបនេះទៀត ព្រះរាជអាជ្ញាមិនត្រូវរួញរាក្នុងការកោះហៅឡើយ ។ ខណៈពេលដែល លោក រូ គឺជាមេធាវីការពារក្តីដែលបានដើរតួដ៏ល្អជាងមេធាវីដែលមកជំនួសការងារគាត់មួងម្កាល ខ្ញុំមានភាពរីករាយដែលបានឃើញគាត់វិលត្រឡប់ពីការឈប់សម្រាកផ្ទាល់ខ្លួនរបស់គាត់នៅសប្តាហ៍នេះ ដោយសារតែការបញ្ចេញនូវយោបល់ដ៏គួរឲ្យចាប់អារម្មណ៍របស់គាត់ ។ លោក វីលលៀម ស្មីត បានកែតម្រូវថាចៅក្រមបានចេញដីកាកោះហៅសាក្សី តែលោក រូ បានឆ្លើយតបថា ខណៈពេលដែលចៅក្រមបានចេញដីកាកោះហៅសាក្សី ព្រះរាជអាជ្ញាបានសុំរួមបញ្ចូល ម៉ម ណៃ ទៅក្នុងបញ្ជីសាក្សីដែលបានស្នើសុំនោះ ។

ការបញ្ចេញយោបល់របស់លោក រូ បានធ្វើឡើងក្រោយពីការវិភាគលើ ម៉ម ណៃ ដែលមើលទៅហាក់បីដូចជាមានភាពស្ងប់ស្ងាត់ និងប្រកបដោយការគេចវេះ ។ នៅពេលដែលត្រូវបានសួរថាតើ ម៉ម ណៃ គិតយ៉ាងដូចម្តេចចំពោះអំឡុងពេលនៃរបបខ្មែរក្រហម ម៉ម ណៃ ហាក់បីដូចជាចាំបាននូវព្រឹត្តិការណ៍ទាំងនោះយ៉ាងច្បាស់ ដោយនិយាយថាស្ថានភាពនៅពេលនោះពិតជាតានតឹងណាស់ដោយសារតែសង្គ្រាម និងរបបអាហារមិនគ្រប់គ្រាន់ ប៉ុន្តែឯករាជ្យភាពរបស់កម្ពុជានិងភាពជាម្ចាស់ការលើខ្លួនឯងគឺជាទិដ្ឋភាពវិជ្ជមានដែលស្របជាមួយនឹងគោលគំនិតខ្លួនទីពឹងខ្លួនដ៏ប្រពៃរបស់ព្រះពុទ្ធផងដែរ ។ នៅពេលដែលត្រូវបានសួរថាតើគាត់មានដឹងទេថាមានចំនួនមនុស្សប៉ុន្មាននាក់ស្លាប់នៅមន្ទីរស-២១ ម៉ម ណៃ បាននិយាយថា «ខ្ញុំមិនមានភារកិច្ច ឬមុខតំណែងដើម្បីដឹងពីរឿងនេះទេ» ។ ហើយខណៈពេលដែលត្រូវបានសួរថាតើមានមនុស្សចំនួនប៉ុន្មាននាក់បានស្លាប់ក្នុងអំឡុងពេលខ្មែរក្រហមនៅប្រទេសកម្ពុជា ម៉ម ណៃ បាននិយាយដោយធម្មតាថាគាត់មិនបានដឹងពីរឿងនេះទេ ។ លោក រូ បានចោទសួរថាតើ ម៉ម ណៃ មានការសោកស្តាយខ្លះដែរឬទេ ហើយ ម៉ម ណៃ ក៏បាននិយាយថាគាត់ពិតជាមានការសោកស្តាយចំពោះ «ក្រុមមនុស្សល្អមួយចំនួនតូច» ដែលត្រូវបានសម្លាប់ ។ បន្ថែមលើនេះ ម៉ម ណៃ មិនមានភាពសោកស្តាយចំពោះ «មនុស្សអាក្រក់» ឡើយ ។

## ឌុច បានសំណូមពរឲ្យ ម៉ម ណៃ និយាយការពិត និងទទួលស្គាល់ឧក្រិដ្ឋកម្មរបស់ខ្លួន

បន្ទាប់ពីភាគីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការសួរសំណួរទៅកាន់ ម៉ម ណៃ លោកប្រធាន ចៅក្រម និល ណុន បានប្រគល់ឱកាសនេះដល់ ឌុច សម្រាប់ការអង្កេតរបស់គាត់ ។ យ៉ាងចម្លែក ឌុច បានពន្យល់ប្រាប់អង្គសវនាការថា គាត់មានភាពស្និទ្ធស្នាលជាមួយបុគ្គលិកប្រុសផ្សេងៗទៀតនៅមន្ទីរស-២១ ប៉ុន្តែមិនដែលស្និទ្ធជាចូលចិត្ត ម៉ម ណៃ ប៉ុន្មានទេ ។ ក្រោយមកអ្វីៗចាប់ផ្តើមមានភាពគួរឲ្យចាប់អារម្មណ៍ ។ ឌុច បាននិយាយថា សៀវភៅសរសេរដែលមាន៣០០ទំព័របន្ថែមដែលលើកឡើងមុននេះបន្តិចបង្ហាញពីការធ្វើទារុណកម្មបានឆ្លុះបង្ហាញពី «ការងារពិតប្រាកដ» របស់អ្នកសួរចម្លើយទាំងនោះ ។ ជាមួយនឹងកាយវិការនិងចំណាប់អារម្មណ៍ដ៏មាំ ឌុច បានប្រាប់ ម៉ម ណៃ ថាកុំឲ្យមានការភ័យខ្លាចនឹងសេចក្តីស្លាប់ «និយាយការពិត» មក ។ ឌុច បានពន្យល់ប្រាប់ថាគាត់បានទទួលស្គាល់នូវឧក្រិដ្ឋកម្មរបស់គាត់ ហើយក៏ប្រាប់ ម៉ម ណៃ ថា «ខ្ញុំចង់ឲ្យអ្នកធ្វើដូចជាខ្ញុំដែរ» ។

ឌុច បានពន្យល់ថាប្រជាជនលើសពីមួយពាន់នាក់ត្រូវបានសម្លាប់នៅក្រោមកណ្តាប់ដៃរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយក៏បានរំឭក ម៉ម ណៃ ថា យើងទាំងពីរនាក់ក៏ជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាដែរ ។ ឌុច បានពន្យល់ថា «យើង» មានទំនួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង ហើយមិនអាចស្តីបន្ទោសមាគ៌ារបស់បក្សឡើយ ។ ទាំងកម្ពុជា ពិភពលោកទាំងមូល

និងភាគីដើមបណ្តឹងរដ្ឋប្បវេណីកំពុងតែស្វែងរកការពិត ។ ឌុច បានរំឭក ម៉ម ណៃ ថាប្រពន្ធនិងកូនស្រីរបស់ ភីង គុន អតីតលោកគ្រូសាស្ត្រាចារ្យរបស់ពួកគេកំពុងតែសម្លឹងមើលមកក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ហើយចង់ដឹងថាតើធាតុរបស់លោកគ្រូសាស្ត្រាចារ្យនៅកន្លែងណា ។ «សូមត្រៀមខ្លួនដើម្បីនិយាយនូវការពិត» ។

បើពិចារណាទៅលើប្តីនិងឪពុកកូនក្តីរបស់គាត់ដែលត្រូវបានលើកឡើងយកមកនិយាយ អ្នកស្រី ស៊ីលកេ ស្តុដហ្សិនស្គី មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានសុំការអនុញ្ញាតពីចៅក្រមដើម្បីឲ្យ ម៉ម ណៃ មានឱកាសផ្តល់នូវព័ត៌មានបន្ថែមទាក់ទងនឹងបញ្ហានេះ ។ ម៉ម ណៃ បាននិយាយថាគាត់មិនមានព័ត៌មានអ្វីនឹងផ្តល់ឲ្យឡើយ ប៉ុន្តែគាត់ក៏បានបង្ហាញពី «ការសោកស្តាយរបស់គាត់ចំពោះក្រុមគ្រួសាររបស់លោកគ្រូសាស្ត្រាចារ្យ ភីង គុន» ហើយបានយំស្រក់ទឹកភ្នែកជាលើកដំបូង ។

ម៉ម ណៃ ត្រូវបានចោទសួរសំណួរពីដំបូងដោយអ្នកស្រី ស្តុដហ្សិនស្គី អំពី ភីង គុន ហើយទោះបីជា ម៉ម ណៃ បានចាំរូបថតរបស់ ភីង គុន និង ទទួលស្គាល់លើចំណារដោយផ្ទាល់ដៃរបស់គាត់លើចម្លើយសារភាពរបស់ ភីង គុន ក៏ដោយ ក៏ ម៉ម ណៃ បាននិយាយថាគាត់មិនបានចាំថាតើគាត់ពិតជាបានសួរចម្លើយ ភីង គុន និងមិនបានដឹងពីជោគវាសនារបស់ ភីង គុន ឡើយ ។ បន្ទាប់មកទៀតដោយស្ថិតនៅក្រោមការចោទសួរពីមេធាវីការពារក្តី ម៉ម ណៃ បានរំឭកឡើងវិញនូវការសួរចម្លើយលើ ភីង គុន ហើយបាននិយាយថាចម្លើយសារភាពរបស់ ភីង គុន មិនត្រូវបានបង្ខំឡើយៈ «ភីង គុន បាននិយាយចេញពីចិត្តរបស់គាត់ដោយខ្លួនឯង» ។

នៅពេលដែល អ្នកស្រី ស្តុដហ្សិនស្គី បានដាក់បង្ហាញរូបថតជាអ្នកទោសរបស់ ភីង គុន នៅលើអេក្រង់ទូរទស្សន៍ ប្រពន្ធនិងកូនស្រីរបស់អ្នកទោសគុកទួលស្លែងរូបនេះត្រូវបានគេឃើញនិងឮសំឡេងយំខ្សឹកខ្សួលយ៉ាងខ្លាំង ទោះបីជាមានកញ្ចក់ខ័ណ្ឌពួកគេដាច់ដោយឡែកពីសាលសាធារណៈក៏ដោយ ។ ស្ត្រីទាំងនេះគឺស្ថិតនៅក្នុងចំណោមភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូចដែលបានចូលរួមក្នុងដំណើរកាត់ក្តីជារៀងរាល់ថ្ងៃ ។

## ការប្រព្រឹត្តខុសក្រិដ្ឋកម្មរួម និងការដាក់ពិរុទ្ធភាពលើខ្លួនឯង បានយកមកពិភាក្សាវែកញែកសម្រាប់ថ្ងៃទីបីក្នុងវិវាទមួយ

ចំណុចដំបូងសម្រាប់ព្រឹកនេះ សហព្រះរាជអាជ្ញាជាតិបានរំឭកប្រាប់ ម៉ម ណៃ អំពីសិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯងដែលមានចែងនៅក្នុងវិធានទី២៨ ។ យ៉ាងណាមិញ សហព្រះរាជអាជ្ញាក៏បានជំរុញឲ្យ ម៉ម ណៃ ផ្តល់នូវសក្ខីកម្មដ៏ពេញលេញមួយទោះបីជាវាអាចក្លាយជាការដាក់ពិរុទ្ធភាពខ្លួនឯងក៏ដោយ ។ សហព្រះរាជអាជ្ញាជាតិបានថ្លែងថា នៅក្នុងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានតែមេដឹកនាំជាន់ខ្ពស់និងអ្នកទាំងឡាយដែល «មានទំនួលខុសត្រូវខ្ពស់បំផុត» តែប៉ុណ្ណោះអាចធ្វើការកាត់ទោសបាន ។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាបានធានាដល់សាក្សីថា ដោយសារតែវាមានរយៈកាលលើពីសាមសិបឆ្នាំទៅហើយនោះ អាជ្ញាយុកាលបានអស់សុពលភាពហើយ ដូច្នេះបុគ្គលដែលមិនមានជាប់ពាក់ព័ន្ធនៅក្នុងបុគ្គលប្រភេទទាំងពីរខាងលើនឹងមិនត្រូវបានធ្វើការកាត់ទោសឡើយ ។ ខ្ញុំបានសម្លឹងមើលទៅកាន់លោក រូ ដោយរំពឹងថាគាត់នឹងធ្វើការបដិសេធភ្លាមៗ ប៉ុន្តែគួរឲ្យភ្ញាក់ផ្អើល គាត់បែរជាមិនបានធ្វើការបដិសេធអ្វីឡើយ ។

លោក រូ បានរង់ចាំរហូតដល់វេនរបស់គាត់ដើម្បីសួរសំណួរទៅកាន់ ម៉ម ណៃ និងបានផ្តល់នូវសេចក្តីជំទាស់លើការធានារបស់សហព្រះរាជអាជ្ញា ។ លោក រូ បានរំឭក ម៉ម ណៃ ពីសិទ្ធិនិងករណីកិច្ចរបស់គាត់ ។ បន្ទាប់មកលោក រូ ក៏បានណែនាំ ម៉ម ណៃ កុំឲ្យជឿលើសហព្រះរាជអាជ្ញានៅពេលដែលសហព្រះរាជអាជ្ញាបានប្រាប់ ម៉ម ណៃ ថាគាត់មិនអាចធ្វើការកាត់ទោសបានទេ ។ ដោយមានការកត់សម្គាល់ឃើញថាក្នុងអំឡុងពេលសម្រាកអាហារថ្ងៃត្រង់លោក រូ បានអាននូវការដាក់សេចក្តីសន្និដ្ឋានពីព្រះរាជអាជ្ញាថាក្នុងនាមជាភាគីមួយរបស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មប្រទេសកម្ពុជាបានទទួលខុសត្រូវសម្រាប់ការកាត់ទោសលើជនទាំងឡាយណាដែលបានប្រព្រឹត្តទារុណកម្ម ។ លោក ស្មិត បានធ្វើការបន្លុកដោយលើកយកនូវវិវាទដដែល «បញ្ហាពិបាកដោះស្រាយ»ដូចកាលពីម្សិលមិញទាក់ទិននឹងការដាក់ពិរុទ្ធភាពលើខ្លួនឯងដែលគួរតែត្រូវបានលើកឡើងជាឯកជនក្នុងវិធានទី២៨ ។

លោកប្រធានចៅក្រមពិតជាមានអារម្មណ៍ថារំខានពីសំណាក់លោក រូ ដោយនិយាយថា លោក រូ មានឱកាសសម្រាប់ធ្វើការសួរសំណួរទៅកាន់សាក្សីមិនមែនមកបញ្ចេញនូវយោបល់

បែបនេះទេ ។ បន្ថែមពីនេះ វាគឺជាភារកិច្ចរបស់ចៅក្រមក្នុងការប្រាប់សាក្សីអំពីសិទ្ធិរបស់គេ ហើយមេធាវីការពារក្តីមិនគួរធ្វើការណែនាំសាក្សីឡើយ ពីព្រោះថាសាក្សីមានមេធាវីផ្ទាល់ខ្លួនដើម្បីពិភាក្សាលើបញ្ហានេះហើយ ។ លោក រូ បានបង្ហាញយ៉ាងត្រឹមត្រូវថាព្រះរាជអាជ្ញាបានបញ្ចេញនូវយោបល់បែបនេះមុន ។ ក្នុងចំណុចសំខាន់នេះ លោកប្រធានចៅក្រមបានប្រាប់លោក រូ ឲ្យចាប់ផ្តើមសួរ ម៉ម ណៃ ឬអង្គុយចុះ ។

បន្ទាប់ពី ម៉ម ណៃ បានចាកចេញពីសាលតុលាការកាលពីពេលថ្ងៃ លោក រូ បានក្រោកឈរដើម្បី «បង្ហាញពីការព្រួយបារម្ភជាបន្ត» ទាក់ទិននឹងការដាក់ពិរុទ្ធភាពលើខ្លួនឯង ។ លោក រូ បាននិយាយថាសាក្សីគួរតែត្រូវបានក្រើនរំឭកឲ្យបានត្រឹមត្រូវអំពីហានិភ័យដែលពួកគេអាចនឹងប្រឈមមុខដោយផ្តល់ឲ្យពួកគេនូវទម្រង់បែបបទជាក់លាក់នៃការទទួលខុសត្រូវតាមផ្លូវច្បាប់លើការប្រព្រឹត្តខុក្រិដ្ឋកម្មរួមក្នុងតុលាការកាត់ក្តីនេះនិងទាក់ទិននឹងការធានាដ៏ខុសឆ្គងរបស់ព្រះរាជអាជ្ញាកាលពីព្រឹកមិញនេះ ។

លោកប្រធានចៅក្រម បានចោទប្រកាន់ព្រះរាជអាជ្ញានិងមេធាវីការពារក្តីពីបទ «ទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន» ពីដំណើរការនីតិវិធី ហើយបន្តនិយាយថាប្រសិនបើព្រះរាជអាជ្ញា ឬមេធាវីមានការអង្កេតនោះគួរតែប្រគល់ជូនចៅក្រមជាលាយលក្ខណ៍អក្សរជាមុនទាក់ទិននឹងវិធានទី២៨នេះ ។ លោកប្រធានចៅក្រមបានថ្លែងនូវការអង្កេតដែលស្តែងនូវការរំខានបន្តិចបន្តួចថាប្រសិនបើភាគីណាមួយនៅតែលើកឡើងពីបញ្ហាដាក់ពិរុទ្ធភាពលើខ្លួនឯងក្នុងដំណើរការនីតិវិធីតទៅទៀត នោះសាក្សីនឹងកាន់តែមានភាពស្ញប់ស្ញាត់ជាងមុន ហើយវានឹងមានផលវិបាកដល់អង្គជំនុំជម្រះក្នុងការទទួលបាននូវការពិត ។

លោក រូ បានខំប្រឹងប្រែងបន្តដោយថ្លែងថាព្រះរាជអាជ្ញាបានបញ្ចេញយោបល់ជាសាធារណៈក្នុងព្រឹកនេះ ដូច្នេះគាត់គ្រាន់តែធ្វើការឆ្លើយតបនឹងបញ្ហានេះជាសាធារណៈដូចគ្នាតែប៉ុណ្ណោះ ។ លោក រូ បាននិយាយថា គាត់ស្វាគមន៍ការប្រជុំជាឯកជនដើម្បីដោះស្រាយនូវសំណួរសំខាន់ៗទាក់ទិននឹងការប្រព្រឹត្តខុក្រិដ្ឋកម្មរួម ។ ដោយពិចារណាឃើញថាការប្រព្រឹត្តខុក្រិដ្ឋកម្មរួមបានពង្រីកនូវការទទួលខុសត្រូវតាមផ្លូវច្បាប់លើខុក្រិដ្ឋកម្មដោយស្មើភាពសម្រាប់បុគ្គលទាំងអស់ដែលស្ថិតនៅក្នុងគម្រោងការខុក្រិដ្ឋកម្មរួមមួយនោះ លោក រូ បានជំទាស់សាជាថ្មីម្តងទៀតថា សាក្សីដែលជាជនដែលនឹងប្រឈមមុខនឹងហានិភ័យនៃការចោទប្រកាន់ប្រសិនបើអង្គជំនុំជម្រះសម្រេចធ្វើការអនុវត្តការទទួលខុសត្រូវតាមផ្លូវច្បាប់នូវការប្រព្រឹត្តខុក្រិដ្ឋកម្មរួមនៅក្នុងដំណើរការកាត់ក្តីឌុច ។ ប្រហែលជាប្រាំលើកហើយសម្រាប់សប្តាហ៍នេះ ការចោទប្រកាន់បានបង្ហាញនូវទស្សនៈរបស់ខ្លួនម្តងហើយម្តងទៀតដែលថាការប្រព្រឹត្តខុក្រិដ្ឋកម្មរួមគ្មានអ្វីជាប់ពាក់ព័ន្ធជាមួយនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯងឡើយ ។

ក្រោយពីការសម្រាករយៈពេលខ្លីមក ចៅក្រមបានសម្គាល់ឃើញថាទាំងការធានារបស់ព្រះរាជអាជ្ញាកាលពីព្រឹកមិញនិងការណែនាំរបស់មេធាវីការពារក្តីទៅកាន់សាក្សីកាលពីរសៀលនេះមិនមានភាពសមរម្យឡើយ ។ លោកប្រធានចៅក្រមព្រមានយ៉ាងដាច់ខាតថាព្រះរាជអាជ្ញានិងមេធាវីការពារក្តីមិនគួរលើកយកនូវបញ្ហាដដែលនេះមកពិភាក្សាក្នុងដំណើរការផ្តល់សក្ខីកម្មរបស់សាក្សីបន្ទាប់ទៀតឡើយ ។

## ម៉ម ណៃ ត្រូវបានផ្តល់ឲ្យមានមេធាវីម្នាក់ ប៉ុន្តែតើមេធាវីដែលបានផ្តល់ឲ្យនោះមានតួនាទីអ្វីខ្លះ?

ក្រោយពី ម៉ម ណៃ បាននិយាយកាលពីថ្ងៃច័ន្ទថា គាត់មិនមានមេធាវី ប៉ុន្តែចង់បានមេធាវីម្នាក់ដែលជាផ្នែកជំនួយការជំនាញដល់សាក្សី អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានជ្រើសរើស លោក គង់ សំអុន ឲ្យធ្វើជាមេធាវីរបស់ ម៉ម ណៃ ។ លោក គង់ សំអុន បានអង្គុយក្បែរមេធាវីការពារក្តីក្នុងដំណើរការផ្តល់សក្ខីកម្មរបស់ ម៉ម ណៃ ហើយបានធ្វើការបដិសេធនិងបញ្ចេញយោបល់មួយចំនួន ។ ការធ្វើបែបនេះគឺមានភាពច្បាស់លាស់ ។

យ៉ាងណាមិញ វាមិនមានភាពច្បាស់លាស់ទេថាតើសិទ្ធិអំណាចរបស់ គង់ សំអុន មានអ្វីខ្លះ និងថាតើតួនាទីអ្វីខ្លះដែលគាត់តម្រូវឲ្យដើរតួនៅក្នុងសាលសវនាការនេះ ។ ខណៈពេលដែល គង់ សំអុន បានបដិសេធលើសំណួរមួយសួរទៅកាន់ ម៉ម ណៃ លោកប្រធានចៅក្រមបាន «ក្រើនរំឭក» គង់ សំអុន ពីការផ្លាស់ប្តូរតួនាទីរបស់គាត់ពីផ្នែកជំនួយការជំនាញដល់សាក្សីគឺដើម្បីធានាឲ្យបានថាសាក្សីនឹងមិនដាក់ពិរុទ្ធភាពលើខ្លួនឯង ហើយនិយាយថាសំណួរ

ដែលសួរក្នុងប្រភេទបែបនេះមិនមានជាប់ពាក់ព័ន្ធជាមួយនឹងការព្រួយបារម្ភរបស់លោក គង់ សំអុន ឡើយ ។ អ្នកនាំពាក្យម្នាក់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានពន្យល់ថាលោក គង់ សំអុន មិនបានធ្វើជាតំណាងឲ្យ ម៉ម ណៃ ក្នុងអង្គសវនាការឡើយ ប៉ុន្តែបែរជាធ្វើការណែនាំ ម៉ម ណៃ ពីសិទ្ធិរបស់គាត់ និងឲ្យ ម៉ម ណៃ ឆ្លើយនឹងសំណួររបស់គាត់ដែលទាក់ទិននឹងបញ្ហាការដាក់ពិរុទ្ធភាពលើខ្លួនឯងទៅវិញ ។ តាមរយៈការបំពេញតួនាទីនៅក្នុងដំណើរការនីតិវិធី វាហាក់បីដូចជាលោក គង់ សំអុន មិនបានស្វែងយល់ពីសិទ្ធិអំណាចដែលមានព្រំដែនកំណត់នេះទេ ។ លើសពីនេះ លោកប្រធានចៅក្រមហាក់បីដូចជាបង្ខំឲ្យជ្រើសរើសមេធាវីរូបនេះ ។ ឧទាហរណ៍ កាលពីម្សិលមិញ គង់ សំអុន បានបដិសេធលើឯកសារដែលបានបង្ហាញនៅលើអេក្រង់ និងបានស្នើថា ម៉ម ណៃ គួរតែផ្តល់ឲ្យនូវឯកសារដើម ។ ការបដិសេធនេះមានប្រសិទ្ធភាព និងបានអនុញ្ញាតដោយតុលាការ ប៉ុន្តែឯកសារនោះមិនមានអ្វីដែលជាប់ពាក់ព័ន្ធជាមួយនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯងនោះទេ ។ ក្នុងទិដ្ឋភាពបែបនេះ គង់ សំអុន ហាក់បីដូចជាដើរតួជាមេធាវីការពារក្តី និងត្រូវបានទទួលការគោរពដូចមេធាវីការពារក្តីដែរ ។

អ្នកនាំពាក្យរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបញ្ជាក់នៅថ្ងៃនេះថា ម៉ម ណៃ បានពិភាក្សាជាមួយនឹងមេធាវីទាក់ទិននឹងការដាក់ពិរុទ្ធភាពលើខ្លួនឯងក្នុងដំណើរការស៊ើបអង្កេតសម្រាប់អង្គហេតុនេះ ។ ហើយព័ត៌មានស្តីពីការកំណត់ពេលដាក់ឯកសារ និងអំឡុងពេលនៃការពិភាក្សានេះមិនមានភាពច្បាស់លាស់ឡើយ ។

ជាក់ស្តែង ប្រសិនបើសេចក្តីណែនាំដែលផ្តល់ឲ្យ ម៉ម ណៃ គ្រាន់តែទាក់ទិននឹងការដាក់ពិរុទ្ធភាព លើខ្លួនឯងតែមួយមុខនោះ ខ្ញុំគិតថាវាមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ តាមទស្សនៈរបស់ខ្ញុំ ម៉ម ណៃ ឥឡូវនេះគឺជាបេក្ខជនដ៏ពិតប្រាកដម្នាក់សម្រាប់ការស៊ើបអង្កេត និងការអនុញ្ញាតសម្រាប់ការផ្តល់នូវសក្ខីកម្មខុសបើយោងតាមវិធាន ៣៥ និង៣៦ ។ តើមេធាវីរបស់ ម៉ម ណៃ អាចណែនាំគាត់នៅក្នុងអំឡុងពេលសម្រាកនេះបានដែរឬទេ ខណៈពេលដែលគាត់ពិតជាត្រូវការនូវការគ្រើនរំឭក? ដោយពិចារណាឃើញថាមេធាវីគ្រាន់តែត្រូវបានផ្តល់ឲ្យ ម៉ម ណៃ កាលពីថ្ងៃច័ន្ទវេលាម៉ោង៤ល្ងាច ហើយ ម៉ម ណៃ ទើបនឹងចាប់ផ្តើមផ្តល់សក្ខីកម្មនៅថ្ងៃអង្គារ ម៉ោង៩ព្រឹកនេះ ។ តើមេធាវីមានពេលគ្រប់គ្រាន់ដើម្បីស្តាប់ដំណើររឿងរបស់ ម៉ម ណៃ ដែរឬទេ? ប្រសិនបើមេធាវីមិនបានស្តាប់នូវដំណើររឿងពេញលេញរបស់ ម៉ម ណៃ តើមេធាវីរូបនេះពិតជាស្ថិតនៅក្នុងគោលជំហរច្បាស់លាស់ដើម្បីដឹងថាតើពេលណាដែល ម៉ម ណៃ អាចនឹងដាក់ពិរុទ្ធភាព ឬក៏ហុកខ្លួនឯងដែរឬទេ?

## សក្ខីកម្មរបស់ ហ៊ីម ហ៊ុយ ត្រូវបានពន្យារពេលដើម្បីអនុញ្ញាតឲ្យមានការពិភាក្សាជាមួយនឹងអ្នកប្រឹក្សា

ហ៊ីម ហ៊ុយ ដែលជាអតីតឆ្មាំយាមមន្ទីរស-២១ បានចូលខ្លួនអង្គុយនៅក្នុងកន្លែងសាក្សីកាលពីរសៀលនេះ ។ លោកប្រធានចៅក្រមបានពន្យល់ប្រាប់ពីសិទ្ធិ និងករណីកិច្ចរបស់ ហ៊ីម ហ៊ុយ ជាពិសេសសិទ្ធិរបស់គាត់ដែលមានចែងក្នុងវិធាន២៨(៩) ដើម្បីស្នើសុំអ្នកប្រឹក្សា ប្រសិនបើបញ្ហាការដាក់ពិរុទ្ធភាពលើខ្លួនឯងកើតមានឡើង ។ ហ៊ីម ហ៊ុយ បានជម្រាបប្រាប់ចៅក្រមថាគាត់មិនបានរៀបចំខ្លួនដើម្បីនិយាយនៅឡើយទេ ហើយចង់ប្រឹក្សាជាមួយនឹងមេធាវីម្នាក់ ។ ខណៈពេលដែលការពន្យល់ណែនាំមិនមានភាពច្បាស់លាស់ ហ៊ីម ហ៊ុយ បានពន្យល់ប្រាប់ថា គាត់បានជួបលោក គង់ សំអុន ដែលជាមេធាវីរបស់ ម៉ម ណៃ «តិចតួចប៉ុណ្ណោះ» ។ លោកប្រធានចៅក្រមបានពន្យារដំណើរការនីតិវិធីនៅពេលដំបូងដើម្បីអនុញ្ញាតឲ្យ ហ៊ីម ហ៊ុយ បានជួបជាមួយនឹងមេធាវី គង់ សំអុន ។

ខណៈពេលដែលខ្ញុំយល់ថានៅក្នុងវិធានទី ២៨(៩) សាក្សីគួរតែត្រូវបានផ្តល់ឲ្យនូវមេធាវីមួយរូប ប្រសិនបើបញ្ហាការដាក់ពិរុទ្ធភាពលើខ្លួនឯងកើតមានឡើងនៅក្នុងដំណើរការនីតិវិធីតើមានហេតុផលដែរឬទេហេតុអ្វីបានជាផ្នែកជំនួយការជំនាញដល់សាក្សីមិនអាចសួរថាតើសាក្សីតម្រូវឲ្យមានអ្នកប្រឹក្សាធ្វើឡើងមុនពេលដំណើរការនីតិវិធី? ក្រោយពីដំណើរនីតិវិធីត្រូវបានពន្យារពេលកាលពីថ្ងៃច័ន្ទ ដើម្បីឲ្យ ម៉ម ណៃ អាចប្រឹក្សាជាមួយនឹងមេធាវីចាត់តាំងថ្មីម្នាក់នោះ ខ្ញុំរំពឹងទុកថានឹងមាននរណាម្នាក់នឹងបានសួរនាំពីករណីរបស់ ហ៊ីម ហ៊ុយ ដើម្បីចៀសវាងការរំខានដល់ដំណើរការនីតិវិធីជាលើកទីពីរក្នុងសប្តាហ៍នេះសម្រាប់ហេតុផលដូចគ្នា ។

**ឡូរ៉ា ម៉ាកដូណាល**

# ការចូលរួមរបស់ចាមម៉ូស្លីមនៅក្នុងការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម

## តើមេដឹកនាំខ្មែរក្រហមនឹងត្រូវចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ដែរឬទេ?

ការជួបពិភាក្សាជាមួយប្រជាជននៅវិហារម៉ូស្លីមពីរនៅខេត្តកំពត ត្រូវបានរៀបចំឲ្យមានការចូលរួមពីប្រជាជនចាមប្រមាណជា ៣៥០ នាក់ ការពិភាក្សានេះនិយាយអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ការអប់រំនិងដំណើរការនីតិវិធីកាត់ទោសមេដឹកនាំខ្មែរក្រហមទាំង ៥ នាក់ ដែលកំពុងបន្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ខណៈពេលដែលការគ្រប់គ្រងជិតបួនឆ្នាំរបស់ខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ត្រូវទទួលខុសត្រូវចំពោះការស្លាប់របស់ប្រជាជនកម្ពុជាប្រមាណមួយភាគបួននៃប្រជាជនសរុប ឧក្រិដ្ឋកម្មនេះបានបន្សល់ទុកនូវស្លាកស្នាមដែលមិនអាចបំភ្លេចបានដល់ប្រជាជន ។ ក្នុងអំឡុងពេលប្រជុំពិភាក្សា ខណៈពេលដែលនិយាយអំពីរបបនោះ អ្នកចូលរួមភាគច្រើនមិនអាចស្វែងរកពាក្យអ្វីមកបង្ហាញពីស្ថានភាពរស់នៅដ៏លំបាករបស់ខ្លួននៅពេលនោះបានឡើយ ។

ជាមួយនឹងយុត្តិធម៌ដែលនឹងកើតមាន ប្រជាជនចាមដែលមានចំនួនច្រើនជាងគេទីពីរនៅក្នុងប្រទេសកម្ពុជាបានសម្រេចប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីអប់រំកូនចៅជំនាន់ក្រោយអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ អំឡុងពេលប្រជុំពិភាក្សា អ្នកចូលរួមជាច្រើនបាននិយាយថា ដំណើរការសិក្សាស្វែងយល់មានតម្លៃសម្រាប់ប្រជាជនទាំងអស់ ។ អត្ថបទនេះនឹងពិភាក្សាអំពីតួនាទីជាប្រវត្តិសាស្ត្រដើម្បីអប់រំក្មេងៗជនជាតិចាមអំពីរបបខ្មែរក្រហម និងទស្សនៈអំពីការបញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សានៅសាលារដ្ឋ ។

**ការសិក្សាអំពីអតីតកាលទាក់ទងនឹងខ្មែរក្រហម**

ប្រវត្តិសាស្ត្រផ្ទាល់មាត់បានចាក់ឫសនៅក្នុងវប្បធម៌របស់



ខ្មែរអ៊ីស្លាមចូលរួមស្តាប់ការណែនាំពីដំណើរការរបស់តុលាការខ្មែរក្រហម

កម្ពុជា ហើយអំណាចនៃការប្រាប់រឿងប្រវត្តិសាស្ត្រមានសារសំខាន់ក្នុងការជួយដល់ប្រជាជនឲ្យបានរំលែកនូវរឿងរ៉ាវរបស់គេទៅឲ្យកូនចៅជំនាន់ក្រោយ ។ នេះគឺជាហេតុផលដែលប្រជាជនជាច្រើនបានចាប់ផ្តើមនិយាយអំពីបទពិសោធន៍ដែលខ្លួនបានជួបប្រទះក្នុងរបបខ្មែរក្រហមទៅកាន់កូនចៅជំនាន់ក្រោយ ។ អ្នកដែលឆ្លងកាត់របបខ្មែរក្រហមបានប្រាប់ក្មេងៗអំពីការជម្លៀសការដាក់ឲ្យនៅបែកគ្នា ការអត់ឃ្លាន ការសម្លាប់ ការធ្វើទារុណកម្ម ភាពភ័យខ្លាច និងការធ្វើទុក្ខបុកម្នេញលើសាសនា ដែលខ្លួនបានចងចាំនិងបទពិសោធន៍ដែលគេបានជួបប្រទះផ្ទាល់ ។ ដំណើរការនៃការប្រាប់នេះបានដំណើរការអស់រយៈពេល៣០ឆ្នាំមកហើយ ។

ហាជី សាឡេស អាយុ៨០ឆ្នាំបាននិយាយថា ការប្រាប់កូនចៅជំនាន់ក្រោយអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហមថាមានសារសំខាន់សម្រាប់ជួយឲ្យក្មេងៗយល់ដឹងអំពីរបបនោះ និងដើម្បីការពារកុំឲ្យរបបដ៏ឃោរឃៅនេះកើតមានម្តងទៀតនៅអនាគត ។ គាត់បានបន្ថែមទៀតថា គាត់ត្រូវតែ «ចងចាំ» ដើម្បីគេចពីអំពើដ៏សាហាវឃោរឃៅនោះ ហើយត្រូវតែ «ចងចាំ» ដើម្បីឆ្ពោះទៅមុខ ។ កូនរបស់គាត់ម្នាក់ដែលបានបញ្ជូនទៅកងកុមារត្រូវបានដុតរំលាយដោយមិនមានការអនុញ្ញាតពីគាត់ ។ គាត់មិនត្រូវបានអនុញ្ញាតឲ្យទៅសួរសុខទុក្ខកូនរបស់គាត់មុនពេលកូនរបស់គាត់ស្លាប់នោះទេ ។ ខ្មែរក្រហមបាននិយាយថា គាត់មិនចាំបាច់ទៅទេ ពីព្រោះគាត់មិនមែនជាគ្រូពេទ្យ ។ គាត់មានអារម្មណ៍ថា អន់ចិត្តនឹងខ្មែរក្រហមដែលបានដុតកូនរបស់គាត់ ពីព្រោះវាខុសពីប្រពៃណីសាសនាអ៊ីស្លាម ។

ដោយធ្វើការរៀបរាប់ពីការធ្វើទុក្ខបុកម្នេញលើសាសនានិងការហាមឃាត់មិនឲ្យប្រើភាសា ណូ ហាលីម៉ា បាននិយាយថា ខ្មែរក្រហមបានបង្ខំឲ្យគាត់ហូបសាច់ជ្រូក មិនឲ្យមានការប្រណិប័តន៍សាសនា ហើយមិនឲ្យនិយាយភាសាចាម ពីព្រោះខ្មែរក្រហមបានចាត់ទុកភាសាចាមជាភាសាបរទេស ។ ប៉ុន្តែគាត់មិនអាចហូបសម្លសាច់ជ្រូក បោះបង់ការសំពះ និងការប្រណិប័តន៍សាសនាឡើយ ។ គាត់បានសុំពេលវេលាខ្មែរក្រហមដើម្បីសម្របនឹងគោលនយោបាយរបស់ខ្មែរក្រហមទាំងនោះ ។ ហាលីម៉ា ឈប់និយាយចាមតែម្តងនៅពេលដែលឈ្លបខ្មែរក្រហមម្នាក់បានព្រមានសម្លាប់គាត់ ។ ទោះជាយ៉ាងនេះក្តី គាត់អាចប្រើប្រាស់ភាសាចាមបន្តិចបន្តួចដើម្បីទំនាក់ទំនងជាមួយបងប្អូនរបស់គាត់ដើម្បីគោលបំណងខ្លះ ។ ស្រដៀងគ្នានេះដែរ តែ អាមីណាស មានភាពភ័យខ្លាចចំពោះកម្មាភិបាលខ្មែរក្រហមក្មេងៗដែលគម្រាមសម្លាប់គាត់ ហើយហាមមិនឲ្យគាត់ប្រណិប័តន៍សាសនាអ៊ីស្លាម ។ គាត់បានប្រាប់រឿងនេះទៅកូនរបស់គាត់ជារៀងរាល់ថ្ងៃ ពីព្រោះគាត់ព្រួយបារម្ភអំពីអនាគតកូននិងក្មេងៗជំនាន់ក្រោយដែលដឹងពីរឿងខ្មែរក្រហមបន្តិចបន្តួចឬមិនជឿថារបបនោះពិតជាធ្លាប់កើតមានទេ ។

មហាម៉េត អាលី ក៏បាននិយាយថា គាត់មានទុក្ខវេទនាណាស់នៅក្នុងរបបខ្មែរក្រហម ។ គាត់បានលួចបូតហូបស្រូវដោយសារតែគាត់ឃ្លានខ្លាំងពេក ។ អាលី បានរអ៊ូរទាំថា ក្មេងៗជំនាន់ក្រោយខ្លះ «មិនជឿទៅលើរឿងនេះទេ ទាល់តែគេបានជួបប្រទះ» ។ រឿងនេះធ្វើឲ្យឪពុកម្តាយជាច្រើនព្រួយបារម្ភអំពីឥរិយាបថរបស់ក្មេងៗទៅលើរបបខ្មែរក្រហម ដូច្នេះឪពុកម្តាយនៅតែបន្តប្រាប់ក្មេងៗជំនាន់ក្រោយអំពីអំពើឃោរឃៅរបស់ខ្មែរក្រហមដើម្បីរំសាយទុក្ខ និងដើម្បីការពារកុំឲ្យរឿងនេះកើតមានម្តងទៀត ។ អាស្រ័យហេតុនេះ កម្មវិធី «ផ្សារភ្ជាប់យុវជនជាមួយឪពុកម្តាយរបស់គេ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានសារសំខាន់ពីព្រោះវាផ្តល់តម្លៃទៅឲ្យប្រវត្តិរឿងរ៉ាវរបស់បុគ្គលម្នាក់សម្រាប់ជាយន្តការក្នុងការផ្លាស់ប្តូរពីការព្រួយបារម្ភរបស់អ្នកនៅរស់ទៅជាដំណើរការប្រាប់ការពិតទៅឲ្យកូនចៅជំនាន់ក្រោយ ។ នៅក្នុងកម្មវិធីនេះ យុវជនតម្រូវឲ្យសរសេរប្រវត្តិរឿងទាក់ទងនឹងបទពិសោធន៍ឪពុកម្តាយរបស់គេដែលអាចធ្វើឲ្យយុវជនទាំងនោះអាចដឹងកាន់តែច្រើនពីរបបខ្មែរក្រហម ។ កម្មវិធីក៏មានគោលបំណងចង់បង្កើនទំនាក់ទំនងរវាងឪពុកម្តាយនិងកូន ហើយក៏ដើម្បីធ្វើឲ្យការឈឺចាប់របស់ឪពុកម្តាយមានភាពធូរស្រាលខណៈពេលដែលគាត់ដឹងថាកូនចៅរបស់គាត់យល់ដឹងពីបទពិសោធន៍ដ៏ជូរចត់របស់គាត់ ។

## ការពិភាក្សាអំពីរបបខ្មែរក្រហម

ការអប់រំក្មេងៗជំនាន់ក្រោយអំពីរបបខ្មែរក្រហមមានសារសំខាន់ក្នុងការបង្កើនការយល់ដឹងរបស់គេនិងសម្រាប់ជាឧបករណ៍ការពារកុំឲ្យរបបនេះកើតឡើងម្តងទៀត ។ មានមធ្យោបាយ

ជាច្រើនដើម្បីអប់រំយុវជនអំពីរបបខ្មែរក្រហមដូចជាតាមរយៈការសម្តែងប្រវត្តិសាស្ត្រផ្ទាល់មាត់ កំណាព្យ រឿងប្រលោមលោក ឬបង្រៀននៅក្នុងថ្នាក់រៀន ។ ការបង្រៀននៅក្នុងថ្នាក់រៀនដែលរួមមានដំណើរការអប់រំដ៏យកចិត្តទុកដាក់ត្រូវបានយល់ស្រប ដោយក្រសួងអប់រំយុវជននិងកីឡា ។ ជាលទ្ធផល ក្មេងៗជំនាន់ក្រោយនឹងយល់ដឹងអំពីប្រវត្តិកម្ពុជាប្រជាធិបតេយ្យតាមរយៈផ្នែកមួយនៅក្នុងកម្មវិធីសិក្សានៅសាលាដែលទើបតែបង្កើតឡើង ។

កិច្ចប្រជុំពិភាក្សានៅខេត្តកំពតបានបង្កឲ្យមានសំណួរសំខាន់មួយចំនួនដូចជា ៖ តើករណីចាមមូស្លីមនៅក្រោមរបបខ្មែរក្រហមគឺជាអំពើប្រល័យពូជសាសន៍ឬទេ? ហើយតើត្រូវធ្វើដូចម្តេចដើម្បីការពារអំពើប្រល័យពូជសាសន៍កុំឲ្យកើតមាន? ដោយរៀបរាប់ពីការធ្វើបាប ចាមមូស្លីម លីប យ៉ាកូប បាននិយាយថាគាត់ជឿថាខ្មែរក្រហមបានសម្លាប់ប្រជាជនដោយមានការប៉ុនប៉ងនិងផែនការទុកមុន ។ បើមិនមានការប៉ុនប៉ងនិងផែនការទេ ខ្មែរក្រហមមិនអាចសម្លាប់ប្រជាជនជាប្រព័ន្ធបែបនេះទេ ។ គាត់បានអះអាងថា «ខ្មែរក្រហមបានសម្រេចរួចទៅហើយថាតើអ្នកណាត្រូវរស់ អ្នកណាត្រូវស្លាប់» ។ ប៉ុន្តែវាពិបាកនឹងស្វែងរកភ័ស្តុតាងជាក់លាក់ឬឯកសារសរសេរដោយដៃដើម្បី បញ្ជាក់ថាខ្មែរក្រហមបានប៉ុនប៉ងឬមានផែនការសម្លាប់ចាមមូស្លីមដោយមូលហេតុសាសនានិងពូជសាសន៍ដែលអាចត្រូវបានចាត់ទុកជាអំពើប្រល័យពូជសាសន៍ដោយយោងទៅតាមឯកសារច្បាប់ ។ ទោះបីជាយ៉ាងណាក៏ដោយការស្វែងរកព័ត៌មានទាក់ទងនឹងភ័ស្តុតាងពីអ្នកដែលធ្លាប់ឆ្លងកាត់អាចធ្វើឲ្យអ្នកស៊ើបអង្កេតអាចស្វែងរកភ័ស្តុតាងដែលមានសារសំខាន់ ។ មានកំណត់សម្គាល់ថា ចាមមូស្លីមភាគច្រើនយល់ថាគេទទួលរងនូវទុក្ខវេទនាដោយសារគោលនយោបាយខ្មែរក្រហមដែលប្រើប្រាស់សម្រាប់បំផ្លាញសាសនា ភាសាចាម ការប្រណិប័តន៍សាសនា និងអត្តសញ្ញាណ ។

កិច្ចពិភាក្សាពីរនៅខែកក្កដាអំពីការអប់រំពីអំពើប្រល័យពូជសាសន៍ និងប្រវត្តិសាស្ត្រផ្ទាល់មាត់ដែលអាចពង្រីកចំណេះដឹងរបស់ចាមមូស្លីមអំពីរបបខ្មែរក្រហម និងតុលាការខ្មែរក្រហមបានធ្វើឲ្យកិច្ចពិភាក្សាជុំវិញប្រធានបទនេះមានភាពទូលំទូលាយហើយប្រហែលជាអាចការពារកុំឲ្យអំពើប្រល័យពូជសាន៍កើតមានម្តងទៀត ។ អ្នកចូលរួមទាំងអស់ចង់ចែករំលែកបទពិសោធន៍របស់គេនៅក្នុងក្រុម ។ ការនិយាយរឿងមានសភាពលាន់ឮជាងមុនខណៈពេលដែលអ្នកភូមិបានជួបជុំគ្នានៅក្នុងកិច្ចប្រជុំ ។ ការអានសៀវភៅក៏អាចជួយអ្នកភូមិឲ្យផ្សារភ្ជាប់រឿងផ្ទាល់ខ្លួនរបស់គេទៅនឹងអត្ថបទដែលសរសេររួចហើយដែរ ។ នៅគ្រប់ពេលពិភាក្សាអ្នកចូលរួមក្មេងៗមួយចំនួនត្រូវបានស្នើឲ្យអានចំណុចដកស្រង់ដែលទាក់ទងនឹងប្រជាជនចាម ។ ប្រជាជនចាមភាគច្រើនបាននិយាយ



សកម្មភាពចែកសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ទៅឲ្យប្រជាជនខ្មែរ

ថាអត្ថបទនោះមានសាច់រឿងស្រដៀងនឹងបទពិសោធន៍របស់គេផ្ទាល់ទោះបីជាអត្ថបទនោះមិនបានរៀបរាប់ឲ្យលម្អិតក៏ដោយ ។

បុរសអាយុ៨៧ឆ្នាំម្នាក់ឈ្មោះ ស៊ីម សាន់ បានបង្ហាញពីអារម្មណ៍របស់គាត់ទៅលើការទស្សនា សវនាការនិងការស្វែងយល់អំពីការកាត់ទោសចុងចោទដែលជាមេដឹកនាំខ្មែរក្រហម ។ គាត់បានរំឭកពីបទពិសោធន៍ជីវិតរបស់គាត់ក្នុងអំឡុងរបបខ្មែរក្រហម

បន្ទាប់ពីគាត់ត្រូវបានជម្លៀសទៅភ្នំវល្លិ៍ក្នុងខេត្តកំពត ។ គាត់បាននិយាយថា ភាពភ័យខ្លាច ការធ្វើការហួសកម្លាំង និងការខ្វះខាតអាហារគឺជាពេលដែលពិបាកជាងគេសម្រាប់គាត់ដែលជាក្មេងនៅជំនាន់ខ្មែរក្រហម ។ គាត់ចង់ស្វែងរកការពិត ហើយគាត់គាំទ្រនឹងការដាក់បញ្ចូលការអប់រំអំពើប្រល័យពូជសាសន៍ទៅក្នុងថ្នាក់រៀន ។

ដើម្បីឆ្លើយតបនឹងសំណួរអំពីការដាក់ទោសមេដឹកនាំខ្មែរក្រហម នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ បាននិយាយថា ការបង្រៀនអំពើប្រល័យពូជសាសន៍នៅក្នុងថ្នាក់រៀន



អាចបម្រើមុខងារច្រើន ហើយការបង្រៀននេះគឺជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយជាច្រើនដែលអាចរួមចំណែកក្នុងការដាក់ទោសរបបខ្មែរក្រហម ។ តែ អាមីណាស យល់ស្របនឹងចម្លើយនេះ ហើយបាននិយាយថាគាត់មិនអាចអភ័យទោសឲ្យ ឌុច និងមេដឹកនាំខ្មែរក្រហមផ្សេងទៀតបានទេពីព្រោះអ្នកទាំងនេះបានប្រព្រឹត្តឧក្រិដ្ឋកម្មយ៉ាងធ្ងន់ធ្ងរទៅលើគ្រួសាររបស់គាត់និងប្រជាជនកម្ពុជាផ្សេងទៀត ។ ខ្មែរក្រហមត្រូវទទួលខុសត្រូវចំពោះការស្លាប់របស់ប្តី និងកូនគាត់ ព្រមទាំងការធ្វើឲ្យគាត់ក្លាយជាស្ត្រីមេម៉ាយ ។ គាត់មិនត្រឹមតែអាណិតខ្លួនគាត់ប៉ុណ្ណោះទេ តែថែមទាំងអាណិតស្ត្រីមេម៉ាយ និងក្មេងកំព្រាផ្សេងទៀតដែលនៅរស់ពីរបបខ្មែរក្រហម ។ គាត់ចង់ឲ្យខ្មែរក្រហមទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលគេបានប្រព្រឹត្តមុនពេលដែលអ្នកទាំងនោះធ្វើការសុំអភ័យទោស ។ គាត់សប្បាយចិត្តនឹងឮថាក្មេងៗជំនាន់ក្រោយនឹងសិក្សាពីរបបនេះនៅសាលារដ្ឋ ។ ការជួបជុំគ្នាបង្កឲ្យមានកិច្ចពិភាក្សាដ៏ល្អមួយនិងផ្តល់ឱកាសដល់អ្នកភូមិអាចបញ្ចេញសំឡេង និងបង្ហាញពីការព្រួយបារម្ភរបស់គាត់ ។

## សេចក្តីសន្និដ្ឋាន

របបខ្មែរក្រហមបានធ្វើឲ្យប្រជាជនកម្ពុជាទាំងអស់ទទួលរងនូវការឈឺចាប់ដែលមិនអាចរៀបរាប់បាន ។ ប្រជាជនចាមត្រូវបានធ្វើបាបនិងហាមឃាត់មិនឲ្យមានការប្រណិប័តន៍សាសនាវប្បធម៌និងប្រពៃណី ព្រមទាំងហាមមិនឲ្យនិយាយភាសាចាម ។ ទាំងនេះគឺជាហេតុផលដែលប្រជាជនចាមដែលមានវ័យចំណាស់នៅតែប្រាប់បទពិសោធន៍ដែលគេបានជួបប្រទះតាមរយៈមធ្យោបាយផ្សេងៗគ្នា ។ ការប្រាប់រឿងគឺជាវិធីសាស្ត្រធម្មតាបំផុតដែលប្រជាជនប្រើប្រាស់ជាលក្ខណៈមិនផ្លូវការដើម្បីអប់រំកូនៗរបស់ខ្លួន ។ ឪពុកម្តាយខ្លះស្ទើតែនិយាយរៀបរាប់លម្អិតអំពីបទពិសោធន៍នេះ ហើយជំរុញឲ្យកូនៗរបស់ខ្លួនសរសេររឿងនោះដើម្បីជាផ្នែកមួយសម្រាប់គម្រោងប្រវត្តិសាស្ត្រផ្ទាល់មាត់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដោយដឹងថាការបង្រៀនអំពើប្រល័យពូជសាសន៍នឹងដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅសាលារដ្ឋ អ្នកភូមិភាគច្រើនបានបង្ហាញពីការពេញចិត្ត ពីព្រោះវានឹងធ្វើឲ្យកូនៗរបស់គាត់យល់ដឹងពីរបបខ្មែរក្រហម ។ ជាងនេះទៅទៀតកូនៗរបស់គាត់អាចយល់ដឹងលម្អិតពីរបបនោះកាន់តែច្រើនជាងមុន ហើយនឹងជឿទៅលើរឿងរ៉ាវដែលកើតឡើងទៅលើឪពុកម្តាយរបស់គេ ។ យន្តការនេះអាចជួយដល់សង្គមកម្ពុជាដែលរួមមានសហគមន៍ចាមឲ្យប្រែក្លាយការចងចាំដ៏ឈឺចាប់របស់គេទៅជាការអប់រំវិញ ។

**ស្វ ហ្សារីណា និង លី សុខឃាង**

# ជីវិតទាសករពលកម្មរបស់ ឌុច

## «ការលត់ដំខ្លួន» នៅព្រៃស

ថ្ងៃនេះ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានឆ្លើយនឹងសំណួររបស់ចៅក្រមទាក់ទងនឹងប្រតិបត្តិការនៅគុកព្រៃសដែលជាកន្លែងឃុំឃាំងដ៏សម្ងាត់មួយទៀតស្ថិតនៅក្រោមអំណាចរបស់ ឌុច ដែលមានឈ្មោះថា មន្ទីរស-២៤ ។

ទោះបីជាតាមរយៈដំណើរការនីតិវិធីមន្ទីរស-២៤ សំដៅទៅលើ «កន្លែងលត់ដំខ្លួន» ក៏ដោយ ក៏ ឌុច បានបញ្ជាក់យ៉ាងច្បាស់នៅថ្ងៃនេះថា កន្លែងលត់ដំខ្លួននេះគឺគ្រាន់តែជាអគារខាងមុខប៉ុណ្ណោះ ចំណែកឯមន្ទីរស-២៤ ទើបជាកន្លែងទាសករពលកម្មពិតប្រាកដដែលផ្តល់ប្រយោជន៍ដល់គោលនយោបាយសម្ងាប់បំផុតពូជរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ខណៈពេលដែលចំនួនអ្នកទោសនៅមន្ទីរ ស-២៤ មិនទាន់មានភាពច្បាស់លាស់នៅឡើយ ហើយអាចនឹងនៅក្នុងស្ថានភាពបែបនេះដដែលនោះ យើងបានដឹងថាក្នុងចំណោមអ្នកទោសរាប់រយ ឬរាប់ពាន់នាក់ដែលបានជាប់ឃុំឃាំងនៅទីនោះ មានតែអ្នកទោស៣០នាក់ប៉ុណ្ណោះត្រូវបានដោះលែងដែលអ្នកទាំងនោះគឺជាកងយោធាដែលត្រូវបញ្ជូនត្រឡប់ទៅកងរបស់ពួកគេវិញ ។ ចំណែកឯអ្នកទោសទាំងអស់ដែលនៅសល់ត្រូវបានបញ្ជូនទៅគុកទួលស្លែង (មន្ទីរស-២១) ឬក៏ទៅវាលពិឃាដជើងឯក ដែលនៅទីនោះពួកគេត្រូវទទួលរងការធ្វើទារុណកម្ម ឬសម្ងាប់ចោល ។

សម្រាប់អ្នកទោសដែលបញ្ជូនទៅមន្ទីរស-២១ ត្រូវបានចាត់ទុកថាជា «ខ្មាំង» របស់បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវតែកម្ទេចចោល ចំណែកអ្នកទោសនៅមន្ទីរស-២៤វិញ ត្រូវបានចាត់ទុកថា «សមាសភាព» ពីព្រោះថាមិនមានភាពច្បាស់លាស់ណាមួយឲ្យដឹងថា ពួកគេជាខ្មាំង ឬមិត្តនោះទេ ។ ការត្រិះរិះពិចារណារបស់បក្សកុម្មុយនីស្តកម្ពុជាហាក់បីដូចជាថាអ្នកទោសដែលមានឋានៈមិនច្បាស់លាស់ទាំងអស់នោះគួរតែបញ្ជូនទៅកាន់កន្លែងធ្វើការងារពលកម្មដោយបង្ខំដើម្បីធ្វើការងារ និងទទួលការឃ្លាំមើលដើម្បី



ឌុច នៅក្នុងអង្គសវនាការ

ធានាថាអ្នកទោសទាំងអស់នេះនឹងមិនបង្កបញ្ហាដល់បក្សកុម្មុយនីស្ត កម្ពុជាឡើយ ។ «សមាសភាព» ដែលបញ្ជូនទៅកាន់មន្ទីរស-២៤ គឺភាគច្រើនសុទ្ធតែជាប្រពន្ធ កូន ឬក៏ជាសាច់ញាតិរបស់អ្នកទោស ដែលបញ្ជូនទៅមន្ទីរស-២១ ។ អ្នកទោសទាំងអស់មិនបានប្រាប់ពីមូលហេតុចំពោះការឃុំឃាំង ឬផ្តល់ឱកាសឲ្យដឹងទាស់ឡើយ ។

សមាសភាព ត្រូវបានបែងចែកជាបីប្រភេទគឺ ល្អ មធ្យម និងអាក្រក់ ដោយផ្អែកទៅលើសកម្មភាពប្រឆាំងដែលពួកគេបានធ្វើ ។ អ្នកទោសដែលនៅក្នុងប្រភេទអាក្រក់ត្រូវបានគេតាមដាន និងឃុំឃាំងនៅកន្លែងដ៏មានសុវត្ថិភាពបំផុត រួចហើយត្រូវបញ្ជូនទៅមន្ទីរស-២១ យ៉ាងឆាប់រហ័សផងដែរ ។ ទោះបីការប្រព្រឹត្តល្អក៏មិនអាចជួយឲ្យអ្នកទោសផ្លាស់ប្តូរពីប្រភេទមួយទៅប្រភេទមួយទៀតបានដែរ ។

នៅមន្ទីរស-២៤ អ្នកទោសត្រូវបានដកហូតសិទ្ធិជាមូលដ្ឋាន ដូចជាសេរីភាពក្នុងការធ្វើដំណើរ និងសេរីភាពក្នុងការនិយាយស្តី ។ ការថែទាំសុខភាពគឺស្ទើរតែមិនមានទាល់តែសោះ ។ អ្នកទោសនៅមន្ទីរស-២៤ បានផ្តល់ឲ្យនូវរបបអាហារប្រសើរជាងអ្នកទោសនៅមន្ទីរស-២១តែបន្តិចបន្តួចប៉ុណ្ណោះ ពីព្រោះថាអ្នកទោសនៅមន្ទីរស-២៤ ត្រូវការកម្លាំងដើម្បីធ្វើការងារ ។ ខណៈពេលដែល ឌុច មិនមានសិទ្ធិអំណាចលើការសួរចម្លើយ និងការធ្វើទារុណកម្មនៅមន្ទីរស-២៤ ឌុច បានជឿថាលេខារបស់គាត់ គឺសមមិត្ត ហ៊ុយ ប្រហែលជាបានប្រើវិធីសាស្ត្រសួរចម្លើយ និងធ្វើទារុណកម្មដោយមិនមានការដឹងឮពី ឌុច ។

នៅមន្ទីរស-២៤ អ្នកទោសត្រូវបានបង្ខំឲ្យធ្វើពលកម្មដូចជាសត្វធាតុ ។ កម្មាភិបាលបានបង្ខំឲ្យអ្នកទោសធ្វើការនៅតាមវាលស្រែក្នុងរយៈពេលយ៉ាងហោចណាស់ប្រាំបីម៉ោងក្នុងមួយថ្ងៃ ហើយទទួលរងនូវការវាយធ្វើបាបនិងជេរប្រមាថថែមទៀត ប្រសិនបើពួកគេលួចឈប់សម្រាក ។ នៅពេលខែភ្លឺ ពេលខ្លះអ្នកទោសទាំងអស់ត្រូវធ្វើការទាំងយប់ ។ ទោះបីជាការងារផលិតកម្មស្រូវ ជាកិច្ចការចម្បងយ៉ាងណាក្តី ក៏អ្នកទោសត្រូវតែជីកប្រឡាយ ដាំបន្លែ ដំណាំ និងចិញ្ចឹមសត្វផងដែរ ។ នៅពេលដែលត្រូវសួរថា តើអ្នកទោសពេលខ្លះត្រូវបានបង្ខំឲ្យអូសនង្គ័លដូចសត្វពាហនៈដែរឬទេ? ឌុច បាននិយាយថា «ខ្ញុំមិនអាចនិយាយថាទេបានទេ» ។ ចំណែកឯក្មេងៗវិញ ត្រូវដើរចាប់កណ្តុរពេលយប់ ។

អ្នកទោសទាំងអស់ក៏ត្រូវបានបង្ខំឲ្យចូលរួម «ការប្រជុំទិតៀន» ប្រចាំសប្តាហ៍ដែលនៅខណៈពេលនោះអ្នកទោសត្រូវធ្វើការវិភាគទៅលើភាពស្មោះត្រង់របស់ខ្លួន និងភាពស្មោះត្រង់របស់មិត្តខ្លួន ។ ដោយមិនរាប់បញ្ចូលលទ្ធផលនៈដែលអ្នកទោសមាននៅក្នុងចិត្ត កម្មាភិបាលក៏បានត្រួតពិនិត្យ និងតាមដានស៊ើបការណ៍ពីការសន្ទនាផ្ទាល់ខ្លួនរបស់អ្នកទោសផងដែរ ។ ខណៈពេលដែលព័ត៌មានអវិជ្ជមានត្រូវបានប្រមូលគ្រប់គ្រាន់ កម្មាភិបាលបានរាយការណ៍ទៅ ឌុច ដែលជាអ្នកសម្រេចថាតើអ្នកទោសទាំងនោះគួរតែបញ្ជូនមកមន្ទីរស-២១ ឬទៅកាន់វាលពិឃាតជើងឯកដើម្បីសម្លាប់តែម្តង ។ ទោះបីជាខិតខំធ្វើការលំបាកយ៉ាងណាក្តី ឬខំសម្តែងនូវអាកប្បកិរិយាល្អប៉ុនណាក៏ដោយ ក៏អ្នកទោសម្នាក់ៗត្រូវបានកម្ទេចចោលទាំងអស់ ។

ដូចគ្នានឹងមន្ទីរស-២១ និងជើងឯក យុទ្ធសាស្ត្រដាក់ស្តែងរបស់ ឌុច គឺធ្វើយ៉ាងណាឲ្យខ្លួនគាត់មានភាពឃ្លាតឆ្ងាយពីប្រតិបត្តិការប្រចាំថ្ងៃនៅមន្ទីរស-២៤តាមដែលអាចធ្វើបាន ។ ឌុច បានអះអាងថា គាត់បានទៅកាន់មន្ទីរស-២៤តែបួនដងគត់ និងមិនដែលបានធ្វើការត្រួតពិនិត្យ និងតាមដានពីស្ថានភាពនៅទីនោះឡើយ ។ ឌុច គ្រាន់តែទទួលបានព័ត៌មានតាមរយៈរបាយការណ៍ប្រចាំថ្ងៃរបស់មិត្ត ហ៊ុយ ប៉ុណ្ណោះ ។ ទោះបីជាការដឹងឮអំពីប្រតិបត្តិការរបស់មន្ទីរស-២៤របស់ ឌុច មានការខ្វះខាតក៏ដោយ ក៏អំណាចរបស់ ឌុច នៅមន្ទីរស-២៤ មានភាពច្បាស់លាស់ណាស់ ។ ឌុច បានរក្សានូវគោលជំហរថា មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាមានអំណាចចាប់ខ្លួនប្រជាជននិងបញ្ជាឲ្យបញ្ជូនពួកគេមកមន្ទីរស-២៤ ។ ប៉ុន្តែខណៈពេលដែលអ្នកទាំងនោះបានបញ្ជូនមកដល់មន្ទីរស-២៤ ឌុច គឺជាអ្នកធ្វើការសម្រេច ។ ឌុច ក៏បានទទួលស្គាល់ថាគាត់តែម្នាក់ឯងដែលជាអ្នកសម្រេចថាតើកម្មាភិបាលនៅមន្ទីរស-២៤ ត្រូវតែបញ្ជូនមកកាន់មន្ទីរស-២១ ឬថាតើអ្នកទោស គួរតែត្រូវកម្ទេចចោលភ្លាមៗនៅឯជើងឯក ជាជាងសួរចម្លើយអ្នកទោសទាំងនោះនៅមន្ទីរស-២១ ។

រៀងរាល់ថ្ងៃ ឌុច បានផ្តល់នូវបម្រែបម្រួលជាច្រើនលើកដែលមានដូចតទៅៈ ខ្ញុំមិនឃើញរឿងរ៉ាវនោះដោយផ្ទាល់ភ្នែកទេ

ប៉ុន្តែយោងតាមការវិភាគរបស់ខ្ញុំ ខ្ញុំអាចសន្និដ្ឋានបានថាអំពើបែបនេះ (X) ប្រហែលជាអាចកើតមានឡើង ។ សក្ខីកម្មរបស់ ឌុច ភាគច្រើនប្រកបដោយសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួននិងការវិភាគលើឯកសារសេសសល់ដែល ឌុច បានធ្វើការសិក្សាក្នុងអំឡុងពេលដំណើរការនីតិវិធី ជាជាងការចងចាំផ្ទាល់ខ្លួនរបស់គាត់ ។ ដូច្នេះហើយបានជាចម្លើយដែលផ្អែកលើទស្សនៈរបស់ ឌុច មានភាពប្រហាក់ប្រហែលនឹងសក្ខីកម្មដ៏ជំនាញក្នុងតុលាការរបស់អាមេរិក ។

## សហព្រះរាជអាជ្ញាអន្តរជាតិនឹងលាលែងឈប់នៅថ្ងៃទី១ ខែកញ្ញា

កាលពីម្សិលមិញ បន្ទាប់ពីបានប្រកាសអំពីការលាលែងនៅថ្ងៃទី១ ខែកញ្ញា ខាងមុខនេះ ដោយសារតែ «បញ្ហាគ្រួសារ និងបញ្ហាផ្ទាល់ខ្លួន» ប្រធានសហព្រះរាជអាជ្ញាអន្តរជាតិ រ៉ូប៊ឺត ពេទីត បានបង្ហាញខ្លួននៅក្នុងសន្និសីទកាសែតប្រចាំសប្តាហ៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅថ្ងៃនេះដើម្បីព្យាយាមធ្វើឲ្យសារព័ត៌មានឈប់ធ្វើសេចក្តីសន្និដ្ឋានតទៅទៀត ។ លោក ពេទីត បាននិយាយម្តងហើយម្តងទៀតថាមូលហេតុលាលែងរបស់គាត់គឺពិតជាទាក់ទងនឹងបញ្ហាផ្ទាល់ខ្លួនពិតមែន ហើយក៏មិនមានជាប់ពាក់ព័ន្ធជាមួយនឹងទំនួលខុសត្រូវរបស់គាត់នៅក្នុងតុលាការដែរ ។ ក្នុងចំណោមការនិយាយបំផ្លើសទាំងនោះបាននិយាយថា ការលាលែងរបស់លោក ពេទីត គឺដោយសារការមិនព្រមព្រៀងគ្នាជាមួយនឹងសហព្រះរាជអាជ្ញាខ្មែរលើបញ្ហាថាតើគួរតែកោះហៅអតីតមេដឹកនាំខ្មែរក្រហមទៀតឬយ៉ាងណា ។ លោក ពេទីត បានជំរុញមិនឲ្យសារព័ត៌មានជឿលើសារសំខាន់ផ្សេងៗដែលកើតមានទាក់ទងនឹងការលាលែងរបស់គាត់ឡើយ ។

លោក ពេទីត បានបញ្ចេញយោបល់ថា ការលាលែងរបស់លោកមិនបានផ្តល់ផលប៉ះពាល់អ្វីដល់តុលាការឡើយ ជាពិសេសគឺដំណើរការកាត់ទោស ឌុច តែម្តង ។ លោកបានពន្យល់ថា តំណែងរបស់សហព្រះរាជអាជ្ញាបានប្រើប្រាស់នូវកិច្ចពិភាក្សាយោបល់ជាក្រុមដើម្បីត្រួតពិនិត្យមើលដំណើរការអភិវឌ្ឍទៅមុខ ដូច្នេះអនុប្រធានដ៏មានសមត្ថភាពរបស់គាត់ត្រៀមនឹងរៀបចំខ្លួនដើម្បីដឹកនាំក្រុមរហូតដល់សង្កេតឃើញដំណើរលឿនទៅមុខ បន្ថែមពីនេះលោក ពេទីត បានពន្យល់ថា បញ្ហាមិនព្រមព្រៀងគ្នារបស់លោកជាមួយនឹងសហព្រះរាជអាជ្ញាខ្មែរ ត្រូវបានសង្ខេបយ៉ាងខ្លី និងបានប្រគល់ជូនដល់អង្គបុរេជំនុំជម្រះដែលឯកសារនោះពោរពេញទៅដោយព័ត៌មានដែលចាំបាច់ ដើម្បីធ្វើសេចក្តីសម្រេច ។ លោក ពេទីត បានផ្តល់សេចក្តីបញ្ជាក់ជាទូទៅមួយដោយចំពោះលើតុលាការអន្តរជាតិដទៃទៀតថា ចៅក្រមទាំងអស់សុទ្ធតែធ្លាប់មានបទពិសោធន៍ទាក់ទងនឹងការផ្លាស់ប្តូរបុគ្គលិកសំខាន់ ទោះបីជាមិនរាប់បញ្ចូលចៅក្រមដែលបាត់បង់នូវភាពជាសមាជិកក៏ដោយ ក៏គ្មានផលប៉ះពាល់ណាមួយកើតមានឡើងក្នុងករណីសុំលាលែងនេះដែរ ។

បញ្ហាដាច់ដោយឡែកមួយទៀត លោក ពេទីត បានអធិប្បាយអំពីបញ្ហាមួយចំនួនដែលតុលាការបានប្រឈមមុខ ។ លោកបានចាត់ទុកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែល «ស្ថិតនៅក្រោមមូលនិធិ និងក្រោមធនធាន» សម្រាប់កិច្ចការដែលតុលាការនេះបានប្រគល់ការទទួលខុសត្រូវទៅឲ្យ ។ លោក ពេទីត បានបញ្ចេញមតិថា តុលាការមិនបានបំពេញតួនាទីល្អនៅឡើយទេដោយមិនបានធ្វើទំនាក់ទំនងជាមួយនឹងប្រជាជនកម្ពុជាថាតើតុលាការកំពុងតែធ្វើអ្វីខ្លះ និងដោយសារមូលហេតុអ្វីខ្លះ ។ លោកក៏បានពន្យល់បន្ថែមថា បញ្ហានេះនឹងក្លាយជាបញ្ហាស្មុគស្មាញសម្រាប់តុលាការក្នុងការបន្សល់ទុកនូវកេរមរតកដ៏មានន័យនិងយូរអង្វែងមួយ ។ លោក ពេទីត ក៏បាននិយាយផងដែរថា តុលាការក៏បានប្រឈមមុខនឹងបញ្ហាខាងក្រៅផងដែរ ។ ដោយនិយាយបញ្ចិតបញ្ចៀងទៅកាន់អន្តរាគមន៍ផ្នែកនយោបាយវិញ លោក ពេទីត បាននិយាយថា លោកមានអារម្មណ៍ថា «រំខាន» ពីព្រោះថាមន្ត្រីដែលជាប់ឆ្នោត និងមន្ត្រីរបស់បក្សនយោបាយដទៃទៀតគិតថាពួកគេអាចប្រាប់តុលាការបានថាតើតុលាការគួរតែធ្វើអ្វីខ្លះ ។ វាត្រូវបានជឿជាក់ជាទូទៅថាមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាឲ្យសហព្រះរាជអាជ្ញាជាតិមិនឲ្យបន្តការកោះហៅមេដឹកនាំខ្មែរក្រហមដទៃទៀតមកធ្វើការកាត់ទោសឲ្យលើសពីមេដឹកនាំទាំងប្រាំដែលស្ថិតនៅក្នុងដំណើរការកាត់ក្តីនោះ ។

មន្ត្រីកិច្ចការសាធារណៈបាននិយាយថា ពួកគេសង្ឃឹមថាសហព្រះរាជអាជ្ញាអន្តរជាតិថ្មីនឹងត្រូវបានតែងតាំងមុនពេលការលាលែងរបស់លោក ពេទីត ។ ប៉ុន្តែពួកគេបានបដិសេធមិនបញ្ចេញយោបល់ថាតើសហព្រះរាជអាជ្ញាអន្តរជាតិថ្មីនោះអាចជានរណាទេ ។

**ឡូរ៉ា ម៉ាក់ដូណាល**

# សន្តិភាព យុត្តិធម៌ និងការផ្សះផ្សា គួរតែប្រកាន់ខ្ជាប់ក្នុងចិត្តប្រជាជនខ្មែរដែលទៅរស់នៅទីក្រុងស៊ីដនី

«ដោយគ្មានក្តីសង្ឃឹមទុកជាមុន ខ្ញុំបានប្រែក្លាយខ្លួនឯងពីអតីតជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យមកជាមនុស្សម្នាក់ដែលជាអ្នកអនុវត្តការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលធ្វើការស្វែងរកការពិត យុត្តិធម៌ និងការផ្សះផ្សាសម្រាប់ប្រជាជនខ្មែរក្នុងប្រទេស ។ ខ្ញុំទទួលបាននូវឱកាសដ៏ល្អដើម្បីចូលរួមសិក្ខាសាលានៅមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវពីជម្លោះនិងសន្តិភាពរបស់សាកលវិទ្យាល័យស៊ីដនី ។ ខ្ញុំមានគោលបំណងមួយដើម្បីកសាងនូវសន្តិភាព ការពិត យុត្តិធម៌ និងការផ្សះផ្សាសម្រាប់សហគមន៍ជនជាតិខ្មែរនៅស៊ីដនី ។ តើមានប្រជាជនខ្មែរដែលរស់នៅស៊ីដនី ប៉ុន្មាននាក់បានយល់ដឹងពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលត្រូវបានគេស្គាល់ថាជាតុលាការខ្មែរក្រហម? តើគេទាំងអស់គ្នាទទួលបាននូវសន្តិភាព យុត្តិធម៌ ការពិត និងការផ្សះផ្សាពីអ្វីដែលធ្លាប់កើតមានចំពោះគេក្នុងរបបខ្មែរក្រហមដែរឬទេ?

ប្រជាជនខ្មែរដែលរស់នៅក្រៅប្រទេសគួរតែឆ្លើយតបទៅនឹងសំណួរទាំងនេះ និងបញ្ជាក់ពីប្រភេទនៃយុត្តិធម៌ ការពិត សន្តិភាព និងការផ្សះផ្សាដែលគេចង់បាន ។ ខ្ញុំបានជួបជាមួយនឹងប្រជាជនខ្មែរដែលរស់នៅក្រៅប្រទេសមួយចំនួនក្នុងសហគមន៍មួយនៅស៊ីដនី ដូចជា ម៉ម ឆាយ៉ារី ឋិន ញែម ពិសី និងឆេង ។ ពីរនាក់ក្នុងចំណោមអ្នកទាំងនេះ មានការយល់ដឹងយ៉ាងល្អពីដំណើរការនៃតុលាការខ្មែរក្រហម ។ ចំណែកឯម្នាក់ទៀតមានការយល់ដឹងតិចតួចបំផុត និងម្នាក់ទៀតមិនបានដឹងថាមានអ្វីកើតឡើងខ្លះនៅក្នុងតុលាការឡើយ ។ នេះគឺជាកាលៈទេសៈដែលដូចគ្នាសម្រាប់ប្រជាជនក្នុងប្រទេសកម្ពុជាដែរ ។ ប៉ុន្តែអ្វីដែលខុសប្លែកគ្នាគឺថាប្រជាជននៅកម្ពុជាមានឱកាសយល់ដឹងពីដំណើរការរបស់តុលាការខ្មែរក្រហមតាមរយៈវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី និងតាមរយៈអង្គការមួយចំនួន ។ ជាមួយគ្នានេះ យុវជនជំនាន់ក្រោយនឹងសិក្សាអំពីរបបខ្មែរក្រហមតាមរយៈកម្មវិធីសិក្សាជាសាធារណៈរបស់គេតាមសាលារៀននៅក្នុងឆ្នាំខាងមុខនេះ ។

សម្រាប់សហគមន៍នៅ ស៊ីដនី វិញ ខ្ញុំបាននាំយកទស្សនាវដ្តី «ស្វែងរកការពិត» មួយចំនួនទៅជាមួយដែរ ។ ម៉ម ឆាយ៉ារី អ្នកប្រឹក្សាជនអន្តោប្រវេសន៍បានប្រាប់ខ្ញុំក្រោយពីអាហារពេលល្ងាចថាអ្នកដែលមករស់នៅក្រៅប្រទេសស្ទើរតែគ្រប់គ្នាដែលធ្លាប់មានបទពិសោធន៍លំបាកវេទនាក្នុងរបបខ្មែរក្រហមនៅតែចងចាំបទពិសោធន៍លំបាកទាំងនោះដូចជាការធ្វើការងារហួសកម្លាំង ការអត់ឃ្លាន និងការធ្វើទារុណកម្ម ។ «សម្រាប់រូបខ្ញុំ ខ្ញុំនៅតែចងចាំរាល់រឿងរ៉ាវដែលបានកើតឡើងចំពោះខ្ញុំក្នុងអំឡុងរបបខ្មែរក្រហមរហូតដល់ចុងបញ្ចប់នៃជីវិតរបស់ខ្ញុំ ហើយខ្ញុំចង់ឲ្យអ្នកគ្រប់គ្នានៅក្នុងសហគមន៍នេះដឹង និងយល់ពីអ្វីដែលគេទាំងអស់គ្នាត្រូវបានបង្ខំឲ្យទទួលយកនូវភាពមិនពិត អយុត្តិធម៌ និងការគាបសង្កត់ពីកម្មាភិបាលខ្មែរក្រហមដែលបច្ចុប្បន្នកំពុងត្រូវបានដោះស្រាយ ។ ឆាយ៉ារី ជាអ្នករស់នៅក្រៅប្រទេសដែលបានយល់ដឹងយ៉ាងច្រើនពីតុលាការ បាននិយាយរៀបរាប់ពាក្យសម្តីទាំងនេះប្រាប់ខ្ញុំ ។

ប្រជាជនខ្មែររស់នៅក្រៅប្រទេសមួយចំនួនបានបាត់បង់ឪពុកម្តាយ អ្នកជិតខាង និងទ្រព្យសម្បត្តិរបស់គេ ។ ជិត៣០ឆ្នាំក្រោយពីរបបខ្មែរក្រហម តើប្រជាជនទាំងនេះទទួលបាននូវអ្វីមកវិញ? តើគេមានបានទទួលនូវសំណងជំងឺចិត្តអ្វីខ្លះពីរបបខ្មែរក្រហមដែរឬទេ? តាមពិតប្រជាជនទាំងនោះមិនទទួលបានអ្វីសោះឡើយពីរបបនេះ ។ លើសពីនេះ គេទាំងអស់គ្នានៅតែមានអារម្មណ៍តានតឹងផ្លូវចិត្តដោយគ្មានភាពធូរស្បើយសោះឡើយ ។ ឋិន ញែម (ឈ្មោះដែលគេដាក់ឲ្យកាលពីគាត់មករស់នៅប្រទេសអូស្ត្រាលី ហើយឈ្មោះខ្មែររបស់គាត់គឺ ប៊ុនថា) បានបាត់បង់ម្តាយគាត់ក្នុងរបបខ្មែរក្រហម ។ ឋិន ញែម នៅក្មេងណាស់ក្នុងពេលនោះ ។ អារម្មណ៍តានតឹងផ្លូវចិត្តរបស់ ឋិន ញែម នៅតែស្ថិតនៅក្នុងចិត្តគាត់ជានិច្ចរហូតមកដល់ពេលនេះ ។ ដោយធ្វើដំណើរជាមួយគាត់នៅប្រទេសអូស្ត្រាលី ឋិន ញែម បាននិយាយប្រាប់ខ្ញុំពីរឿងរ៉ាវជាច្រើនដូចជាការឃុំឃាំងខ្លួនគាត់ជាមួយនឹងឪពុកម្តាយគាត់នៅ

ឯវត្តសំរោងខ្នុង ខេត្តបាត់ដំបង (ទីតាំងនេះត្រូវបានស៊ើបអង្កេតដោយក្រុមគូរប្លង់ផែនទីរបស់មជ្ឈមណ្ឌលកម្ពុជានៅឆ្នាំ១៩៩៧) ។ ប៊ុនថា បាននិយាយថា «ខ្ញុំបានព្យាយាមរស់នៅដោយគ្មានឪពុកម្តាយ និងតស៊ូធ្វើដំណើរផ្សងព្រេងមកប្រទេសអូស្ត្រាលីតាំងពីឆ្នាំ១៩៨៣» ។ ប៊ុនថា បានបន្តទៀតថា «ជីវិតរបស់ខ្ញុំនាពេលនេះមិនមានបញ្ហាអ្វីទេ ពីព្រោះថាខ្ញុំមានការងារល្អធ្វើនៅប្រទេសអូស្ត្រាលីនេះ ហើយខ្ញុំក៏មានប្រាក់សម្រាប់ផ្គត់ផ្គង់ជីវិតរបស់ខ្ញុំដែរ ។ យ៉ាងណាមិញ ខ្ញុំនៅតែចង់បានជានិច្ចនូវយុត្តិធម៌និងការផ្សះផ្សាពីតុលាការខ្មែរក្រហម ។ ខ្ញុំមិនចង់ឲ្យតុលាការផ្តល់ឲ្យខ្ញុំនូវជីវិតរបស់ឪពុកម្តាយខ្ញុំត្រឡប់មកវិញឡើយ ប៉ុន្តែខ្ញុំចង់ឲ្យតុលាការផ្តល់នូវការពិតដ៏បរិសុទ្ធយុត្តិធម៌និងការផ្សះផ្សាសម្រាប់ប្រជាជនខ្មែរគ្រប់រូបទាំងអស់ ។

ប្រជាជនរស់នៅក្រៅប្រទេសដែលមានវ័យចំណាស់ៗស្ទើរតែទាំងអស់នៅស៊ីដនីតែងតែទៅវត្តដើម្បីបន់ស្រន់មិនត្រឹមតែសម្រាប់សេចក្តីសុខក្នុងជីវិតនៅពេលបច្ចុប្បន្ននិងអនាគតប៉ុណ្ណោះទេ តែក៏សម្រាប់ដួងព្រលឹងជីដូនជីតានិងសាច់ញាតិដែលត្រូវបានសម្លាប់ក្នុងរបបខ្មែរក្រហមដែរ ។ ច្រើនឆ្នាំមុន រាល់ពេលដែលមានពិធីបុណ្យប្រពៃណីខ្មែរ ពេលខ្លះម្តាយរបស់ខ្ញុំបានប្រាប់ឲ្យខ្ញុំបន់ស្រន់សូមឲ្យដួងព្រលឹងរបស់ពូ បងប្រុស និងសាច់ញាតិដទៃទៀតទទួលបាននូវជីវិតល្អប្រសើរនៅជាតិក្រោយ ។ ប៉ុន្តែខ្ញុំមិនត្រូវបាននរណាប្រាប់ថាតើមានរឿងអ្វីខ្លះបានកើតឡើងមុនពេលដែលបងប្អូនសាច់ញាតិរបស់ខ្ញុំបានស្លាប់នោះទេ ។ នេះជាអ្វីដែលខ្ញុំកត់សម្គាល់ឃើញថា ប្រជាជនខ្មែរជាច្រើនតែងតែរក្សានូវភាពស្ងប់ស្ងាត់ចំពោះអ្វីដែលបានកើតឡើងក្នុងគ្រួសារ ពីព្រោះគេទាំងអស់គ្នាគិតថាបញ្ហាពីអតីតកាលអាចប៉ះពាល់ដល់យុវជនជំនាន់ក្រោយបច្ចុប្បន្ននេះ ។ នេះជាកំហុសមួយក្នុងការលាក់បាំងនូវការពិតពីអំពើឃោរឃៅដែលប្រព្រឹត្តឡើងក្នុងអតីតកាល ។ ដើម្បីកសាងនូវសន្តិភាព ស្វែងរកយុត្តិធម៌និងការផ្សះផ្សាសម្រាប់ប្រជាជនដែលឆ្លងកាត់នូវបទពិសោធន៍នៃភាពភ័យរន្ធត់ដែលមិនបានគិតដល់ទាំងអស់នេះនិងដើម្បីតភ្ជាប់នូវអ្វីដែលកើតមានពីអតីតកាល យុវជនជំនាន់ក្រោយគួរតែមានឱកាសដើម្បីធ្វើការស្វែងយល់នូវបញ្ហាទាំងអស់បែបនេះនិងស្វែងរកនូវដំណោះស្រាយដើម្បីការពារសកម្មភាពទាំងអស់នេះនៅពេលអនាគត ។

ខ្ញុំត្រូវបានអញ្ជើញឲ្យចូលរួមក្នុងសិក្ខាសាលាមួយស្តីពីដំណោះស្រាយជម្លោះនៅឯមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវជម្លោះនិងសន្តិភាពកាលពីខែកក្កដា ឆ្នាំ២០០៩ នៅសកលវិទ្យាល័យស៊ីដនី ។ ខ្ញុំបានទទួលការយល់ដឹងយ៉ាងច្រើនពីបទពិសោធន៍ដែលបានកើតមានឡើងក្នុងប្រទេសជាច្រើនដូចជា អាហ្វ្រិកខាងត្បូង រ៉ាន់ដា ទីម័រខាងកើត សេរ៉ាឡេអូន និងប្រទេសក្រោយជម្លោះដទៃទៀត ។ គោលបំណងសំខាន់នៃសិក្ខាសាលានេះគឺដើម្បីធ្វើការផ្លាស់ប្តូរទស្សនៈយោបល់ទាក់ទិននឹងជម្លោះនិងដំណោះស្រាយដែលកើតមានឡើងក្នុងប្រទេសនីមួយៗ ។ ខ្ញុំបានចែករំលែកនូវបទពិសោធន៍របស់ខ្ញុំ ក្នុងនាមជាជនរងគ្រោះនៃរបបខ្មែរក្រហមនិងកិច្ចការរបស់ខ្ញុំនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលព្យាយាមកសាងការពិត សន្តិភាព និងការផ្សះផ្សាសម្រាប់ប្រជាជនខ្មែរទាំងអស់ ។ ក្នុងបទបង្ហាញរបស់ខ្ញុំ ខ្ញុំបានលើកឡើងពីបញ្ហាការងារបច្ចុប្បន្នរបស់ខ្ញុំគឺ «គម្រោងអប់រំស្តីពីអំពើប្រល័យពូជសាសន៍» ពីព្រោះគម្រោងនេះគឺពិតជាមានសារសំខាន់សម្រាប់កសាងសន្តិភាពនិងការផ្សះផ្សាសម្រាប់ប្រជាជនខ្មែរទាំងអស់ ជាពិសេសសម្រាប់យុវជនជំនាន់ក្រោយ ។ ជាមួយគ្នានេះ ខ្ញុំក៏ត្រូវបានគេសួរនូវសំណួរជាច្រើនទាក់ទងនឹងគម្រោងនេះផងដែរ ។

ចុងបញ្ចប់ ខ្ញុំសូមចែករំលែកនូវអ្វីដែលខ្ញុំបានយល់ដឹងពីសន្តិភាព និងជម្លោះរបស់ប្រទេសជាច្រើននៅឯមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវពីជម្លោះ និងសន្តិភាពរបស់សកលវិទ្យាល័យស៊ីដនីទៅកាន់មនុស្សដែលខ្ញុំគិតថាគួរតែដឹង និងយល់ជាពិសេសគឺប្រជាជនខ្មែរដែលរស់នៅស៊ីដនី ។ ខ្ញុំពិតជាចង់ផ្តល់ឲ្យអ្នកទាំងអស់នោះនូវការយល់ដឹងពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងជួយឲ្យគេយល់ពីរបៀបកសាងសន្តិភាព ការពិត យុត្តិធម៌ និងការផ្សះផ្សាក្នុងប្រទេសកម្ពុជា និងប្រទេសដទៃទៀត ។

ខ្ញុំសូមថ្លែងអំណរគុណដល់លោកបណ្ឌិត វីនឌី ឡាមប៊ីន ដែលតែងតែជំរុញលើកទឹកចិត្តនិងបានផ្តល់ឲ្យខ្ញុំនូវឱកាសដើម្បីលើកឡើងនូវបទពិសោធន៍ជាច្រើនរបស់ខ្ញុំក្នុងសិក្ខាសាលានេះ ។

**ផេង ពងរ៉ាស៊ី**

# អតីតកាលរបស់ម្តាយខ្ញុំ

ប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហម បានបន្សល់ទុកនូវបទពិសោធន៍ដ៏ជូរចត់ដល់ប្រជាជនខ្មែរដែលបានឆ្លងកាត់របបដ៏ឃោរឃៅនេះ ដោយបានឆក់យកជីវិតមនុស្សស្លូតត្រង់ជាច្រើននាក់ដោយគ្មានអាណិតអាសូរ ។ រាល់ពេលដែលឮពាក្យខ្មែរក្រហម ខ្ញុំតែងតែស្រមៃឃើញក្រុមមនុស្សដែលមានសម្លៀកបំពាក់ពណ៌ខ្មៅ បង់ក្រមាពណ៌ក្រហមដែលម្តាយរបស់ខ្ញុំតែងតែនិយាយប្រាប់ជានិច្ច ។ ខ្ញុំផ្ទាល់មិនដឹងថាតើបទពិសោធន៍ដែលខ្មែរក្រហមបានបន្សល់ទុកឲ្យប្រជាជនខ្មែរដែលនៅរស់រានមានជីវិតក្នុងពេលសព្វថ្ងៃនេះមានការលំបាកយ៉ាងណានោះទេ ។ ប៉ុន្តែបន្ទាប់ពីបានស្តាប់ការរៀបរាប់របស់ម្តាយខ្ញុំដែលជាក្មេងស្រីជំទង់ម្នាក់នៅក្នុងរបបខ្មែរក្រហមមកនោះមក ខ្ញុំពិតជាមានអារម្មណ៍តក់ស្លុតចំពោះអ្វីដែលខ្មែរក្រហមបានធ្វើចំពោះប្រជាជនរួមជាតិរបស់ខ្លួន ។

ក្នុងអំឡុងពេលនោះ ម្តាយរបស់ខ្ញុំទើបតែមានអាយុ១៣ឆ្នាំ រស់នៅទីក្រុងភ្នំពេញ ជាមួយឪពុកម្តាយរបស់គាត់ ។ ជីតារបស់ខ្ញុំជាសន្តិសុខយាមផ្សារធំថ្មី ចំណែកឯជីដូនរបស់ខ្ញុំរកស៊ីលក់នំបញ្ចុក ។ គាត់រៀនបានត្រឹមតែថ្នាក់ទី១១ចាស់ប៉ុណ្ណោះ ក្រោយមកក៏ឈប់រៀនដើម្បីមកជួយលក់អីវ៉ាន់ម្តាយរបស់គាត់ ។ នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមចូលដល់ភ្នំពេញ ម្តាយរបស់ខ្ញុំក៏ដូចជាក្មេងៗនិងប្រជាជនចាស់ទាំងអស់ដែរបាននាំគ្នាមកមកឈរទះដៃអបអរសាទរនិងលើកទង់សគ្រវី ដោយមើលទៅមានទឹកមុខសប្បាយរីករាយនៅពេលដែលឃើញពួកខ្មែរក្រហមមក ។ ផ្ទុយទៅវិញ ខ្មែរក្រហមដែលសុទ្ធតែមានអាវុធគ្រប់ដៃបានទាញកាំភ្លើងបាញ់ទាហានដែលមកឈរនៅតាមផ្លូវជាមួយនឹងប្រជាជនធម្មតាដោយគ្មានការសួរនាំអ្វីឡើយ ។ ឃើញដូច្នេះ ម្តាយរបស់ខ្ញុំមានភាពតក់ស្លុតយ៉ាងខ្លាំង ហើយក៏សម្រេចចិត្តត្រឡប់មកកន្លែងលក់នំបញ្ចុករបស់ជីដូនខ្ញុំវិញ ។ មិនយូរប៉ុន្មាន នៅពេលល្ងាច កងទ័ពខ្មែរក្រហមបានប្រកាសប្រាប់គ្រួសារនៅក្នុងទីក្រុងភ្នំពេញទាំងអស់ឲ្យរៀបចំអីវ៉ាន់ចេញពីទីក្រុងភ្នំពេញតែរយៈពេលបីថ្ងៃប៉ុណ្ណោះ ដោយសារខ្មែរក្រហមត្រូវការរៀបចំទីក្រុង



ការរស់នៅរបស់ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ម្តងទៀត ។ ពេលនោះគ្រួសារម្តាយរបស់ខ្ញុំនៅតែទៅរកស៊ីលក់ដូរធម្មតា ។ ប៉ុន្តែនៅពេលរសៀលថ្ងៃទីពីរបន្ទាប់ពីខ្មែរក្រហមចូលដល់ភ្នំពេញ កងទ័ពខ្មែរក្រហមបានធ្វើការសម្លុតនិងភ្លង់កាំភ្លើងបង្ខំឲ្យគ្រួសារម្តាយរបស់ខ្ញុំរៀបចំអីវ៉ាន់ចេញពីផ្ទះ ។ ដោយសារមិនហ៊ានប្រឆាំងនឹងបញ្ជារបស់ខ្មែរក្រហម ជីដូនរបស់ខ្ញុំបានប្រមូលយកវត្ថុមានតម្លៃ ចាន ឆ្នាំង អង្ករបន្តិចបន្តួចចាកចេញ ។ ម្តាយរបស់ខ្ញុំបានធ្វើដំណើររួមជាមួយនឹងបងប្អូនជីដូនមួយរបស់គាត់ ជីដូន និងជីតារបស់ខ្ញុំសរុបមានគ្នាចំនួនប្រាំមួយនាក់ ។ គ្រួសាររបស់ម្តាយខ្ញុំមិនបានធ្វើដំណើរទៅឆ្ងាយប៉ុន្មានទេ ពួកគាត់បានចូលទៅស្នាក់នៅផ្ទះបងប្អូនជីដូនមួយជីតារបស់ខ្ញុំសិនដើម្បីចាំត្រឡប់មកវិញ ។

ដោយមានអារម្មណ៍មិនស្រួលនៅក្នុងចិត្ត ជីតារបស់ខ្ញុំបានយកសំបកកង់ចាស់ និងឈើមកធ្វើជារទេះសម្រាប់ដឹកអីវ៉ាន់នៅពេលដែលពួកគាត់កំពុងស្នាក់នៅផ្ទះរបស់បងប្អូនជីដូនមួយគាត់នៅឯបឹងទំពន់ ។ មួយថ្ងៃក្រោយមក កងទ័ពខ្មែរក្រហមបានចូលមកដល់ផ្ទះដែលគ្រួសារម្តាយខ្ញុំបានស្នាក់នៅ ហើយប្រាប់ពួកគាត់ឲ្យរៀបចំចេញដំណើរទៅតាមបញ្ជារបស់អង្គការនៅព្រឹកថ្ងៃស្អែក ។ ជីដូននិងជីតារបស់ខ្ញុំបាននាំគ្នាយកវត្ថុមានតម្លៃរបស់ពួកគាត់ទៅកប់នៅបាតបឹង និងរក្សាទុកខ្លះជាប់នឹងខ្លួន ។ ពេលព្រឹកឡើង ពួកគាត់ក៏នាំគ្នាចាប់ផ្តើមចេញដំណើរដោយជីតារបស់ខ្ញុំជាអ្នកអូសរទេះ ហើយម្តាយនិងជីដូនរបស់ខ្ញុំជិះនៅក្នុងរទេះ ។ ក្នុងពេលធ្វើដំណើរម្តាយរបស់ខ្ញុំបានឃើញសាកសពមនុស្សជាច្រើន ខ្លះហើម ខ្លះដាច់ដៃ ដាច់ជើង និងដាច់ក្បាលដែលមើលទៅគួរឲ្យខ្លាច ។ ម្តាយខ្ញុំពេលខ្លះស្ទើរតែមិនហ៊ានមើលសាកសពទាំងនោះទេ ព្រោះថាមានមនុស្សច្រើនណាស់ដែលស្លាប់ ហើយក្នុងចំណោមអ្នកទាំងនោះមានទាហាននិងប្រជាជនធម្មតាដែលមិនស្តាប់តាមបញ្ជារបស់ខ្មែរក្រហម ។ ធ្វើដំណើរមិនបានប៉ុន្មានផង រទេះរបស់ពួកគាត់ខូចប្រើការលែងកើត ដូច្នេះក្រុមគ្រួសារម្តាយខ្ញុំត្រូវតែសម្រេចចិត្តដើរ ។ តាមផ្លូវធ្វើដំណើរ ប្រជាជនត្រូវបានអនុញ្ញាតឲ្យឈប់ដាំបាយហូបមួយរយៈនៅកន្លែងដែលមានស្រះទឹក ។ នៅពេលយប់ គ្រួសារម្តាយខ្ញុំត្រូវតែដេកនៅតាមចិញ្ចើមផ្លូវដែលមានសាកសពមនុស្សស្លាប់នៅក្បែរនោះ ។ ក្រុមគ្រួសាររបស់ម្តាយខ្ញុំបានធ្វើដំណើរមកដល់ផ្លូវបំបែកមួយដែលមានប្រជាជនជាច្រើនកំពុងតែប្រជ្រៀតគ្នាទៅកាន់ខេត្តបាត់ដំបងនិងខេត្តមួយចំនួននៅប៉ែកពាយព្យ ។ ដោយសារតែ ជីតារបស់ខ្ញុំមានស្រុកកំណើតនៅតាកែវ ពួកគាត់នាំគ្នាចាំរហូតដល់គេបើកច្រកផ្លូវមួយទៀតដែលឆ្ពោះទៅកាន់ខេត្តមួយចំនួនដូចជាតាកែវនិងខេត្តនៅឯប៉ែកនិរតី ។

ក្រោយពីច្រកផ្លូវទៅកាន់ប៉ែកនិរតីបានបើក ក្រុមគ្រួសាររបស់ម្តាយខ្ញុំបានបន្តធ្វើដំណើរអស់រយៈពេលប្រហែលមួយអាទិត្យទម្រាំទៅដល់ស្រុកកំណើតរបស់ជីតាខ្ញុំ ។ ពេលមកដល់ស្រុកកំណើតភ្លាម ពួកគាត់ត្រូវបានខ្មែរក្រហមបញ្ជាឲ្យទៅរស់នៅជាមួយប្រជាជនមូលដ្ឋាននៅលើផ្ទះធំមួយដែលគ្មានជញ្ជាំង ។ ដីស្រែ ចម្ការ និងដើមឈើដែលធ្លាប់ជាកម្មសិទ្ធិរបស់ជីតាខ្ញុំត្រូវបានហាមឃាត់ដាច់ខាតមិនឲ្យប៉ះពាល់ព្រោះថាវាជារបស់សមូហភាព ។ រយៈពេលពីរថ្ងៃក្រោយមក ម្តាយរបស់ខ្ញុំ និងបងស្រីរបស់គាត់ត្រូវបានបញ្ចូលក្នុងកងកុមារដែលគាត់ត្រូវតែធ្វើការងារមួយចំនួនដូចជារែកលាមកគោ ឃ្វាលគោ កាប់ដី បុកាស់ប្ញសឈើជាដើម ។ មូលដ្ឋានដែលម្តាយខ្ញុំរស់នៅមានទីតាំងនៅក្បែរផ្ទះជីតាខ្ញុំ ដូច្នេះម្តាយរបស់ខ្ញុំតែងតែលួចមកលេងផ្ទះជានិច្ច ។ ក្នុងកងកុមារម្តាយខ្ញុំគាត់បានទទួលរបបអាហារគួរសមដែលពេលខ្លះមានបាយនិងម្ហូបបន្តិចបន្តួចដែលអង្គការឲ្យហូប ។ ប៉ុន្តែរយៈពេលមួយខែក្រោយមក ម្តាយខ្ញុំក៏ត្រូវបានបញ្ចូលក្នុងកងនារីវិញ ។ ពេលនោះ គាត់ត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែនិងជីកប្រឡាយនៅឆ្ងាយពីផ្ទះ ។ ដោយសារតែរបបអាហារមិនគ្រប់គ្រាន់ មានតែបបរពំនូតបាយមួយដុំសម្រាប់ហូបពេលសម្រាកនិងខ្វះជាតិអំបិល ម្តាយខ្ញុំបានកើតជំងឺហើម ។ ប៉ុន្តែ ទោះបីជាឈឺក៏ដោយ ក៏គាត់ត្រូវបានបង្ខំឲ្យធ្វើការដូចធម្មតាដែរ ។ ក្រោយមក ដំណឹងឈឺរបស់ម្តាយខ្ញុំបានឮទៅដល់ជីតារបស់ខ្ញុំ ។ ជីតារបស់ខ្ញុំជាមនុស្សក្លាហាន ដូច្នេះគាត់ក៏បានទៅសុំអំបិលនិងស្ករពីប្រធានភូមិថា “អង្គការធ្លាប់ប្រាប់ថាពេលខ្វះខាតត្រូវតែស្នើ” ហេតុអ្វីសំណើនេះត្រូវបានបដិសេធទៅវិញ ។ ជីតាខ្ញុំដឹងថាផ្ទះប្រធានភូមិនោះមានស្ករនិងអំបិលពេញពាង ដូច្នេះដើម្បីជួយម្តាយរបស់ខ្ញុំ ជីតាខ្ញុំលួចទៅផ្ទះប្រធានភូមិនោះដើម្បីលួចអំបិលនិងស្ករ ។ សំណាងល្អគ្មាននរណាឃើញគាត់ទេ ព្រោះប្រធានភូមិនោះរវល់និយាយពិភាក្សា

គ្នា ។ ពេលបានអំបិលនិងស្ករហើយ ជីតាខ្ញុំបានយកទៅឲ្យជីដូនខ្ញុំ ដើម្បីឲ្យគាត់ពួតយកទៅឲ្យម្តាយខ្ញុំដែលនៅឆ្ងាយ ។ ជីតាខ្ញុំបានផ្ញើស្ករនិងអំបិលតាមអ្នកដែលនៅក្បែរមូលដ្ឋានរបស់ម្តាយខ្ញុំ ។ មួយរយៈពេលក្រោយមក ម្តាយខ្ញុំក៏បានជាសះស្បើយ ។ ជារៀងរាល់ថ្ងៃ ម្តាយខ្ញុំតែងតែធ្វើការធ្ងន់ៗដូចក្រុមនារីដទៃទៀតដែរ ។ ដោយសារតែគាត់ជាមនុស្សព្យាយាមនឹងការងារ គាត់មិនដែលទទួលរងការធ្វើបាបពីប្រធានកងនារីឡើយ ។ ថ្ងៃមួយដោយសារតែនឹកជីដូនរបស់ខ្ញុំពេក ម្តាយខ្ញុំក៏សុំការអនុញ្ញាតពីប្រធានកងរបស់គាត់ទៅលេងផ្ទះ ។ ប៉ុន្តែគាត់ត្រូវបានហាមឃាត់មិនឲ្យទៅ ។ យ៉ាងណាមិញ ម្តាយខ្ញុំក៏សម្រេចលួចមកលេងជីដូនគាត់បន្ទាប់ពីគាត់ធ្វើការងារថ្ងៃត្រង់ចប់ ។ មកដល់ផ្ទះជីដូនខ្ញុំមិនបានប៉ុន្មានផង គាត់ត្រូវបានឈ្លបពីរនាក់មកតាមដល់ផ្ទះ ។ ជីដូននិងជីតាខ្ញុំមានការតក់ស្លុតខ្លាំងណាស់ដោយគិតថា ម្តាយខ្ញុំនឹងត្រូវឈ្លបសម្លាប់ហើយ ។ ផ្ទុយទៅវិញ គាត់ត្រូវបានលើកលែងទោស ដោយសារតែគាត់ជាមនុស្សខំធ្វើការ ។

ទោះបីជាខ្ញុំជាក្មេងជំនាន់ក្រោយដែលមិនបានឆ្លងកាត់និងបានរស់នៅក្នុងរបបខ្មែរក្រហមក៏ដោយ ក៏ខ្ញុំបានយល់ដឹងកាន់តែច្បាស់អំពីរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈការអានសៀវភៅនិងបទពិសោធន៍ការងារដែលខ្ញុំកំពុងតែដកស្រង់ក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ទំព័រប្រវត្តិសាស្ត្រស្តីពីអំពើសាហាវឃោរឃៅនិងអមនុស្សធម៌របស់ខ្មែរក្រហមដែលខ្ញុំបានអានកន្លងមកនៅតែតាមលងបន្លាចរូបខ្ញុំក៏ដូចជាប្រជាជនខ្មែរទូទៅផងដែរ ។ លើសពីនេះខ្ញុំមានការសោកស្តាយយ៉ាងខ្លាំងចំពោះជីវិតមនុស្សរាប់ពាន់នាក់ដែលត្រូវបានសម្លាប់យ៉ាងអាណោចអាធ័ម ។ ខ្ញុំជឿជាក់ថាប្រជាជនខ្មែរដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដ៏អាក្រក់ដូជាតិនេះចង់ឃើញយុត្តិធម៌សម្រាប់ប្រជាជនដែលបាត់បង់ជីវិតទៅហើយ ក៏ដូចជាសម្រាប់ធ្វើឲ្យអារម្មណ៍តានតឹងទាក់ទងនឹងបទពិសោធន៍ដ៏ជូរចត់របស់ពួកគាត់មានភាពធូរស្បើយ នៅពេលដែលយុត្តិធម៌ត្រូវបានស្វែងរកឃើញយ៉ាងពិតប្រាកដ ។ ក្តីសង្ឃឹមសម្រាប់យុត្តិធម៌របស់ប្រជាជនខ្មែរទូទាំងប្រទេសនៅពេលនេះគឺអាស្រ័យទៅលើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលកំពុងតែធ្វើការកាត់ក្តីមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់មួយរូបក្នុងចំណោមប្រាំរូបដែលមានវ័យកាន់តែចាស់ជរាទៅហើយ ។ ដោយមិនបោះបង់ចោលនូវក្តីសង្ឃឹមមួយនេះ ប្រជាជនខ្មែររួមទាំងយុវជនជំនាន់ក្រោយប្រាថ្នាសូមឲ្យយុត្តិធម៌នឹងត្រូវបានរកឃើញយ៉ាងពិតប្រាកដក្នុងពេលឆាប់ៗនេះដើម្បីយកមកលុបលាងនូវទំព័រប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ដ៏សែនខ្លោងងឹតនេះ និងដើម្បីធ្វើឲ្យប្រទេសកម្ពុជានិងប្រជាជនកម្ពុជារស់នៅក្នុងបច្ចុប្បន្នប្រកបដោយសុខសន្តិភាពនិងភាពរីកចម្រើនទៅមុខជារៀងរហូត ។

**វ៉ែន សុខស្រីនិត**

# សេចក្តីប្រកាសរកប្តី និងបងជីដូនមួយ

នាងខ្ញុំឈ្មោះ មី សយ អាយុ៥៧ សព្វថ្ងៃរស់នៅភូមិគគី ឃុំគគី ស្រុករមាសហែក ខេត្តស្វាយរៀង ។ ខ្ញុំមានកូនប្រុស៥នាក់ ស្លាប់អស់៤នាក់ ។ ខ្ញុំសូមប្រកាសសួររកប្តីឈ្មោះ គឹម ពុធ (សព្វថ្ងៃគាត់មានអាយុ៦៣ឆ្នាំ) និង បងប្អូនជីដូនមួយឈ្មោះ ឌួង ថន (សព្វថ្ងៃមានអាយុ៤០ឆ្នាំ) មានស្រុកកំណើតនៅភូមិគគី ឃុំគគី ស្រុករមាសហែក ខេត្តស្វាយរៀង ។ នៅឆ្នាំ១៩៧៥ ពេលដែលកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះ គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅរស់នៅខេត្តពោធិ៍សាត់ ។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាត់តាំងប្តីរបស់ខ្ញុំឲ្យធ្វើការនៅកន្លែងមួយឆ្ងាយពីភូមិ ។ ក្រោយមក ប្រជាជននៅក្នុងភូមិបានមកប្រាប់ខ្ញុំថា គាត់ត្រូវអង្គការចាប់ដាក់រថយន្ត រួចបញ្ជូនទៅក្រុងភ្នំពេញ ។ ចាប់តាំងពីពេលនោះ ខ្ញុំមិនដែលបានទទួលដំណឹងពីគាត់ឡើយ ។ ចំណែក ថន ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅរស់នៅខេត្តបាត់ដំបង រួចក៏បាត់ខ្លួនរហូតដែរ ។

ប្រសិនបើបងប្អូនណាបានស្គាល់ ឬបានឮដំណឹងពីឈ្មោះទាំងពីរខាងលើនេះ សូមមេត្តាទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ សូមអរគុណ ។



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 117, September 2009 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.